សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management



# ដំណើរការពន្ធដារនៅកម្ពុជា

## ភាគ១

បណ្ឌិត ម៉ៅ សាវ

ឆ្នាំ ២០២១

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
ក្រសួងអប់រំ យុវជន និងកីឡា

មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

CAMBODIA
RESEARCH CREATIVITY INNOVATION

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្រប ទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវ និងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមាន សហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្ដល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្ដល់ការគាំទ្រដល់ការ **រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្តីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្តីថ្លែងអំណរគុណ

ការចងក្រងសៀវភៅនេះជាសមិទ្ធផលមួយថ្មី ដែលបានមកពីការខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង និង មានការគាំទ្រពីក្រសួង ស្ថាប័ន និង មនុស្សសំខាន់ៗ ជាច្រើនទៀត សម្រាប់ជាគន្លឹះក្នុងការផ្តល់កម្លាំងចិត្តជួយជំរុញឱ្យមានការរៀបចំ និពន្ធ និង ចងក្រងសៀវភៅគោលនេះឡើង ។

ជាបឋមខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានជួយឧបត្ថម្ភ គាំទ្រ និងលើកទឹកចិត្តក្នុងការនិពន្ធ ចងក្រងស្នាដៃមុខវិជ្ជាគោលសម្រាប់កម្រិតឧត្តមសិក្សា ជាភាសាជាតិ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម **ហោ ប៉េង** សាកលវិទ្យាធិការនៃសាកលវិទ្យា ល័យជាតិគ្រប់គ្រងដែលតែងតែលើកទឹកចិត្តតាមរយៈបង្កើតកម្មវិធី កិច្ចការស្រាវជ្រាវ និង បោះពុម្ពផ្សាយជា ព្រឹត្តិបត្រស្រាវជ្រាវនិងអភិវឌ្ឍ (ដំណើរការពន្ធដារនៅកម្ពុជា) ប្រចាំសាកលវិទ្យាល័យ ។

សូមថ្លែងអំណរគុណដល់គណៈកម្មការពិនិត្យស្នាដៃ ដែលបានជួយសម្របសម្រួលនិងផ្តល់យោបល់កែលម្អ ជាហេតុធ្វើឱ្យស្នាដៃស្រាវជ្រាវនេះប្រព្រឹត្តទៅដោយរលូនសម្រាប់បោះពុម្ពផ្សាយ ប្រចាំគ្រឹះស្ថានសិក្សា ។

សូមថ្លែងអំណរគុណដល់សាលាក្រោយបរិញ្ញាបត្រដែលបានផ្តល់កម្មវិធីសម្បូរ បែបក្នុងការសរសេរព្រឹត្តិបត្រស្រាវជ្រាវ សម្រាប់បំពេញលក្ខខណ្ឌប្រឡងបញ្ចប់និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ និងការសរសេរ និក្ខេបបទគ្រប់កម្រិត ជាកត្តានាំឱ្យលេចរូបរាងស្នាដៃនេះឡើង ។

# អារម្ភកថា

ដំណើរការនៃការប្រមូលពន្ធនិងច្បាប់ពន្ធគឺជាបទដ្ឋានគតិយុត្ត បញ្ញាតិអោយមនុស្សទូទៅគោរពនិង យកទៅអនុវត្តតាម។ ការសិក្សាអំពីទ្រឹស្តីនឹងខ្លឹមសារអំពីដំណើរការនៃការប្រមូលពន្ធនិងច្បាប់ពន្ធ មិនមែន ជាការងាយស្រួលនោះទេ ជាពិសេសការសិក្សាទៅលើ ការអនុវត្តជាក់ស្តែងប្រចាំថ្ងៃ។

សៀវភៅស្តីអំពីដំណើរការ នៃការប្រមូលពន្ធនិងច្បាប់ពន្ធនេះ រៀបរៀងឡើងដើម្បីផ្តល់ចំណេះដឹង ស្តីពី ពន្ធដារជូនដល់អ្នកជាប់ពន្ធ និង ជំនាញបច្ចេកទេស នៃការប្រមូលពន្ធនៅកម្ពុជា ទៅតាមប្រភេទពន្ធ នីមួយៗ ដែលមាន ២៣ ប្រភេទដូចជា ការចុះបញ្ជី ការផ្តល់សេវាកម្ម ការចេញលិខិតប្រកាសពន្ធ ពន្ធលើ ប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្ស ពន្ធលើប្រាក់ចំណូល ពន្ធអចលនទ្រព្យ ពន្ធប្រាក់ចំណេញមូលធន ពន្ធ ប្រថាប់ត្រា ពន្ធប៉ាតង់ ពន្ធលើមធ្យោបាយដឹកជញ្ជូន អាករលើតម្លៃបន្ថែម អាករពិសេស ពន្ធកាត់ទុក ពន្ធអប្បរមា អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ ការប្រកាសពន្ធតាមអនឡាញនិងការបង់ប្រាក់តាមធានា គារ ។ល។

តែទោះជាយ៉ាងនេះក្តី ខ្ញុំជឿជាក់ថា វាមិនទាន់មានលក្ខណៈវិទ្យាសាស្ត្រគ្រប់ជ្រុងជ្រោយនោះទេ ព្រោះការចងក្រងសៀវភៅនេះ ដោយពឹងផ្អែកទៅលើឯកសារដកស្រង់ចេញពីអគ្គនាយកដ្ឋានពន្ធដារ និង ច្បាប់ពន្ធដែលមានស្រាប់ធ្វើជាមូលដ្ឋាន ហើយឯកសារពុំទាន់បានរៀបរយល្អនៅឡើយ។

ខ្ញុំសង្ឃឹមថា សៀវភៅមួយនេះនឹងលើកកម្ពស់គុណភាព ដល់ការសិក្សារបស់និស្សិតគ្រប់កម្រិត និង បានរួមចំណែក ជួយពង្រឹងទៅដល់នីតិវិធីនៃការប្រមូលពន្ធ របស់រដ្ឋបាលសាពើពន្ធ និង ស្ថាប័នពាក់ព័ន្ធ ផ្សេងៗទៀត។ ទន្ទឹមនឹងនេះ យើងខ្ញុំសូមអភ័យទោសក្នុងករណីដែលមានកំហុសឆ្គងទាំងឡាយដូចជា អក្ខវិរុទ្ធ ពាក្យពេចន៍ ឃ្លោងឃ្លា ដែលបានកើតឡើងដោយអចេតនា ក្នុងការចងក្រងបោះពុម្ពសៀវភៅ មួយ នេះ។

ជូនពរឲ្យប្អូនៗសិស្ស-និស្សិតគ្រប់កម្រិតទទួលបានជោគជ័យក្នុងការសិក្សា ។

ថ្ងៃ ចន្ទ ១០កើត ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានី ភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០២១

**បណ្ឌិត ម៉ៅ សាទី**

# មាតិកា


បុព្វកថា.....I

សេចក្តីថ្លែងអំណរគុណ.....VII

អារម្ភកថា.....VIII


# ជំពូកទី ១ ៖ ប្រភេទពន្ធថ្នាក់ជាតិ


១ សេចក្តីផ្តើម.....XXV

២ ប្រវត្តិពន្ធដារនៅកម្ពុជា.....XXV

៣ អគ្គនាយកពន្ធដារ.....XXVI

៤ សញ្ញាណទូទៅនៃពន្ធដារ.....XXVII


## មេរៀនទី ១ ៖ ការចុះបញ្ជីពន្ធដារ


១ គោលបំណង.....០១

២ និយមន័យ.....០១

៣ នីតិវិធីនៃការចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មាន.....០២

៣.១.ការចុះបញ្ជី.....០២

៣.២.ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ.....០៤

៣.៣.កម្រៃសេវានៃការបង់ពន្ធប៉ាតង់និងពន្ធប្រថាប់ត្រាមានលក្ខណៈគតិយុត្ត.....០៦

៣.៤.រយៈពេលទទួលបាននៃការចុះបញ្ជីពន្ធដារ.....០៨

៣.៥.ការបដិសេធការស្នើសុំការចុះបញ្ជីពន្ធដា……………………………………..០៩
៤ ការចុះពិនិត្យស្ថានភាពអាជីវកម្មនិងបញ្ជីអចត្តមានសម្រាប់ការចុះបញ្ជី..........១០
៤.១.ការចុះពិនិត្យស្ថានភាពអាជីវកម្ម…………………………………………….១០
៤.២.ការចុះបញ្ជីពន្ធដារជាឯកតោភាគី......................................................... ១០
៤.៣.បញ្ជីអវិជ្ជមានសម្រាប់អ្នកចុះបញ្ជី……………………………………………១១
៥ សិទ្ធិរបស់អ្នកជាប់ពន្ធ...................................................................................១២
៥.១.សិទ្ធិរបស់អ្នកជាប់ពន្ធ................................................................................ ១២
៥.២.ទោសទណ្ឌ...................................................................................................១២

## មេរៀនទី ២ ៖ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ

១ គោលបំណង...................................................................................................១៤
២ និយមន័យ.......................................................................................................១៤
៣ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស...............................១៤
៤ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម........................១៦

## មេរៀនទី ៣ ៖ ការប្រមូលពន្ធលើប្រាក់ចំណេញ

.១ កម្មវត្ថុនៃពន្ធ..................................................................................................១៨
២ គោលបំណង.....................................................................................................១៨
៣ របបកំណត់ពន្ធ.................................................................................................២១
៤ ឆ្នាំជាប់ពន្ធ........................................................................................................២១
៤.១.ឆ្នាំជាប់ពន្ធ…………………………………………………………………….២១
៥ វិធានគណនេយ្យ...............................................................................................២២

៦ ប្រាក់ចំណេញជាប់ពន្ធ.....២៣

៧ ការកំណត់ប្រាក់ចំណេញជាប់ពន្ធ.....២៣

៨ ប្រាក់ចំណេញលើកលែងពន្ធ.....២៣

៩ ការកំណត់ប្រាក់ចំណូលរបស់ក្រុមអាជីវកម្ម.....២៤

១០ ការកាត់កង.....២៥

១០.១ ការកាត់កងដែលអនុញ្ញាត.....២៥

១០.២ ចំណាយ ការប្រាក់.....២៥

១០.៣ រំលោះនៃទ្រព្យរូបីយ.....២៦

១០.៤ រំលោះនៃទ្រព្យអរូបីយ.....២៦

១០.៥ រំលោះធនធានធម្មជាតិ.....២៧

១០.៦ វិភាគទានសប្បុរធម៌.....២៧

១០.៧ ការយោងការខាតបង់ទៅមុខ.....២៧

១០.៨ ការបែងចែកប្រាក់ចំណូលនិងការកាត់កងក្នុងចំណោមអ្នកជាប់ពន្ធ.....២៨

១០.៩. ការកាត់កងដែលមិនអនុញ្ញាត.....២៨

១១ អត្រាពន្ធនិងប្រាក់ត្រូវបង់.....២៩

១១.១ អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ.....២៩

១១.២ ពន្ធលើសហគ្រាសធានារ៉ាប់រង.....៣០

១១.៣ ពន្ធលើប្រាក់ចំណេញចំពោះអាជីវកម្មមិន ទាក់ទិន.....៣០

១១.៤ ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ.....៣១

១២ ពន្ធដទៃទៀត.....៣១

១៣ ពន្ធកាត់ទុកនិងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ.........................................៣២

១៤ កាត់ទុកប្រាក់ពន្ធ១៤%នៃការទូទាត់ប្រាក់ចំណេញក្នុងការធ្វើអាជីវកម្ម......... ៣៣

១៥ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់..............................................៣៣

១៦ ភាតព្វកិច្ចទូទៅសម្រាប់អ្នកជាប់ពន្ធ.....................................................................៣៤

១៦.១ ពន្ធតាមរបបពិតឬរបបចំរុះពេញ.......................................................៣៤

១៦.២ អ្នកជាប់ពន្ធតាមរបបពិត.....................................................................៣៤

១៦.៣ បុគ្គលឬអ្នកទទួលភារៈបើកប្រាក់កាត់ទុកប្រាក់ពន្ធ......................... ៣៥

១៦.៤ ភាតព្វកិច្ចរបស់បុគ្គលបង់ប្រាក់រំដោះពន្ធ.......................................... ៣៦

១៦.៥ ប្រតពប្រាក់ចំណូល..............................................................................៣៦

១៦.៦ ការកំណត់ប្រតព.................................................................................៣៧

១៧ គណនាប្រាក់ពន្ធប្រចាំឆ្នាំត្រូវបង់......................................................................៣៧

១៧.១ រូបមន្តគណនាប្រាក់ពន្ធ......................................................................៣៧

១៧.២ ឥណទានពន្ធបរទេស ……………………………………………………..៣៩

១៧.៣ ការគណនាប្រាក់ពន្ធត្រូវបង់ឬឥណទានពន្ធ..................................៤១

១៧.៤ គណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬ ឥណទានពន្ធ.....៤១

## មេរៀនទី ៤ ៖ ការប្រមូលពន្ធលើប្រាក់បៀវត្ស

១ កម្មវត្ថុ.................................................................................................................៤៤

២ គោលដៅពន្ធទៅលើប្រាក់បៀវត្ស.................................................................... ៤៥

៣ ប្រាក់បៀវត្សលើកលែងពន្ធ.................................................................................៤៨

៣.១.ប្រាក់បៀវត្សដែលមន្ត្រីនិងនិយោជិតនៃបេសកម្មទូតឬកុងស៊ុល.........៤៨

៣.២.ប្រាក់បៀវត្សដែលតំណាងមន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរ

ជាតិ.....................................................................................................៤៩

៤ មូលដ្ឋានគិតពន្ធប្រចាំខែ ប្រាក់បៀវត្សជាប់ពន្ធ.......................................................៤៩

៤.១.មូលដ្ឋានគិតពន្ធប្រចាំខែ.......................................................................................៤៩

៤.២.រូបមន្តគណនាប្រាក់ពន្ធលើប្រាក់បៀវត្ស .................................................................៥១

៤.៣.ប្រាក់បៀវត្សជាប់ពន្ធ...............................................................................................៥២

៤.៤.អត្រាកំណើនប្រាក់បៀវត្សថ្មីតាមចំណាត់ថ្នាក់.............................................................៥៣

៤.៥.ទាយជ្ជទានសម្រាប់សហព័ន្ធនិងកូនក្នុងបន្ទុក.........................................................៥៣

៤.៦.ការគណនាប្រាក់ពន្ធលើប្រាក់បៀវត្ស.........................................................................៥៥

៤.៧.ការកំណត់ប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែម...........................................................៥៨

៤.៨.ឥណទានពន្ធបរទេស................................................................................................. ៥៨

៥ និវាសនជនទទួលបានឥណទានប្រាក់បៀវត្សចំពោះបៀវត្សប្រភពបរទេស...៥៩

៦ ភាតព្វកិច្ចរបស់និយោជកនិងនិយោជិត.........................................................................៦៥

៦.១.បំណុលពន្ធ និងភាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ ...........................................................៦៥

៦.២.ការបង់ប្រាក់ដែលកាត់ទុក.........................................................................................៦៦

៦.៣.ការកាត់ទុកប្រាក់ពន្ធការកាន់បញ្ជីកានិងរបាយការណ៍ .........................................៦៦

## មេរៀនទី ៥ ៖ ការប្រមូលពន្ធលើប្រាក់ចំណូល

១ គោលបំណង.............................................................................................................៦៧

២ គោលដៅ ...............................................................................................................៦៧

៣ អ្នកជាប់ពន្ធ.............................................................................................................៦៧

៤ អ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន.......................................................៦៧

៥ ប្រភពចំណូល...........................................................................................................៧១

៦ ប្រាក់ចំណូលមិនជាប់ពន្ធ........................................................................ ៧៥

៧ វិធានទូទៅស្តីពីប្រាក់ចំណូលជាប់ពន្ធ.......................................................................៧៦

៧.១ ឆ្នាំជាប់ពន្ធ.......................................................................................................៧៦

៧.២ ប្រាក់ចំណូលជាប់ពន្ធ.......................................................................................៧៧

៧.៣ ទ្រព្យសកម្មអាជីវកម្ម.......................................................................................៨១

៧.៤ វិធានគណនេយ្យ...............................................................................................៨៤

៧.៥ ការកែតម្រូវក្រៅគណនេយ្យ...............................................................................៨៦

៧.៦ បន្ទុកភស្តុតាង.................................................................................................. ៨៦

៧.៧ សំវិធានធន......................................................................................................៨៦

៨ វិធានទូទៅស្តីពីស្តុកនិងការងារកំពុងដំណើរការ...................................................៨៨

៨.១ ដំណើរការស្តុក................................................................................................. ៨៨

៨.២ ការវាយតម្លៃស្តុក.............................................................................................. ៩២

៨.៣ ការវាយតម្លៃការងារកំពុងដំណើរការ..................................................................៩៥

៩ វិធានទូទៅស្តីពីចំណូលអាជីវកម្ម ........................................................................៩៥

៩.១ គោលការណ៍ទូទៅនៃការទទួលស្គាល់ចំណូល.......................................................៩៥

៩.២ លក្ខខណ្ឌបន្ថែមក្នុងការទទួលស្គាល់ចំណូល.......................................................៩៧

៩.៣ ចំណូលពីសកម្មភាពអាជីវកម្ម............................................................................៩៨

៩.៤ ចំណូលបន្ទាប់បន្សំ..........................................................................................៩៩

៩.៥ ចំណូលផ្សេងៗ................................................................................................១០០

១០ វិធានទូទៅស្តីពីចំណាយ .....................................................................................១០៣

១០.១ គោលការណ៍សម្រាប់ចំណាយអាជីវកម្ម..........................................................១០៣

១០.២ គោលការណ៍សម្រាប់ចំណាយអាចកាត់កងបាន..........................១០៥

១០.៣ គោលការណ៍សម្រាប់ចំណាយមិនអាចកាត់កងបាន......................១០៨

១១ ចំណាយអាចកាត់កងបាននិងចំណាយមិនអាចកាត់កងបាន........................១០៩

១១.១ ចំណាយបង្កើតសហគ្រាស...............................................................១០៩

១១.២ ការទិញ .........................................................................................១១០

១១.៣ ចំណាយសេវាខាងក្រៅ.......................................................................១១៥

១១.៤ ពន្ធនិងអាករ.....................................................................................១១៧

១១.៥ បៀវត្សនិងចំណាយប្រហាក់ប្រហែល...............................................១១៨

១១.៦ ការប្រាក់..........................................................................................១២១

១១.៧ ចំណាយពិសេស ...............................................................................១២៣

១២ វិធានទូទៅស្តីពីរំលស់.............................................................................១២៥

១២.១ រំលស់និងលក្ខខណ្ឌរំលស់.................................................................១២៥

១២.២ ទ្រព្យសកម្មរយៈពេលវែងដែលអនុញ្ញាតឲ្យធ្វើរំលស់.................១២៧

១២.៣ វិធីកត់ត្រាទ្រព្យសកម្មរយៈពេលវែង ..........................................១៣០

១២.៤ រំលស់ត្រូវធ្វើលើមូលដ្ឋាននិងក្នុងដែនកំណត់នៃថ្លៃដើម.............១៣២

១២.៥ វិធីរំលស់ធម្មតា.................................................................................១៣៤

១២.៦ ពេលចាប់ផ្តើមធ្វើរំលស់ ...................................................................១៣៦

១២.៧ រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស..................១៣៩

១២.៨ វិធីរំលស់ពិសេស .............................................................................១៤៤

១៣ វិធានទូទៅស្តីពីតម្លៃលើសនិងតម្លៃខ្វះនៃទ្រព្យសកម្ម...................................១៤៧

១៣.១ គោលការណ៍.....................................................................................១៤៧

១៣.២ ការគណនាតម្លៃលើសប្អូតម្លៃខ្វះ......១៤៨

១៣.៣ ករណីពិសេស......១៥០

១៤ ការគណនាពន្ធលើប្រាក់ចំណូល......១៥១

១៤.១ ប្រាក់ចំណូលជាប់ពន្ធ......១៥១

១៤.២ ការគណនាពន្ធលើប្រាក់ចំណូល......១៥៥

១៤.៣ ការគណនាពន្ធលើប្រាក់ចំណូលត្រូវបង់ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ......១៥៦

១៤.៤ ការគណនាប្រាក់ពន្ធអប្បបរមាប្រាក់ពន្ធត្រូវបង់ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ......១៥៧

១៤.៥ វិធានស្តីពីការយោងការខាតបង់......១៥៨

១៤.៦ អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ......១៦១

១៤.៧ ឥណទានពន្ធបរទេស ......១៦២

១៤.៨ ពន្ធបង់មុនលើការបែងចែកភាគលាភ......១៦៣

១៥ បញ្ជីគណនេយ្យ ......១៦៥

១៥.១ ភាតព្វកិច្ចគណនេយ្យ ......១៦៥

## មេរៀនទី ៦ ៖ ការប្រមូលពន្ធលើចំណេញមូលធន

១ គោលបំណង......១៦៨

២ គោលដៅ......១៦៨

៣ និយមន័យ......១៦៨

៤ ការលើកលែងពន្ធ......១៧០

៥ ពេលសម្រេចបានបានចំណេញមូលធន......១៧១

៦ ចំណាយដែលអាចកាត់កងបាន.........................................................................................១៧១

៧ វិធាននៃការកាត់កងចំណាយ...........................................................................................១៧២

៨ ថ្លៃលក់និងថ្លៃដើមនៃទ្រព្យ................................................................................................១៧២

៩ អត្រាពន្ធ..........................................................................................................................១៧៤

១០ ការគណនាចំណូលមូលធន..............................................................................................១៧៤

១១ ការគណនាពន្ធលើចំណេញមូលធន...................................................................................១៧៦

១២ ពន្ធលើចំណេញមូលធនចំពោះទ្រព្យនៅក្រៅពីព្រះរាជាណាចក្រកម្ពុជា .....១៧៦

១៣ ការដាក់លិខិតប្រកាសពន្ធនិងបង់ប្រាក់ពន្ធ.....................................................................១៧៧

១៤ ឯកសារត្រូវ.....................................................................................................................១៧៧

១៥ សិទ្ធិក្នុងការត្រួតពិនិត្យ...................................................................................................១៧៨

១៦ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មូលធន.............................................................................១៧៨

១៧ ការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន....................................................................១៧៨

## មេរៀនទី ៧ ៖ ពន្ធកាត់ទុក

១ និយមន័យ.........................................................................................................................១៧៨

២ គោលការណ៍.......................................................................................................................១៧៨

៣ ការទូទាត់ប្រភេទពន្ធកាត់ទុកទៅឲ្យនិវាសនជន..................................................................១៧៨

៤ អត្រាភាគរយនៃពន្ធកាត់ទុកលើការទូទាត់ឲ្យនិវាសនជននិងអនិវាសនជន១៨២

៥ ការលើកលែងពន្ធកាត់ទុក...................................................................................................១៨៥

៦ ការគណនាប្រាក់ពន្ធ........................................................................................................ ១៨៧

៧ ភាតព្វកិច្ចនិងការទទួលខុសត្រូវរបស់ភ្នាក់ងារ......................................................................១៨៧

## មេរៀនទី ៨ ៖ ការប្រមូលពន្ធលើអាករលើតម្លៃបន្ថែម

១ និយមន័យ....................................................................................................១៨៨

២ ភារកិច្ចកិច្ចចុះបញ្ជី.............................................................................................១៨៩

៣ ការតម្រូវចំពោះការចុះបញ្ជី..................................................................................១៩១

៣.១ ទម្រង់នៃពាក្យស្នើសុំចុះបញ្ជី........................................................... ១៩១

៣.២ សិទ្ធិក្នុងការចុះបញ្ជី ........................................................................ ១៩១

៣.៣ កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី...................................១៩២

៣.៤ វិញ្ញាបនបត្រចុះបញ្ជី.........................................................................១៩២

៣.៥ ការដាក់តាំងវិញ្ញាបនបត្រចុះបញ្ជី......................................................១៩២

៣.៦ បញ្ជីអាករតម្លៃបន្ថែម.........................................................................១៩២

៣.៧ អំណាចក្នុងការចុះបញ្ជី......................................................................១៩៣

៣.៨ សេចក្តីជូនដំណឹងអំពីការយល់ព្រមឬមិនយល់ព្រមចុះបញ្ជី............១៩៣

៣.៩ សេចក្តីជូនដំណឹងអំពីការចុះបញ្ជីជាឯកតោភាគី..............................១៩៣

៣.១០ ការប្រែប្រួលព័ត៌មានបុគ្គលជាប់អាករ........................................... ១៩៣

៤ ការចុះបញ្ជីសហគ្រាសវិនិយោគ..........................................................................១៩៤

៤.១ ការចុះបញ្ជីសហគ្រាសវិនិយោគ ........................................................១៩៤

៤.២ លក្ខខណ្ឌនៃការចុះបញ្ជី...................................................................១៩៤

៤.៣ ការបង្វិលសងវិញនូវអាករលើធាតុចូល...........................................១៩៤

៤.៤ ភារកិច្ចរបស់សហគ្រាសវិនិយោគ ................................................. ១៩៥

៤.៥ ការបញ្ឈប់លក្ខណៈសម្បត្តិជាសហគ្រាសវិនិយោគ.........................១៩៥

៥ ការលុបចោលការចុះបញ្ជី....................................................................................១៩៥

៥.១ ការបញ្ឈប់អាជីវកម្ម ...................................................................... ១៩៥

៥.២ ការថយចុះផលរបរជាប់អាករ.............................................................. ១៩៥

៥.៣ សិទ្ធិលុបចោលការចុះបញ្ជីដោយស្ម័គ្រចិត្ត......................................... ១៩៦

៥.៤ សិទ្ធិលុបចោលការចុះបញ្ជី ................................................................ ១៩៦

៥.៥ លិខិតជូនដំណឹងដែលទាក់ទិននឹងការស្នើសុំលុបចោលការចុះបញ្ជី.១៩៧

៥.៦ ការបរិច្ឆេទមានប្រសិទ្ធភាពនៃការលុបចោលការចុះបញ្ជី ............... ១៩៧

៥.៧ ការលុបចេញពីបញ្ជី ........................................................................ ១៩៧

៥.៨ បំណុលអាករនៅពេលលុបចោលការចុះបញ្ជី ...................................... ១៩៧

៥.៩ ប្រសិទ្ធភាពនៃការលុបចោលចំពោះកាតព្វកិច្ចតាមផ្លូវច្បាប់........... ១៩៨

៦ ឥណទានអាករលើធាតុចូល........................................................................ ១៩៨

៦.១ ឥណទានអាករលើធាតុចូលនៅពេលចាប់ផ្ដើមចុះបញ្ជីអាករលើតម្លៃ

បន្ថែម .................................................................................................. ១៩៨

៦.២ ការគណនាអាករដែលត្រូវបង់............................................................ ១៩៩

៦.៣ កាលបរិច្ឆេទដល់កំណត់នៃអាករលើធាតុចូល .................................. ២០១

៦.៤ អាករលើធាតុចូលដែលមិនអនុញ្ញាតជាឥណទានអាករ ................. ២០១

៦.៥ អាករលើធាតុចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់

អាករនិងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ......................... ២០២

៦.៦ ការគណនាឥណទានអាករលើធាតុចូល .......................................... ២០២

៦.៧ ការផ្គត់ផ្គង់ជាប់អាករដែលមានលក្ខណៈតិចតួច ............................ ២០៣

៦.៨ ការផ្គត់ផ្គង់មិនជាប់អាករ ................................................................ ២០៣

៦.៩ វិធីផ្សេងទៀតសម្រាប់គណនាអាករលើធាតុចូលដែលអាចកាត់

កខបាន.......................................................................................................២០៤
៦.១០ ជម្រើសវិធីគណនាឥណទានអាករលើធាតុចូលដែលអាចកាត់កខ
បាន..............................................................................................................២០៥
៦.១១ ការគណនាប្រចាំឆ្នាំនៃអាករលើធាតុចូលដែលអាចកាត់កខបាន..២០៥
៦.១២ កំណែតម្រូវប្រចាំឆ្នាំអាករលើធាតុចូលដែលអាចកាត់កខបាន ...២០៦
៦.១៣ ភស្តុតាងដើម្បីស្នើសុំឥណទានអាករលើធាតុចូលដែលអាចកាត់កខ
បាន..............................................................................................................២០៦
៦.១៤ ការបង្វិលសងឥណទានអាករលើធាតុចូលលើស...........................២០៦
៦.១៥ គោលដៅសំខាន់ៗនៃអាករលើតម្លៃបន្ថែម....................................២០៨
៧ វិក្កយបត្រអាករ...................................................................................២០៨
៧.១ លក្ខខណ្ឌទាក់ទិននិងការចេញនិងការប្រើប្រាស់វិក្កយបត្រអាករ..២០៨
៨ ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកម្មនិងអង្គការអន្តរជាតិ...................... ២០៩
៨.១ ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកម្មការទូតនិងអង្គការ
អន្តរជាតិ.......................................................................................................២០៩
៩ វិធានការនិងនីតិវិធីសម្រាប់ការផ្គត់ផ្គង់ជាប់អាករ..........................................២១១
៩.១ ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញ ...............................................................២១១
៩.២ ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញនិងសេវា ..........................................២១១
៩.៣ ទីកន្លែងនៃការផ្គត់ផ្គង់ការនាំចូល....................................................២១២
៩.៤ ការផ្គត់ផ្គង់លាយឡំគ្នារវាងទំនិញនិងសេវា.................................២១២
៩.៥ ពេលផ្គត់ផ្គង់.........................................................................................២១២
១០ ការកែតម្រូវទឹកប្រាក់អាករ.......................................................................២១៤

១០.១ នីតិវិធីកែតម្រូវទឹកប្រាក់អាករនៅក្រោយពេលផ្គត់ផ្គង់និងពេលចេញវិក្កយបត្រ.....២១៤

១១ បញ្ជីការគណនេយ្យ កំណត់ត្រា និង ព័ត៌មាន.....២១៦

១១.១ បញ្ជីការគណនេយ្យ និង កំណត់ត្រាដែលត្រូវការកាន់កាប់ថែរក្សាដោយបុគ្គលជាប់អាករ.....២១៦

១២ ការផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់.....២១៩

១២.១ ការគណនាអាករលើការលក់ទំនិញដល់បុគ្គលមិនជាប់អាករ.....២១៩

១៣ ការផ្គត់ផ្គង់ដោយភ្នាក់ងារ.....២១៩

១៣.១ លក្ខខណ្ឌនៃការផ្គត់ផ្គង់ទំនិញឬសេវាដោយភ្នាក់ងារ.....២១៩

១៤ ការប្រមូលអាករលើតម្លៃបន្ថែមលើការនាំចូល.....២២០

១៤.១ ការប្រមូលអាករលើតម្លៃបន្ថែមនៅពេលនាំចូល.....២២០

១៥ អត្រាសូន្យភាគរយនៃការនាំចេញនូវទំនិញនិងសេវា.....២២១

១៥.១ ដែនអនុវត្តនៃអត្រាសូន្យភាគរយសម្រាប់ការនាំចេញទំនិញនិងសេវា.....២២១

១៦ ការផ្ទេរអាជីវកម្ម.....២២២

១៦.១ លក្ខខណ្ឌនិងការតម្រូវសម្រាប់ការផ្ទេរអាជីវកម្ម.....២២២

១៧ ឥណទានសម្រាប់អាករលើធាតុចូលរបស់អ្នកប្រើប្រាស់.....២២៣

១៧.១ ភាពអាចទទួលបាននូវឥណទានអាករលើធាតុចូលឬឥណទានអាករលើការប្រើប្រាស់.....២២៤

១៧.២ លក្ខខណ្ឌក្នុងការស្នើសុំឥណទានអាករលើធាតុចូលឬឥណទានអាករលើការប្រើប្រាស់.....២២៤

១៧.៣ វិធីស្នើរសុំឥណទានអាករ ..........................................................២២៥

១៧.៤ សិទ្ធិនៃការប្រមូលមកវិញនូវឥណទានអាករ.............................២២៥

១៨ អាករលើតម្លៃបន្ថែមលើទំនិញមួយចំនួន...................................................២២៥

១៩ អាករតម្លៃបន្ថែមសម្រាប់គោលដៅកសិកម្ម...................................................២២៦

២០ អាករតម្លៃបន្ថែមលើអាហារ........................................................................២២៦

២១ ការគណនាអាករតម្លៃបន្ថែមសម្រាប់អ្នកជាប់ពន្ធតូច................................២២៧

## មេរៀនទី ៩ ៖ ការប្រមូលពន្ធលើអាករពិសេស

១ និយមន័យ..................................................................................................២២៨

២ គោលបំណង..............................................................................................២២៨

២.១ ការគ្រប់គ្រងនិងការប្រមូលអាករ.................................................... ២២៨

២.២ អាករពិសេសទៅលើសេវាដឹកជញ្ជូនតាមផ្លូវអាកាស.................. ២២៩

២.៣ សេវាទូរគមនាគមន៍ក្នុងនិងក្រៅប្រទេសឬសេវាលំហែរកំសាន្ត...២២៩

៣ ការលើកលែងអាករ....................................................................................២៣០

៤ មូលដ្ឋានគិតអាករ អត្រាអាករ និងការគណនាអាករ......................................២៣០

៤.១ មូលដ្ឋានគិតអាករ.................................................................................២៣០

៤.២ មូលដ្ឋានគិតអាករពិសេសលើសេវា ................................................២៣១

៤.៣ មូលដ្ឋានគិតអាករពិសេសលើទំនិញនាំចេញ.................................២៣១

៥ មូលដ្ឋានគិតអាករ អត្រាអាករ និងការគណនា.................................................២៣១

៥.១ អត្រាអាករ .........................................................................................២៣១

៥.២ អត្រាអាករពិសេសលើសេវា..............................................................២៣២

៦ ការប្រកាសពន្ធនិងការបង់ពន្ធ.......................................................................២៣២

៧ សមត្ថកិច្ចគ្រប់គ្រងនិងការប្រមូលអាករពិសេស........................................ ២៣៣
៨ អាករបំភ្លឺសាធារណៈ.............................................................................................២៣៥
    ៨.១ កម្មវត្ថុ..................................................................................................២៣៥
    ៨.២ ការលើកលែងអាករ.................................................................................... ២៣៥
៩ មូលដ្ឋានគិតអាករ អត្រាអាករ ការគណនាអាករ ..............................................២៣៦
១០ ការប្រកាសនិងការបង់ពន្ធ.....................................................................................២៣៧
១១ អាករលើការស្នាក់នៅ...........................................................................................២៣៩
    ១១.១ និយមន័យ.................................................................................................. ២៣៩
    ១១.២ គោលបំណង...............................................................................................២៣៩
១២ មូលដ្ឋានគិតអាករ អត្រាអាករ និងការគណនា ..............................................២៤០

## មេរៀនទី ១០ ៖ ការប្រមូលពន្ធលើថ្លៃឈ្នួលផ្ទះនិងដី

១ និយមន័យ.......................................................................................................២៤៣
២ កម្មវត្ថុ.............................................................................................................២៤៣
៣ មូលដ្ឋានគិតពន្ធ អត្រាពន្ធ..................................................................................២៤៥
    ៣.១.មូលដ្ឋានគិតពន្ធលើឈ្នួលផ្ទះនិងដី .........................................................២៤៥
    ៣.២.ការគណនាពន្ធលើឈ្នួលផ្ទះ....................................................................២៤៥
៤ ការលើកលែងពន្ធ ...........................................................................................២៤៦

# មេរៀនទី ១១ ៖ ការប្រមូលពន្ធអប្បរមា

១ និយមន័យ....................................................................................................២៤៧

២ ការគណនាពន្ធអប្បបរមា......................................................................................២៤៧

៣ មូលដ្ឋានគិតពន្ធនិងអត្រាពន្ធអប្បបរមា.......................................................................២៤៨

៤ ការដាក់លិខិតប្រកាសពន្ធនិងការបង់ពន្ធ.....................................................................២៤៩

៥ លិខិតប្រកាសពន្ធប្រចាំឆ្នាំ........................................................................................២៥០

៦ អាជីវកម្មជាប់ពន្ធតាមរបបម៉ៅការ..............................................................................២៥០

# សេចក្តីផ្តើម

## ១.ប្រវត្តិពន្ធដារនៅកម្ពុជា

កម្ពុជា ជាអាណាចក្រចាប់ពីសតវត្សទី១ រហូតដល់សតវត្សទី១៣ ហើយដែលគ្រប់គ្រងដោយព្រះបាទជ័យវរ្ម័នទី៧ ប្រជាជនមានភាពសុខសាន្ត បង្ករបង្កើនផលធ្វើស្រែចំការបានភោគផលច្រើនសន្ធឹកសន្ធាប់ ហើយប្រជាជនមានកាតព្វកិច្ចយកភោគផលដែលបង្កបង្កើនផលបានមួយផ្នែកតូចទៅជួយដល់រដ្ឋកាលដែលដឹកនាំនៅតាមតំបន់រស់នៅរបស់ពួកគាត់។ ក្រោយជាបន្តបន្ទាប់មកកម្ពុជាធ្លាក់ចូលសង្រ្គាមរ៉ាំរ៉ៃ ដណ្តើមអំណាចគ្នាធ្វើអោយប្រជាជនរងទុក្ខវេទនាគ្មានពេលល្ហែ រហូតមកដល់ទស្សវត្សឆ្នាំ ១៩៥០ ដែលគ្រប់គ្រងដោយបារាំងពេលនោះ បារាំងតម្រូវអោយប្រជាជនខ្មែរចេះបង់ពន្ធជូនដល់រដ្ឋការបារាំង។ លុះរហូតមកដល់ឆ្នាំ១៩៥៣ កម្ពុជាបានទទួលឯករាជ្យពីបារាំងហើយ ក៏បានរៀបចំរដ្ឋឡើងវិញដោយបែងចែកទៅតាមក្រសួងនានាដែលជាសេនាធិការរបស់រដ្ឋ ក្នុងនោះក្រសួងពន្ធដារដើរតួរនាទី យ៉ាងសំខាន់ ជាស្នូលក្នុងការប្រមូលពន្ធដើម្បីទ្រទ្រង់សេដ្ឋកិច្ចជាតិ។ អំឡុងឆ្នាំ១៩៧៥-១៩៧៩ កម្ពុជាធ្លាក់ចូលរបបប្រល័យពូជសាសន៏ កាប់សម្លាប់ប្រជាជនឯងគ្មានត្រាប្រណី រាល់ហេដ្ឋារចនាសម្ព័ន្ធត្រូវបានវាយបំផ្លាញចោលទាំងអស់។

ក្រោយថ្ងៃរំដោះ១៩៧៩ -១៩៨០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងមកវិញ។ ហើយស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងប្រទេសកម្ពុជាមានការរីកចម្រើន ចាប់តាំងពីរាជរដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៩៣ ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្របខណ្ឌ័នៃការគ្រប់គ្រងសេដ្ឋកិច្ចអភិវឌ្ឍន៍ ដើម្បីរៀបចំគោលនយោបាយជាតិ និងយុទ្ធសាស្រ្ត តាមចក្ខុវិស័យព្រមទាំងកន្សោមអាទិភាពនៃតម្រូវការវិនិយោគ ដោយត្រូវធ្វើការកំណែទំរង់ថ្មីលើស្ថាបន័ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដើម្បីឈានជើងចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី ។ ដោយកម្ពុជាជាប្រទេសមួយស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ តម្រូវការចាំបាច់គឺការ ទាក់ទាញវិនិយោគទុន អោយចូលមកបណ្តាក់ទុនអោយបានច្រើន ដែលកត្តានេះរាជរដ្ឋាភិបាលកម្ពុជាត្រូវរៀបចំ ការប្រមូលពន្ធនិងច្បាប់ពន្ធអោយស្របទៅនឹងបណ្តាប្រទេសរីកចំរើនមួយចំនួន ព្រោះថា វិស័យពន្ធដារផ្តល់នូវប្រាក់ចំណូលច្រើនជាងគេ ដល់ថវិកាជាតិ ហេតុនេះការរៀបចំការប្រមូលពន្ធនិងច្បាប់ពន្ធជាបញ្ហាដ៏សំខាន់សំរាប់ប្រទេសកម្ពុជាក្នុងដំណើរការអភិវឌ្ឍន៍ សេដ្ឋកិច្ចរបស់ខ្លួន ។ រហូតដល់ឆ្នាំ ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានតម្លើងជាអគ្គនាយកដ្ឋានពន្ធដារ។ សព្វថ្ងៃនេះអគ្គនាយកដ្ឋានពន្ធដារមានការអភិវឌ្ឍន៍យ៉ាងខ្លាំងជាមួយ និង សមត្ថភាពក្នុងការប្រមូលពន្ធដ៏មានប្រសិទ្ធភាព ដោយមានការ

ទទួលស្គាល់យ៉ាងមុតមាំពីសំណាក់ប្រជានជន ។ អគ្គនាយកដ្ឋានពន្ធដារ បារៀបចំការប្រមូលពន្ធចំនួន ២៣ ប្រភេទ និងផ្តល់ភាពងាយស្រួលទៅដល់ប្រជាជនក្នុងការបង់ពន្ធ ហើយបង្កើតសាខាពន្ធដារជាខណ្ឌ័ ខេត្ត ចំនួន ៣៣ និងបានបង្កើតសេវាកម្មបង់ពន្ធ តាមប្រព័ន្ធអេឡិចត្រូនិចផងដែរ ។(អគ្គនាយកដ្ឋានពន្ធដារ ២០១៤-២០១៨)

**២.អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តវិធានការលើកកម្ពស់វប្បធម៏បង់ពន្ធ អោយមានភាពល្អប្រសើរជាងមុនដោយមានការកើនឡើងជាបន្តបន្ទាប់ នៃអត្រាការបង់ពន្ធទាន់ពេលវេលា ដោយសារការបង្កើនភាពងាយស្រួលក្នុងការបង់ពន្ធ និងពង្រីកគុណភាពសេវាការអប់រំដល់អ្នកជាប់ពន្ធ ព្រមទាំងការកែសម្រួលគោលនយោបាយសារពើពន្ធមួយចំនួន ដែលបានជួយលើកកម្ពស់កិច្ចសម្រួលពាណិជកម្ម និងចូលរួមពង្រឹងសមធម៏ក្នុងការបង់ពន្ធ។

សមិទ្ធផលចម្បងៗ នៅក្នុងការប្រមូលពន្ធរួមមានៈការសុំចុះបញ្ជីពន្ធដារតាមប្រព័ន្ធអេឡិចត្រូនិក និងដំណើរការប្រព័ន្ធទិន្នន័យប្រមូលផ្តុំ(Centralized database), ការចុះអង្កេតសហគ្រាសនៅក្នុងរាជធានី-ខេត្តបានពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងអប់រំ,ការដាក់បញ្ហាពិគ្រោះយោបល់, ការដាក់អោយដំណើរការមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (Call centre 1277) និងការដាក់អោយមានកម្រងសំណួរ-ចម្លើយ(FAQs),ការដាក់អោយប្រើប្រាស់វិក្កយបត្រតែមួយ(Single invoice), និងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក(e-payment) និងបានបង្កើតជម្រើសបន្ថែមក្នុងការបង់ពន្ធតាមប្រព័ន្ធធានាគារ, ការរៀបចំសៀវភៅណែនាំស្តីពីការកំណត់ហានិភ័យអ្នកជាប់ពន្ធ និងប្រកាសស្តីពីវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូល និងចំណាយក្នុងចំណោមបុគ្គលទាក់ទិន ព្រមទាំងបានកសាងសមត្ថភាពសវនកម្មពន្ធដារ, អនុវត្តសេចក្តីណែនាំស្តីពីនីតិវិធីនៃការធ្វើសវនកម្មលើការធ្វើអាជីវកម្ម និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសវនកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងបានអនុវត្ត

យន្តការទូទាត់បំណុលជាដំណាក់កាល, កែសម្រួលវិធាន និង នីតិវិធីដោះស្រាយបណ្តឹងតវ៉ាពន្ធដារ និង បង្កើតគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ។

ទន្ទឹមនេះ ដើម្បីបន្តពង្រឹងអភិបាលកិច្ច អគ្គនាយកដ្ឋានពន្ធដារ បានខិតខំផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវតារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈ ព្រមទាំងបានរៀបចំឱ្យមានកន្លែង ឬប្រអប់សំបុត្រទទួលបណ្តឹង ជាពិសេសក្នុងករណីមានការអនុវត្តខុសឆ្គង ការយកកម្រៃលើសពីការកំណត់ ឬការឃើតយ៉ាវជាដើម។ អ្នកជាប់ពន្ធដែលបានចុះបញ្ជីរួចមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ។ នាពេលកន្លងមកនៅ អគ្គនាយកដ្ឋានពន្ធដារបានខិតខំកែលម្អការចាត់ចែងលិខិតប្រកាស ដោយបានបញ្ចូលគ្នានូវលិខិតប្រកាស ប្រចាំខែ និងប្រចាំឆ្នាំ, និងដាក់លិខិតប្រកាសនៅលើគេហទំព័រដែលអ្នកជាប់ពន្ធអាចទាញយកមកប្រើបាន ដើម្បីពង្រីកសេវាបង់ប្រាក់ពន្ធតាមប្រព័ន្ធធនាគារ។

ដើម្បីឈានទៅរកប្រសិទ្ធភាពនៃការប្រមូលពន្ធ ត្រូវបានអនុវត្តវិធានការកែទម្រង់រដ្ឋបាលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធភាគច្រើនត្រូវបានបញ្ចប់ ការប្រមូលចំណូលពន្ធទទួលបានជោគជ័យហួសពីការរំពឹងទុក។ (អគ្គនាយកដ្ឋានពន្ធដារ ២០១៩-២០២៣)

### ៣.និមិត្តសញ្ញាណពន្ធដារ

#### ១.និយមន័យ

ពន្ធ = ចង, ជាប់, ជំពាក់, សួយសារ អាករដែលប្រជាពលរដ្ឋត្រូវបង់តាមកាលកំណត់។

ពន្ធ = ម្ចាស់របស់ត្រូវបង់ជូនរាជការ តាមចំនួនដែលមានកម្រិតទុកជាស្រេចក្នុងបញ្ជី។

ពន្ធ = គឺជាកាតព្វកិច្ចបង់ជាប្រាក់ឬជាវត្ថុរបស់អ្នកជាប់ពន្ធទៅរាជរដ្ឋាភិបាល ហើយអ្នកជាប់ពន្ធទាំងនោះទទួលតម្លៃតបស្នងពីរដ្ឋាភិបាលវិញ តាមរយៈទំនិញ និងសេវាសាធារណៈ។

ពន្ធ = គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិការជាតិ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។

ពន្ធ = ជាឧបករណ៍របស់រាជរដ្ឋាភិបាល ដែលបានបង្កើតឡើង ដើម្បីកៀរគរចំណូល ចូលថវិការជាតិសម្រាប់ចំណាយលើសេវាសារណៈ។

ពន្ធ = សំដៅដល់ ពន្ធអាករ (ពន្ធផ្ទាល់ និងពន្ធប្រយោល)។

**២.គោលដៅពន្ធដារ**

គោលបំណងនៃការប្រមូលចំណូលពន្ធ ដើម្បីកំណត់នៅក្នុងគោលនយោបាយចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដោយផ្តោតសំខាន់ទៅលើការកសាងរដ្ឋបាលមួយ ដែលមានសមត្ថភាពរឹងមាំ ដើម្បីរួមចំណែកគាំទ្រដល់កំណែរទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅទៅដល់ការចូលរួមគាំទ្រដល់សេដ្ឋកិច្ច និងសង្គមអោយមានភាពរុងរឿងជានិច្ចនិរន្តរ៍ដើម្បីឆ្លើយតបនឹងបំណងប្រាថ្នា និងការរំពឹងទុកកាន់តែខ្ពស់របស់ប្រជាពលរដ្ឋ។

ជាមួយគ្នានេះ ការប្រមូលចំណូលពន្ធបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើអោយសំរេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ការកាត់បន្ថយភាពក្រីក្រ បង្កើតការងារសមរម្យជូនប្រជាពលរដ្ឋ ការបន្តតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ការបង្កើនគុណភាព និងពង្រីងវិសាលភាពសេវាសាធារណ សំខាន់ៗ ទាំងហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្ត អប់រំ សុខាភិបាល និងសេវាមូលដ្ឋានចំបាច់ផ្សេងៗទៀត រួមទាំងរបបសន្តិសុខសង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋទូទៅ និងការកាត់បន្ថយគម្លាតនៃការរីកចម្រើន រវាងទីក្រុងនិងជនបទ ជាពិសេសការបន្តពង្រឹងភាពជាម្ចាស់ ក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍របស់ខ្លួ

# មេរៀនទី ១ ៖ ការចុះបញ្ជីពន្ធដារ

## ១-គោលបំណង

គោលបំណងកំណត់នូវវិធាននិងនីតិវិធី នៃការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ស្របតាមមាត្រា ៧៦ មាត្រា១០១ និងមាត្រា១០៣ នៃច្បាប់សារពើពន្ធ សំដៅពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ និងគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធ ដើម្បីគាំទ្រទៅដល់ការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រង ការប្រមូលពន្ធ អោយកាន់តែមានតម្លាភាព និងមានប្រសិទ្ធភាព។

## ២-និយមន័យ

- ពាក្យ "ការចុះបញ្ជីពន្ធដារ" សំដៅទៅដល់ការចុះបញ្ជីអ្នកជាប់ពន្ធទាំងឡាយ ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការប្រកបរបរអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- ពាក្យ "អ្នកជាប់ពន្ធដារ" សំដៅទៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ច ត្រូវបង់ពន្ធ។
- ពាក្យ "អាជីវកម្ម" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គល ក្នុងគោលដៅផលិត និងលក់ទំនិញផ្គត់ផ្គង់សេវា ភតិសន្យា ជួលឬលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀតរួមទាំងសកម្មភាពរបស់ ស្ថាប័ន ឬអង្គការនានាដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រា៣ថ្មី នៃច្បាប់សារពើពន្ធ។

•ពាក្យ "សកម្មភាពសេដ្ឋកិច្ច" សំដៅដល់សកម្មភាព បុគ្គលដែលធ្វើជានិច្ចជាកាលជាប់បន្ត ឬ ធ្វើមួយគ្រា ដើម្បីរក ឬ មិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬ មានបំណងផ្គត់ផ្គង់ទំនិញ ឬ សេវាអោយដល់បុគ្គលដ៏ទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

•ពាក្យ "បុគ្គល" សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល។

•ពាក្យ "ទីចាត់ការសហគ្រាស" សំដៅដល់ទីកន្លែងគ្រប់គ្រងប្រតិបត្តិការអាជីវកម្មរបស់សហគ្រាស។

•ពាក្យ "ទីកន្លែងប្រកបអាជីវកម្មជាគោលដើម" សំដៅដល់ទីកន្លែងគោលដើមសម្រាប់ផ្គត់ផ្គង់ទំនិញ ឬ សេវារបស់សហគ្រាស។

•ពាក្យ "សាខា" សំដៅដល់កន្លែងគ្រប់គ្រងទំនិញ ឬ សេវាដែលមិនមែនជាកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់សហគ្រាស។ សម្រាប់គោលដៅ ជាទីកន្លែងណាមួយត្រូវបានចាត់ទុកជាសាខារបស់សហគ្រាស ក្នុងករណីដែលទីកន្លែងនោះ ធ្វើអាជីវកម្មលើសពី ០៦ ខែ ជាប់គ្នានៃឆ្នាំប្រតិទិន។(ប្រក.លេខ ៧០១ សហវ. ១៤ .០៩.២០២០)

## ៣-នីតិវិធីនៃការចុះបញ្ជីពន្ធដារនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

### ៣.១-ការចុះបញ្ជី

១-បុគ្គលទាំងឡាយត្រូវចុះបញ្ជី នៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ ថ្ងៃ នៃ ថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី លិខិតអនុញ្ញាតិចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ បុគ្គលដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារ ជាអាទិ៍៖

ក-ស្ថាប័នរដ្ឋ បេសកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហ

ប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណៈបក្សនយោបាយ។

ខ-ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សាខាក្រុមហ៊ុនបរទេស ការិយាល័យតំណាង សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតសហគ្រាសសាធារណៈសហគ្រាសរដ្ឋ និង ក្រុមហ៊ុនចម្រុះរដ្ឋ។

គ-សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ឃ-បុគ្គលដទៃទៀតដែលធ្វើសកម្មភាពអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-បុគ្គលដែលតម្រូវអោយចុះបញ្ជីពន្ធដារស្របតាមចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬកម្រិតផលរបរ ដូចមានចែងក្នុងបញ្ញត្តិច្បាប់ស្តីពីពន្ធដារ និងត្រូវស្នើសុំចុះបញ្ជីទៅតាមទ្រង់ទ្រាយគតិយុត្តនៃបុគ្គលស្នើសុំដូចខាងក្រោម៖

ក- បុគ្គលដែលបានចុះបញ្ជីពន្ធដារ ត្រូវធ្វើឡើងតាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservices.gov.kh ស្របទៅតាមកាលកំណត់ដូចមានចែងក្នុងអនុក្រឹត្យលេខ ៨៤ អ ន ក្រ.បក ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្ម ទៅតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ បុគ្គលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃគេហទំព័រចុះបញ្ជីអាជីវកម្មនឹងទទួលបាន ឯកសារបញ្ជាក់ការការចុះបញ្ជីពន្ធដារ ជាទម្រង់ឌីជីថលដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជីអាជីវកម្មនេះ។

ខ- បុគ្គលណាមួយដែលមានបំណងចុះបញ្ជីដោយផ្ទាល់ នៅរដ្ឋបាលសារពើពន្ធឬមិនអាចធ្វើការចុះបញ្ជីតាមគេហទំព័រចុះបញ្ជីអាជីវកម្មបាន ការចុះបញ្ជីពន្ធដារ

ត្រូវធ្វើឡើងតាមរយៈការបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវ ដូចមាននៅក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារ និង ធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធតាម (ទម្រង់១០១)។

៣-រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងប្រាក់ពន្ធ កម្រៃសេវា ដោយបញ្ជាក់កាលបរិច្ឆេទនៃការប្រគល់ទទួលបន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំនោះត្រឹមត្រូវ និងគ្រប់គ្រាន់។ ដោយឡែក ការស្នើសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរបស់បុគ្គល រដ្ឋបាលសាពើពន្ធត្រូវបំលែងឯកសារ បញ្ចូលព័ត៌មានការស្នើសុំចុះបញ្ជី និងសម្របសម្រួលទូទាត់ប្រាក់ពន្ធ កម្រៃសេវាចុះបញ្ជីទៅតាមគេហទំព័រចុះបញ្ជីអាជីវកម្ម https//www.registrationservices.gov.kh អោយបានរួចរាល់ និងត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជី និងប្រាក់ពន្ធ កម្រៃសេវាចុះបញ្ជី នៅក្រោយពេលបានទទួលលិខិតជាសាអេឡិចត្រូនិកបញ្ជាក់ការទទួលពាក្យស្នើសុំពីគេហទំព័រចុះបញ្ជីអាជីវកម្ម។ (ប្រក. លេខ ៧០១ សហវ. ១៤ .០៩.២០២០)

### ៣.២-ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

១-អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ មានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងករណីដែលមានព័ត៌មានណាមួយក្នុងចំណោមព័ត៌ខាងក្រោះ

ក- អាសយដ្ឋាន

ខ- ទ្រង់ទ្រាយ

គ- នាមករណ៏

ឃ- កម្មវត្ថុអាជីវកម្ម ឬ សកម្មភាពអាជីវកម្ម

ង- ការផ្ទេរ ឬការផ្លាស់ប្តូរម្ចាស់ភាគហ៊ុន

ច- សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬ សាខា

ជ- អ្នកទទួលបន្ទុកកិច្ចការពន្ធដារ

ឈ- ព័ត៌មានគណនីធនាគារ

ញ- ព័ត៌មានទំនាក់ទំនងលេខទូរស័ព្ទ សារអេឡិចត្រូនិក

២-អ្នកជាប់ពន្ធដែលមានផ្លាស់ប្តូរព័ត៌មាន ត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មាន ដោយត្រូវបំពេញព័ត៌មាន និងត្រូវភ្ជាប់មកជាមួយនូវឯកសារចុងក្រោយ នៃឯកសារបញ្ជាក់ការផ្លាស់ប្តូរព័ត៌មាននោះតែប៉ុណ្ណោះ ដូចមាននៅក្នុងកំណត់ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និង ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់១០១) ចំណែកការផ្លាស់ប្តូរព័ត៌មានសាខា ឬបន្ថែមសាខា អ្នកជាប់ពន្ធត្រូវបំពេញព័ត៌មានសាខាតាមទម្រង់(១០១-C) និងភ្ជាប់ឯកសារដូចមាននៅក្នុងឧបសម្ព័ន្ធស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន។

៣-អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ ប៉ុន្តែ មិនទាន់មានអត្តសញ្ញាណកម្ម សារពើពន្ធ តាមទម្រង់ថ្មីដែលរដ្ឋបាលសារពើពន្ធបានកំណត់ ប្រធាន ឬ អ្នកតំណាង ម្ចាស់សហគ្រាស ឬ អ្នកតំណាង របស់បុគ្គល ត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មានដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារ និង ធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ(ទម្រង់១០១)។

៤-តាមការចាំបាច់ ឬនៅពេលដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថា អ្នកជាប់ពន្ធបានប្រើប្រាស់ព័ត៌មិនពិត ឬមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ឬ មិនច្បាស់លាស់ ឬ ឯកសារក្លែងក្លាយ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតអញ្ជើញ អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមគេហទំព័រចុះបញ្ជីអាជីវកម្មមកផ្តល់ព័ត៌មានបន្ថែម ឬមកធ្វើបច្ចុប្បន្នភាព។ ក្នុងករណីអ្នកជាប់ពន្ធមិនបានបង្ហាញខ្លួនតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ បុគ្គលនោះនឹងត្រូវដាក់ចូលក្នុងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជីរបស់អគ្គនាយក

ដ្ឋានពន្ធដារ ការចុះបញ្ជីពន្ធដារត្រូវបានបដិសេធ និងមិនត្រូវបានអនុញ្ញាតិអោយចុះបញ្ជីអាជីវកម្មដ៏ទៃទៀតតាមគេហទំព័រចុះបញ្ជីអាជីវកម្មឡើយ។(ប្រក.លេខ ៧០១ សហវ. ១៤ .០៩.២០២០)

**៣.៣-កម្រៃសេវា ការបង់ពន្ធប៉ាតង់ និងពន្ធប្រថាប់ត្រាលើ ឯកសារមានលក្ខណៈគតិយុត្ត**

១-កម្រៃសេវាចុះបញ្ជីពន្ធដារ មានដូចខាងក្រោម៖

ក- ០ រៀល សម្រាប់ស្ថាប័នរដ្ឋ បេសកម្មការទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណៈបក្សនយោបាយ។

ខ- ២០ ០០០រៀល សម្រាប់បុគ្គលដែលបានស្នើសុំចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ឬ អ្នកជាប់ពន្ធដែលមានកម្រិតផលរបរទាបជាងអ្នកជាប់ពន្ធតូច។

គ- ៤០០ ០០០រៀល សម្រាប់បុគ្គលដែលបានចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យម ឬ ជាអ្នកចាប់ពន្ធធំ។

២-កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធដូចមាននៅខាងក្រោម៖

ក-០ រៀល សម្រាប់ស្ថាប័នរដ្ឋ បេសកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា និងគណៈបក្សនយោបាយ។

ខ-១០ ០០០រៀល សម្រាប់បុគ្គលដែលបានចុះបញ្ជី ជាអ្នកជាប់ពន្ធតូច ឬ ជាអ្នកជាប់ពន្ធដែលមានកម្រិតផលរបរទាបជាងអ្នកជាប់ពន្ធតូច។

គ-២០០ ០០០រៀល សម្រាប់បុគ្គលដែលបានចុះបញ្ជីពន្ធដារ ជាអ្នកជាប់ពន្ធមធ្យម

ឬ ជាអ្នកជាប់ពន្ធធំ។

៣-កម្រៃសេវាត្រូវបានអនុវត្តផងដែរចំពោះ៖

ក- ការស្នើសុំផ្លាស់ប្តូរព័ត៌មាន រដ្ឋបាលសារពើពន្ធនិងត្រូវផ្តល់ជូនឡើងវិញនូវ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករតម្លៃបន្ថែម អតប) ឬ លិខិតបញ្ជាក់ការចុះបញ្ជីសាខា ឬ លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។

ខ- ការស្នើសុំផ្លាស់ប្តូរព័ត៌មាន ឬ បន្ថែមសាខា ដែលរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជូនឡើងវិញ ឬផ្តល់ជូនបន្ថែមនូវលិខិតបញ្ជាក់ការចុះបញ្ជីសាខា អ្នកជាប់ពន្ធត្រូវបង់កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានទៅតាមចំនួនសាខានីមួយៗ ដែលបានស្នើសុំ។

គ- ការស្នើសុំបោះពុម្ពឡើងវិញនូវវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ឬ លិខិតបញ្ជាក់ការចុះបញ្ជីសាខា ឬ លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។ ដោយឡែក ចំពោះការស្នើសុំ បោះពុម្ពប័ណ្ណសំគាល់ការចុះបញ្ជីពន្ធដារ (កាត) អ្នកជាប់ពន្ធត្រូវបានតម្រូវ អោយបង់កម្រៃសេវាចំនួន ៥ ០០០ រៀល។

៤- ដើម្បីលើកទឹកចិត្ត និងជំរុញការចុះបញ្ជីអាជីវកម្ម រាល់ការស្នើសុំចុះបញ្ជីដែលមានការតម្រូវអោយបង់ពន្ធប៉ាតង់ និង ពន្ធប្រថាប់ត្រានៅលើឯកសារមានលក្ខណៈគតិយុត្តត្រូវអនុវត្តដូចខាងក្រោម៖

ក- ពន្ធប៉ាតង់ត្រូវបានតម្រូវអោយបង់ ៥០ (ហាសិប) ភាគរយ នៃប្រាក់ពន្ធប៉ាតង់ត្រូវបង់ប្រចាំឆ្នាំ នៅពេលស្នើសុំចុះបញ្ជីពន្ធដារ ទៅតាមសកម្មភាពអាជីវកម្ម

នីមួយៗ ដែលបានស្នើសុំ។

ខ- ពន្ធប្រថាប់ត្រាលើឯកសារមានលក្ខណៈគតិយុត្តស្ដីពីការបង្កើតក្រុមហ៊ុន ត្រូវបានលើកលែង។(ប្រក.លេខ ៧០១ សហវ. ១៤ .០៩.២០២០)

## ៣.៤-រយៈពេលទទួលបានការចុះបញ្ជីពន្ធដារ ឬ ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

១-អ្នកជាប់ពន្ធអាចទទួលបានសេចក្ដីសម្រេចចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មាន ក្នុងរយៈពេល ៧ ថ្ងៃ ទៅ ១០ ថ្ងៃ នៃ ថ្ងៃធ្វើការ។

២-ឯកសារផ្លូវការ នៃការចុះបញ្ជីពន្ធដារឬការធ្វើបច្ចុប្បន្នភាពព័ត៌មាន ដែលរដ្ឋបាលសារពើពន្ធ ត្រូវប្រគល់អោយអ្នកជាប់ពន្ធមានដូចខាងក្រោម៖

ក-ស្ថាប័នរដ្ឋ បេសកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការ បច្ចេកទេសរបស់រដ្ឋាភិបាលនានា គណៈបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ

-ប័ណ្ណសំគាល់ការចុះបញ្ជីពន្ធដារ(កាត)

-លិខិតជូនដំណឹង ស្ដីពីការបំពេញកាតព្វកិច្ចសារពើពន្ធ

ខ- អ្នកជាប់ពន្ធធំអ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូចដែលជាសហគ្រាសអាជីវកម្ម ឬ បុគ្គលដូចមានចែងដូចខាងក្រោម៖

-វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ(អាករលើតម្លៃបន្ថែម-អតប)

-ប័ណ្ណសំគាល់ការចុះបញ្ជីពន្ធដារ(កាត)

-ប័ណ្ណពន្ធប៉ាតង់

-លិខិតជូនដំណឹង ស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ

គ- អ្នកជាប់ពន្ធដ៏ទៃទៀត ឬ អ្នកជាប់ពន្ធដែលមានកម្រិតផលរបរ ទាបជាងអ្នកជាប់ពន្ធតូច

-លិខិតបញ្ជាក់ការចុះបញ្ជីបន្ធដារ

-ប័ណ្ណសំគាល់ការចុះបញ្ជីពន្ធដារ(កាត)

៣-ក្រោយពេលទទួលបានការសម្រេចអោយចុះបញ្ជីពន្ធដារ ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ រដ្ឋបាលសារពើពន្ធអាចចុះដល់ទីតាំងអ្នកជាប់ពន្ធ ដើម្បីប្រគល់ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ និងពិនិត្យផ្ទៀងផ្ទាត់ចំណុចនិយាមកាទីតាំង ថតរូបទីតាំង និងកត់ត្រាទិន្នន័យទីតាំងផ្សេងៗ របស់អ្នកជាប់ពន្ធចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ។

**៣.៥-ការបដិសេធន៍ការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ**

ក្នុងករណី បុគ្គលណាមួយដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ មិនបានបំពេញព័ត៌មាននិងផ្តល់ឯកសារភ្ជាប់អោយបានត្រឹមត្រូវ ឬ មិនគោរពតាមលក្ខខណ្ឌ តាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ ឬជាប់ទាក់ទិននឹងសហគ្រាស ឬសមាគមន៏ ឬអង្គការនានា ដ៏ទៃទៀតដែលមានជំពាក់បំណុល ឬមិនមានទីលំនៅ ឬកន្លែងធ្វើអាជីវកម្មជាប់លាប់ ឬកន្លែងធ្វើសកម្មភាពអាជីវកម្មមិនសមស្របនឹងកម្មវត្ថុដែលបានស្នើសុំ រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធន៏ការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៏អក្សរ

ដល់អ្នកជាប់ពន្ធ ស្តីពីការបដិសេធន៏ចំពោះការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធក្នុងអំឡុងពេល ៣០ ថ្ងៃយ៉ាងយូរ។(ប្រក.លេខ ៧០១ សហវ. ១៤ .០៩.២០២០)

## ៤-ការចុះពិនិត្យស្ថានភាពអាជីវកម្ម និងបញ្ជីអចិន្ត្រៃយ៍សម្រាប់ការចុះបញ្ជី

### ៤.១-ការចុះពិនិត្យស្ថានភាពអាជីវកម្ម

ក្នុងករណីដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថា ព័ត៌នៃការចុះបញ្ជីរបស់អ្នកជាប់ពន្ធមិនច្បាស់លាស់គ្រប់ជ្រុងជ្រោយ រដ្ឋបាលសារពើពន្ធអាចពិនិត្យស្ថានភាពអាជីវកម្ម ដល់ទីតាំងរបស់អ្នកជាប់ពន្ធ ឬអញ្ជើញប្រធានក្រុមប្រឹក្សាភិបាល ម្ចាស់សហគ្រាស ឬប្រធានសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលជាអ្នកទទួលបន្ទុក កិច្ចការពន្ធដារមកផ្តល់ព័ត៌មាន ផ្តល់ឯកសារពាក់ព័ន្ធនានា ឬធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណដោយការចុះហត្ថលេខា ការថតរូប ស្កេនម្រាមដៃ និងប្រឹក្សាយោបល់ពាក់ព័ន្ធនិងច្បាប់បទប្បញ្ញាតិស្តីពីពន្ធដារ ដោយផ្ទាល់រដ្ឋបាលសារពើពន្ធ ឬតាមមធ្យោបាយបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត។

ក្នុងករណីដែលប្រធានក្រុមប្រឹក្សា ម្ចាស់សហគ្រាស ឬប្រធានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលណាមួយមិនអាចអញ្ជើញមកបង្ហាញខ្លួនដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធបាន ត្រូវធ្វើលិខិតផ្ទេរសិទ្ធិអោយអ្នកតំណាងណាមួយ នៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឬសមាគមអង្គការមិនមែនរដ្ឋាភិបាល ដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ច មកបំពេញកាតព្វកិច្ចជំនួសខ្លួនបាន ឬក្នុងករណីចាំបាច់អាចស្នើសុំអោយរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប ស្កេនម្រាមដៃ ដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ។(ប្រក.លេខ ៧០១ សហវ. ១៤ .០៩.២០២០)

### ៤.២-ការចុះបញ្ជីពន្ធដារដោយឯកតោភាគី

បុគ្គលទាំងឡាយដែលច្បាប់បានកំណត់អោយចុះបញ្ជីហើយ ពុំបានមកចុះបញ្ជី ឬមិនបានមកចុះបញ្ជីតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីអ្នកជាប់ពន្ធ

ជាឯកតោភាគី។ ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី និង កំណត់នូវអ្នកតំណាងណាមួយរបស់សហគ្រាស ដើម្បីទទួលបន្ទុកលើកិច្ចការពន្ធដារ។

### ៤.៣- បញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី

១- អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី សម្រាប់កត់ត្រាអត្តសញ្ញាណរបស់បុគ្គលណាមួយ៖

ក- ជាប់ទាក់ទិននិង សហគ្រាស សមាគម ឬអង្គការនានា ដ៏ទៃទៀត ក្នុងគោលបំណងប្រព្រឹត្តិបទល្មើសគេចវេះពន្ធ។

ខ- មានជំពាក់បំណុលពន្ធ ឬជាប់ទាក់ទិននិងសហគ្រាស សមាគម ឬអង្គការនានា ដ៏ទៃទៀត ដែលមានជំពាក់បំណុលពន្ធ។

គ- ខកខានមិនមកបង្ហាញខ្លួន ផ្តល់ព័ត៌មានបន្ថែម និង ផ្តល់ឯកសារតម្រូវនានា តាមការអញ្ជើញ របស់រដ្ឋបាលសារពើពន្ធ។

ឃ- ជាប់ទាក់ទិននិងសហគ្រាស សមាគម ឬ អង្គការនានា ដ៏ទៃទៀត ដែលត្រូវបានអគ្គនាយកដ្ឋានពន្ធដារ ចុះបញ្ជីពន្ធឯកតោភាគី ហើយមិនបានផ្តល់កិច្ចសហការ បំពេញព័ត៌មាននិងផ្តល់ឯកសារ តាមតម្រូវការសម្រាប់ការចុះបញ្ជីពន្ធដារ អោយបានចប់សព្វគ្រប់។

ង- រដ្ឋបាលសារពើពន្ធ មានមូលដ្ឋានច្បាស់លាស់ ជឿជាក់ថាមិនមែនជាបុគ្គលដែលទទួលផលពិតប្រាកដពីអាជីវកម្ម ឬប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬ មានចេតនាផ្តល់គំនិតជំរុញ ឬ ជួយជ្រោមជ្រែង ឬអូសទាញអ្នកជាប់ពន្ធ ឬបុគ្គលម្នាក់ទៀត អោយប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពី ពន្ធដារ ឬ

បទល្មើសសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម។

២- អគ្គនាយកដ្ឋានពន្ធដារ ត្រូវចែករំលែកបញ្ជី អវិជ្ជមានសម្រាប់ការចុះបញ្ជី ដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តាមរយៈការផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) សម្រាប់ជាកម្មវត្ថុនៃការចូលរួមសហការ ក្នុងការពិនិត្យ និង សម្រេចផ្តល់ការអនុញ្ញាត ចំពោះការស្នើសុំចុះបញ្ជី។

៣-បុគ្គលិកដែលត្រូវបានដាក់ចូលក្នុងបញ្ជីអវិជ្ជមាន នៃការចុះបញ្ជីរបស់អគ្គនាយកដ្ឋានពន្ធដារ នឹងមិនត្រូវបានអនុញ្ញាតអោយចុះបញ្ជីអាជីវកម្ម ដ៏ទៃទៀតតាមគេហទំព័រចុះបញ្ជីអាជីវកម្មឡើយ វៀរលែងតែបុគ្គលនោះបានដោះស្រាយរួចរាល់នូវកាតព្វកិច្ចសារពើពន្ធជាមួយ នឹងអគ្គនាយកដ្ឋានពន្ធដារ។(ប្រក.លេខ ៧០១ សហវ. ១៤ .០៩.២០២០)

## ៥- សិទ្ធិរបស់អ្នកជាប់ពន្ធ

### ៥.១-សិទ្ធិរបស់អ្នកជាប់ពន្ធ

អ្នកជាប់ពន្ធមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំអោយពិនិត្យឡើងវិញ លើការបដិសេធន៏ការចុះបញ្ជីពន្ធដារ ឬការដាក់បញ្ចូលក្នុងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី ឬការលុបចេញពីបញ្ជីពន្ធដារ។ ក្នុងករណីអ្នកជាប់ពន្ធមិនយល់លើសេចក្តីសម្រេច របស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចប្តឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ។

### ៥.២- ទោសទណ្ឌ

ការមិនបានចុះបញ្ជី ឬការមិនបានជូនដំណឹងអំពីការផ្លាស់ប្តូរព័ត៌មាន ឬមិនបានធ្វើបច្ចុប្បន្នភាពព័ត៌មានអោយបានទាន់ពេលវេលា តាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ ឬត្រូវ

បានចុះបញ្ជីឯកតោភាគី នឹងត្រូវទទួលរងនូវ អោយបង់ប្រាក់ពន្ធ កម្រៃសេវាចុះបញ្ជី នឹងទោសទណ្ឌចំពោះការប្រព្រឹត្តិអំពើរាំងស្ទះ ក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលដែលត្រូវបានរដ្ឋបាលសារពើពន្ធចុះបញ្ជីជាឯកតោភាគី ហើយមិនបានបំពេញកាតព្វកិច្ចចុះបញ្ជីអោយបានរួចរាល់ ត្រូវបានចាត់ទុកថា បានប្រព្រឹត្តិបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលនឹងត្រូវទទួលរងទោសទណ្ឌស្របតាម មាត្រា ១៣៦ នៃច្បាប់សារពើពន្ធ។

# មេរៀនទី ២ ៖ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ

## ១- គោលបំណង

ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីអោយមានសង្គតិភាពក្នុងការគ្រប់គ្រង ប្រមូលចំណូលពន្ធគ្រប់ប្រភេទ អោយមានប្រសិទ្ធភាព និងតម្លាលភាព និងសមធម៌ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចព្រះរាជាណាចក្រកម្ពុជា។

## ២- និយមន័យ

- ពាក្យ "ផលរបរ" សំដៅដល់តម្លៃនៃការផ្គត់ផ្គង់ ទំនិញ ឬ សេវាដែលជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ។
- ពាក្យ "ទ្រព្យសកម្ម" សំដៅដល់ទ្រព្យសម្បត្តិនានា ដែលត្រូវបានយកមកប្រើប្រាស់ក្នុងអាជីវកម្មរួមមាន៖ ទ្រព្យសកម្មរយៈពេលខ្លី និង ទ្រព្យសកម្មរយៈពេលវែង។

## ៣- ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកទៅលើកម្រិតផលរបរប្រចាំឆ្នាំ ទៅតាមវិស័យចម្បងៗ រួមមាន វិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និង វិស័យសេវាកម្ម។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវចាត់ថ្នាក់ជា បី ប្រភេទ ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធតូច គឺ ជាសហគ្រាសឯកបុគ្គល និង សហគ្រាសសហកម្មសិទ្ធិដែល៖

ក-មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១០០០ លានរៀល សម្រាប់វិស័យកសិកម្ម, សេវាកម្ម, និងពាណិជ្ជកម្ម។

ខ-មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១ ៦០០ លានរៀល សម្រាប់

វិស័យឧស្សាហកម្ម។

គ-មានផលរបរក្នុងរយៈពេល បី ខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិន ចរន្តចាប់ពី ៦០ លានរៀល ឡើងទៅ។

ឃ-រំពឹងថាមានផលរបរក្នុងរយៈពេល បី ខែជាប់គ្នាទៅមុខចាប់ពី ៦០ លានរៀល ឡើងទៅ។

ង-ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬ ស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ និងសេវា រួមទាំងភាស៊ី។

២-អ្នកជាប់ពន្ធមធ្យមគឺ ជាបុគ្គលិកដែលស្ថិតនៅក្នុងក្របខណ្ឌណាមួយ ក្នុងចំនោមលក្ខខណ្ឌដូចខាងក្រោមៈ

ក-មានផលរបរលើសពី ១០០០ លាន រៀលឡើងទៅដល់ ៤០០០ លាន រៀល សម្រាប់វិស័យកសិកម្ម។

ខ-មានផលរបរលើសពី ១០០០ លាន រៀល ឡើងទៅដល់ ៦០០០ លាន រៀល សម្រាប់វិស័យ សេវាកម្ម និង ពាណិជ្ជកម្ម។

គ-មានផលរបរលើសពី ១៦០០ លាន រៀល ឡើងទៅដល់ ៨០០០ លាន រៀល សម្រាប់វិស័យ ឧស្សាហកម្ម។

ឃ-សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល មានការិយាល័យតំណាង។

ង-ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលនានា ឬ គម្រោងដែលស្ថិតក្រោមស្ថាប័ននេះ។

ច-ជាបេសកម្មទូត និង កុងស៊ុលបរទេស អង្គការអន្តរជាតិ និង ទីភ្នាក់ងារសហ

ប្រតិបត្តិការ បច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬ គម្រោងដែលស្ថិតក្រោម ស្ថាប័នទាំងនេះ។

៣-អ្នកជាប់ពន្ធធំ គឺជាបុគ្គលដែលស្ថិតនៅក្នុលក្ខខណ្ឌណាមួយក្នុងចំនោមលក្ខខណ្ឌ ដូចខាងក្រោម៖

ក-មានផលរបរលើសពី ៤០០០ លាន រៀល ឡើងទៅ សម្រាប់វិស័យកសិកម្ម។

ខ-មានផលរបរលើសពី ៦០០០ លាន រៀល ឡើងទៅ សម្រាប់វិស័យសេវាកម្ម ពាណិជ្ជកម្ម។

គ-មានផលរបរលើសពី ៨០០០ លាន រៀល ឡើងទៅ សម្រាប់វិស័យឧស្សាហកម្ម។

ឃ-ជាបុត្រសម្ព័ន្ធក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស។

ង-ជាសហគ្រាសដែលបានចុះបញ្ជី ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់។ (ប្រ.ក.លេខ ០០៩ សហវ. ចុះថ្ងៃ ១២ .១. ២០២១)

## ៤-ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម

ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធ បានប្រកាស មិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង របស់អ្នកជាប់ពន្ធទេនោះ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិ ធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធឡើងវិញ ដោយផ្អែកលើតម្លៃទ្រព្យសកម្ម ដែលបានប្រើប្រាស់ក្នុអាជីវកម្ម របស់សហគ្រាសដូចខាងក្រោម៖

១-អ្នកជាប់ពន្ធតូច

ក-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លាន រៀល ដល់ ១០០០ លាន រៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និង ពាណិជ្ជកម្ម។

ខ-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លាន រៀល ដល់ ២០០០ លាន

រៀល សម្រាប់វិស័យឧស្សាហកម្ម។

២-អ្នកជាប់ពន្ធមធ្យម

ក-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ១០០០ លាន រៀល ដល់ ២០០០ លាន រៀល សម្រាប់វិស័យ កសិកម្ម សេវាកម្ម និង ពាណិជ្ជកម្ម។

ខ-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០០ លាន រៀល ដល់ ៤០០០ លាន រៀល សម្រាប់វិស័យឧស្សាហកម្ម។

៣-អ្នកជាប់ពន្ធធំ

ក-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២០០០ លាន រៀល សម្រាប់វិស័យ កសិកម្ម សេវាកម្ម និង ពាណិជ្ជកម្ម។

ខ-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ៤០០០ លាន រៀល សម្រាប់វិស័យ ឧស្សាហកម្ម។ (ប្រ.ក.លេខ ០០៩ សហវ. ចុះថ្ងៃ ១២ .១. ២០២១)

# មេរៀនទី ៣ ៖ ការប្រមូលពន្ធលើប្រាក់ចំណេញ

## ១- កម្មវត្ថុនៃពន្ធ

ពន្ធលើប្រាក់ចំណេញ គឺ ជាបំណុលរបស់បុគ្គលនិវាសជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និង ប្រាក់ចំណូលប្រភពបរទេស និង របស់បុគ្គលអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

## ២- គោលបំណង

១- ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់៖

ក- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬ មានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃ នៅក្នុងរយៈពេល ១២ ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។

ខ-នីតិបុគ្គល ឬ ក្រុមអាជីវកម្ម ដែលបានបង្កើត ឬ ត្រូវបានគ្រប់គ្រងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ឬ ដែលមានកន្លែងប្រកបអាជីវកម្ម ជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" មានន័យថា បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន តាមចំណុច ១ ខាងលើនេះនិងទទួលបានចំណូលប្រភពកម្ពុជា។

៣- ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាស ឬ អង្គការនានា ដែលប្រកបអាជីវកម្ម ទោះបីបាន ឬ មិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ច របស់រាជរដ្ឋាភិបាលក្តី។

- ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការសាសនា

អង្គការសប្បុរសធម៌ ឬ អង្គការមិនស្វែងរកចំណេញ។

- ចំពោះបុគ្គលអនិវាសនជន ពាក្យ "នីតិបុគ្គល" សំដៅដល់គ្រឹះស្ថាន អចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលទេ នូវ ក្រុមអាជីវកម្ម ឬ សហគ្រាសឯកបុគ្គល។

៤- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់ នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬ ភ្នាក់ងារនិវាសជន នៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះបុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន។

- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរនូវ សមាគម ឬ រូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គលអនិវាសជន ធ្វើសកម្មភាពសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។

៥- ពាក្យ "ក្រុមអាជីវកម្ម" សំដៅដល់ក្រុមសមូហនាមដែលមានម្ចាស់ភាគទុនជារូបវន្តបុគ្គល និវាសនជនយ៉ាងច្រើន១០នាក់ ហើយក្នុងនោះចំណែកសមាមាត្ររបស់ម្ចាស់ភាគទុននៅក្នុងខ្ទង់មូលធន ប្រាក់ចំណេញ និង ការខាតបង់ត្រូវស្របតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយអនុក្រឹត្យ។ ក្នុងនិយមន័យនេះ "ក្រុមអាជីវកម្ម" មិនអាចជាសមាជិករបស់ក្រុមហ៊ុនបុគ្គលណាមួយហើយក៏មិនរាប់បញ្ចូលផងទេ នូវក្រុមហ៊ុនដើមទុន គ្រឹះស្ថានអចិន្ត្រៃយ៍ ឬ សហគ្រាសឯកបុគ្គល។

៦- ពាក្យ "សហគ្រាសឯកបុគ្គល" សំដៅដល់សហគ្រាសអាជីវកម្ម ដែលជាកម្មសិទ្ធិ ១០០ ភាគរយ របស់រូបវន្តបុគ្គលណាម្នាក់។ ក្នុងនិយមន័យនេះ ប្តី ប្រពន្ធ និងកូន ក្នុងបន្ទុកត្រូវចាត់ទុកថា ជារូបវន្តបុគ្គលតែម្នាក់។

៧- ពាក្យ "អាជីវកម្ម" សំដៅដល់ សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គល ដែលមានគោលដៅទាញយកប្រាក់ចំណេញអំពី ការផលិតនិងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬ ការលក់ទ្រព្យសម្បត្តិ ឬ សកម្មភាពផ្សេងទៀត។

៨- ពាក្យ "ភាគលាភ" សំដៅដល់ ចំណែកជាសាច់ប្រាក់ ឬ ជាទ្រព្យ ដែលនីតិបុគ្គលបានចែកឲ្យអ្នកចូលហ៊ុន ទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួន នៅក្នុងដើមទុនផ្ទាល់របស់ នីតិបុគ្គល។

៩- ពាក្យ "អ្នកចូលហ៊ុន" សំដៅដល់ បុគ្គលដែលមានចំណែកភាគកម្ម នៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល។ បុគ្គលត្រូវទទួលបានប្រាក់ចំណូល ឬ ប្រាក់ចំណេញក្នុងឋានៈ ជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះ។

១០- ពាក្យ "បុគ្គលទាក់ទិន" សំដៅដល់

ក- សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ- សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬ សហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬ ក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅ ក្រោមការគ្រប់គ្រងរួមគ្នា។

- ពាក្យ "គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិចាប់ពី ៥១ ភាគរយ ឡើងទៅលើតម្លៃ ឬ សិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស។

១១- ពាក្យ "អ្នកវិនិយោគ" មានន័យថា បុគ្គលណាមួយដែលអនុវត្ត គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

១២- ពាក្យ "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" មានន័យថា គម្រោងវិនិយោគដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលស្គាល់ថា ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## ៣- របបកំណត់ពន្ធ

១- ការកំណត់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមរបបពិត របបបំព្រួញ និង របបម៉ៅការ (ឥឡូវគេហៅថាអ្នកជាប់ ពន្ធតូច ពន្ធមធ្យម ពន្ធធំ)។

២- វិធាននិងនីតិវិធី ដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធឲ្យស្ថិតក្នុងរបបពន្ធណាមួយ នៃរបបទាំងបីខាងលើនេះ ត្រូវកំណត់ដោយអនុក្រិត្យ ដោយផ្អែកលើទ្រង់ទ្រាយអាជីវកម្ម ប្រភេទសកម្មភាពអាជីវកម្ម និង កម្រិតផលរបរ។(តាមមាត្រ ៦ នៃច្បាប់សារពើពន្ធ)

## ៤- ប្រាក់ចំណេញជាប់ពន្ធនិងអត្រាពន្ធ

### ៤.១-ឆ្នាំជាប់ពន្ធ

១- ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះ របបពិត (របបស្វ័យប្រកាស) ត្រូវគណនាចេញពីលទ្ធផលនៃគុល្យការសម្រេចបានក្នុងឆ្នាំ សារពើពន្ធកន្លងទៅ។

២-ប្រសិនជាពុំមានតុល្យការណាមួយ បានបញ្ចប់ក្នុងកំឡុង នៃ ឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំជាបន្ទាប់ត្រូវ គិតយកលើប្រាក់ចំណេញ ក្នុងរយៈវេលា ដែលកន្លងទៅ ចាប់តាំងពីថ្ងៃផុតរយៈពេលជាប់ពន្ធ ដែលកន្លងហួសទៅនោះ។ ចំពោះសហគ្រាសថ្មីត្រូវគិត ចាប់តាំងពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការមកទល់ នឹង ថ្ងៃ ទី ៣១ ធ្នូ នៃ ឆ្នាំដែលត្រូវគិតពន្ធ។

៣-ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះ របបបំព្រួញ និង របបម៉ៅការ (ពន្ធតូច) ត្រូវគណនាតាម វិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់ នៅក្នុងឆ្នាំប្រតិទិនកន្លងមក។

៤-សេចក្ដីណែនាំនានា ស្ដីពីការធ្វើរបាយការណ៍ ការដាក់លិខិតប្រកាសចុងក្រោយសម្រាប់សហគ្រាសដែលបញ្ឈប់អាជីវកម្ម ឬ រៀបចំឡើងវិញ ឬ ត្រូវបានលក់ ឬ ផ្ទេរក្នុងឆ្នាំប្រតិទិនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។(មាត្រា៧, ៨ នៃច្បាប់សារពើពន្ធ)

## ៥- វិធានគណនេយ្យ

១- ចំពោះអ្នកជាប់ពន្ធតាម របបបំព្រួញ (ពន្ធតូច) ដែលប្រើវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់ ប្រាក់ចំណូលត្រូវគិតបញ្ចូល ទៅក្នុងឆ្នាំដែលបានទទួលជាក់ស្ដែង នូវសាច់ប្រាក់ ឬទ្រព្យដ៏ទៃទៀត ទោះបីជាការទូទាត់បានធ្វើឡើង សម្រាប់ឆ្នាំផ្សេងទៀតក្ដី។ ឯចំណាយ ឬ ការកាត់កងនានា អាចផាត់ចេញនៅក្នុងឆ្នាំដែលចំណាយ ឬ ខ្ទង់ផ្សេងទៀតត្រូវបានទូទាត់សងជាក់ស្ដែង លើកលែងតែចំណាយទូទាត់មុននិងអនុញ្ញាតឲ្យដល់រំលស់។

២- ចំពោះអ្នកជាប់ពន្ធតាម របបពិត (របបស្វ័យប្រកាស) ដែលប្រើវិធីសាស្ត្រ គណនេយ្យតាមប្លង់គណនេយ្យទូទៅ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំ ដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬ មិនបានទូទាត់ក្ដី។

៣-ចំពោះធនាគារ និង ស្ថាប័នសញ្ច័យធន ក្នុងស្រុកត្រូវបានអនុញ្ញាតឲ្យធ្វើ សំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យ ដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ។ វិធាននិងនីតិវិធី ស្ដីពីការកាត់កងនានាត្រូវបានកំណត់ដោយអនុក្រិត្យ។(តាមមាត្រ ៦ នៃច្បាប់សារពើពន្ធ)

## ៦- ប្រាក់ចំណេញជាប់ពន្ធ

ពន្ធលើប្រាក់ចំណេញអ្នកជាប់ពន្ធគឺ ជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផល ទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទ ដែលសហគ្រាសសម្រេចបាន រួមបញ្ចូលទាំងតម្លៃលើស បានមកពីការលក់ចំណែកនានា នៃទ្រព្យសកម្ម ក្នុងពេលកំពុងប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលអំពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ឬ វិនិយោគការប្រាក់ ថ្លៃឈ្នួល និង សួយសារផង។

## ៧- ការកំណត់ប្រាក់ចំណេញជាប់ពន្ធ

ប្រាក់ចំណេញជាប់ពន្ធ កើតចេញពីចំនួនលើស នៃ ផលដុលដែលសម្រេចបាន អាស្រ័យដោយមានការចំណាយ ដើម្បីនាំមកវិញនិងរក្សាទុកនូវចំណេញ។

## ៨- ប្រាក់ចំណេញលើកលែងពន្ធ

១- ពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះ

ក-ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬ ប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល

ខ-ប្រាក់ចំណូលរបស់អង្គការណាមួយដែលៈ

- ត្រូវបានរៀបចំឡើង និង ដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធ៌ម វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ។
- គ្មានចំណែកណាមួយនៃទ្រព្យ ឬ ប្រាក់ចំណូលត្រូវបានប្រើប្រាស់ ជាផលប្រយោជន៍ឯកជន។

គ-ប្រាក់ចំណូលរបស់អង្គការពលករ ឬ សភាពាណិជ្ជកម្ម ក្នុងករណីដែលប្រាក់ចំណូលរបស់អង្គការទាំងនោះ មិនត្រូវបានប្រើប្រាស់ជាផល ប្រយោជន៍ឯក

ជនសម្រាប់អ្នកចូលហ៊ុន ឬ រូបវន្តបុគ្គល។

ឃ-ប្រាក់ចំណេញដែលបានមកពីការលក់ ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាម របបពិត ផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនបានកែច្នៃ ឬ កែច្នៃហើយក៏ដោយ ទៅតាមទម្លាប់នៃការងារកសិកម្ម។

ង-ភាគលាភដែលបានទទួលមកពី សហគ្រាលនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា ២០ ថ្មី មាត្រា ២៣ ថ្មី និងមាត្រា ២៦ ថ្មី នៃច្បាប់ នេះត្រូវបានបង់រួចរាល់។

២-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវ កំណត់ដោយប្រកាសអំពីនីតិវិធីនៃ ការស្នើសុំលើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើកលែងពន្ធ ការប្រកាសសារពើពន្ធ និងការចុះបញ្ជី។ (តាមមាត្រា ៩ នៃច្បាប់សារពើពន្ធ)

## ៩- ការកំណត់ប្រាក់ចំណូលរបស់ក្រុមអាជីវកម្ម

១- ចំពោះក្រុមអាជីវកម្ម ក្នុងការកំណត់ប្រាក់ចំណូលរបស់ខ្លួន សម្រាប់ឆ្នាំជាប់ពន្ធណាមួយសមាជិកម្នាក់ៗ ត្រូវគិតដាច់ដោយឡែកពីគ្នានូវចំណែករៀងៗខ្លួន នៅក្នុងខ្ទង់ចំណូល ចំណេញ ខាត ការកាត់កងឥណទាន និង វិភាគទានសប្បុរសធម៌ ក្នុងឆ្នាំនោះ។

២-វិធានសម្រាប់កំណត់ចំនួនទឹកប្រាក់ដែលត្រូវបែងចែក ការចាត់ចែងចំពោះវិភាគទានផ្សេងៗ និង ការកែតម្រូវទៅលើចំណែកជាមូលដ្ឋាន របស់សមាជិកម្នាក់ៗនៃក្រុមអាជីវកម្ម នៅក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវកំណត់ដោយអនុក្រឹត្យ។(តាមមាត្រា ១០ នៃច្បាប់សារពើពន្ធ)

## ១០- ការកាត់កង

### ១០.១-ការកាត់កងដែលអនុញ្ញាត

១-វៀរលែងតែបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១២ ដល់មាត្រា ១៨ នៃច្បាប់សារពើពន្ធ ចំណាយដែលអនុញ្ញាតឲ្យកាត់កងរួមមាន បន្ទុកដែលអ្នកជាប់ពន្ធបានទូទាត់ ឬ ត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម។

២-ថ្លៃឈ្នួល ការប្រាក់ ការប៉ះប៉ូវ ការទូទាត់ ឬ កម្រៃនានាដែលបានបើកឲ្យអ្នកទទួលខុសត្រូវ ឬ អភិបាលរបស់សហគ្រាស សមាជិកភាគទុន ឬ សមាជិករបស់ក្រុមអាជីវកម្ម សមាជិកនៃគ្រួសារអ្នកជាប់ពន្ធ ឬ បុគ្គលទាក់ទិនផ្សេងទៀតក្នុងករណីមានភស្តុតាងបញ្ជាក់ថា ការទូទាត់នោះបានអនុវត្តចំពោះការបំពេញសេវាជាក់ស្តែង ហើយក្នុងកម្រិតសមហេតុសមផលផងដែរ។

៣-ប្រាក់ដែលបានទូទាត់លើអាគារថ្មី ឬ ទ្រព្យសកម្មដទៃទៀតការកែលម្អជាប់លាប់ ឬការកែលម្អនានា ក្នុងនោះមានទាំងការប្រាក់ និងប្រាក់ពន្ធអាករ ដែលបានបង់ក្នុងរយៈពេលសាងសង់ ឬ ទិញចូលផង។ ទឹកប្រាក់នោះត្រូវកត់ត្រា ចូលក្នុងគណនីទ្រព្យសកម្ម ដែលពាក់ព័ន្ធ ហើយត្រូវកាត់កងតាមការ រំលស់ដូចមានចែងក្នុងមាត្រា១៣ នៃច្បាប់សារពើពន្ធ។

### ១០.២-ចំណាយការប្រាក់

ត្រូវបានអនុញ្ញាតឲ្យកាត់កង នូវ ចំណាយលើការប្រាក់ ដែលអ្នកជាប់ពន្ធបានទូទាត់ ឬ ត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ប៉ុន្តែ មិនឲ្យលើសពីផលបូកនៃចំណូលការប្រាក់ របស់អ្នកជាប់ពន្ធ និង ៥០ ភាគរយ នៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ របស់អ្នកជាប់ពន្ធនៅក្នុងឆ្នាំជាប់ពន្ធ។

ចំណូលសុទ្ធក្រៅពីការប្រាក់ គឺជាប្រាក់ចំណូលដុល ក្រៅពីចំណូលការប្រាក់ ដក

ខ្ទង់ចំណាយនានាដែលអនុញ្ញាត ឲ្យផាត់ចេញលើកលែងតែចំណាយការប្រាក់។

ចំណាយការប្រាក់ដែលសល់ ពីកាត់កងខាងលើត្រូវចាត់ទុកជា ចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយការផាត់ចេញត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រានេះដូចគ្នា។

**១០.៣-រំលស់នៃទ្រព្យរូបី**

ថ្នាក់ ១- អគារ និងរចនាសម្ព័ន្ធ ព្រមទាំងសមាសភាគរបស់វា

– អត្រារំលស់ ៥% តាមវិធីសាស្ត្រស្មើភាគ។

ថ្នាក់ ២-កុំព្យូទ័រ ប្រព័ន្ធព័តមានអេឡិច ត្រូនិចសហ្វវែរ និង បរិក្ខារទុកដាក់ទិន្នន័យ

– អត្រារំលស់ ៥០% តាមវិធីសាស្ត្ររំសល់ថយជាលំដាប់។

ថ្នាក់ ៣- រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹមនិងបរិក្ខារការិយាល័យ។

– អត្រារំសល់ ២៥% តាមវិធីរំលស់ថយជាលំដាប់។

ថ្នាក់ ៤- ទ្រព្យរូបីឯទៀតទាំងអស់

– អត្រារំលស់ ២០% តាមវិធីរំសល់ថយជាលំដាប់។

(មាតត្រា១៣ នៃច្បាប់សារពើពន្ធ)

**១០.៤-រំលស់នៃទ្រព្យអរូបី**

ចំពោះទ្រព្យអរូបី ដែលរួមមាន ប្រកាសសនីយប័ត្រ សិទ្ធិចម្លង គំរូប្លង់ គំរូ និងសិទ្ធិអាជីវកម្មដែលមានអាយុកាលកំណត់។ អត្រារំលស់លើទ្រព្យនីមួយៗត្រូវ គណនាដោយផ្អែកលើអាយុកាលរបស់ទ្រព្យនោះ តាមវិធីសាស្ត្ររំលស់ស្មើភាគ បើសិនជាអាយុកាលនៃទ្រព្យអរូបី មិនអាចកំណត់បាន។

–រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមអត្រា ១០% លើតម្លៃទ្រព្យអរូបី។

## ១០.៥-រំលស់ធនធានធម្មជាតិ

១- ទាយជ្ជទានឲ្យដល់ការ រំលស់លើធនធានធម្មជាតិ មានជាអាទិ៍ប្រេងកាត និង ឧស្ម័នធម្មជាតិ ត្រូវបានកំណត់ដូចតទៅ៖

ក-ចំណាយក្នុងការរុករក និង អភិវឌ្ឍន៍ក្នុងនោះមានទាំង ការប្រាក់ដែលជាប់ទាក់ទងដល់ចំណាយនោះផង ត្រូវបូកបញ្ចូលទៅក្នុង គណនីទ្រព្យសកម្ម នៃធនធាននោះ។

ខ-ទឹកប្រាក់រំលស់លើ ធនធានធម្មជាតិ នីមួយៗ ដែលត្រូវផាត់ចេញនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាដោយយកសមតុល្យ នៃ គណនីធនធានធម្មជាតិទៅ គុណ និង ផលចែក រវាងបរិមាណដែលបានផលិត ចេញអំពីធនធានធម្មជាតិ នៅក្នុងឆ្នាំ និង ចំនួនប្រាន់ស្មាន នៃផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ។(តាមមាត្រា១៥ នៃច្បាប់សារពើពន្ធ)

២-នីតិវិធីសម្រាប់ប៉ាន់ស្មាននៃផលិតផលសរុប ត្រូវកំណត់ដោយអនុក្រឹត្យ។

## ១០.៦-វិភាគទានសប្បុរសធម៌

ត្រូវបានអនុញ្ញាតឲ្យផាត់ចេញនូវវិភាគទានសប្បុរសធម៌ ដែលបានបរិច្ចាគឲ្យអង្គការនានា ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់ពន្ធ ប៉ុន្តែមិនត្រូវឲ្យលើសពី ៥% នៃប្រាក់ចំណេញជាប់ពន្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌ទាំងនោះឡើយ។

## ១០.៧-ការយោងការខាតបង់ទៅមុខ

ក្នុងករណីដែលមានការខាងបង់ នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះ

ត្រូវចាត់ជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពី ប្រាក់ចំណេញសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ។ បើប្រាក់ចំណេញនេះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃកាខាតបង់ដែលនៅសេសសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូត ដល់ឆ្នាំជាប់ពន្ធទី៥។ (តាមមាត្រា ១៧ នៃច្បាប់សារពើពន្ធ)

**១០.៨-ការបែងចែកប្រាក់ចំណូលនិងការកាត់កងក្នុងចំណោមអ្នកជាប់ពន្ធ**

ក្នុងករណីសហគ្រាសចាប់ពី ២ ឡើងទៅ ទោះបីជាបានបង្កើត ឬ រៀបចំឡើងនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាហើយស្ថិតក្រោមកម្មសិទ្ធិរួមគ្នា ក្នុងករណីចាំបាច់រដ្ឋបាលសារពើពន្ធអាចធ្វើការបែងចែកប្រាក់ចំណូលដុល ប្រាក់ផាត់ចេញ ឬ អត្ថប្រយោជន៍ផ្សេងៗ ក្នុងចំណោមសហគ្រាសនិងម្ចាស់កម្មសិទ្ធិទាំងនោះ ដើម្បីទប់ស្កាត់ការចៀសវាង ឬ គេចវេះពន្ធ ឬក៏ដើម្បីឆ្លុះបញ្ចាំងឲ្យបានច្បាស់លាស់នូវ ប្រាក់ចំណូលរបស់សហគ្រាស ឬ របស់ម្ចាស់កម្មសិទ្ធិ។

**១០.៩-ការកាត់កងដែលមិនអនុញ្ញាត**

១-ចំណាយលើសកម្មភាពទាំងឡាយ ដែលជាទូទៅចាត់ទុកជាការកំសាន្ត ការសំរាកលំហែ ការទទួលភ្ញៀវ ឬ ការប្រើប្រាស់មធ្យោបាយណាមួយ ដែលមិនជាប់ទាក់ទិននិងសកម្មភាពទាំងនេះ។

២-ចំណាយសម្រាប់ការរស់នៅផ្ទាល់ខ្លួន ឬ ក្រុមគ្រួសារ លើកលែងតែអត្ថប្រយោជន៍ជាប្រាក់ ឬ ជាវត្ថុ ដែលជាប្រាក់ពន្ធត្រូវបានកាត់ទុកតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស។

៣-ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធប្រាក់ចំណេញ បានកំណត់ និង កាត់ទុកដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្សបានកំណត់។

៤- ការខាតបង់លើការលក់ ឬ ដោះដូរទ្រព្យសម្បត្តិ ទោះដោយផ្ទាល់ ឬ ប្រយោលក្តី

រវាងបុគ្គលទាក់ទិន។

៥-ចំណាយនានា វៀរលែងតែចំណាយដែលកើតមានហើយ ហើយអ្នកជាប់ពន្ធអាច បញ្ជាក់ច្បាស់លាស់នូវចំនួនទឹកប្រាក់ និង គោលដៅអាជីវកម្ម ស្របទៅតាមបែបបទដែលត្រូវ កំណត់ដោយអនុក្រឹត្យ។(តាមមាត្រា ១៩ នៃច្បាប់សារពើពន្ធ)

## ១១-អត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់

### ១១.១-អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

១- ២០ % ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល

២- ៣០% ចំពោះប្រាក់ចំណេញដែលសម្រេចបាន ក្រោមកិច្ចសន្យាបែងចែកផលិត ផលប្រេងកាតនិងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្ម លើធនធានធម្មជាតិ រួមទាំង ព្រៃឈើ រ៉ែ មាស ឬ ត្បូងថ្មមានតម្លៃនានា។

៣- ៩% ចំពោះប្រាក់ចំណេញ របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់រយៈពេលអន្តរកាល៥ឆ្នាំ ដោយគិត ចាប់ផ្តើមពីថ្ងៃប្រកាសឲ្យប្រើប្រាស់ ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រ កម្ពុជា។

៤-០%ចំពោះប្រាក់ចំណេញ របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥-តាមតារាងអត្រាពន្ធ កំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែល សម្រេចបានដោយរូបវន្តបុគ្គល និងចំណែកដែលត្រូវបែងចែកឲ្យសមាជិកម្នាក់ៗ របស់ក្រុមអាជីវ កម្មដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល។

តារាងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

| | | |
|---|---|---|
| ពី 0 | ដល់ | ៦,000,000 0 % |
| ពី ៦,000,000 | ដល់ | ១៥,000,000 ៥% |
| ពី ១៥,000,000 | ដល់ | ១០២,000,000 ១0% |
| ពី ១០២,000,000 | ដល់ | ១៥0,000,000 ១៥% |
| | លើសពី | ១៥0,000,000 ២0% |

៦- សិទ្ធិ បុព្វសិទ្ធិ និងសិទ្ធិដទៃទៀត ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បានទទួលក្រោមច្បាប់ស្តីពីវិសោធន៍កម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា មិនអាចផ្ទេរ ឬ ប្រគល់ជូនទៅតតីយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬ រំលាយបញ្ចូលគ្នា។(តាមមាត្រា២០ នៃច្បាប់សារពើពន្ធ)

**១១.២-ពន្ធលើសហគ្រាសធានារ៉ាប់រង**

១- ៥ % ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុល ដែលទទួលបាន នៅក្នុងឆ្នាំជាប់ពន្ធចំពោះការធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្តនូវហានិភ័យនៅ ព្រះរាជាណាចក្រកម្ពុជា។

២- តាមអត្រាកំណត់ក្នុងមាត្រា ២០ នៃច្បាប់សារពើពន្ធ ចំពោះសកម្មភាពដទៃទៀត ដែលមិនមែនជាការធានារ៉ាប់រង ឬ ធានារ៉ាបង់រងបន្ត។

**១១.៣-ពន្ធលើប្រាក់ចំណេញចំពោះអាជីវកម្មមិនទាក់ទិន**

១- ពន្ធលើប្រាក់ចំណេញត្រូវកំណត់ស្មើនឹង ២០ ភាគរយ លើចំនួនប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិនរបស់អង្គការនានា ដូចមានចែងក្នុងមាត្រា៩ នៃច្បាប់សារពើពន្ធ។

២-សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណេញ ពាក្យ "ប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិន" គឺ ជាផលដក រវាងប្រាក់ចំណូលដុលសម្រេចបានពីអាជីវកម្មមិនទាក់ទិន ដែលអង្គការណាមួយបានធ្វើជាទៀតទាត់ និង ការកាត់កងនានា ទាក់ទិនផ្ទាល់ទៅនឹងការធ្វើអាជីវកម្មដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញបានអនុញ្ញាត។

៣-ពាក្យ "អាជីវកម្មមិនទាក់ទិន" សំដៅ អាជីវកម្មខាងពាណិជ្ជកម្ម ឬ ឧស្សាហកម្ម ឬ អាជីវកម្មផ្សេងទៀតរបស់អង្គការដើម្បីស្វែងរកប្រាក់ចំណេញ ឬ មូលនិធិ ហើយពុំមានទាក់ទិនជាសំខាន់ដល់គោលដៅ ឬ មុខងារដែលជាមូលដ្ឋាននៃការលើកលែងពន្ធ ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់សារពើពន្ធ។ (មាត្រា ២២ នៃច្បាប់សារពើពន្ធ)

### ១១.៤-ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ

ពន្ធលើប្រាក់ចំណេញបន្ថែម ត្រូវបង់ក្នុងចំនួនស្មើនឹង ២០ ភាគរយ នៃទឹកប្រាក់បែងចែក។

## ១២-ពន្ធដទៃទៀត

ពន្ធអប្បបរមា ត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបពិត(របបស្វ័យប្រកាស) ពន្ធអប្បបរមា ជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបពិតលើកលែងតែ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា ១ ភាគរយ លើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។(តាមមាត្រា ៣៧ ៣៨ ៣៩ នៃច្បាប់សារពើពន្ធ)

## ១៣-ពន្ធកាត់ទុកនិងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

អ្នកជាប់ពន្ធ និវាសនជន ដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬ ជាវត្ថុឲ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុក និង បង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម៖

ក-អត្រា ១៥ ភាគរយ ចំពោះរួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬ សេវាប្រហាក់ប្រហែល។

ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា

សួយសារចំពោះទ្រព្យអរូបីនិងភាគកម្ម ក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលមិនមែនជាធនាគារ ឬ ស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជន។

ខ-អត្រា ១០ ភាគរយ ចំពោះ ប្រាក់ចំណូលពីការឲ្យជួលចលនឬអចលនទ្រព្យ។

គ-អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬ ស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់។

ឃ-អត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬ ស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីសន្សំ គ្មានកាលកំណត់។ (តាមមាត្រា ២៥ នៃច្បាប់សារពើពន្ធ)

## ១៤-កាត់ទុកប្រាក់ពន្ធ ១៤% នៃការទូទាត់ប្រាក់ចំណេញក្នុងការធ្វើអាជីវកម្ម

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ប្រាក់ចំណូលខាងក្រោមនេះ ឲ្យទៅអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធចំនួន ១៤ ភាគរយនៃទឹកប្រាក់ត្រូវបើក៖

ក-ការប្រាក់

ខ-សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗទាក់ទិននិងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ-ការទូទាត់ចំពោះ សេវាគ្រប់គ្រង និង សេវាបច្ចេកទេសនានា ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឃ-ភាគលាភ

## ១៥-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញ តាមរបបពិត រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាម អត្រា ៩% មានកាតព្វកិច្ច បង់ប្រាក់រំដោះ ប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែ។

ផលរបររបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកលែងពីការបង់ប្រាក់រំដោះនេះ។

ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កង ពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។ (តាមមាត្រា ២០ នៃច្បាប់សារពើពន្ធ)

## ១៦-ភារកិច្ចរបស់អ្នកជាប់ពន្ធ

### ១៦.១-ភារកិច្ចទូទៅសម្រាប់អ្នកជាប់ពន្ធតាមរបបពិតនិងរបបបំព្រួញ

១- អ្នកជាប់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់ពន្ធតាមរបបពិត ឬ របបបំព្រួញត្រូវផ្ញើជូនជារៀងរាល់ឆ្នាំទៅរដ្ឋបាលសារពើពន្ធ នូវលិខិតប្រកាសប្រាក់ចំណេញ ដែលខ្លួនសម្រេចបានក្នុងឆ្នាំសារពើពន្ធមុន។ លិខិតប្រកាសនោះត្រូវចុះបញ្ជីជាដាច់ខាត ក្នុងរយៈវេលា ៣ ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។

២-អ្នកជាប់ពន្ធតាមរបបពិត ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធដោយភ្ជាប់ជាមួយនូវៈ

ក-តារាងតុល្យការ

ខ-គណនីលទ្ធផល

គ-តារាងពត៌មានបន្ថែម

៣-អ្នកជាប់ពន្ធតាមរបបបំព្រួញ ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់ជាមួយនូវ ឯកសារនានា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន។

៤-ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទ និង ក្នុងរយៈពេលដូចគ្នានេះដែរ។(តាមមាត្រា២៩ នៃច្បាប់សារពើពន្ធ)

### ១៦.២-ភារកិច្ចសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ

១- អ្នកជាប់ពន្ធតាមរបបម៉ៅការ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ ជូនរដ្ឋបាលសារ

ពើពន្ធជារៀងរាល់ឆ្នាំ យ៉ាងយឺតបំផុតនៅ ថ្ងៃ ទី ៣១ តុលា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន។

២- ចំនួនប្រាក់ចំណេញ ម៉ៅការ ត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យ និង ពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬ អ្នកតំណាង។ ប្រាក់ចំណេញម៉ៅការនេះ ត្រូវគិតតាមអត្រាចំណេញទៅតាមប្រភេទ និងតាមមុខរបរអាជីវកម្ម ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣-កម្រិតពន្ធលើប្រាក់ចំណេញ ម៉ៅការ ត្រូវកំណត់ជា ស្ថេរវន្ត សម្រាប់រយៈពេលមួយមានកំណត់ ៣ ខែ ៦ ខែ ឬ ឆ្នាំ។

៤-អ្នកជាប់ពន្ធលើប្រាក់ចំណេញតាមរបបម៉ៅការ ត្រូវបង់ពន្ធនេះជារៀងរាល់ខែតាមពេលវេលាដែលកំណត់ ដោយរដ្ឋបាលសារពើពន្ធ។

## ១៦.៣-បុគ្គលឬអ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធ

១-បុគ្គល ឬ អ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធ តាមមាត្រា ២៥ ថ្មី និង មាត្រា ២៦ ថ្មី នៃច្បាប់សារពើពន្ធ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ និង បង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធ បានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃ ខែបន្ទាប់ពី ខែ ដែលបានធ្វើការទូទាត់។

២-សហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធ លើប្រាក់ចំណេញបន្ថែម លើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រា ២៣ ថ្មី នៃច្បាប់សារពើពន្ធ និងបង់ពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធ បានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃ ខែបន្ទាប់ពីខែដែលបានធ្វើការបែងចែកត្រូវបានទូទាត់។

**១៦.៤-ភាតព្វកិច្ចរបស់បុគ្គលដែលត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ**

បុគ្គលដែលមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធ លើប្រាក់ចំណេញត្រូវដាក់លិខិតប្រកាសសារពើពន្ធ និង បង់ប្រាក់រំដោះពន្ធ លើប្រាក់ចំណេញ ជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធ បានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃ ខែបន្ទាប់ពីខែដែលបំណុលបានកើនឡើង។

**១៦.៥-ប្រភពប្រាក់ចំណូល**

១- ការប្រាក់ដែលបង់ដោយសហគ្រាស និវាសនជន ក្រុមអាជីវកម្មនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

២-ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន។

៣-ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជណាចក្រកម្ពុជា។

៤-ប្រាក់ចំណូលពីការគ្រប់គ្រង និង សេវាបច្ចេកទេសដែលបានទូទាត់ ដោយបុគ្គលនិវាសនជន។

៥-ប្រាក់ចំណូលដែលបានមកពី ចលនៈទ្រព្យ ក្នុងករណីដែលទ្រព្យនោះ ស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦-ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬ សិទ្ធិប្រើប្រាស់ទ្រព្យអរូបី ដែលបានទូទាត់ដោយបុគ្គលនិវាសនជន ឬ បុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៧- ផលចំណេញពីការលក់អចលនទ្រព្យ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយ នៃ អចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨-បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ចំពោះហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៩-ផលចំណេញពីការលក់អចលនទ្រព្យ ដែលជាចំណែកនៃ ទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ របស់អ្នកជាប់ពន្ធអនិវាសនជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០-ប្រាក់ចំណូលពីសកម្មភាពអាជីវកម្ម របស់បុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។( តាមមាត្រា ៣៣ នៃច្បាប់សារពើពន្ធ )

### ១៦.៦-ការកំណត់ប្រភព

ក្នុងករណីដែលគ្មានព័ត៌មានគ្រប់គ្រាន់ ដើម្បីកំណត់ប្រភពចំណូល ឬ បើសិនជាវិធាននានា ដែលមានរួចមកហើយពុំអាចឆ្លុះបញ្ចាំង ឲ្យបានច្បាស់លាស់នូវ ប្រាក់ចំណូលពីប្រភពណាមួយបានទេនោះ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ ប្រភពនៃប្រាក់ចំណូលនោះ។

## ១៧-គណនាប្រាក់ពន្ធប្រចាំឆ្នាំត្រូវបង់

### ១៧.១-រូបមន្តគណនាប្រាក់ពន្ធ

ឥណពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា នូវប្រាក់ពន្ធបានបង់នៅប្រទេសក្រៅនីមួយៗ និងឯកសារខាងក្រោមនេះ ត្រូវផ្តល់ដោយអគ្គនាយកដ្ឋានពន្ធដារ( នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធខេត្ត ខណ្ឌ ដែលគ្រប់គ្រងប្រមូលពន្ធលើសហគ្រាសនោះ )៖

**ពន្ធត្រូវបង់ = មូលដ្ឋានប្រាក់ចំណេញ × អត្រាភាគរយ**

# តារាងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

| ការគណនាពន្ធលើប្រាក់ចំណេញ (រូបវន្តបុគ្គល) | | |
|---|---|---|
| ប្រាក់ចំណេញជាប់ពន្ធក្នុងមួយឆ្នាំ | ភាគរយ | លម្អៀងតាមចំណាត់ថ្នាក់ |
| ពី 0 ដល់ ៦ 000 000 | 0 % | |
| ពី ៦ 000 000 ដល់ ១៥ 000 000 | ៥% | ៣00 000 |
| ពី ១៥ 000 000 ដល់ ១0២ 000 000 | ១0% | ១ 0៥0 000 |
| ពី ១0២ 000 000 ដល់ ១៥0 000 000 | ១៥% | ៦ ១៥0 000 |
| លើសពី ១៥0 000 000 | ២0% | ១៣ ៦៥0 000 |

| ការគណនាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ<br>(សហគ្រាសនីតិបុគ្គល) | |
|---|---|
| ប្រភេទសកម្មភាព | ប្រាក់ពន្ធ(រៀល) |
| គ្រប់សកម្មភាពអាជីវកម្មទាំងអស់ លើកលែងតែគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងអំឡុងពេលលើកលែងពន្ធ កិច្ចសន្យាបែងចែកផលប្រេង ឬឧស្ម័នធម្មជាតិ និង ធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្ត ចំពោះហានិភ័យក្នុងព្រះរាជាណាចក្រកម្ពុជា | ២០% នៃ ប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ (ប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិនក្នុងករណីអង្គការមិនស្វែងរកប្រាក់ចំណេញ) |
| គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងអំឡុងពេលលើកលែងពន្ធ | ស្មើសូន្យ = (0) |
| កិច្ចសន្យាបែងចែកផលប្រេង ឬ ឧស្ម័នធម្មជាតិ | ៣០% នៃ ប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ |
| ធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្ត ចំពោះហានិភ័យក្នុងព្រះរាជាណាចក្រកម្ពុជា | ៥% នៃបុព្វលាភធានារ៉ាប់រងដុល |

(តាមមាត្រា ៣៦ នៃច្បាប់សារពើពន្ធ)

### ១៧.២-ឥណទានពន្ធបរទេស

អ្នកជាប់ពន្ធនិវាសនជនកម្ពុជា ទទួលបានឥណទានពន្ធបរទេសដែលត្រូវបានបង់លើប្រភពចំណូលបរទេស។ ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា នូវប្រាក់ពន្ធបានបង់

នៅប្រទេសក្រៅនីមួយៗ និងឯកសារខាងក្រោមនេះ ត្រូវផ្តល់ជូនអគ្គនាយកដ្ឋានពន្ធដារ(នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬ សាខាពន្ធដារខេត្ត ខណ្ឌដែលគ្រប់គ្រងប្រមូលពន្ធលើសហគ្រាសនោះ)៖

•ឯកសារថតចម្លង (លិខិតប្រកាសពន្ធ និង ឯកសារយោង) បញ្ជាក់ពីការបំពេញកាតព្វកិច្ចនៅបរទេសនោះ។

•បង្កាន់ដៃពន្ធថតចម្លង បង្ហាញអំពីប្រាក់ពន្ធដែលចេញដោយ រដ្ឋបាលសារពើពន្ធនៅបរទេសនោះ។

*ឥណទាននេះគឺជាចំនួនដែលទាបជាងគេ ក្នុងចំណោម៖

•ប្រាក់ពន្ធដែលបានបង់ជាក់ស្តែង នៅប្រទេសក្រៅណាមួយ

•ចំណែកនៃពន្ធប្រាក់ចំណេញកម្ពុជា ដែលបានមកពីប្រាក់ចំណូល ប្រភពបរទេស

**អនុវត្តរូបមន្តដូចខាងក្រោម**

| **ក** = **ខ** × (**គ**/**ឃ**) |
|---|

**ក៖** ចំណែកនៃពន្ធប្រាក់ចំណេញកម្ពុជា ដែលបានមកពីប្រាក់ចំណូលប្រភពបរទេស

**ខ៖** ពន្ធលើប្រាក់ចំណេញកម្ពុជា ដែលបានមកពីប្រាក់ចំណូលគ្រប់ប្រភព

**គ៖** ប្រាក់ចំណូលប្រភពបរទេស

**ឃ៖** ប្រាក់ចំណូលគ្រប់ប្រភព

ប្រសិនបើ ឥណទានពន្ធបរទេសលើសពីប្រាក់ពន្ធ លើប្រាក់ចំណេញ ចំនួនទឹកប្រាក់ដែលលើស នោះ អាចយោងទៅប្រើប្រាស់នៅឆ្នាំបន្តបន្ទាប់ រហូតដល់ឆ្នាំទី៥ គិតពីឆ្នាំឥណទានពន្ធនោះបាន កើតឡើង។(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣)

## ១៧.៣-គណនាប្រាក់ពន្ធត្រូវបង់ ឬ ឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

១-ក្នុងករណីដែលលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់ពន្ធ មានចំនួនច្រើនជាង ផលបូក នៃចំនួនប្រាក់ពន្ធដែលបានកាត់ទុក ក្នុងនាមអ្នកជាប់ពន្ធតាម មាត្រា ២៥ នៃ ច្បាប់ពន្ធ និងចំនួនប្រាក់រំដោះពន្ធ លើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់ ប្រចាំឆ្នាំតាមមាត្រា ២៨ នៃ ច្បាប់ពន្ធ អ្នកជាប់ពន្ធត្រូវបង់បន្ថែម ចំនួនដែលលម្អៀងនោះជូនរដ្ឋបាលសារពើពន្ធ។

២-ប្រសិនបើលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់ពន្ធ មានចំនួនតិចជាងផល បូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុក ក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា ២៥ នៃច្បាប់ពន្ធ និង ចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ដែលអ្នកជាប់ពន្ធបានបង់ សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ នៃច្បាប់ពន្ធ ក្រោយពីបានគិតបំណុលពន្ធអប្បបរមារួចហើយ អ្នកជាប់ពន្ធអាចសុំបង្វិលសង វិញនូវចំនួនដែលលម្អៀង ឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ឆ្នាំបន្ទាប់។

## ១៧.៤-គណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬ ឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

១-អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមានៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ ពន្ធអប្បបរមាត្រូវបង់អាចត្រូវបានកាត់បន្ថយ ដោយបំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំជាប់ពន្ធ ជាមួយគ្នាតាមមាត្រា ២០ នៃច្បាប់ពន្ធ។

២-ពន្ធអប្បបរមា ត្រូវអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបពិតទាំងអស់(ក្រៅពីគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងអំឡុងពេលលើកលែងពន្ធ)។ ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា ១ % នៃផលរបរប្រចាំឆ្នាំ(រួមបញ្ចូលទាំងពន្ធ អាករនានា វៀរលែងអាករលើតម្លៃបន្ថែម) ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។ ពន្ធអប្បបរមានេះត្រូវបានកាត់បន្ថយដោយបំណុលពន្ធលើប្រាក់ចំណេញ។

ក-ប្រសិនបើ បំណុលពន្ធលើប្រាក់ចំណេញ ច្រើនជាងពន្ធអប្បបរមា ក្នុងករណីនេះអ្នកជាប់ពន្ធមិនត្រូវជាប់ពន្ធអប្បបរមាទេ។

ខ-ប្រសិនបើ បំណុលពន្ធលើប្រាក់ចំណេញ តិចជាងពន្ធអប្បបរមា ចំនួនដែលលើសនៃពន្ធអប្បបរមា គឺ ត្រូវបានទទួលស្គាល់ជាឥណទានពន្ធ ហើយអាចយោងទៅកាត់កងជាមួយប្រាក់រំដោះពន្ធ លើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធបន្តបន្ទាប់។

៣-**ករណីសិក្សា: "ក"** ជាសហគ្រាស នីតិបុគ្គលដែលមាន ផលរបរប្រចាំ ឆ្នាំ ២៥០,០០០,០០០ លាន រៀល និងប្រាក់ចំណេញប្រចាំឆ្នាំ ២០,០០០,០០០ លាន រៀល។ សហគ្រាសមានសិទ្ធិទទួលឥណទានពន្ធ ៥០០,០០០ រៀល។

## **អនុវត្តរូបមន្ត**

| |
|---|
| **បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ = ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ × អត្រាភាគរយ – ឥណទានពន្ធបរទេស** |

**ការគណនាដូចខាងក្រោម៖**

(២០,០០០,០០០ × ២០%) – ៥០០,០០០

= ៣,៥០០,០០០ លានរៀល

•ពន្ធអប្បបរមា របស់សហគ្រាស ត្រូវបានគណនាដូចខាងក្រោម៖

២៥០,០០០,០០០ × ១% = ២,៥០០,០០០ រៀល

•ដោយបំណុលពន្ធលើប្រាក់ចំណេញច្រើនជាង ពន្ធអប្បបរមា

ដូចច្នេះ ពន្ធត្រូវបង់គឺ ៣,៥០០,០០០ លាន រៀល ជាចំនួនទឹកប្រាក់ដែលធំជាង។

(**អ្នកជាប់ពន្ធមិនត្រូវជាប់ពន្ធអប្បបរមាទេ**)

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្តីណែនាំគណនាពន្ធ)

# មេរៀនទី ៤ ៖ ការប្រមូលពន្ធលើប្រាក់បៀវត្ស

## ១-កម្មវត្ថុនៃពន្ធ

ពន្ធលើប្រាក់បៀវត្ស គឺ ជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្ស ដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។

ប្រាក់ចំណូលទាំងអស់ ដែលទទួលបានពីសកម្មភាពការងារនានាត្រូវជាប់ពន្ធលើប្រាក់បៀវត្ស។

ប្រាក់ចំណូលនេះត្រូវប្រមូលតាមរបៀបកាត់ទុក ដោយនិយោជកនៅពេលបើកប្រាក់បៀវត្ស។

**ស្ថានភាពបម្រើការងារ**

ត្រូវចាត់ទុកជានិយោជិក ហើយជាប់ពន្ធលើប្រាក់បៀវត្ស បើសិនរូបវន្តបុគ្គលមានស្ថានភាពបម្រើការងារស្របតាមលក្ខខណ្ឌពីរដូចខាងក្រោម៖

- មិនមានហានិភ័យនៃការទទួលប្រាក់ទូទាត់
- មិនអាចកំណត់ពេលវេលា ទីកន្លែងសម្រាប់បំពេញការងារ
- មិនចំណាយដើមទន់ច្រើន ដើម្បីទិញឧបករណ៍សម្រាប់បំពេញការងារ
- មិនបំពេញសកម្មភាពឲ្យបុគ្គលច្រើននាក់ក្នុងពេលតែមួយ។

រូបវន្តបុគ្គលនិវាសនជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស។

រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។( តាមមាត្រា ៤១ នៃច្បាប់សារពើពន្ធ )

## ២-គោលដៅពន្ធនៅលើប្រាក់បៀវត្ស

១-ពាក្យ "និវាសនជន" ក្នុងករណីដែលប្រើចំពោះនិយោជិក អ្នកជាប់ពន្ធ ឬ រូបវន្តបុគ្គល មានន័យថា ដែលមាននិវាសនដ្ឋាន ឬ មានកន្លែងស្នាក់នៅជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ដែលមានវត្តមាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា លើសពី ១៨២ ថ្ងៃ នៅក្នុងរយៈពេល ១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។

២- ពាក្យ "អនិវាសនជន" មានន័យថា បុគ្គលណាមួយដែលមិនមែនជា និវាសនជន និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

៣- ពាក្យ "និយោជក" រួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសជន ក្រុមអាជីវកម្ម និវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកប្រាក់ចំណេញ ឬ រូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម។

៤- ពាក្យ "និយោជិត" សំដៅដល់ រូបវន្តដែលបានទទួលប្រាក់បៀវត្ស អំពីសកម្មភាពបំរើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវឬ អភិបាលរបស់សហគ្រាសមន្ត្រីរាជការមន្ត្រីជ្រើសតាំងដោយការបោះឆ្នោត លើកលែងតែសមាជិករដ្ឋសភា និង ព្រឹទ្ធសភា។

៥- ពាក្យ "ប្រាក់បៀវត្សប្រភពកម្ពុជា" មានន័យថា ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះប្រាក់បៀវត្ស ដែលអនិវាសនជនបានទទួល ក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេស ដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ។

៦-ពាក្យ "បរទេស"

ក-ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថាដែលជាអនិវាសនជន

ខ-ចំពោះការកំណត់ប្រភពប្រាក់ចំណូលមានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា

៧-ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់ បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់បន្ថែមម៉ោង ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឲ្យដល់និយោជិត ឬ ដែលបានទូទាត់ដើម្បីប្រយោជន៍ផ្ទាល់ ឬ ប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

៨-ពាក្យ "អត្ថប្រយោជន៍បន្ថែម" រួមមានទំនិញ និងសេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬ វត្ថុផ្សេងទៀត ដែលនិយោជកផ្តល់ឲ្យដោយផ្ទាល់ ឬ ដោយប្រយោលដល់រូបវន្តបុគ្គលចំពោះសកម្មភាពបម្រើការងារ។

ជារៀងរាល់ខែ និយោជកត្រូវកាត់ទុកពន្ធតាមអត្រា ២០%។

តម្លៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់ ហើយត្រូវជាប់ពន្ធក្នុងខែ ដែលបានផ្តល់ឲ្យនិយោជិត។

៩-ពាក្យ "អត្ថប្រយោជន៍បន្ថែម" រួមមាន៖

ក-យានជំនិះគ្រប់ប្រភេទ

ខ-ម្ហូបអាហារ

គ-លំនៅដ្ឋាន ការស្នាក់នៅ

ឃ-ទឹក ភ្លើង ទូរស័ព្ទ

ង-អ្នកបម្រើការងារនៅក្នុងលំនៅដ្ឋាន

ច-ប្រាក់ឲ្យខ្ចីដោយឥតគិតការប្រាក់ទាបជាងការប្រាក់ទីផ្សារ (អត្រាការប្រាក់ទីផ្សារ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ)។

ឆ-ការលក់ទំនិញចុះថ្លៃ

ជ-ជំនួយផ្នែកអប់រំសម្រាប់និយោជិតដែលមិនមែនជាចំណែកណាមួយ នៃកម្មវិធីបណ្តុះបណ្តាលទាក់ទិនផ្ទាល់ទៅ និង ការបំពេញការងាររបស់និយោជិតនោះ។

ឈ-ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត

ញ-បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព លើកលែងតែមានផ្តល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឲ្យដល់និយោជិតគ្រប់គ្នា ដោយគ្មានការបែងចែកតាមតួនាទី ឬ មុខងារ។

ដ-ចំណែកនៃការឧបត្ថម្ភលើចំណាយដែលមិនសមហេតុសមផល និងមិនចាំបាច់សម្រាប់អាជីវកម្ម។

ឋ-ចំនួនទឹកប្រាក់បង់ចូលមូលនិធិ សុខមាលភាពសង្គមដែលលើសកម្រិតដែលច្បាប់អនុញ្ញាត។

ឌ-ចំនួនប្រាក់បង់ចូលបេឡាសោធនដែលលើសពី ១០% នៃប្រាក់បៀវត្សប្រចាំខែគ្មានបូកអត្ថប្រយោជន៍បន្ថែមរបស់និយោជិត។

ឍ-ចំណាយសម្រាប់ការទទួលភ្ញៀវ ការកំសាន្ត ការសម្រាកលំហែ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលទាក់ទិននឹងសកម្មភាពទាំងនេះ ដែលមិនមែនជាចំណែកណាមួយនៃទំនាក់ទំនងបម្រើការងារ។

១០-ប្រាក់ឧបត្ថម្ភដែលមិនជាប់ពន្ធបៀវត្ស និងអត្ថប្រយោជន៍បន្ថែម

ក-សោហ៊ុយធ្វើដំណើរ និង ការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណកន្លែងធ្វើការ ស្របតាមបញ្ញត្តិនៃច្បាប់ការងារ

ខ-ប្រាក់ថ្លៃបាយដែលផ្តល់ឲ្យនិយោជិតទាំងអស់ គ្មានបែងចែកតួនាទី

គ-មូលនិធិបេឡាសន្តិសុខសង្គម សុខមាលភាពសង្គមតាមបញ្ញត្តិច្បាប់

ឃ-ប្រាក់ធានារ៉ាប់រងសុខមាលភាព ឬ បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬ សុខភាព ដែលផ្តល់ឲ្យកម្មករនិយោជិតគ្រប់គ្នា

ង-ប្រាក់ឧបត្ថម្ភទារកដ្ឋាន ឬចំណាយទារកដ្ឋាន តាមច្បាប់ការងារ

ច-ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬ ប្រាក់បំណាច់បញ្ឈប់ លែងឲ្យធ្វើការក្នុងកម្រិត ដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។(តាមមាត្រ ៤២ នៃច្បាប់សារពើពន្ធ)

## ៣-ប្រាក់បៀវត្សរ៍លើកលែងពន្ធ

### ៣.១-ប្រាក់បៀវត្សរ៍របស់មន្ត្រីការទូត និង មន្ត្រីបរទេសដទៃទៀត

១- ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្ស ចំពោះ៖

ក-ប្រាក់បៀវត្សដែលមន្ត្រីនិងនិយោជិតនៃបេសកម្មការទូត ឬកុងស៊ុលរបស់រាជរដ្ឋាភិបាលបរទេសណាមួយដែលកាត់លិខិតឆ្លងដែន ការទូត ឬ ថ្លូវការ របស់ប្រទេសនោះ បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ-ប្រាក់បៀវត្សដែលតំណាង មន្ត្រី និង និយោជិតបរទេសរបស់អង្គការអន្តរជាតិ និងរបស់ទីភ្នាក់ងារ ខាងសហប្រតិបត្តិការបច្ចេកទេស នៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌ នៃការបំពេញមុខងារ ជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ (តាមមាត្រា ៤៣ នៃច្បាប់សារពើពន្ធ)

### ៣.២-ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត

១-ប្រាក់សំណងដោយពិតប្រាកដនូវ ចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និង សម្រាប់ជាប្រយោជន៍នៃនិយោជិត ហើយដែលបានបំពេញល័ក្ខខ័ណ្ឌដូចតទៅ៖

ក- បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និង ដាច់ខាតរបស់សហគ្រាស

ខ- មិនបង្ហាញលក្ខណៈហួសប្រមាណ ឬ ស្តុកស្តម្ភហួសហេតុ

គ- បានបង្ហាញជាភស្តុតាងដោយវិក្កយបត្រវាយលម្អិត និងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមជាអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ

២- ប្រាក់បំណាច់នៃការបញ្ឈប់លែងឲ្យធ្វើការ តាមប្បញ្ញត្តិក្នុងច្បាប់ការងារ

៣-លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច តាមប្បញ្ញត្តិក្នុងច្បាប់ការងារ

៤-ការផ្គត់ផ្គង់ឲ្យដោយឥតយកថ្លៃ ឬ យកថ្លៃទាបជាងថ្លៃដើម នូវ ឯកសណ្ឋាន ឬ បរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស។

៥-ប្រាក់បំណាច់ ម៉ៅការ សម្រាប់ចំណាយបេសកម្ម និង ការធ្វើដំណើរ។

(តាមមាត្រា ៤៤ នៃច្បាប់សារពើពន្ធ)

## ៤-មូលដ្ឋានគិតពន្ធប្រចាំខែ ប្រាក់បៀវត្សរ៍ជាប់ពន្ធ ប្រចាំខែ និងការកំណត់ប្រាក់ពន្ធប្រចាំខែ

### ៤.១-មូលដ្ឋានគិតពន្ធប្រចាំខែ

មូលដ្ឋានគិតពន្ធប្រចាំខែរបស់ និវាសនជន គឺជាប្រាក់បៀវត្សរ៍ជាប់ពន្ធដោយផាត់ចេញនូវ ៖

១-ប្រាក់កាត់ទុកដែលជាកាតព្វកិច្ច ក្នុងការប្រតិបត្តិតាមច្បាប់ការងារ ដើម្បីបង្កើតបេឡាសោធននិងជានាសុខមាលភាពសង្គម។

២-ការទូទាត់នានា ដែលត្រូវបានលើកលែងពន្ធដូចមានចែង ក្នុងមាត្រា ៤៤ នៃច្បាប់ពន្ធ។

## តារាងអត្រាភាគរយបៀវត្សប្រចាំខែត្រូវចាប់ពន្ធ

| **តារាងទី១ ភាគរយបៀវត្សប្រចាំខែត្រូវជាប់ពន្ធ** | **អត្រាពន្ធ** |
|---|---|
| ពី ០ ដល់ ៥០០ ០០០ | ០% |
| ពី ៥០០ ០០១ ដល់ ១ ២៥០ ០០០ | ៥% |
| ពី ១ ២៥០ ០០១ ដល់ ៨ ៥០០ ០០០ | ១០% |
| ពី ៨ ៥០០ ០០១ ដល់ ១២ ៥០០ ០០០ | ១៥% |
| លើសពី ១២ ៥០០ ០០១ | ២០% |

## តារាងអត្រាភាគរយបៀវត្សប្រចាំខែ និង លម្អៀងតាមចំណាត់ថ្នាក់

| **តារាងទី២ ការគណនាពន្ធលើប្រាក់បៀវត្ស – និវាសនជន** | | |
|---|---|---|
| ប្រាក់បៀវត្សប្រចាំខែ(រៀល) | ភាគរយ | លម្អៀងតាមថ្នាក់ |
| ពី ០ ដល់ ៥០០ ០០០ | ០% | ០ រៀល |
| ពី ៥០០ ០០១ ដល់ ១ ២៥០ ០០០ | ៥% | ២៥ ០០០ រៀល |
| ពី ១ ២៥០ ០០១ ដល់ ៨ ៥០០ ០០០ | ១០% | ៨៧ ០០០ រៀល |
| ពី ៨ ៥០០ ០០១ ដល់ ១ ២ ៥០០ ០០០ | ១៥% | ៥១២ ៥០០ រៀល |

| | | |
|---|---|---|
| លើសពី ១២ ៥០០ ០០១ | ២០% | ១ ១៣៧ ០០០ រៀល |

(តាមមាត្រា ៤៧ នៃច្បាប់សារពើពន្ធ)

## ៤.២-រូបមន្តគណនាប្រាក់ពន្ធលើប្រាក់បៀវត្ស

| តារាងទី៣ រូបមន្តគណនាប្រាក់ពន្ធលើប្រាក់បៀវត្ស | | | |
|---|---|---|---|
| **ប្រាក់បៀវត្សប្រចាំខែ** | **អាត្រាពន្ធ** | **លម្អៀងតាមថ្នាក់** | **រូបមន្ត** |
| ពី ០ ដល់ ៥០០ ០០០ | ០% | ០ | ០ |
| ពី ៥០០ ០០១ ដល់ ១ ២៥០ ០០០ | ៥% | ២៥ ០០០ | ប្រាក់ពន្ធ= មពប × ៥% – ២៥ ០០០ |
| ពី ១ ២៥០ ០០១ ដល់ ៨ ៥០០ ០០០ | ១០% | ៨៧ ០០០ | ប្រាក់ពន្ធ=មពប×១០% – ៨៧ ៥០០ |
| ពី ៨ ៥០០ ០០១ ដល់ ១ ២ ៥០០ ០០០ | ១៥% | ៥១២ ៥០០ | ប្រាក់ពន្ធ=មពប×១៥%–៥១២៥០០ |
| លើសពី ១២ ៥០០ ០០១ | ២០% | ១ ១៣៧ ០០០ | ប្រាក់ពន្ធ=មពប×២០%–១ ១៣៧ ៥០០ |

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្តីណែនាំគណនាពន្ធ)

## ៤.៣-ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

១-ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជនរួមមាន៖

ក- ប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជា

ខ-ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស

គ-ប្រាក់បុរេប្រទាន ប្រាក់ឲ្យខ្ចីឬប្រាក់រំដោះ ដែលនិយោជកបើកឲ្យនិយោជិត។

២-ផ្អែកលើការបង្ហាញភស្តុតាង នៃ ស្ថានភាពគ្រួសារនិយោជិត និវាសនជនណាមួយដែលមាន៖

ក-កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធ ចំនួន ១៥០,០០០ រៀល (មួយសែនប្រាំម៉ឺនរៀល) ក្នុងកូនម្នាក់ៗក្នុងមួយខែ។

ខ-សហព័ន្ធដែលធ្វើជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយ មូលដ្ឋានកំណត់ពន្ធចំនួន ១៥០,០០០ រៀល (មួយសែនប្រាំម៉ឺនរៀល) សម្រាប់តែ ម្នាក់ ក្នុងមួយខែ។

គ-កូនក្នុងបន្ទុក អាយុមិនលើសពី១៤ឆ្នាំ ឬជាសិស្ស ឬជានិស្សិតដែលមានអាយុមិនលើសពី២៥ឆ្នាំ។

៣-ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធរួមមានប្រាក់បៀវត្សប្រភពកម្ពុជា ដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ពន្ធ។ (តាមមាត្រា ៤៤ នៃច្បាប់សារពើពន្ធ)

## ៤.៤-អត្រាកំណើនប្រាក់បៀវត្សថ្មីតាមចំណាត់ថ្នាក់

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស(ពបវ) ត្រូវអនុវត្តតាមអត្រាកំណើនថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិត ចាប់ពី ខែ កុម្ភៈ ឆ្នាំ ២០២០ តរៀងទៅ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ពន្ធប្រចាំខែនីមួយៗ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់។

### តារាងអត្រាកំណត់តាមថ្នាក់ថ្មីពន្ធលើប្រាក់បៀវត្ស

| តារាងទី៤ ភាគរយបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | អត្រាពន្ធ |
|---|---|
| ពី 0 ដល់ ១ ៣00 000 | 0% |
| ពី ១ ៣00 00១ ដល់ ២ 000 000 | ៥% |
| ពី ២ 000 00១ ដល់ ៨ ៥00 000 | ១0% |
| ពី ៨ ៥00 00១ ដល់ ១២ ៥00 000 | ១៥% |
| លើសពី ១២ ៥00 000 | ២0% |

## ៤.៥-ទាយជ្ជទានសម្រាប់សហព័ន្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភស្តុតាង នៃស្ថានភាពគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ ត្រូវបានអនុញ្ញាតអោយកាត់បន្ថយមូលដ្ឋានគិតពន្ធ

លើប្រាក់បៀវត្ស ចំពោះកូនក្នុងបន្ទុក និងសហព័ន្ធជាមេផ្ទះ ក្នុងម្នាក់ៗ ១៥០ ០០០ រៀល ក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើអោយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ដែលនាំអោយមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សក្នុងរង្វង់ ១ ៣០០ ០០១ ដល់ ២ ០០០ ០០០ រៀល (ប្រមាណពី ៣២៥ ទៅ ៥០០ដុល្លាអាមេរិក) អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។ (អនក្រ.លេខ ០៩. ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២០)

### ៤.៦-ការគណនាពន្ធលើប្រាក់បៀវត្ស

១-យោងតាមមាត្រា៤២ថ្មី នៃច្បាប់សារពើពន្ធ ពាក្យថា "ប្រាក់បៀវត្ស" សំដៅដល់បៀវត្ស ភាគលាភ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់អោយដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬជាប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

២-ប្រាក់ឧបត្ថម្ភមួយចំនួនដែលកម្មករនិយោជិត រោងចក្រ សហគ្រាស ទទួលបានពីការបំពេញការងារ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុក ពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រូវបានអនុញ្ញាតអោយដកចេញពីមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។

៣-ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសនជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស ដោយយកចំនួនប្រាក់បៀវត្សសរុប ក្រៅអំពីប្រាក់រង្វាន់ និងប្រាក់ឧបត្ថម ដូចមាននៅក្នុងចំនុច ២ ខាងលើ ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ន្ធនិងកូនក្នុងបន្ទុក។ បន្ទាប់មក ត្រូវពិនិត្យមើលថា តើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើប

យកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើប្រាក់ពន្ធ សម្រាប់ថ្នាក់អត្រានោះ។ លម្អៀលើប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្ស ដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ០០០ ០០០ រៀល ដំបូង និងលម្អៀងលើស នៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

៤-តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើប្រាក់ពន្ធតាមថ្នាក់នីមួយៗៈ

| តារាងទី៥ បៀវត្សជាប់ពន្ធប្រចាំខែ | ភាគរយ | លម្អៀងតាមថ្នាក់ | រូមន្តគណនា |
|---|---|---|---|
| ពី ០ ដល់ ១ ០០០ ០០០ ៛ | ០ % | ០ | |
| ពី ១ ០០០ ០០០ ដល់ ១ ៥០០ ០០០ ៛ | ៥% | ៥០ ០០០ ៛ | ពបវ= មពបវ × អត្រា ៥% – ៥០ ០០០ |
| ពី ១ ៥០០ ០០១ ដល់ ៨ ៥០០ ០០០ ៛ | ១០% | ១២៥ ០០០ ៛ | ពបវ= មពបវ × អត្រា ១០% – ១២៥ ០០០ |
| ពី ៨ ៥០០ ០០០៛ ដល់ ១២ ៥០០ ០០០៛ | ១៥% | ៥៥០ ០០០ ៛ | ពបវ= មពបវ × អត្រា ១៥% – ៥៥០ ០០០ |
| លើសពី ១២ ៥០០ ០០០ ៛ | ២០% | ១ ១៧៥ ០០០ ៛ | ពបវ= មពបវ × អត្រា ២០% – ១ ១៧៥ ០០០ |

**<u>រូបមន្តៈ</u>**

*ទាយជ្ជទានសហព័ន្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០ ៛ × សហព័ន្ធ និង ចំនួនកូនក្នុងបន្ទុក

*មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(មពបវ)= ប្រាក់បៀវត្សជាប់ពន្ធ(ពបវ) – ទាយជ្ជទានសហព័ន្ធកូនក្នុងបន្ទុក

*ពន្ធលើប្រាក់បៀវត្ស(ពបវ)= មូលដ្ឋានគិតពន្ធ(មពបវ) × អត្រាពន្ធ(%) – លម្អៀងលើប្រាក់ពន្ធតាមចំណាត់ថ្នាក់នីមួយៗ(លបព)

**<u>កំណត់សំគាល់៖</u>**

ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ(ពបវ) មានរួមបញ្ចូលនូវប្រាក់ឧត្តម្ភដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះ ត្រូវបានអនុញ្ញាតឲ្យដកចេញពីប្រាក់បៀវត្សជាប់ពន្ធ(ពបវ)។

**ករណីសិក្សាទី១៖** កម្មករនិយោជិតម្នាក់មានប្រាក់បៀវត្ស ២ ០០០ ០០០ រៀល

**ក.១ ករណីនៅលីវ**

មពបវ = ២ ០០០ ០០០ ៛ ជាប់ពន្ធក្នុងអត្រា ១០ %

លបព = ១២៥ ០០០ ៛

ពបវ = (២ ០០០ ០០០៛ × ១០ %) – ១២៥ ០០០ ៛ = <u>៧៥ ០០០ ៛</u>

**ក.២ ករណីនៅលីវ**

មពបវ = ១ ៩០០ ០០០ ៛ , ប្រាក់ឧបត្ថម្ភផ្សេងៗ = ១០០ ០០០ ៛

លបព = ៦៥ ០០០ ៛

មពបវ = ១ ៩០០ ០០០ ៛ – ១០០ ០០០ ៛ = ១ ៨០០ ០០០ ៛(ត្រូវជាប់ពន្ធអត្រា៥%)

ពបវ = (១ ៨០០ ០០០ × ៥%) – ៦៥ ០០០ ៛ = <u>២៥ ០០០ ៛</u>

**ខ ករណីមានសហព័ន្ធជាមេផ្ទះ និងកូនបីនាក់ក្នុងបន្ទុក**

ទាយជ្ជទានសហព័ន្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០ ៛ × ៤ = ៦០០ ០០០ ៛

មពបវ = ១ ៩០០ ០០០៛ – ១០០ ០០០៛ – ៦០០ ០០០៛ = ១ ២០០ ០០០៛

(ត្រូវជាប់ពន្ធនៅអត្រា០%)

លបព = ០ ៛

ពបវ = (១ ២០០ ០០០៛ × ០ %) – ០៛ = <u>០៛</u>

**ករណីសិក្សាទី២៖** អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់បានប្រាក់បៀវត្ស ៨ ៧០០ ០០០ រៀល

**ក ករណីនៅលីវ**

មពបវ = ៨ ៧០០ ០០០៛ (ជាប់អត្រាពន្ធ១៥%)

លបព = ៥៩០ ០០០៛

ពបវ = (៨ ៧០០ ០០០៛ × ១៥%) – ៥៩០ ០០០៛ = <u>៧១៥ ០០០៛</u>

**ខ ករណីមានសហព័ន្ធជាមេផ្ទះ និងកូនបីនាក់ក្នុងបន្ទុក**

ទាយជ្ជទានសហព័ន្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០ ៛ × ៤ = ៦០០ ០០០ ៛

មពបវ = ៨ ៧០០ ០០០៛ – ៦០០ ០០០៛ = ៨ ១០០ ០០០៛(ជាប់ពន្ធ១០%)

លបព = ១៦៥ ០០០៛

ពបវ = (៨ ១០០ ០០០៛ × ១០%) – ១៦៥ ០០០៛ = <u>៦៤៥ ០០០៛</u>

(អគ្គនាយកដ្ឋានពន្ធដារ,២០១៣,សេចក្ដីណែនាំគណនាពន្ធ)

## ៤.៧-ការកំណត់ប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែម

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែ និយោជកត្រូវកាត់ទុក និង បង់ប្រាក់ពន្ធតាមកាលកំណត់តាម អត្រា ២០% នៃ តម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់ឲ្យនិយោជិតទាំងអស់។

សម្រាប់អ្នកជាប់ពន្ធ អនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឲ្យតាមអត្រា ២០% លើ រាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធ។ ពន្ធកាត់ទុកនេះ គឺ ជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស។

ចំពោះការទូទាត់ប្រាក់បៀវត្ស អ្នកជាប់ពន្ធអនិវាសនជន មិនមានការអនុញ្ញាត្ត ឲ្យដកចេញនូវ ទាយជ្ជទាន សម្រាប់សហព័ន្ធជា មេផ្ទះ និង កូនក្នុងបន្ទុកឡើយ។ (តាមមាត្រា ៤៨ ៤៩ នៃច្បាប់សារពើពន្ធ)

## ៤.៨-ឥណទានពន្ធបរទេស

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួល ប្រាក់បៀវត្សប្រភពបរទេសនិងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវ ឥណទានពន្ធសម្រាប់កាត់កងពី ប្រាក់ពន្ធលើប្រាក់បៀវត្ស ដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ។

ការបង្វិលសងឥណទានពន្ធបរទេសអាចធ្វើទៅបាន លុះណាតែអ្នក ជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេស សេចក្តីបញ្ជាក់របស់និយោជិក និង រដ្ឋបាលសារពើពន្ធ នៃទីកន្លែងបំរើការងារនៅឯបរទេស។

**៥-និវាសនជនទទួលបានឥណទានពន្ធលើប្រាក់បៀវត្សចំពោះបៀវត្សប្រភពបរទេស**

ឥណទានសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្សត្រូវបានអនុញ្ញាត **លុះត្រាតែមានចំនួនតិចជាងគេក្នុងចំណោមៈ**

•ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅនោះ

•ចំនួនដែលបានយកមកពីប្រាក់ពន្ធ លើប្រាក់បៀវត្សសរុបពីគ្រប់ប្រភពក្នុងរយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាកំណើនតាមថ្នាក់ថ្មី ទៅគុណនឹងផលចែក រវាងប្រាក់បៀវត្សដែលទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព។

**ករណីសិក្សាទី១៖** លោក ចំរើន សម្បត្តិ ជានិវាសនជនប្រទេសកម្ពុជា ទទួលបានប្រាក់បៀវត្ស

ចំនួន ១០ ០០០ ០០០ រៀល នៅប្រទេសកម្ពុជា

ចំនួន ៣ ០០០ ០០០ រៀល នៅប្រទេស **ក** ជាប់ពន្ធតាមអត្រា ២០% ស្មើនឹង ប្រាក់ពន្ធ ៦០០ ០០០ រៀល

ចំនួន ២ ០០០ ០០០ រៀល នៅប្រទេស **ខ** ជាប់ពន្ធតាមអត្រា ១៥% ស្មើនឹង ប្រាក់ពន្ធ ៣០០ ០០០ រៀល

**ឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្ស**

**<u>របៀបគណនា</u>**

ប្រាក់បៀវត្សសរុបពីគ្រប់ប្រភព

= ១០ ០០០ ០០០ + ៣ ០០០ ០០០ + ២ ០០០ ០០០

= ១៥ ០០០ ០០០ រៀល

= (១៥ ០០០ ០០០ × ២០%) – ១ ១៧៥ ០០០

= ១ ៨២៥ ០០០ រៀល

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា ចំពោះចំណូលពីប្រទេស **ក**

= ១ ៨២៥ ០០០ × (៣ ០០០ ០០០/១៥ ០០០ ០០០)

= ៣៦៥ ០០០ រៀល

ក្នុងករណីខាងលើនេះ បង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា(៣៦៥ ០០០រៀល) ទាបជាងពន្ធលើប្រាក់បៀវត្សដែលបានបង់ជាក់ស្តែងនៅប្រទេស **ក** (៦០០ ០០០រៀល)។

ដូចច្នេះ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ

៣៦៥ ០០០ រៀល

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា ចំពោះចំណូលពីប្រទេស **ខ**

= ១ ៨២៥ ០០០ × (២ ០០០ ០០០/១៥ ០០០ ០០០)

= ២៤៣ ៣៣៣ រៀល

ក្នុងករណីខាងលើនេះ បង្ហាញថាពន្ធលើប្រាក់បៀវត្សនៅកម្ពុជា (២៤៣ ៣៣៣ រៀល) ទាបជាងពន្ធលើប្រាក់បៀវត្សដែលបានបង់ជាក់ស្តែងនៅប្រទេស **ខ** (៣០០ ០០០រៀល)

ដូចច្នេះ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ

២៤៣ ៣៣៣ រៀល

ដូចនេះប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា បន្ទាប់ពីការកាត់កង

**ឥណទានពន្ធ**

= ប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា មិនទាន់កាត់កងឥណទានពន្ធ – (ពន្ធលើ

ប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលប្រទេស **ក** + ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលប្រទេស **ខ**)

= ១ ៨២៥ ០០០ – (៣៦៥ ០០០ + ២៤៣ ៣៣៣)

= **១ ២១៦ ៦៦៧ រៀល**

**ករណីសិក្សាទី២៖** លោក ចាន់ រតនា ជានិវាសនជនប្រទេសកម្ពុជា ទទួលប្រាក់បៀវត្ស

ចំនួន ១០ ០០០ ០០០ រៀល នៅប្រទេសកម្ពុជា

ចំនួន ៣ ០០០ ០០០ រៀល នៅប្រទេស **ក** ជាប់ពន្ធតាមអត្រា ១០% ស្មើនឹងប្រាក់ពន្ធ ៣០០ ០០០ រៀល

ចំនួន ២ ០០០ ០០០ រៀល នៅប្រទេស **ខ** ជាប់ពន្ធតាមអត្រា ១០% ស្មើនឹងប្រាក់ពន្ធ ២០០ ០០០ រៀល

ឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្ស៖

**របៀបគណនា**

ប្រាក់បៀវត្សសរុបពីគ្រប់ប្រភព

= ១០ ០០០ ០០០ + ៣ ០០០ ០០០ + ២ ០០០ ០០០

= ១៥ ០០០ ០០០ រៀល

ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភព

= (១៥ ០០០ ០០០ × ២០%) – ១ ១៧៥ ០០០

= ១ ៨២៥ ០០០ រៀល

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា ចំពោះចំណូលពីប្រទេស **ក**

= ១ ៨២៥ ០០០ × (៣ ០០០ ០០០/១៥ ០០០ ០០០)

= ៣៦៥ ០០០ រៀល

ក្នុងករណីខាងលើនេះ បង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ក** (៣០០ ០០០ រៀល)ទាបជាងពន្ធលើប្រាក់បៀវត្សដែលបានបង់ជាក់ស្តែងនៅប្រទេសកម្ពុជា(៣៦៥ ០០០រៀល)។

ដូចច្នេះ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ

៣០០ ០០០ រៀល

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា ចំពោះចំណូលពីប្រទេស **ខ**

= ១ ៨២៥ ០០០ × (២ ០០០ ០០០/១៥ ០០០ ០០០)

= ២៤៣ ៣៣៣ រៀល

ក្នុងករណីខាងលើនេះ បង្ហាញថាពន្ធលើប្រាក់បៀវត្សនៅប្រទេស **ខ** (២០០ ០០០ រៀល) ទាបជាងពន្ធលើប្រាក់បៀវត្សដែលបានបង់ជាក់ស្តែងនៅប្រទេសកម្ពុជា(២៤៣ ៣៣៣ រៀល)

ដូចច្នេះ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ ២០០ ០០០ រៀល

ដូចនេះប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា បន្ទាប់ពីការកាត់កង

**ឥណទានពន្ធ**

= ប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា មិនទាន់កាត់កងឥណទានពន្ធ – (ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ក** + ពន្ធលើប្រាក់បៀវត្សនៅចំពោះចំណូលប្រទេស **ខ**)

= ១ ៨២៥ ០០០ – (៣០០ ០០០ + ២០០ ០០០)

= **១ ៣២៥ ០០០ រៀល**

**ករណីសិក្សាទី៣៖** លោក សុខ មាន ជានិវាសនជនប្រទេសកម្ពុជា ទទួលប្រាក់បៀវត្ស

ចំនួន ១០ ០០០ ០០០ រៀល នៅប្រទេសកម្ពុជា

ចំនួន ៣ ០០០ ០០០ រៀល នៅប្រទេស **ក** ជាប់ពន្ធតាមអត្រា ២០% ស្មើនឹង

ប្រាក់ពន្ធ ៦០០ ០០០ រៀល

ចំនួន ២ ០០០ ០០០ រៀល នៅប្រទេស **ខ** ជាប់ពន្ធតាមអត្រា ១០% ស្មើនឹង

ប្រាក់ពន្ធ ២០០ ០០០ រៀល

ឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្ស៖

**របៀបគណនា**

ប្រាក់បៀវត្សសរុបពីគ្រប់ប្រភព

= ១០ ០០០ ០០០ + ៣ ០០០ ០០០ + ២ ០០០ ០០០

= ១៥ ០០០ ០០០ រៀល

ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភព

= (១៥ ០០០ ០០០ × ២០%) – ១ ១៧៥ ០០០

= ១ ៨២៥ ០០០ រៀល

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា ចំពោះចំណូលពីប្រទេស **ក**

= ១ ៨២៥ ០០០ × (៣ ០០០ ០០០/១៥ ០០០ ០០០)

= ៣៦៥ ០០០ រៀល

ក្នុងករណីខាងលើនេះ បង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅប្រទេស កម្ពុជា (៣៦៥ ០០០រៀល) ទាបជាងពន្ធលើប្រាក់បៀវត្សដែលបានបង់ជាក់ស្តែងនៅប្រទេស **ក** (៦០០ ០០០ រៀល)

ដូចច្នេះ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ

<u>៣៦៥ ០០០ រៀល</u>

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា ចំពោះចំណូលពីប្រទេស **ខ**

= ១ ៨២៥ ០០០ × (២ ០០០ ០០០/១៥ ០០០ ០០០)

= ២៤៣ ៣៣៣ រៀល

ក្នុងករណីខាងលើនេះ បង្ហាញថាពន្ធលើប្រាក់បៀវត្សនៅប្រទេស **ខ** (២០០ ០០០ រៀល) ទាបជាងពន្ធលើប្រាក់បៀវត្សដែលបានបង់ជាក់ស្តែងនៅប្រទេសកម្ពុជា (២៤៣ ៣៣៣ រៀល)

ដូចច្នេះ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ

<u>២០០ ០០០ រៀល</u>

ដូចនេះប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា បន្ទាប់ពីការកាត់កង

**ឥណទានពន្ធ**

= ប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា មិនទាន់កាត់កងឥណទានពន្ធ – (ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលប្រទេស **ក** + ពន្ធលើប្រាក់បៀវត្សនៅចំពោះចំណូលប្រទេស **ខ**)

= ១ ៨២៥ ០០០ – (៣៦៥ ០០០ + ២០០ ០០០)

= **<u>១ ២៦០ ០០០ រៀល</u>**

ឥណទានពន្ធលើប្រាក់បៀវត្ស ត្រូវកំណត់ដាច់ដោយឡែក សម្រាប់ប្រាក់បៀវត្សបរទេសនីមួយៗ ហើយឯកសារទាំងអស់ត្រូវបញ្ជូនមកកាន់អគ្គនាយកដ្ឋានពន្ធដារៈ

- សេចក្តីបញ្ជាក់របស់និវាសនជនឬ កិច្ចសន្យាបម្រើការងារដែលមានបញ្ជាក់លម្អិត

អំពីការងារបានបំពេញ កាលបរិច្ឆេទ និង ចំនួនប្រាក់បៀវត្សបានទូទាត់សម្រាប់ការងារនៅប្រទេសក្រៅ។

- ច្បាប់ចម្លងនៃទម្រង់ឯកសារដែលនិយោជក បានដាក់ជូនរដ្ឋបាលសារពើពន្ធប្រទេសក្រៅនោះ ដើម្បីបង់ប្រាក់ពន្ធ។
- បង្កាន់ដៃទទួលប្រាក់ពន្ធបរទេសដែលរដ្ឋបាលសារពើពន្ធ ប្រទេសក្រៅចេញឲ្យ (អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្ដីណែនាំគណនាពន្ធ)

## ៦-ភាតព្វកិច្ចរបស់និយោជកនិងនិយោជិត

### ៦.១-បំណុលពន្ធ និងភាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ

១-ពន្ធនេះ គឺជាបំណុលរបស់រូបវន្តបុគ្គល ដែលបានទទួលប្រាក់បៀវត្ស រួមទាំងរូបវន្តបរទេសផង វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ។

២-ពន្ធលើប្រាក់បៀវត្សត្រូវ ប្រមូលតាមរបៀបកាត់ទុកជាមុន ជារៀងរាល់ខែ ដោយនិយោជកនៅរាល់ពេលបើកប្រាក់បៀវត្ស។

៣-ប្រសិនបើនិយោជកស្នាក់នៅបរទេស តំណាងសារពើពន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនិយោជកបានចាត់តាំង គឺ ជាអ្នកទទួលភារៈកាត់ទុក ពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្សទៅឲ្យនិយោជិត និង បង្វែរប្រាក់ពន្ធទាំងនោះជូនរដ្ឋ។

៤-និយោជក ឬ អ្នកតំណាងនិវាសនជន នៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកបរទេស ហើយនិងនិយោជិតត្រូវទទួលខុសត្រូវរួមមាន ក្នុងការបង់ពន្ធលើ ប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រកម្ពុជាដោយពុំ កំណត់ថាប្រាក់បៀវត្ស បានបើកឲ្យនៅក្នុង ព្រះរាជាណាចក្រ

កម្ពុជា ឬ នៅបរទេសឡើយ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្សនិយោជក ត្រូវទទួលខុសត្រូវចំពោះច្បាប់នេះទោះបីជាប្រាក់ពន្ធត្រូវបានបង់ដោយនិយោជិតរួចហើយក្តី។

### ៦.២-ការបង់ប្រាក់ពន្ធដែលបានកាត់ទុក

ប្រាក់ពន្ធកាត់ទុកដែលបានទាក់ទង ដល់ការបើកប្រាក់បៀវត្សធ្វើឡើង ក្នុងខែណាមួយត្រូវបង់យ៉ាងយឺតបំផុត នៅថ្ងៃទី ២០ នៃខែបន្ទាប់ ជូនទៅដល់រដ្ឋបាលសារពើពន្ធ នៅកន្លែងនៃលំនៅដ្ឋាន ឬ គ្រឹះស្ថានជាគោលដើមនៃអ្នកទទួលភារៈកាត់ទុកប្រាក់ពន្ធនោះ។

### ៦.៣-ការកាត់ទុកប្រាក់ពន្ធការកាន់បញ្ជិកានិងរបាការណ៍

គ្រប់និយោជកដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធត្រូវទទួលបំពេញភារកិច្ច៖

១- កាត់ទុកប្រាក់ពន្ធមុនពេលបើកបៀវត្ស

២-រាយការណ៍ជូនរដ្ឋបាលសារពើពន្ធ និង និយោជិតអំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក។

៣-កាន់កាប់និងថែរក្សាបញ្ជិការ ដែលកំណត់ដោយប្រកាស របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។( តាមមាត្រា ៥២ នៃច្បាប់សារពើពន្ធ )

# មេរៀនទី ៥៖ ពន្ធលើប្រាក់ចំណូល

## ១- គោលបំណង

ពន្ធលើប្រាក់ចំណូលមានគោលបំណងប្រមូលផ្តុំ កែសម្រួល និងធ្វើបច្ចុប្បន្នភាពប្រកាសនិងបទប្បញ្ញត្តិនានាទាក់ទងនឹងពន្ធលើប្រាក់ចំណូល ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

## ២- គោលដៅ

ពន្ធលើប្រាក់ចំណូលមានគោលដៅកំណត់នូវ វិធាន និង នីតិវិធីនានាក្នុងការអនុវត្តបទបញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។

## ៣- អ្នកជាប់ពន្ធ

សម្រាប់គោលដៅ នៃពន្ធលើប្រាក់ចំណូល អ្នកជាប់ពន្ធសំដៅ ដល់បុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធដែលក្នុងនោះមាន រូបវន្តបុគ្គល និងនីតិបុគ្គល។

## ៤- អ្នកជាប់ពន្ធនិវាសជន និងអ្នកជាប់ពន្ធអនិវាសនជន

១-ចំពោះរូបវន្តបុគ្គល ពាក្យ " អ្នកជាប់ពន្ធនិវាសនជន សំដៅដល់រូបវន្តបុគ្គលណាម្នាក់ដែលមានលក្ខណវិនិច្ឆ័យចាប់ ពីមួយឡើងទៅក្នុងចំណោមលក្ខណវិនិច្ឆ័យទាំងបី ដូចខាងក្រោម៖

ក-រូបវន្តបុគ្គលមាននិវាសនដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិទ្ធិ ឬជួល ឬភតិសន្យា ផ្ទះ អគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន។ល។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះ តែងតែស្នាក់នៅ ឬ កាន់កាប់។

ខ-រូបវន្តបុគ្គលមានកន្លែងស្នាក់នៅជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា

តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅ ដោយផ្អែកទៅលើកត្តានានា ដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅចរិតនៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្តបុគ្គល ធ្វើសកម្មភាពសង្គមសំខាន់ៗ។

គ-រូបវន្តបុគ្គលមានវត្តមាននៅក្នុង ព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃ ក្នុងមួយលើក ឬ ច្រើនលើកក្នុងរយៈពេល ១២ ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅ ក្នុងព្រះរាជាណាចក្រកម្ពុជាវត្តមានក្នុងចំណែកណាមួយនៃថ្ងៃ ត្រូវរាប់ថាជា ១ ថ្ងៃពេញ។ក្នុងករណីដែលមានភាពមិនច្បាស់លាស់ ក្នុងការវិនិច្ឆ័យតាមលក្ខខណ្ឌ ដែលមានចែងក្នុងចំណុច **ក** និង ចំណុច **ខ** ខាងលើនេះ វត្តមានរបស់រូបវន្តបុគ្គលដែលមានចែងក្នុងចំណុច **គ** គឺ ជាលក្ខខណ្ឌចុងក្រោយសម្រាប់កំណត់ភាពជា និវាសនជនរបស់រូបវន្តបុគ្គល។

២-ចំពោះនីតិបុគ្គលពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់អង្គភាពដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រងឬដែលមានទីកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាស ឬអង្គភាពនានា ដែលប្រកបអាជីវកម្ម ទោះបីជាបាន ឬ មិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។

ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវក្រុមហ៊ុនមូលធន ស្ថាប័នរាជរដ្ឋាភិបាល អង្គការ

សាសនា អង្គការសប្បុរសធម៌ អង្គការមិនស្វែងរកប្រាក់ចំណេញ ឬ គ្រឹះស្ថានអចិន្ត្រៃយ៍ របស់បុគ្គលនិវាសនជន ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពាក្យ "នីតិបុគ្គល"ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនសហកម្មសិទ្ធិ ឬ សហគ្រាសឯកបុគ្គល។

៤-ពាក្យ " គ្រឹះស្ថានអចិន្ត្រៃយ៍ " សំដៅទៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់ នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬ ភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជាដែលតាមរយៈនេះបុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន។

ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរនូវបណ្តាញ ឬ រូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គលអនិវាសនជន ធ្វើសកម្មភាពសេដ្ឋកិច្ចនៅ ព្រះរាជាណាចក្រកម្ពុជា។ ចំពោះសកម្មភាពអាជីវកម្មតាមរយៈ ប្រព័ន្ធអេឡិចត្រូនិកអ្នកជាប់ពន្ធ អនិវាសនជនត្រូវបានចាត់ទុកថាមាន គ្រឹះស្ថានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញ ឬ សេវាត្រូវបានផ្គត់ផ្គង់ឬ ប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវបានចាត់ទុកថាជា នីតិបុគ្គលនិវាសនជន ចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ សម្រាប់គោលដៅនៃគ្រឹះស្ថានអចិន្ត្រៃយ៍ ជាអាទិ៍មាន៖

ក- ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង

ខ- សាខារបស់សហគ្រាសបរទេស ឬភ្នាក់ងារ

គ- ការិយាល័យរបស់សហគ្រាសបរទេស

ឃ- ឃ្លាំង រោងចក្រ រោងជាង កសិដ្ឋាន ឬ កន្លែងដាំដុះ

ង-កន្លែងយករ៉ែអណ្តូងប្រេងកាត ឬ ឧស្ម័នធម្មជាតិកន្លែងយកថ្ម ឬ ធនធានធម្មជាតិផ្សេងៗទៀត។

ច-ការដ្ឋានកន្លែងសាងសង់គម្រោងការសាងសង់ ឬ គម្រោងការផ្គុំដំឡើង និង សកម្មភាពតាមដានពិនិត្យ ដែលជាប់ទាក់ទិននឹងទីកន្លែង ឬ គម្រោងការទាំងនោះក្នុងករណីដែលទីកន្លែង សាងសង់ ឬ គម្រោងការ ឬ សកម្មភាពទាំងនោះមានរយៈពេលលើសពី១៨២ ថ្ងៃ ក្នុងមួយលើក ឬ ច្រើនលើកក្នុងរយៈពេល ១២ ខែណាមួយ។

ឆ-ការផ្តល់សេវាដែលក្នុងនោះមានទាំងសេវា ទីប្រឹក្សាផងធ្វើឡើងដោយនិយោជិត ឬ បុគ្គលិកផ្សេងទៀតរបស់សហគ្រាសបរទេស ក្នុងករណីដែលសកម្មភាពទាំងនោះដែលបានប្រព្រឹត្តទៅនៅ ក្នុងព្រះរាជាណាចក្រកម្ពុជាអស់រយៈពេលសរុបលើសពី ១៨២ ថ្ងៃ ក្នុងមួយលើក ឬ ច្រើនលើកក្នុងរយៈពេល ១២ ខែ ណាមួយ។

ជ-សកម្មភាពអាជីវកម្ម (រួមបញ្ចូលទាំងប្រតិបត្តិការឧបករណ៍ធុនធ្ងន់) សម្រាប់ការស្វែងរុករក ឬការធ្វើអាជីវកម្ម ធនធានធម្មជាតិ សម្រាប់មួយលើក ឬច្រើនលើកដែលមានរយៈពេលសរុប លើសពី ៩០ ថ្ងៃ ក្នុងអំឡុងពេល ១២ ខែ ណាមួយ។

ឈ-បន្ថែមលើសេចក្តីថ្លែង ក្នុងចំណុច ក ដល់ចំណុច ជ ខាងលើនេះបុគ្គលណាមួយ ត្រូវបានចាត់ទុកជាគ្រឹះស្ថានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលបុគ្គលនោះបំពេញលក្ខខណ្ឌចាប់ពីមួយឡើងទៅក្នុងចំណោមលក្ខខណ្ឌទាំងបីដូចតទៅ៖

-មាននិងប្រើជាប្រចាំនូវសិទ្ធិអំណាច ក្នុងការចុះកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងនាមសហគ្រាសបរទេសណាមួយ

-កាន់កាប់ជាប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នូវស្តុកទំនិញ ហើយបុគ្គល នោះតែងធ្វើការបញ្ចេញ ឬ ផ្គត់ផ្គង់ទំនិញចេញពីស្តុកនោះ នៅក្នុងនាម សហគ្រាសបរទេសណាមួយ។

-ធ្វើការប្រមូលបុព្វលាភ ឬ ធ្វើការធានារ៉ាប់រងលើកលែងតែការធានារ៉ាប់រងបន្ត នូវហានិភ័យនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាសហគ្រាសបរទេសណាមួយ។

៣-ក្នុងការអនុវត្តរដ្ឋបាលសារពើពន្ធ ត្រូវបានវិនិច្ឆ័យទៅតាមករណីដោយឡែកនីមួយៗ ទៅតាមព្រឹត្តិការណ៍ជាក់ស្តែង នៃករណីនីមួយៗ ថាតើមាន ឬ គ្មានគ្រឹះស្ថានអចិន្ត្រៃយ៍លើកលែងតែការអនុវត្ត នូវប្រការទាំងឡាយ នៃកិច្ចព្រមព្រៀងអន្តរជាតិ។

៥-ពាក្យ "ក្រុមហ៊ុនមូលធន" រួមមានក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនឯកជនទទួលខុសត្រូវ មានកម្រិត សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។

៦-ពាក្យ "សហគ្រាស" សំដៅដល់គ្រឹះស្ថាន ឬ អង្គភាពដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលប្រកបអាជីវកម្ម។

៧-ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" សំដៅដល់បុគ្គលណាមួយ ដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងទទួល បាននូវប្រាក់ចំណូលប្រភពកម្ពុជា។ (តាមមាត្រា ៣ ថ្មី នៃច្បាប់សារពើពន្ធ)

**៥- ប្រភពចំណូល**

១-អនុលោមតាមមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដោយមិនមានការកម្រិតត្រឹម

តែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជា រួមមាន៖

ក- ការប្រាក់ដែលបង់ដោយអ្នកជាប់ពន្ធនិវាសនជន

ខ- ភាគលាភដែលបានបែងចែក ដោយអ្នកជាប់ពន្ធ និវាសនជន សម្រាប់គោលដៅ នៃចំណុចខាងលើនេះ ក្នុងករណីមានការផ្ទេរចំណែកណាមួយ ឬ ទាំងស្រុងនៃប្រាក់ចំណូលរក្សាទុក ទៅក្នុងដើមទុនរបស់សហគ្រាស ប្រសិនបើមានពេលណាមួយសហគ្រាសដកដើមទុនបែងចែកឱ្យម្ចាស់ភាគហ៊ុន ការដកដើមទុននោះ ត្រូវបានចាត់ទុកជាការ បែងចែកភាគលាភ ចំពោះចំណែកដើមទុនដែលបានមកពីប្រាក់ចំណូលរក្សាទុក ក្នុងករណីមានការផ្ទេរចំណែកណាមួយ ឬ ទាំងស្រុងនៃភាគហ៊ុន ក្នុងដើមទុន ឬ មូលធន របស់សហគ្រាសដែលមានប្រាក់ចំណូលរក្សាទុក ដែលជាប់ទាក់ទិន នឹង ភាគហ៊ុនដែលបានផ្ទេរ ទោះបីបានបង្វែរឬ មិនបានបង្វែរចូលក្នុងដើមទុន ឬ មូលធនក៏ដោយត្រូវចាត់ទុកថាបានបែងចែកជាភាគលាភ។

គ- ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឃ-ប្រាក់ចំណូលពីការគ្រប់គ្រង និងសេវាបច្ចេកទេសដែលបានទូទាត់ដោយអ្នកជាប់ពន្ធនិវាសនជន។ សម្រាប់គោលដៅនៃចំណុចនេះ

- ពាក្យ "សេវាគ្រប់គ្រង" សំដៅទៅដល់សេវាដែលមានចរិតគ្រប់គ្រងទាំងឡាយដែលបានធ្វើឡើងដើម្បីបំពេញមុខងារគ្រប់គ្រង នៅក្នុងការប្រកបអាជីវកម្មជាអាទិ៍មាន ការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល ការគ្រប់គ្រងភ្នាក់ងារលក់។ល។

•ពាក្យ "សេវាបច្ចេកទេស" សំដៅដល់សេវាទាំងឡាយដែលមានចរិតជាបច្ចេកទេសដែល តម្រូវឱ្យមានជំនាញ ឬ មានចំណេះដឹងបច្ចេកទេសក្នុងការអភិវឌ្ឍន៍ ឬ បង្កើតជាតុចូលនានានៅក្នុងអាជីវកម្ម ជាអាទិ៍មាន សេវា វិទ្យាសាស្ត្រ រូបសាស្ត្រ គីមីសាស្ត្រ វេជ្ជសាស្ត្រ ទន្តសាស្ត្រ ឱសថសាស្ត្រ នីតិសាស្ត្រ ធារាសាស្ត្រ បសុវប្បាស្ត្រ សិល្បៈ អប់រំសិក្សាធិការ វិស្វកម្មស្ថាបត្យកម្ម ការសិក្សាស្រាវជ្រាវ គណនេយ្យ សេដ្ឋកិច្ច សុខុមាលភាព ថាមពលបរមាណូ រួមទាំងសេវាពិគ្រោះយោបល់។ល។

•ពាក្យ "សេវាពិគ្រោះយោបល់" សំដៅដល់សេវាផ្តល់ប្រឹក្សា ដោយអ្នកជំនាញ ឬ អ្នកដែលមានវិជ្ជាជីវៈទាក់ទិនទៅនឹងសេវាបច្ចេកទេ។

ង-ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យ ឬ អចលនទ្រព្យក្នុងករណីដែលមានទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ច-ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបីដែលបានទូទាត់ ដោយបុគ្គលនិវាសនជន ឬ បុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

•ពាក្យ" សួយសារចំពោះទ្រព្យសកម្មអរូបី" សំដៅដល់ការអនុញ្ញាតឱ្យប្រើប្រាស់នូវសិទ្ធិបោះពុម្ពផ្សាយ និង លក់ស្នាដៃ អក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ឬ ជាសិទ្ធិប្រហាក់ប្រហែល (រួមទាំងសិទ្ធិចម្លងនិង ផ្សាយខ្សែអាត់សំឡេង ឬ វីដេអូ) ប្រកាសនីយបត្រតក្កកម្ម សិទ្ធិធ្វើអាជីវកម្ម ម៉ាកសញ្ញាផលិត ម៉ាកសញ្ញាពាណិជ្ជកម្ម គំនូរ គំរូប្លង់ គម្រោង រូបមន្ត ការសម្ងាត់ អំពីវិធីផលិត ជារួមគឺអ្វីៗ ទាំង

អស់ដែលជាកម្មសិទ្ធិអរូបី ឬ សិទ្ធិផ្សេងៗ ។

-ចំណេះដឹង ឬ ចំណេះធ្វើ ឬ ជាព័ត៌មានទាក់ទិននឹងបទពិសោធន៍ផ្សេងៗ ក្នុង វិស័យឧស្សាហកម្ម ពាណិជ្ជកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន បច្ចេកទេស

-ការផ្ទេរសិទ្ធិលើចំណេះ ឬ ព័ត៌មាន ដូចមានរៀបរាប់នៅក្នុងចំណុចខាងលើនេះ

-ការផ្តល់យោបល់ ឬ ការផ្តល់សេវាទាក់ទិននឹងការអនុវត្ត ឬ ការប្រើប្រាស់សិទ្ធិ ដូចមានរៀបរាប់ក្នុងចំណុចនេះ សួយសារ ចំពោះទ្រព្យសកម្មអរូបី រួមបញ្ចូល ផងដែរ នូវការទូទាត់រាល់អត្ថប្រយោជន៍ផ្សេងៗ ពីភាគកម្មក្នុងធនធានរ៉ែ ក្រៅ ពីប្រាក់ចំណូលសុទ្ធ បានមកពីអាជីវកម្មលើធនធាននេះ និង ភាគលាភ។

ឆ-ផលចំណេញពីការលក់អចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយ នៃអចលនទ្រព្យដែលស្ថិតនៅ ក្នុង ព្រះរាជាណាចក្រកម្ពុជា ឬ ចំណេញមូលធនពីទ្រព្យសកម្មហិរញ្ញវត្ថុ និង ទ្រព្យសកម្មវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ចំណេញមូលធនពីការ ផ្ទេរចំណែកណាមួយ ឬ ទាំងស្រុងនៃភាគហ៊ុន នៅក្នុងដើមទុនផ្ទាល់របស់សហ គ្រាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជ-បុព្វលាភធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្តចំពោះហានិភ័យ នៅក្នុងព្រះរាជាណា ចក្រកម្ពុជា។

ឈ-ផលចំណេញពីការលក់ចលនទ្រព្យដែលជាចំណែក នៃ ទ្រព្យអាជីវកម្មរបស់ គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធ អនិវាសនជន នៅក្នុងព្រះរាជាណាចក្រ កម្ពុជា។

៣- ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ អនិវាសនជនតាមរយៈ គ្រឹះស្ថាន អចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-អនុលោមតាមមាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធប្រាក់ចំណូលណាមួយ ដែល មិនត្រូវបានកំណត់ថាជាប្រាក់ ចំណូលប្រភពកម្ពុជា ដូចមានចែងក្នុងចំណុច ១ ខាងលើនេះ ត្រូវ បានចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស។

៣-ដូចមានចែងក្នុងមាត្រា ៣ នៃច្បាប់ស្តីពីសារពើពន្ធក្នុងករណីដែលគ្មានព័ត៌មានគ្រប់ គ្រាន់ដើម្បីកំណត់ប្រភព ចំណូល ឬ ប្រសិនបើមាន វិធាននានាដែលអនុលោមតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធឬ បទប្បញ្ញត្តិដ៏ទៃទៀតស្តីពីពន្ធដារពុំអាចឆ្លុះបញ្ចាំង ឱ្យបានច្បាស់លាស់នូវ ប្រាក់ចំណូលពីប្រភពណាមួយបានទេ រដ្ឋបាលសារពើពន្ធ ជាអ្នកកំណត់ប្រភព នៃ ប្រាក់ចំណូល នោះ។

## ៦- ប្រាក់ចំណូលមិនជាប់ពន្ធ

១- ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលរបស់ស្ថាប័នរាជរដ្ឋាភិបាល។

២- ប្រាក់ចំណូលរបស់៖

ក-អង្គការណាមួយ ដែលត្រូវបានរៀបចំឡើង និង ដំណើរការសម្រាប់គោលដៅ សុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬ អប់រំហើយ គ្មានចំណែកណាមួយនៃទ្រព្យ ឬ ប្រាក់ចំណូលដែលត្រូវបានប្រើប្រាស់ជា ផល ប្រយោជន៍ឯកជន។

ខ-សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលរបស់សមាគម ទាំងនោះមិន ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល។

ប្រាក់ចំណូលលើកលែងពន្ធ ក្នុងលក្ខខណ្ឌនេះ មិនរាប់បញ្ចូលប្រាក់ចំណូលពីសកម្មភាពដែលមិនស្ថិត ក្នុងគោលដៅសុទ្ធសាធរបស់សមាគម ឬ អង្គការទាំងនោះទេ។(តាមមាត្រា ៩ ថ្មី នៃច្បាប់សារពើពន្ធ)

## ៧-វិធានទូទៅស្តីពីប្រាក់ចំណូលជាប់ពន្ធ

### ៧.១-ឆ្នាំជាប់ពន្ធ

១- ចំពោះនីតិបុគ្គល

ក-ពន្ធលើប្រាក់ចំណូលត្រូវបានគណនាចេញ ពីលទ្ធផលគណនេយ្យ ដែលបានសម្រេចបានក្នុងឆ្នាំ ប្រតិទិននីមួយៗ (ថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ)

ខ-ចំពោះសហគ្រាសថ្មី ដែលចាប់ផ្តើមអាជីវកម្មក្នុងពេលណាមួយ នៃឆ្នាំប្រតិទិនលទ្ធផលគណនេយ្យត្រូវគិតចាប់តាំងពី ថ្ងៃ ដែលចាប់ផ្តើមប្រកបអាជីវកម្មមកទល់នឹង ថ្ងៃ ទី ៣១ ខែ ធ្នូ នៃឆ្នាំប្រតិទិននោះ។

គ-ប្រសិនបើមានលទ្ធផលគណនេយ្យច្រើនតៗគ្នា ក្នុងឆ្នាំប្រតិទិនណាមួយនៃលទ្ធផល គណនេយ្យទាំងឡាយត្រូវ បូកបញ្ចូលគ្នា ធ្វើជាមូលដ្ឋានគិតពន្ធលើប្រាក់ចំណូល។

ឃ-សហគ្រាសដែលត្រូវបានគ្រប់គ្រងដោយ នីតិបុគ្គលអនិវាសនជន អាចស្នើសុំអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិនៈ

-ចំពោះសហគ្រាសដែលផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មត្រូវបង្ហាញលទ្ធផល គណនេយ្យចុងក្រោយដែលត្រូវគិត ។

-ចាប់ពីថ្ងៃទី០១ ខែ មករា រហូតដល់ថ្ងៃដែលផ្អាកឬ បញ្ឈប់សកម្មភាពជាស្ថាពរ

សម្រាប់សហគ្រាស ដែលប្រើប្រាស់ឆ្នាំប្រតិទិន ជាឆ្នាំជាប់ពន្ធ។

-ចាប់ពីដើមឆ្នាំជាប់ពន្ធចរន្ត រហូតដល់ថ្ងៃផ្អាក ឬ បញ្ឈប់សកម្មភាពជាស្ថាពរ សម្រាប់សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធ ខុសពីឆ្នាំប្រតិទិន។

២-ចំពោះ រូបវន្តបុគ្គល ពន្ធលើប្រាក់ចំណូលត្រូវបានគណនា ចេញពីប្រាក់ចំណូលសរុបដែលសម្រេចបានក្នុងឆ្នាំ ប្រតិទិននីមួយៗ។ (តាមមាត្រា៦ ថ្មី នៃច្បាប់សារពើពន្ធ)

**៧.២-ប្រាក់ចំណូលជាប់ពន្ធ**

១-ដូចមានចែងក្នុងមាត្រា ៧ ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធ បានមកពីលទ្ធផលទាំងអស់ នៃប្រតិបត្តិការគ្រប់ប្រភេទ ដែលសហគ្រាសសម្រេចបានរួមបញ្ចូលទាំងតម្លៃលើសបានមកពីការលក់ចំណែកនានា នៃទ្រព្យសកម្មក្នុងពេលកំពុងប្រកបអាជីវកម្មឬ នៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ថ្លៃឈ្នួល និងសួយសារព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទ្រព្យសកម្មវិនិយោគ រាប់ទាំងអចលនទ្រព្យផង។ ប្រាក់ចំណូលជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវ ចំណេញមូលធនទាំងអស់ ពីអចលនទ្រព្យទ្រព្យហិរញ្ញវត្ថុ ឬ ទ្រព្យសកម្មវិនិយោគ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលសម្រេចបានមកពីប្រតិបត្តិការនានា ក្រៅពីប្រតិបត្តិការអាជីវកម្ម។ តាមនិយមន័យនេះ ការប្រកបអាជីវកម្មណាមួយទោះបី ច្បាប់អនុញ្ញាត ឬ មិនអនុញ្ញាតក្តីក៏ មិនអាចរួចផុតពីការបង់ពន្ធលើប្រាក់ចំណូលឡើយ។

២-ប្រាក់ចំណូលជាប់ពន្ធ កើតចេញពីការកាត់កងគ្នា រវាងចំណូលដុល និងចំណាយទាំងអស់ ដែលកើតចេញពីប្រតិបត្តិការគ្រប់ប្រភេទ របស់សហគ្រាសក្នុងរយៈពេល កំពុងដំណើរការ ឬនៅពេលបញ្ចប់អាជីវកម្ម។ តាមគោលការណ៍គណនេយ្យ ប្រាក់ចំណូលជាប់ពន្ធគឺ ជាសមតុល្យនៃ គណនីលទ្ធផលដែលសម្រេចបានពី ប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាស។ ប្រតិបត្តិការ

ទាំងនេះអាចទាក់ទងដោយផ្ទាល់ នឹង សកម្មភាពរបស់សហគ្រាស ឬ អាចមិនទាក់ទងដោយផ្ទាល់ នឹងសកម្មភាពរបស់សហគ្រាសដែលអាចប្រព្រឹត្តទៅ ក្នុងលក្ខណៈជាគោលដើម ឬ ក្នុងលក្ខណៈបន្ទាប់បន្សំ។ ប្រតិបត្តិការ ទាំងនេះ ជាអាទិ៍មាន ៖

ក-ការផ្តត់ផ្គង់ទំនិញ ឬ សេវា ឬប្រតិបត្តិការដទៃទៀត(ជំនួញជើងសាការងារយកកម្រៃជើងសា សម្បទានសិទ្ធិ នៃទ្រព្យអរូបី...)

ខ-ការបញ្ចេញចំណែកណាមួយនៃទ្រព្យសកម្ម ក្នុងន័យនេះការបញ្ចេញសំដៅដល់ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលនាំដល់ការបញ្ចេញចំណែកណាមួយនៃទ្រព្យសកម្ម របស់សហគ្រាសដូចជាការលក់ ការដកហូត ទ្រព្យសម្បត្តិតាមផ្លូវច្បាប់ឧបហារិត(ការដាក់បញ្ចូលជាដើមទុន) ការដោះដូរ ការដែលត្រូវផ្តល់ជាអំណោយ ការដកចេញនូវទ្រព្យសកម្ម...។

គ-ចំពោះសហគ្រាសនីតិបុគ្គល ឬ សហគ្រាសឯកបុគ្គល ត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធនូវ៖

-តម្លៃលើសនៃទ្រព្យសកម្មដែលបានលក់

-ទ្រព្យសកម្មដែលមិនបានលក់ នាថ្ងៃផ្អាកសកម្មភាព (ទ្រព្យសកម្មរយៈពេលវែង ស្តុកទំនិញ វត្ថុធាតុដើម ការងារកំពុងដំណើរការ) ត្រូវចាត់ទុកថាជាការយកវិញរបស់ម្ចាស់សហគ្រាស(ផ្ទេរពីទ្រព្យអាជីវកម្មទៅទ្រព្យឯកជន) ទ្រព្យសម្បត្តិទាំងនេះ ត្រូវវាយតម្លៃតាមតម្លៃទីផ្សារ។

៣-ប្រាក់ចំណូលជាប់ពន្ធ គឺ ជាចំនួនលម្អៀងរវាងតម្លៃនៃទ្រព្យសកម្មសុទ្ធ នាពេលបិទ និងនាពេលបើកនៃរយៈពេល ជាប់ពន្ធ។

ក-ប្រាក់ចំណូលជាប់ពន្ធគឺជាចំនួនលម្អៀង រវាងតម្លៃនៃទ្រព្យសកម្មសុទ្ធនាពេល បិទនិងនាពេលបើក នៃរយៈពេលមួយដែលជាលទ្ធផល ក្នុងរយៈពេលនោះត្រូវបានប្រើប្រាស់ទុកជាមូលដ្ឋានសម្រាប់គិតពន្ធដោយត្រូវ ដកចេញនូវឧបហារិត និង បូកចូលនូវរាល់ការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬ ត្រូវការកាត់យកមុន ដែលម្ចាស់សហគ្រាសបានធ្វើនៅក្នុងគ្រា។ និយមន័យនេះបានបង្ហាញឱ្យឃើញថា នៅក្នុងប្រាក់ចំណូលជាប់ពន្ធ ក៏ មានផងដែរនូវផលចំណេញទាំងឡាយ ដែលបានកើតឡើង ក្នុងកាលៈទេសៈណាមួយ ដែលសហគ្រាសមិនបានធ្វើប្រតិបត្តិការដូចជាករណីតម្លៃលើស ដែលបានកើតឡើង ក្នុងពេលដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ក្នុងពេលរឹបអូស ឬ ក្នុងពេលមានព្រឹត្តិការណ៍ ដែលនាំដល់ការទទួលប្រាក់សំណងធានារ៉ាប់រង។

ខ-ទ្រព្យសកម្មសុទ្ធគឺ ជាតម្លៃពិតនៃទ្រព្យសកម្មសរុប ដកផលបូកនៃខ្ទង់នានាខាងគណនីបំណុលដែលក្នុងនោះមាន ឥណទេយ្យតតិយជន (បំណុលរយៈពេលវែង ឬ ខ្លី) និង សំវិធានធន ដែលបានបង្កើតឡើងដោយស្របច្បាប់។

-ទ្រព្យសកម្មសរុប រួមមានខ្ទង់ សំខាន់ៗដូចខាងក្រោម៖

-ទ្រព្យសកម្មរយៈពេលវែង ជាអាទិ៍មាន ដីធ្លីរបស់សហគ្រាសការរៀបចំតុបតែងដីធ្លីរបស់សហគ្រាស អគារ សំណង់របស់សហគ្រាស រោងចក្រ មូលនិធិពាណិជ្ជកម្ម ចំណាយបង្កើតសហគ្រាសដំបូង...។

-ទ្រព្យសកម្មរយៈពេលខ្លី ជាអាទិ៍ មាន ស្តុក (ទំនិញ វត្ថុធាតុដើម និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ សំបកវេចខ្ចប់ ផលិតផលការងារកំពុងដំណើរការ.) ប័ណ្ណបណ្តាក់

ទុនផ្សេងៗ ប្រាក់នៅធនាគារ ប្រាក់ក្នុងបេឡា (ចំណាយស្រាវជ្រាវ និង អភិវឌ្ឍន៍ និង ចំណាយលើទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត៖ ចំណាយទាំងនេះ មិនបង្កើតបានជាតម្លៃពិតប្រាកដ នៃ ទ្រព្យសកម្មទេ)

-ឥណទេយ្យ នៃ តតិយជន៖ គឺជាបំណុលពិតប្រាកដ និង ជាស្ថាពរទាំងគោលការណ៍ និង ទាំងទឹកប្រាក់ បំណុលដែលបានចុះកិច្ចសន្យាសម្រាប់ តម្រូវការអាជីវកម្ម និងដែលផ្សាភ្ជាប់នឹងការគ្រប់គ្រងធម្មតារបស់សហគ្រាស។

-សំវិធានធន៖ ខ្ទង់ទាំងនេះត្រូវតែបានបង្កើតឡើងដោយស្របច្បាប់

គ-ឧបហារិត៖ ឧបហារិតទោះជាប្រាក់ ឬ ជាវត្ថុក្តី មិនមែនជាប្រាក់ចំណូលជាប់ពន្ធទេ ឧបហារិត ដោយម្ចាស់សហគ្រាសឯកបុគ្គល នៅក្នុងករណីដែលមានសក្ខីកម្មត្រឹមត្រូវនោះត្រូវកាត់កង ពីចំនួនលម្អៀងរវាងតម្លៃទ្រព្យសកម្មពិតនាពេលបិទ និង នាពេលបើកនៃរយៈពេលជាប់ពន្ធ។

ឃ-ការដកយកប្រើប្រាស់ផ្ទាល់ខ្លួន ឬ ការកាត់យកមុនរបស់ម្ចាស់សហគ្រាស ជាអាទិ៍ មាន ៖

-ការដកយកនូវវត្ថុធាតុដើមផលិតផលសម្រេច ទំនិញ សេវា សម្រាប់តម្រូវការផ្ទាល់ខ្លួន របស់ម្ចាស់សហគ្រាស និង គ្រួសារ (ឧទាហរណ៍ ម្ហូបអាហារ សំលៀកបំពាក់បរិក្ខារប្រើប្រាស់ក្នុងផ្ទះសម្ភារៈ និង សេវាផ្សេងៗ របស់ម្ចាស់សហគ្រាសសំណង់)

-ការប្រើប្រាស់ដែលជាតម្រូវការផ្ទាល់ខ្លួន របស់ម្ចាស់សហគ្រាសនូវ ទ្រព្យសកម្មរបស់សហគ្រាស (ផ្ទះ រថយន្ត...)

ង-ការលក់ឱ្យម្ចាស់ភាគទុន នូវ ទំនិញ ឬ សេវាតាមថ្លៃទាបជាង ថ្លៃជម្មតា (ថ្លៃជំហោងដៃ ឬ ថ្លៃទីផ្សារ) ដែលអនុវត្តចំពោះអតិថិជនទូទៅ

ច-ត្រូវបានកំណត់ជាប្រាក់ចំណូលជាប់ពន្ធផងដែរ ចំពោះ ៖

-ការលុបចោលបំណុល

-ការកាត់បន្ថយបំណុលដែលម្ចាស់បំណុលបានផ្ដល់ឱ្យសហគ្រាស

-គណនីទុនម្ចាស់ទ្រព្យ និង បំណុលទាំងឡាយដែលគ្មានការពិត គ្មានភ័ស្តុតាងបញ្ជាក់

-ការបង្កើតឡើងវិញខាងទ្រព្យសកម្មនូវខ្ទង់ដែលមិនបានកត់ត្រា

ឆ-រាល់ការប្រែប្រួលនៃទ្រព្យសកម្ម សុទ្ធត្រូវបានអនុញ្ញាត ឱ្យមានការកែតម្រូវលើរាល់ការខុសឆ្គង ដែលមាននៅក្នុងតារាងតុល្យការនៅពេលបញ្ចប់ការិយបរិច្ឆេទណាមួយហើយប្រសិនបើការកែតម្រូវ នាំឱ្យមានការកើនឡើងខាងគណនីទ្រព្យសកម្ម ឬមានការថយចុះខាងគណនីបំណុល តម្រូវឱ្យមានការកំណត់ឡើងវិញនូវប្រាក់ ចំណូលជាប់ពន្ធនៃការិយបរិច្ឆេទនោះ។ អ្នកជាប់ពន្ធមានសិទ្ធិកែតម្រូវតារាងតុល្យការ នាពេលបើកការិយបរិច្ឆេទបន្តបន្ទាប់ ដែលស្ថិតក្នុងរយៈពេលនៃអាជ្ញាយុកាល កែតម្រូវលើកលែងតែតារាងតុល្យការ នាពេលបើកនៃការិយបរិច្ឆេទដំបូង។

## ៧.៣-ទ្រព្យសកម្មអាជីវកម្ម

១- ដោយហេតុថា តម្លៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទ និង ពេលបើកការិយបរិច្ឆេទត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋាន សម្រាប់គណនាប្រាក់ពន្ធ សហគ្រាសត្រូវកត់ត្រាទ្រព្យសកម្ម

អាជីវកម្មដែលជាចំណែក នៃ ទ្រព្យរបស់សហគ្រាសទៅតាមប្រភេទនីមួយៗ ឱ្យបានច្បាស់លាស់។

២-ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាស ឯកបុគ្គលត្រូវគោរពតាម គោលការណ៍ដូច ខាងក្រោម ៖

ក-ម្ចាស់សហគ្រាសត្រូវញែកឱ្យដាច់ពីគ្នា រវាងទ្រព្យសកម្មអាជីវកម្ម និង ទ្រព្យ ឯកជនរបស់ម្ចាស់សហគ្រាស។ ការកត់ត្រា ក្នុងតារាងតុល្យការ បង្កើតជា លក្ខណវិនិច្ឆ័យខុសគ្នា រវាងទ្រព្យសកម្មអាជីវកម្ម និង ទ្រព្យឯកជន។

ខ-ម្ចាស់សហគ្រាសឯកបុគ្គល ពុំមានសិទ្ធិកត់ត្រា ឬ មិនកត់ត្រានូវចំណែកណា មួយនៃ ទ្រព្យសកម្ម ឬ ទុនម្ចាស់ទ្រព្យ និង បំណុលតាមការយល់ឃើញរបស់ ខ្លួនឡើយ។

គ-ម្ចាស់សហគ្រាសឯកបុគ្គលត្រូវកត់ត្រា ក្នុងតារាងតុល្យការនៃសហគ្រាសខ្លួននូវ ចំណែកទាំងអស់ នៃ ទ្រព្យសកម្មព្រមទាំង ទុនម្ចាស់ទ្រព្យ និង បំណុលដែល ជាប់ទាក់ទងនឹង ប្រតិបត្តិការអាជីវកម្មដូចខាងក្រោម៖

-រាល់ទ្រព្យសកម្មរយៈពេលវែង ប្រើប្រាស់សម្រាប់ការ ធ្វើសកម្មភាពអាជីវកម្ម (ជាអាទិ៍មានមូលនិធិពាណិជ្ជកម្មសម្ភារៈដឹកជញ្ជូន)។ ត្រូវតែកត់ត្រាផងដែរ ក្នុងទ្រព្យសកម្ម នៃ តារាងតុល្យការ នូវទ្រព្យសកម្មរយៈពេលវែង ទាំងឡាយ ដែលប្រើប្រាស់ចម្រុះ (សម្រាប់ប្រើប្រាស់អាជីវកម្ម និង ប្រើប្រាស់ផ្ទាល់ខ្លួន) រាល់ទ្រព្យសកម្មរយៈពេលខ្លីដែលទាក់ទិននឹងសកម្មភាពអាជីវកម្ម (ស្តុក ទំនិញ ផលិតផល វត្ថុធាតុដើម ឥណទេយ្យ ប្រាក់ក្នុងដៃ...)

-ទុនម្ចាស់ទ្រព្យ និងបំណុលដែលទាក់ទិននឹង សកម្មភាពអាជីវកម្ម (ការខ្ចីបុល

ដើម្បីទិញទ្រព្យសកម្ម រយៈពេលវែង បំណុលរយៈពេលខ្លី ឬ វែង...)

ឃ-ម្ចាស់សហគ្រាសឯកបុគ្គល មិនត្រូវបានអនុញ្ញាតឱ្យកត់ត្រាក្នុងតារាងតុល្យការ សហគ្រាសរបស់ខ្លួនទេនូវ ទ្រព្យដែលមិនទាក់ទិន នឹងការធ្វើសកម្មភាពអាជីវកម្មក្នុងនោះ។

-អចលនទ្រព្យ ឬ ចំណែកណាមួយ នៃអចលនទ្រព្យដែលមិនបម្រើសកម្មភាពអាជីវកម្ម (ឧទាហរណ៍ ផ្ទះសម្រាប់ស្នាក់នៅ.)

-ការឱ្យខ្ចី ឬ ការខ្ចីបុល ដែលមិនទាក់ទិនដល់សកម្មភាពអាជីវកម្ម ដូច្នេះ តារាងតុល្យការ នៃសហគ្រាសឯកបុគ្គល ត្រូវតែគូសបញ្ជាក់ឱ្យឃើញនូវ រាល់ទ្រព្យដែលមានលក្ខណៈ បម្រើអាជីវកម្មតាមចរិត តាមការដាក់ប្រើប្រាស់ ឬ តាមគោលដៅដោយបង្ហាញតែតម្លៃទាំងនេះប៉ុណ្ណោះ។

ង-ការតម្រូវឱ្យមានការញែកដាច់ពីគ្នា រវាងទ្រព្យសកម្មអាជីវកម្ម និងទ្រព្យឯកជនមានលក្ខណៈសំខាន់ណាស់ពីព្រោះ ៖.

-ចំណាយដែលជាមូលដ្ឋានសម្រាប់ការកំណត់ ប្រាក់ចំណូលជាប់ពន្ធត្រូវតែជាចំណាយទាំងឡាយដែល ទាក់ទិននឹងចំណែកនៃទ្រព្យសកម្មអាជីវកម្ម។ តាមន័យនេះ ចំណាយទាំងឡាយដែលទាក់ទិននឹងទ្រព្យសកម្ម ប៉ុន្តែ មិនបានកត់ត្រាខាងទ្រព្យសកម្ម នៃតារាងតុល្យការ មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។

-ការផ្ទេរទ្រព្យសកម្មអាជីវកម្ម ទៅទ្រព្យឯកជន ត្រូវបានចាត់ទុកថាជាការលក់ដែលបណ្តាលឱ្យមានតម្លៃលើសត្រូវជាប់ពន្ធ ឬ តម្លៃខ្វះត្រូវកាត់ចេញពីប្រាក់ចំណូលជាប់ពន្ធ។

-ប្រតិបត្តិការបញ្ច្រាស គឺ ការផ្ទេរទ្រព្យសកម្មពីទ្រព្យឯកជន ទៅទ្រព្យសកម្មអាជីវកម្មគឺជាឧបហារិតហើយ ឧបហារិតនេះត្រូវកត់ត្រាតាមតម្លៃពិតប្រាកដនាថ្ងៃដែលមានការផ្ទេរនេះ។

៣-ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសនីតិបុគ្គល ត្រូវគោរពតាមគោលការណ៍៖

ក-ទ្រព្យសកម្មអាជីវកម្មគឺ ជាទ្រព្យរបស់សហគ្រាសជាគតិយុត្ត ទ្រព្យសកម្មអាជីវកម្ម របស់សហគ្រាសនីតិបុគ្គល ត្រូវដាច់ដោយឡែកពីទ្រព្យរបស់អ្នកចូលហ៊ុន ឬ ម្ចាស់ហ៊ុន។

ខ-សម្រាប់សហគ្រាស ដែលបង្កើតឡើងដោយគ្មានមូលដ្ឋានច្បាប់ ច្បាស់លាស់ ទ្រព្យសកម្មនានាដែលអ្នកចូលហ៊ុន បានយល់ព្រមដាក់ ជាកម្មសិទ្ធិរួមត្រូវតែកត់ត្រា ខាងទ្រព្យសកម្មនៃតារាងតុល្យការ។

(ប្រ.ក. លេខ០៩៨. សហវ. ចុះ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០)

## ៧.៤-វិធានគណនេយ្យ

១- អនុលោមតាមវិធាន គណនេយ្យជាធរមាន នៃ ព្រះរាជាណាចក្រកម្ពុជា ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះត្រូវបានទូទាត់ ឬមិនទាន់ទូទាត់ក្តី។ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវចំណាយរបស់អ្នកជាប់ពន្ធ បានកើតឡើងលទ្ធផល នៃ សកម្មភាពសេដ្ឋកិច្ច ដែលជាប់ទាក់ទិនដល់ខ្ទង់ចំណាយនោះបានកើតឡើង និង ចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាច បង្ហាញច្បាស់លាស់។

២-ចំពោះប្រតិបត្តិការដែលគិតតម្លៃជារូបិយប័ណ្ណបរទេស ត្រូវអនុវត្តតាមគោលការណ៍

ដូចខាងក្រោម ៖

ក-ត្រូវកត់ត្រាចូលក្នុង បញ្ជីគណនេយ្យ ជាប្រាក់រៀលកម្ពុជា ដោយប្រើជាអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា នាថ្ងៃធ្វើប្រតិបត្តិការ។

ខ-ក្នុងករណីមានប្រព័ន្ធធនាគារប្តូរប្រាក់ ឥណទេយ្យ ឬ បំណុល ត្រូវប្តូរជាប្រាក់រៀលលើមូលដ្ឋាន នៃអត្រាប្តូរប្រាក់នាពេលកំណត់ ដែលបានចែងក្នុងកិច្ចសន្យា

គ-ប្រសិនបើឥណទេយ្យ ឬ បំណុលបានកើតឡើង និង ត្រូវបានទូទាត់នៅក្នុងការិយបរិច្ឆេទតែមួយនោះ ចំនួនលម្អៀងដែលបានពិនិត្យឃើញរវាងតម្លៃនាពេលកើតឡើងនិងកត់ចូលបញ្ជី និង តម្លៃនាពេលទូទាត់សង គឺជាការខាតបង់ ឬ ចំណេញពីការប្តូរប្រាក់ដែលត្រូវកត់ត្រា ជាចំណាយហិរញ្ញវត្ថុឬ ចំណូលហិរញ្ញវត្ថុនៃ ការិយបរិច្ឆេទ។

ឃ-នាពេលបញ្ចាប់ការិយបរិច្ឆេទ ឥណទេយ្យឬ បំណុលជារូបិយប័ណ្ណបរទេសត្រូវវាយតម្លៃតាមអត្រាប្តូរប្រាក់ នាថ្ងៃបិទការិយបរិច្ឆេទ លម្អៀងដែលវាកើតចេញមកពីការវាយតម្លៃនេះ ត្រូវកត់ត្រាជាការខាត ឬ ចំណេញពីការប្តូរប្រាក់។

ង-នៅក្នុងការិយបរិច្ឆេទបន្ទាប់នៅពេលទូទាត់ឥណទេយ្យ ឬ បំណុលពាក់ព័ន្ធនឹងការខាតឬចំណេញ ពីការប្តូរប្រាក់ ត្រូវកត់ត្រាតាមប្រាក់លម្អៀងរវាងតម្លៃរបស់វានៅពេលទូទាត់ និងតម្លៃរបស់វានាពេលបិទ នៃការិយបរិច្ឆេទមុន។

ច-ចំពោះសាច់ប្រាក់ ជារូបិយប័ណ្ណបរទេស ដែលសហគ្រាសមាននៅក្នុង ការិយបរិច្ឆេទសហគ្រាស ត្រូវអនុវត្តតាមវិធីដូចគ្នា នឹងវិធានដែលបានចែងសម្រាប់ឥណទេយ្យ ឬ បំណុលនៃចំណុច **ឃ** ខាងលើនេះ។

### ៧.៥-ការកែតម្រូវក្រៅគណនេយ្យ

តាមវិធានគណនេយ្យប្រាក់ចំណូលសុទ្ធ ឬខាតគឺជាសមតុល្យនៃគណនីលទ្ធផលនៃការិយបរិច្ឆេទ ប៉ុន្តែដោយសារបទប្បញ្ញត្តិស្តីពីពន្ធដារ បានកំណត់ដោយឡែកដូចនេះ ត្រូវមានការកែតម្រូវក្រៅគណនេយ្យ ដោយមានការបញ្ចូលមកវិញ ឬ កាត់ចេញនូវចំណូលនិងចំណាយ។

### ៧.៦-បន្ទុកភស្តុតាង

១-នៅពេលដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬ ក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធ លើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាន នៃព័ត៌មានជាក់លាក់ ដែលរដ្ឋបាលសារពើពន្ធមាន ក្នុងករណីមិនយល់ស្រប ចំពោះការកំណត់ពន្ធរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង្ហាញភស្តុតាង ដើម្បីបញ្ជាក់ថាការកំណត់ពន្ធនោះមិនត្រឹមត្រូវ។

២-នៅពេលដែលប្រាក់ចំណូលដែលបានប្រកាស ដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្ម ឬ វត្ថុនានាដែលធ្វើឱ្យឃើញលើចំណាយស្តុកស្តមរបស់អ្នកជាប់ពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិ កំណត់ពន្ធដោយផ្អែកទៅលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មាន់សមស្រប ទៅនឹងទំហំនៃចំណាយដែលបានទិញទ្រព្យសកម្ម ឬ វត្ថុនានាដែលលេចធ្លោនោះ។ ក្នុងករណីមិនយល់ស្របចំពោះការកំណត់ពន្ធ របស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធត្រូវ បង្ហាញភស្តុតាងដើម្បីបញ្ជាក់ថា ការកំណត់ពន្ធនោះមិនត្រឹមត្រូវ។

### ៧.៧-សំវិធានធន

១-ស្របតាមមាត្រា ៦ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូលការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់ថាបន្ទុករបស់

អ្នកជាប់ពន្ធបានកើតឡើងលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ច ដែលជាប់ទាក់ទងទៅដល់ខ្ទង់ចំណាយនោះបានកើតឡើង និង ចំនួនទឹកប្រាក់ដែលជាបន្ទុក របស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។

ដូច្នេះក្រៅតែពីធនាគារក្នុងស្រុក សំវិធានធនដែលធ្វើឡើងដោយសហគ្រាសផ្សេងទៀតសម្រាប់រ៉ាប់រងបន្ទុកចំណាយ ឬការខាតបង់នានា ដែលមិនទាន់កើតមានឡើងជាក់ស្តែង មិនត្រូវបានអនុញ្ញាត ឱ្យកាត់កងជាចំណាយឡើយ ទោះបីលទ្ធភាពនៃការកើតមានបន្ទុកចំណាយ ឬការខាតបង់ទាំងនេះ មានកម្រិតខ្ពស់ ឬ ជាក់លាក់យ៉ាងណាក៏ដោយ។

២-ចំពោះធនាគារក្នុងស្រុក សំវិធានធន សម្រាប់ឥណទេយ្យជាប់សង្ស័យត្រូវបានកំណត់ដូចក្នុងតារាងខាងក្រោម៖

| ល.រ | ចំណាត់ថ្នាក់ហានិភ័យឥណទាន | សំវិធានធនដែលបានអនុញ្ញាត |
|---|---|---|
| ១ | ធម្មតា | 0% |
| ២ | ឃ្លាំមើល | 0% |
| ៣ | ក្រោមស្តង់ដា | អនុវត្តតាមច្បាប់និងបទប្បញ្ញត្តិស្តីពីធនាគារ |
| ៤ | សង្ស័យ | អនុវត្តតាមច្បាប់និងបទប្បញ្ញត្តិស្តីពីធនាគារ |
| ៥ | បាត់បង់ | អនុវត្តតាមច្បាប់និងបទប្បញ្ញត្តិស្តីពីធនាគារ |

សំវិធានធន ដែលបានអនុញ្ញាតក្នុងនោះ មិនអនុវត្តចំពោះប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុទេ។ ធនាគារក្នុងស្រុកត្រូវបញ្ចូលមកជាប្រាក់ចំណូលជាប់ពន្ធ ក្នុងឆ្នាំជាប់ពន្ធវិញនូវចំនួនទឹកប្រាក់ឥណទានដែលបានអនុញ្ញាតឱ្យកាត់កង ជាសំវិធានធនចំពោះឥណទេយ្យជាប់សង្ស័យរួម

ទាំងការប្រាក់ និង ចំណាយផ្សេងៗ នៅពេលដែលបានទទួលការបង់សងមកវិញ នូវ ឥណទេយ្យដែលជាប់សង្ស័យទាំងនោះ។

សម្រាប់គោលដៅនេះ ពាក្យ "ធនាគារ" សំដៅដល់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិ ក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុ របស់ព្រះរាជាណាចក្រកម្ពុជា។

## ៨-វិធានទូទៅស្តីពីស្តុកនិងការងារកំពុងដំណើរការ

### ៨.១-ដំណើរការស្តុក

១-ស្តុកកើតចេញពីទ្រព្យសកម្មទាំងអស់ ជាកម្មសិទ្ធិរបស់សហគ្រាស គឺ ទ្រព្យសកម្មដែលចូលរួមក្នុងវដ្តនៃអាជីវកម្មរបស់សហគ្រាសដើម្បី៖

ក-លក់ក្នុងសភាពដើម ឬ លក់ក្រោយការកែច្នៃ ឬ ក្រោយការផលិត ។

ខ-ប្រើប្រាស់អស់ក្នុងដំណាក់កាលប្រើប្រាស់ដំបូង។

២- ស្តុករួមមាន៖

ក-ទំនិញសម្ភារៈផ្គត់ផ្គង់ (វត្ថុធាតុដើមសម្ភារៈប្រើប្រាស់ សម្ភារៈវេចខ្ចប់) ផលិតផល (ផលិតផលពាក់កណ្តាលសម្រេចផលិតផលសម្រេច កាកសំណល់ឬ វត្ថុធាតុសម្រាប់យកទៅកែច្នៃឡើងវិញ)

ខ-ការងារកំពុងដំណើរការ គឺជាទ្រព្យសកម្ម ឬសេវាដែលកំពុងកកើតឡើងនៅក្នុងដំណើរការផលិតកម្ម។

៣-ត្រូវចាត់ទុកជាស្តុកផងដែរ នូវរាល់ផលិតផល ឬ ទំនិញ ឬ វត្ថុធាតុដើមដែលជាកម្មសិទ្ធិរបស់សហគ្រាស ទោះបីស្ថិត នៅក្នុង ឬនៅក្រៅទីតាំងផ្ទាល់របស់សហគ្រាសក៏ដោយ។

៤-នៅពេលធ្វើសារពើភណ្ឌ ប្រសិនបើផលិតផល ឬ ទំនិញ ឬ វត្ថុធាតុដើមដែលសហគ្រាសមិនទាន់បានទទួលមានភាពប្រាកដប្រជាថា ជាកម្មសិទ្ធិរបស់សហគ្រាសហើយនោះ ត្រូវតែឆ្លុះបញ្ចាំងក្នុង ស្តុក និង ត្រូវកត់ត្រាចូលតារាងតុល្យការ នៃការិយបរិច្ឆេទ។

៥-ផលិតផល ឬទំនិញ ឬវត្ថុធាតុដើមដែលស្តុកទុក នៅក្នុងឃ្លាំងនានានៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ឬ ដែលបានប្រគល់ឱ្យអ្នកក្រៅថែទាំ ឬជាបញ្ញើ ឬ ជាការដាក់ធានា ឬ ជាការឱ្យខ្ចី ត្រូវតែឆ្លុះបញ្ចាំងក្នុងទ្រព្យសកម្មនៃសហគ្រាស ដែលនៅតែជាម្ចាស់កម្មសិទ្ធិ។

៦-ត្រូវបានចាត់ទុកជាស្តុក ប្រសិនបើផលិតផលឬ ទំនិញបានបំពេញលក្ខខណ្ឌទាំងពីរដូចខាងក្រោម ៖

ក-ផលិតផលឬទំនិញ ឬវត្ថុធាតុដើម ជាកម្មសិទ្ធិរបស់សហគ្រាស នាថ្ងៃធ្វើសារពើភណ្ឌ ទោះបីផលិតផល ឬទំនិញ មិនស្ថិតក្នុងឃ្លាំងរបស់សហគ្រាស ក៏ដោយ

ខ-ផលិតផល ឬ ទំនិញ ឬ វត្ថុធាតុដើម មានគោលដៅទុកសម្រាប់លក់ទៅវិញក្នុងសភាពដើម ឬ បន្ទាប់ពីកែច្នៃរួច ឬ ទុកសម្រាប់ផលិត (គឺ ជាចំណែកនៃទ្រព្យសកម្មរយៈពេលខ្លី របស់សហគ្រាសដែលមិនអាចធ្វើជាទ្រព្យសកម្មរយៈពេលវែងបាន) ។

៧-ទ្រព្យសកម្ម កំពុងដំណើរការប្រព្រឹត្តទៅ ឬ កំពុងដំណើរការ និង មិនទាន់ត្រូវបានបញ្ចប់នាពេលបញ្ចប់ការិយបរិច្ឆេទ។ ទ្រព្យសកម្មកំពុងតែដំណើរការ ច្រើនកើតមាននៅក្នុង សហគ្រាសសំណង់ សហគ្រាសសាធារណការ និង បណ្តាសហគ្រាសដែលកំពុងអនុវត្តការងារដោយឧបករណ៍ធុនធ្ងន់ និងដែលប្រើរយៈពេលវែងក្នុងដំណើរការ ឬ ការផលិត។

៨-សហគ្រាសមិនត្រូវឆ្លុះបញ្ចាំងក្នុងស្តុកទេ នូវទ្រព្យដែលប្រគល់បាន តែមិនទាន់ចេញ

វិក្កយបត្រ។

៩-គណនីស្តុក និងគណនីផលិតផលកំពុងផលិត អាចត្រូវបានបែងចែកជា ៖

ក-គណនីវត្ថុធាតុដើមនិងសម្ភារៈផ្គត់ផ្គង់៖កត់ត្រានូវវត្ថុ និងវត្ថុធាតុបានកែច្នៃច្រើន ឬតិចដែលសម្រាប់បញ្ចូលក្នុងធាតុផ្សំ នៃផលិតផលកំពុងតែកែច្នៃឬការផលិត

ខ-គណនីផ្គត់ផ្គង់ផ្សេងៗ ។ កត់ត្រានូវ វត្ថុ និង វត្ថុធាតុបានកែច្នៃច្រើនឬតិចដែលប្រើប្រាស់អស់នៅពេលប្រើដំបូង ឬ ក៏ប្រើប្រាស់អស់ដោយឆាប់រហ័សក្នុងការផលិត ឬ កែច្នៃ និងមិនចូលក្នុងធាតុផ្សំនៃផលិតផលដែលបានផលិត ឬ កែច្នៃ ឬ ប្រើប្រាស់ក្នុងអាជីវកម្ម ជាសំបកវេចខ្ចប់។ គណនីនេះរួមមាន៖

-វត្ថុធាតុប្រើប្រាស់

-សម្ភារៈផ្គត់ផ្គង់ប្រើប្រាស់ ។

-គ្រឿងឆេះ

-សម្ភារៈថែទាំ

-សម្ភារៈផ្គត់ផ្គង់រោងជាង និងរោងចក្រ

-សម្ភារៈផ្គត់ផ្គង់ឃ្លាំង

-សម្ភារៈផ្គត់ផ្គង់ការិយាល័យ

-សំបកវេចខ្ចប់ ៖

-សំបកវេចខ្ចប់មិនប្រមូលវិញ

-សំបកវេចខ្ចប់ប្រមូលវិញដែលមិនអាចកត់ភិនភាគបាន

គ-គណនីកំពុងដំណើរការសម្រាប់ផលិតផល៖ កត់ត្រាផលិតផលកំពុងផលិតនិង

ការងារកំពុងដំណើរការ។

ឃ-គណនីកំពុងដំណើរការសម្រាប់សេវា៖ កត់ត្រាការសិក្សាស្រាវជ្រាវនិងការផ្តត់ផ្គង់សេវា ដែលមិនទាន់ចប់ និងដែលអនុវត្តតាមកិច្ចសន្យាមួយដែលមិនបានគ្រោងទុកនូវការផ្ទេរកម្មសិទ្ធិជាបណ្ដើរៗ ឬកត់ត្រាសម្រាប់ការសិក្សាស្រាវជ្រាវ និងការផ្គត់ផ្គង់សេវា ដែលបានចប់ហើយតែកិច្ចសន្យាត្រូវបានចែងថា ទាល់តែមានការយល់ព្រមរបស់អតិថិជនលើតម្លៃ ទើបការងារនេះក្លាយជាឥណទេយ្យបាន។

ង-ស្តុកផលិតផល រួមមាន ៖

-ផលិតផលពាក់កណ្តាលសម្រេចគឺ ផលិតផលដែលបានឈានដល់ ដំណាក់ការបង្កើយណាមួយ ប៉ុន្តែត្រូវទុកសម្រាប់បញ្ចូលក្នុងដំណាក់ការថ្មី មួយទៀត នៃ វដ្ត នៃផលិតកម្ម។

-ផលិតផលសម្រេច៖ គឺផលិតផលដែលបានដល់ដំណាក់ការបង្ហើយជាស្ថាពរ ក្នុងវដ្តនៃ ផលិតកម្ម។

-កាកសំណល់៖ គឺ ជាកាកសំណល់សល់ពីផលិតកម្មដែលអាចលក់បាន ( ឧទាហរណ៍៖កម្ទេចកំណាត់ កម្ទេចកម្ទីឈើ កម្ទេចលោហៈធាតុ កម្ទេចក្រដាស...) ឬ ជាវត្ថុធាតុប្រមូលបាន ដូចជាបំណែកនិងវត្ថុធាតុផ្សេងៗ ដែលប្រមូលបាន នៅពេលដែលទ្រព្យសកម្ម រយៈពេលវែងណាមួយ ត្រូវបានឈប់ប្រើប្រាស់ ឬ ត្រូវបានរុះរើដោះបំបែក។ វត្ថុធាតុទាំងនេះ ទុកសម្រាប់ប្រើប្រាស់ ក្នុង វដ្តអាជីវកម្ម ឬ ទុកសម្រាប់លក់។

ច-ស្តុកទំនិញ៖ គឺជាទំនិញដែលសហគ្រាស ទិញដើម្បីលក់ទៅវិញដោយមិនបាច់កែច្នៃ។

ឆ-ស្តុកកំពុងនៅតាមផ្លូវ៖

-វត្ថុធាតុសម្ភារៈផ្គត់ផ្គង់ឬទំនិញដែលមិនទាន់បានទទួលបញ្ចូលឃ្លាំង ប៉ុន្តែបានក្លាយជាកម្មសិទ្ធិ របស់សហគ្រាសរួចហើយ។

-ផលិតផល ឬ ទំនិញបញ្ចេញពីឃ្លាំង កំពុងប្រគល់ឱ្យអតិថិជន ប៉ុន្តែនៅជាកម្មសិទ្ធិរបស់សហគ្រាសនៅឡើយ។

-វត្ថុធាតុសម្ភារៈផ្គត់ផ្គង់ផលិតផលឬទំនិញរក្សាទុកនៅកន្លែងលក់ដែលស្ថិតនៅក្រៅទីស្នាក់ការ ឬផ្ញើទុកនៅតតិយជន។ (ប្រក.លេខ០៩៨.សហវ.២៩.០១.២០២០)

**៨.២-ការវាយតម្លៃស្តុក**

១-ការវាយតម្លៃតាមបរិយាទានលទ្ធកម្ម (ថ្លៃដើមទំនិញដែលទទួលបាន)តាមថ្លៃទិញពិតដែលផ្សំឡើងដោយ៖

ក-ថ្លៃទិញតាមវិក្កយបត្រការចុះថ្លៃការបន្ថយថ្លៃឬ ការបង្វិលតម្លៃដែលពាក់ព័ន្ធនឹងការទិញ ដែលអ្នកផ្គត់ផ្គង់បានយល់ព្រមផ្តល់ឱ្យ ត្រូវកាត់ចេញពីថ្លៃទិញ។

ខ-ចំណាយបន្ទាប់បន្សំពាក់ព័ន្ធផ្ទាល់នឹង ការទិញឬការផ្គត់ផ្គង់ ដែលក្នុងនោះមានការដឹកជញ្ជូនសោហ៊ុយឆ្លងកាត់ ប្រាក់កម្រៃ ឬ កម្រៃជើងសា ការលើក ឬ ដាក់ទំនិញពន្ធគយ និង ពន្ធអាករផ្សេងទៀតត្រូវលើកលែង តែអាករលើតម្លៃបន្ថែមដែលអាចស្នើសុំជាឥណទានវិញបាន។

ចំណាយទូទៅនៃការផ្គត់ផ្គង់ និង ចំណាយក្នុង ការស្តុកមិនត្រូវគិតបញ្ចូលក្នុង

បរិយាទាន លទ្ធកម្មទេ ការខាតឬការខ្ចះខ្ចាយជាយថាហេតុព្រមទាំងចំណាយហិរញ្ញវត្ថុផងក៏មិនត្រូវគិតបញ្ចូលក្នុងបរិយាទាននេះដែរ។

២-ការវាយតម្លៃតាមបរិយាទាន ផលិតកម្ម (ថ្លៃដើមផលិតផល)ដែលត្រូវបានផ្សំឡើងដោយ ៖

ក-បរិយាទានលទ្ធកម្មនៃវត្ថុធាតុដើមឬ សម្ភារៈផ្គត់ផ្គង់ដែលបានប្រើប្រាស់សម្រាប់ផលិតកម្ម។

ខ-ចំណាយដោយផ្ទាល់ដើម្បីនាំផលិតផលទៅដល់ទីកន្លែង និងទៅតាមលក្ខខណ្ឌដែលផលិតផលនោះ ស្ថិតនៅជាក់ស្តែង សហគ្រាសអាចបូកបញ្ចូលចំណាយមិនផ្ទាល់ ក្នុងលក្ខខណ្ឌដែលចំណាយនោះ អាចបញ្ចូលដោយសមហេតុ សមផលទៅក្នុងបរិយាទាន ផលិតកម្មនៃស្តុក។

គ-មិនត្រូវគិតបញ្ចូល ក្នុងបរិយាទានផលិតកម្មទេ នូវ រាល់ចំណាយរដ្ឋបាលទូទៅចំណាយស្តុកផលិតផល ចំណាយស្រាវជ្រាវនិងអភិវឌ្ឍន៍ និងចំណាយហិរញ្ញវត្ថុ

៣-ការកំណត់បរិយាទានបញ្ចេញនៃស្តុក៖

ក-ចំពោះទំនិញ ឬផលិតផលដែលមានលក្ខណៈដាច់ដោយឡែកពីគ្នា បរិយាទាននៃស្តុកត្រូវកំណត់តាមបរិយាទានបញ្ចូល នៃស្តុកទំនិញ ឬផលិតផលនីមួយៗនោះ។

ខ-ចំពោះទំនិញឬផលិតផលដែលអាចដោះដូរគ្នាបាន និងដែលមិនមានលក្ខណៈដាច់ដោយឡែកពីគ្នា ត្រូវបានអនុញ្ញាតឱ្យប្រើវិធីពីរយ៉ាង ដូចខាងក្រោមនេះសម្រាប់កំណត់បរិយាទាននៃស្តុក៖

បរិយាទានមធ្យមភាគសមតា ដែលមានពីររបៀបៈ

-បរិយាទានមធ្យមភាគសមតាប្រចាំខែៈ ក្នុងនេះ បរិយាទានឯកតានៃស្តុកក្នុង ខែណាមួយត្រូវស្មើ នឹងផលបូក នៃបរិយាទាន នៃ ស្តុកដើមខែ និងបរិយាទាន ចូលនៃការទិញ ឬ ផលិតកម្មទាំងអស់នៅក្នុងខែនោះ ត្រូវចែកនឹង ផលបូកនៃ បរិមាណស្តុកដើម ខែ និង បរិមាណនៃការទិញ ឬ ការផលិតទាំងអស់នៅក្នុង ខែនោះ។បរិយាទានឯកតាដែលបានគណនាឃើញនេះ ត្រូវយកទៅប្រើប្រាស់ សម្រាប់វាយតម្លៃទំនិញចេញទាំងអស់នៅក្នុងខែនោះ។

-បរិយាទានមធ្យមភាគសមតាក្រោយពេលបញ្ចូលម្តងៗៈ បរិយាទានឯកតានៃ ការបញ្ចេញស្តុកដែលបានធ្វើឡើង ក្រោយការបញ្ចូលស្តុកណាមួយត្រូវស្មើនឹង ផលបូកនៃបរិយាទានស្តុកដែលនៅសល់ មុនការបញ្ចូលនិងបរិយាទាន នៃការ បញ្ចូល ចែកនឹងផលបូកនៃបរិមាណស្តុក ដែលនៅសល់ពីមុន ការបញ្ចូល និង បរិមាណនៃការបញ្ចូល។ បរិយាទានឯកតា ដែលបានគណនាឃើញនេះ ត្រូវ បានយកទៅប្រើប្រាស់សម្រាប់វាយតម្លៃទំនិញចេញរហូតដល់មានការបញ្ចូល ទំនិញថ្មីទៀត វិធីចូលមុនចេញមុន (FIFO)៖ ទំនិញ ឬ ផលិតផលដែលចូល ស្តុកមុនត្រូវបញ្ចេញមុន។

-ក្នុងករណី សហគ្រាសប្រើប្រាស់ វិធីគ្រប់គ្រងស្តុកតាមការិយបរិច្ឆេទ ស្តុកចុង ក្រោយ ត្រូវបានវាយតម្លៃតាមបរិយាទានចូលនៃទំនិញឬ ផលិតផលដែលចូល ក្រោយគេបំផុត។

-ក្នុងករណី សហគ្រាសប្រើប្រាស់វិធីចេញចូលជាអចិន្ត្រៃយ៍ ស្តុកចុងក្រោយត្រូវ

វាយតម្លៃតាមបរិយាទានទិញចូលជាក់ស្តែង។

(ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

**៨.៣-ការវាយតម្លៃការងារកំពុងដំណើរការ**

ការងារកំពុងដំណើរការត្រូវវាយតម្លៃបរិយាទានផលិតកម្មដែលជាអាទិ៍ផ្សំឡើងដោយៈ

ក-បរិយាទាននៃសម្ភារៈដែលបានប្រើប្រាស់

ខ-ចំណាយពលកម្ម

គ-ចំណាយនានានៅការដ្ឋាន

ឃ-មួយភាគនៃចំណាយទូទៅនៃស្នាក់ការកណ្តាល និង មួយភាគនៃ រំលស់ ដែលជាទូទៅច្រើនតែវាយតម្លៃតាមវិធីប៉ាន់ស្មាន។ សហគ្រាសមិនអាចយកមកគិតបញ្ចូលបានទេ នូវចំណាយសុទ្ធសាធខាងពាណិជ្ជកម្ម និង ខាងរដ្ឋបាលព្រមទាំង ចំណាយហិរញ្ញវត្ថុ។

**៩-វិធានទូទៅស្តីពីចំណូលអាជីវកម្ម**

**៩.១-គោលការណ៍ទូទៅនៃការទទួលស្គាល់ចំណូល**

១-សហគ្រាសត្រូវអនុវត្តវិធានគណនេយ្យ តាមប្រព័ន្ធគណនេយ្យជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល សហគ្រាសត្រូវទទួលស្គាល់ចំណូលនៅក្នុងការិយបរិច្ឆេទដែលខ្ទង់ចំណូលបានកើតឡើង ទោះបីប្រាក់ចំណូលនោះត្រូវបានទូទាត់ ឬមិនទាន់ទូទាត់ក្តី។

២-ចំពោះការផ្គត់ផ្គង់ទំនិញ ឬ សេវាសហគ្រាសត្រូវបានកត់ត្រា ជាចំណូលនៅពេលចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្របានចេញមុនពេលបញ្ជូនទំនិញ ឬទទួលប្រាក់ ឬពេលបញ្ជូន

ទំនិញឬការបំពេញសេវាឬពេលទូទាត់ប្រាក់។ដោយឡែកសហគ្រាសដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ត្រូវអនុវត្តការទទួលស្គាល់ចំណូលតាម វិធានគណនេយ្យជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

៣-ក្នុងករណីទំនិញ ឬ សេវាត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលណាមួយ សហគ្រាសត្រូវកត់ត្រាជាចំណូលនៅពេលដែលទំនិញនោះ ត្រូវបានយកទៅប្រើប្រាស់ដំបូង ឬជាពេលដែលសេវាត្រូវបានបំពេញរួចរាល់។

៤-ក្នុងករណីទំនិញ ឬ សេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយសហគ្រាស ត្រូវកត់ត្រាជាចំណូល នៅពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈ ជាការផ្ទេរសិទ្ធិ ប្រើប្រាស់ឬ សិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាត្រូវបានបំពេញ រួចរាល់។

៥-ចំពោះការផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួល ឬការផ្គត់ផ្គង់ទំនិញ ឬសេវាក្រោមកិច្ចសន្យា ឬ ច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក ឬ ការផ្គត់ផ្គង់សេវាជាប់បន្ត ទំនិញ ឬ សេវាទាំងនោះ ត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ ចំពោះតែចំណែកដែលបានផ្គត់ផ្គង់រួចរាល់ ក្នុងរយៈពេលដែលបានកំណត់ក្នុងកិច្ចសន្យា ឬរយៈពេលដែលច្បាប់បានកំណត់ហើយសហគ្រាសត្រូវកត់ត្រាជាចំណូលនៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗនៅកាលបរិច្ឆេទណាមួយមុនគេក្នុងចំណោមកាលបរិច្ឆេទ ដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។

៦-ចំពោះភតិសន្យាហិរញ្ញវត្ថុ សហគ្រាសត្រូវកត់ត្រាជាចំណូលនៅកាលបរិច្ឆេទ ដែលកើតឡើងមុនគេ ក្នុងចំណោមកាលបរិច្ឆេទ ដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។

៧-ចំពោះសេវាខាងហិរញ្ញវត្ថុ វៀរលែងតែឥណទេយ្យដែលបានអនុញ្ញាតឱ្យធ្វើសំវិធាន

ធនតាមបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលធនាគារព្យួរទុកការប្រាក់សហគ្រាស ត្រូវកត់ត្រាជាចំណូល នៅកាលបរិច្ឆេទ ដែលបានទទួលការប្រាក់ ប្រាក់កម្រៃ ឬ កម្រៃជើងសា ដូចមានចែងនៅក្នុង កិច្ចសន្យាផ្គត់ផ្គង់សេវាខាងហិរញ្ញវត្ថុ ឬកាលបរិច្ឆេទនៃការបង់ការប្រាក់ ប្រាក់កម្រៃឬកម្រៃជើងសា ប្រសិនបើការបង់ប្រាក់ត្រូវបានធ្វើឡើងមុនកាលបរិច្ឆេទដែលត្រូវបង់ប្រាក់។

៨-ចំពោះសហគ្រាសសំណង់ ឬ សហគ្រាសធ្វើសេវាសាងសង់ សហគ្រាសត្រូវកត់ត្រាជាចំណូល នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗនៅកាលបរិច្ឆេទមុនគេក្នុងចំណោមកាលបរិច្ឆេទ ដែលការទូទាត់ត្រូវដល់កំណត់តាមកិច្ចសន្យា និង កាលបរិច្ឆេទដែលតម្រូវឱ្យកត់ត្រា ជាចំណូលក្នុងបញ្ជីគណនេយ្យ ដែលត្រូវអនុវត្តវិធានគណនេយ្យ តាមប្រព័ន្ធគណនេយ្យជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

## ៩.២-លក្ខខណ្ឌបន្ថែមក្នុងការទទួលស្គាល់ចំណូល

ចំពោះការផ្គត់ផ្គង់ទំនិញ ការទទួលស្គាល់ចំណូលកើតឡើង នៅពេលផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ដែលក្នុងករណីទូទៅត្រូវកើតឡើងនៅពេលប្រគល់ទំនិញ។ការផ្គត់ផ្គង់ទំនិញអាចធ្វើឡើងក្រោមលក្ខខណ្ឌដូចខាងក្រោម៖

ក-ការផ្គត់ផ្គង់ក្រោមលក្ខខណ្ឌព្យួរកិច្ចសន្យា៖ ក្នុងករណីនេះ ការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ត្រូវចំណុះទៅនឹង ការសម្រេចអោយបាននូវព្រឹត្តិការណ៍អ្វីមួយក្នុងអនាគត។ ផ្ទុយទៅវិញបើព្រឹត្តិការណ៍នោះមិនកើតឡើង កិច្ចសន្យានេះ នឹងត្រូវព្យួរទុករហូតដល់ពេលដែល ព្រឹត្តិការណ៍កើតឡើងដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ឬ សិទ្ធិប្រើប្រាស់និងធ្វើឱ្យខ្ទង់ចំណូលមានភាពអាចទារបាន។

ខ-ការផ្គត់ផ្គង់ក្រោមលក្ខខណ្ឌរំលាយកិច្ចសន្យា៖ ក្នុងករណីនេះ ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ត្រូវបានធ្វើឡើងភ្លាមៗ ដូចគ្នានឹងការផ្គត់ផ្គង់តាមកិច្ចសន្យាសាមញ្ញៗ ដែរ ប៉ុន្តែ កិច្ចសន្យាត្រូវលុបចោលវិញ ប្រសិនបើលក្ខខណ្ឌដែលបានគ្រោងទុកក្លាយទៅជាពិត។

ដូច្នេះប្រាក់ចំណូលត្រូវទទួលស្គាល់ក្នុងការិយបរិច្ឆេទដែលមានកាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់។ ប្រសិនបើក្រោយមកលក្ខខណ្ឌរំលាយ កិច្ចសន្យាក្លាយទៅជាពិត ការលុបចោលនូវការផ្គត់ផ្គង់ត្រូវទទួលស្គាល់ក្នុងការិយបរិច្ឆេទ ដែលលក្ខខណ្ឌបាន ក្លាយទៅជាការពិត។

គ-ប្រាក់កាត់ទុកដើម្បីធានា៖ ចំពោះប្រាក់ដែលអ្នកទិញបានកាត់ទុក ជាបណ្ដោះអាសន្ន ដើម្បីធានាលើគុណភាពការងារដែលបានផ្គត់ផ្គង់ អ្នកផ្គត់ផ្គង់ត្រូវគិតបញ្ចូលក្នុងលទ្ធផល នៃ ការិយបរិច្ឆេទចរន្ត នាពេលប្រគល់ទទួលការងារ ឬនាពេលដាក់ការងារឱ្យនៅក្រោមការទទួលខុសត្រូវរបស់ម្ចាស់កម្មសិទ្ធិ នៃការងារ

ឃ-ប្រាក់កក់៖ ប្រាក់កក់ដែលអ្នកទិញបានបង់ជាមុន នាពេលបញ្ជាទិញ ទំនិញឬសេវា ដែលជាចំណែកមួយនៃថ្លៃទិញ ទំនិញឬ សេវាហើយអ្នកផ្គត់ផ្គង់ត្រូវកត់ត្រាប្រាក់កក់ នេះជាចំណូលនាថ្ងៃទទួលប្រាក់។

## ៩.៣-ចំណូលពីសកម្មភាពអាជីវកម្ម

ចំណូលពីការធ្វើអាជីវកម្ម គឺជាចំណូលបានពីការផ្គត់ផ្គង់ទំនិញ ឬសេវាដែលជាសកម្មភាពអាជីវកម្ម ដែលមានបញ្ជាក់នៅលើប័ណ្ណបង់ពន្ធប៉ាតង់ របស់សហគ្រាស។ ចំណូលទាំងនេះរួម

បញ្ចូលទាំងការទទួលស្គាល់ចំណូលដែលកើតអំពីការយកទំនិញ ឬ សេវាសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលណាម្នាក់ផងដែល។

ចំណូលពីសកម្មភាពអាជីវកម្ម និង ចំណូលបន្ទាប់បន្សំ គឺ ជាផលរបរដែលជាមូលដ្ឋានសម្រាប់គណនាប្រាក់រំដោះពន្ធ លើប្រាក់ចំណូល និង ពន្ធអប្បរមា។

### ៩.៤-ចំណូលបន្ទាប់បន្សំ

ចំណូលបន្ទាប់បន្សំគឺ ជាចំណូលទាំងឡាយដែលមិនមែនជា ចំណូលពីសកម្មភាពអាជីវកម្មរបស់សហគ្រាស ប៉ុន្តែត្រូវគិតបញ្ចូលផងដែរ ទៅក្នុងប្រាក់ចំណូលសហគ្រាស។ ចំណូលបន្ទាប់បន្សំមានជាអាទិ៍៖

១-ចំណូលពីការជួលអចលនទ្រព្យ ទោះបីជាអចលនទ្រព្យនោះចូលរួម ឬ មិនចូលរួមក្នុងសកម្មភាពអាជីវកម្មក្តី។

២-អចលនទ្រព្យដាក់ឱ្យ តតិយជនប្រើប្រាស់ដោយឥតគិតថ្លៃត្រូវបានកំណត់ថា សហគ្រាសបានទទួលចំណូលជាប់ពន្ធ ដែលមានទឹកប្រាក់ស្មើនឹងថ្លៃឈ្នួលតាមទីផ្សារ នៃអចលនទ្រព្យ

៣-អចលនទ្រព្យដែលដាក់ឱ្យនិយោជិតប្រើប្រាស់ជាលក្ខណៈឯកជនដោយឥតគិតថ្លៃត្រូវកំណត់ថា សហគ្រាសបានទទួលចំណូលជាប់ពន្ធ ដែលមានទឹកប្រាក់ស្មើ នឹង ថ្លៃឈ្នួលតាមទីផ្សារនៃអចលនទ្រព្យ វៀរលែងតែអចលនទ្រព្យដែលដាក់ឱ្យកម្មករនិយោជិត ប្រើប្រាស់ជារួមស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

៤-សួយសារ៖ ចំណូលបានមកពីអាជីវកម្ម លើទ្រព្យសកម្មអរូបីផ្សេងៗ ដូចជាប្រកាសនីយបត្រតក្កកម្ម សិទ្ធិចម្លង គំនូរ គំរូប្លង់ សិទ្ធិអាជីវកម្ម សញ្ញាផលិត វិធីធ្វើ... ។

៥-ចំណូលបន្ទាប់បន្សំដទៃទៀតជាអាទិ៍មាន៖ចំណូលពីការលក់កាកសំណល់ការជួល

សម្ភារៈអាជីវកម្ម ប្រាក់ចំណូល ពីសំបកវេចខ្ចប់... ។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

**៩.៥-ចំណូលផ្សេងៗ**

ក្រៅពីចំណូលពីសកម្មភាពអាជីវកម្ម និង ចំណូលបន្ទាប់បន្សំ សហគ្រាសត្រូវនៅមានចំណូលផ្សេងៗ ជាច្រើនទៀតដែល ត្រូវបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធ ជាអាទិ៍មាន៖

១- ចំណូលពីមូលបត្រ ភាគហ៊ុន និង ចំណូលភាគលាភ។

២-ចំណូលហិរញ្ញវត្ថុ៖ ចំណូលបានពីឥណទេយ្យប្រាក់ជានា គណនីសន្សំគណនីចរន្ត

៣-ប្រាក់ចំណូលពីសកម្មភាពដែលបានធ្វើឡើងសម្រាប់ជាប្រយោជន៍បុគ្គលិក។

៤-អំណោយ និងឧបត្ថម្ភកធន៖

ក-អំណោយ និងឧបត្ថម្ភកធនត្រូវគិតបញ្ចូលក្នុងចំណូលជាប់ពន្ធនៃការិយបរិច្ឆេទដែលបានទទួលអំណោយនិងឧបត្ថម្ភកធនទាំងនេះ។ អំណោយនិងឧបត្ថម្ភកធន ជាអាទិ៍មាន ៖

-អំណោយផ្សេងៗ ទោះបានពីប្រភពណាក៏ដោយ

-ឧបត្ថម្ភកធនសម្រាប់អាជីវកម្ម ដែលរដ្ឋសមូហភាពសាធារណ តតិយជនបានផ្តល់ឱ្យ (ឧទាហរណ៍៖ ប្រាក់ប៉ះប៉ូវសម្រាប់បំពេញថ្លៃ ត្រូវឧបត្ថម្ភកធនសម្រាប់សម្រាលបន្ទុកអាជីវកម្មឧបត្ថម្ភកធនសម្រាប់ ជានាលំនឹង...)

ខ-ឧបត្ថម្ភកធនវិនិយោគ ៖

-ចំពោះឧបត្ថម្ភកធនវិនិយោគសម្រាប់ទ្រព្យសកម្មថ្នាក់១ ដែលមានតម្លៃចាប់ពី ៤០ លានរៀល ឡើងទៅ សហគ្រាសមិនត្រូវបានកត់ត្រាជាចំណូលទាំងស្រុងសម្រាប់ឆ្នាំជាប់ពន្ធទេ។

ក្នុងករណីនេះ សហគ្រាសត្រូវបានកត់ត្រាឧបត្ថម្ភកធនវិនិយោគ មួយចំណែក ម្តងៗ ជាចំណូលជាប់ពន្ធ។ សម្រាប់ឆ្នាំជាប់ពន្ធនីមួយៗ ចំណែកដែលត្រូវកត់ត្រាជាចំណូលជាប់ពន្ធ ត្រូវមានទឹកប្រាក់ស្មើគ្នា នឹងរំលស់នៃទ្រព្យសកម្មដែលបានទទួល ឬដែលបានបង្កើតដោយសារឧបត្ថម្ភកធនវិនិយោគក្នុងឆ្នាំជាប់ពន្ធដដែលនោះ។ ឧទាហរណ៍៖ ចំពោះទ្រព្យសកម្មក្នុងថ្នាក់ដែលមានអត្រារំលស់ស្មើភាគ ៥ ភាគរយ និង ដែលត្រូវបានទទួលមកដោយ ឧបត្ថម្ភកធនក្នុងតម្លៃ ១០០ លានរៀល ចំណែកត្រូវកត់ត្រាជា ចំណូលជាប់ពន្ធសម្រាប់ឆ្នាំ ជាប់ពន្ធនីមួយៗ គឺត្រូវស្មើនឹង ៥ លានរៀល (លើកលែងតែឆ្នាំបញ្ចប់រំលស់)។

-សម្រាប់ទ្រព្យសកម្មដែលស្ថិតនៅក្នុងថ្នាក់២ ថ្នាក់៣និង ថ្នាក់៤ ឧបត្ថម្ភកធនវិនិយោគ ត្រូវកត់ត្រាជាចំណូលជាប់ពន្ធទាំងស្រុង ដោយកាត់កង តាមតារាងរំលស់ ដើម្បីកំណត់ចំនួនសមស្របសម្រាប់រំលស់ទ្រព្យសកម្ម នៅឆ្នាំទីមួយដែលទ្រព្យទាំងនោះត្រូវបានដាក់ប្រើប្រាស់។

៥-ការសាងសង់ ឬ កែលម្អអចលនទ្រព្យ ដែលអ្នកជួលធ្វើឡើងដោយសោហ៊ុយផ្ទាល់ខ្លួន និងដោយមិនបានគិតថ្លៃពី សហគ្រាសវិញ ដែលនាំឱ្យមានការកើនឡើង នូវតម្លៃ នៃ អចលនទ្រព្យកំណើន នៃតម្លៃអចលនទ្រព្យដែលនៅសល់ ត្រូវគិតបញ្ចូលទៅក្នុងប្រាក់ចំណូលជាប់ពន្ធ នៅក្នុងឆ្នាំជាប់ពន្ធដែលអចលនទ្រព្យត្រូវបានប្រគល់មកវិញ។

៦-តម្លៃលើសពីការលក់ ឬ ឈប់ប្រើប្រាស់ទ្រព្យសកម្មអាជីវកម្ម។

៧-សំណងធានារ៉ាប់រង៖ សំណងធានារ៉ាប់រង ដែលសហគ្រាសបានទទួល ក្រោយពីមានពេលកើតមហន្តរាយ (អគ្គិភ័យ ចោរកម្ម ការខូចខាតទ្រព្យសកម្ម ផ្សេងៗ) ឬមាននៅក្នុងក្រប

ខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងដែលបានចុះកិច្ចសន្យាសម្រាប់ ជាប្រយោជន៍ ដល់សហគ្រាស។ ប្រាក់សំណងនេះត្រូវកត់ត្រាក្នុងចំណូលជាប់ពន្ធរបស់សហគ្រាស។ ដោយឡែក ការខាត បង់ និង ចំណាយរបស់សហគ្រាស ក្នុងការដាក់ឱ្យដំណើរការឡើងវិញ នូវទ្រព្យសកម្មដែលខូចខាតត្រូវកត់ត្រាជាចំណាយ។

៨-សំណងផ្សេងៗ ជាអាទិ៍មាន៖

ក-សំណងចំពោះការកេណ្ឌប្រមូលយកទៅប្រើប្រាស់ នូវមធ្យោបាយផ្សេងៗ ដូចជាកាណូតដែលរដ្ឋបានកេណ្ឌឱ្យទៅដឹកប្រជាជនពេលមានគ្រោះទឹកជំនន់ ...

ខ-សំណងពីការលុបកិច្ចសន្យា

គ-សំណងផ្ដល់ឱ្យជាជំងឺចិត្ត

ឃ-សំណងការខូចខាតដោយការធ្វើអាជីវកម្មប្រជែងគ្នាមិនស្មោះត្រង់។

៩-ការបន្ធូរបន្ថយនូវពន្ធអាករដែលមានកាលពីមុនបានកាត់ចេញពីប្រាក់ចំណូលជាប់ពន្ធ៖ ប្រាក់បន្ធូរបន្ថយនេះ គឺ ជាចំណូលនៃការិយបរិច្ឆេទ ដែលសហគ្រាសត្រូវបានទទួល ផលប្រយោជន៍នេះ។

១០-ការបន្ថយបំណុលការបន្ថយបំណុលដែលអ្នកផ្គត់ផ្គង់ឬ តតិយជនបានយល់ព្រមផ្ដល់ឱ្យសហគ្រាស និង ដែលបានធ្វើឱ្យមានការកើនឡើងនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាសត្រូវកត់ត្រាជាចំណូលនៃការិយបរិច្ឆេទដែលសហគ្រាស បានទទួលការយល់ព្រមបន្តនេះ។

(ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

## ១០-វិធានទូទៅស្តីពីចំណាយ

### ១០.១-គោលការណ៍សម្រាប់ចំណាយអាជីវកម្ម

១-ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កងគឺ ជាចំណាយសម្រាប់ធ្វើអាជីវកម្មដែលអ្នកជាប់ពន្ធបានទូទាត់ ឬ ត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ និងដែលមិនបញ្ចូលមកវិញនូវទ្រព្យសកម្ម ឬ ដែលគ្មានការលុបបំណុលណាមួយ។

២-ចំណាយបានទូទាត់ ឬ ត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ៖ ចំណាយក្នុងឆ្នាំជាប់ពន្ធណាមួយអាចកាត់កងបាន តែក្នុងឆ្នាំជាប់ពន្ធនោះ។ អ្នកជាប់ពន្ធមិនអាចរំកិលកាលបរិច្ឆេទ កត់ត្រាចំណាយពីឆ្នាំជាប់ពន្ធមួយ ទៅឆ្នាំជាប់ពន្ធមួយទៀតបានឡើយ។ ដើម្បីកំណត់លទ្ធផលនៃឆ្នាំជាប់ពន្ធណាមួយត្រូវគិតបញ្ចូលតែហេតុការណ៍និងប្រតិបត្តិការទាំងឡាយណាដែលនាំឱ្យលទ្ធផលនោះសម្រេចបានតែប៉ុណ្ណោះ ដូចជា ៖

ក-ចំណាយដែលទាក់ទងនឹងឆ្នាំជាប់ពន្ធមុនៗ៖ ចំណាយណាមួយដែលបានកើតឡើងនិងជាកម្មវត្ថុត្រូវកត់ត្រាជាចំណាយ នៃឆ្នាំជាប់ពន្ធមុនណាមួយមិនអាចយកមកកាត់កងក្នុងឆ្នាំជាប់ពន្ធចរន្តបានទេ។

ខ-ចំណាយមិនបានទូទាត់នៅក្នុងឆ្នាំជាប់ពន្ធ ប្រសិនបើចំណាយមួយដែលត្រូវជាចំណាយ នៃ ឆ្នាំជាប់ពន្ធណាមួយ ប៉ុន្តែនៅពេលបិទបញ្ជីចំណាយនេះមិនទាន់បានទូទាត់នៅឡើយ សហគ្រាសត្រូវកត់ត្រាចំណាយនេះ ក្នុងគណនីត្រូវសង (ឧទាហរណ៍៖ ឈ្នួលផ្ទះមិនបានបង់ពន្ធ មិនបានបង់ក្នុងឆ្នាំជាប់ពន្ធ..)។ ក្នុងករណី មិនបានកត់ត្រាបែបនេះទេ ចំណាយនេះមិនអាចលើកយកទៅកត់ត្រាជាចំណាយនៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់បានឡើយ។

គ-ចំណាយនៃឆ្នាំជាប់ពន្ធបន្ទាប់៖ មិនត្រូវបានអនុញ្ញាតទេ នូវ ការកត់បញ្ចូលទៅក្នុងឆ្នាំជាប់ពន្ធមួយ នូវចំណាយដែលទាក់ទិននឹងឆ្នាំជាប់ពន្ធបន្ទាប់ៗ។

ឃ-ចំណាយទាំងឡាយដែលបានទូទាត់ជាមុន ត្រូវកាត់ចេញតែពីចំណូល នៃ ឆ្នាំជាប់ពន្ធណាដែលចំណាយទាំងនោះបានកើតឡើងតែប៉ុណ្ណោះ។

៣-ចំណាយដើម្បីប្រកបអាជីវកម្ម ត្រូវបានអនុញ្ញាតឱ្យកាត់កង តែចំណាយណាមួយដែលបានធ្វើដើម្បីបម្រើអាជីវកម្ម ឬដើម្បីជាប្រយោជន៍នៃអាជីវកម្ម។ ដូច្នេះចំណាយណាដែលមិនផ្សាភ្ជាប់ទៅនឹងការគ្រប់គ្រងធម្មតា ឬ ដែលផ្តល់ប្រយោជន៍ដល់តតិយជន គឺ មិនអាចកាត់កងបានទេ។ ចំណាយដែលមិនមែនជាចំណាយដើម្បីប្រកបអាជីវកម្ម ជាអាទិ៍មាន៖

ក-ចំណាយបម្រើតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស (ឧទាហរណ៍៖ ចំណាយលំនៅដ្ឋានពន្ធផ្ទាល់ខ្លួននិងចំណាយលើយានជំនិះប្រើប្រាស់ជាឯកជន សោហ៊ុយលើអ្នកបម្រើ លាភការផ្តល់ជូនម្ចាស់សហគ្រាសឯកបុគ្គល ឬសហព័ន្ធប្រាក់កាត់យកផ្ទាល់ពីការទូទាត់របស់អតិថិជន ...)។

ខ-ចំណាយលេចធ្លោឬស្តុកស្តម្ភហួសហេតុដែលគ្មានប្រយោជន៍ ឬមានប្រយោជន៍តិចតួចពេកដល់អាជីវកម្ម។

ពាក្យ "ចំណាយស្តុកស្តម្ភហួសហេតុ" សំដៅដល់ចំណាយលើសពីតម្រូវការ ឬខ្ជះខ្ជាយហួសពីភាពសមហេតុសមផលថ្លៃ ឬ តម្លៃខ្ពស់មិនសមហេតុសមផល ឬលេចធ្លោហួសពេក។

៤-ចំណាយដែលមិនបញ្ចូលមកវិញ នូវទ្រព្យសកម្ម ឬ ដែលគ្មានការលុបបំណុលណា

មួយៈ គឺ ជាចំណាយដែលបណ្តាលឱ្យមានការថយចុះ នូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស។ ដូចនេះ ចំណាយណាមួយដែលមិនបណ្តាលឱ្យមានការថយចុះ នូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស គឺមិនអាចកាត់កងបានទេ។ចំណាយដែលមិនបណ្តាលឱ្យមានការថយចុះនូវទ្រព្យសកម្មសុទ្ធជាអាទិ៍មានៈ

ក-ចំណាយដែលមិនមែនជាបន្ទុករបស់សហគ្រាសខ្លួនឯងផ្ទាល់

ខ-ចំណាយដែលមានការបញ្ចូលមកវិញ នូវចំណែកថ្មីមួយក្នុងទ្រព្យសកម្ម ឬដែលបណ្តាលឱ្យមានការកើនតម្លៃនៃចំណែកណាមួយនៃទ្រព្យសកម្ម។

គ-ចំណាយសម្រាប់បង្កើនអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មណាមួយ

ឃ-ចំណាយដែលនាំឱ្យមានការលុបបំណុល (ឧទាហរណ៍ៈ ការសងប្រាក់ខ្ចី)

## ១០.២-គោលការណ៍សម្រាប់ចំណាយអាចកាត់កងបាន

១-សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូលចំណាយនានាដែលអាចអនុញ្ញាតឱ្យកាត់កងបានលុះណាតែចំណាយទាំងនោះបំពេញបាននូវលក្ខខណ្ឌទាំងឡាយដូចខាងក្រោមៈ

ក-ហេតុការណ៍ដែលបណ្តាលឱ្យមានចំណាយ បានកើតឡើង និង ជាកាតព្វកិច្ចពិតប្រាកដ របស់សហគ្រាសមានន័យថា ភាពពិតរបស់ចំណាយនោះត្រូវបានបញ្ជាក់ អះអាងដោយភ័ស្តុតាងដែលអាចត្រួតពិនិត្យបាន ឧទាហរណ៍ៈ វិក្កយបត្រ ប្រតិវេទន៍គយ លិខិតឆ្លើយឆ្លងពាណិជ្ជកម្ម កិច្ចសន្យាផ្តល់ នូវ ប្រាក់កម្ចីប័ណ្ណចំណាយ...។

ខ-លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលទាក់ទិននឹងចំណាយបានកើតឡើងៈ ក្នុងករណីដែលចំណាយ តម្រូវឱ្យមានការទូទាត់សង ចំពោះការផ្គត់ផ្គង់ទ្រព្យ

សកម្មទំនិញ ឬសេវា លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចកើតឡើងនៅពេលដែលសហគ្រាសបានទទួលការផ្គត់ផ្គង់ទ្រព្យសកម្ម ទំនិញ ឬ សេវា ក្នុងករណីដែលចំណាយបានកើតឡើង ដោយសារសហគ្រាស បានប្រើប្រាស់ទ្រព្យសកម្ម ឬ បានផ្គត់ផ្គង់ទំនិញ ឬសេវាលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចកើតឡើងនៅពេលដែលសហគ្រាសបានប្រើប្រាស់ទ្រព្យសកម្ម ឬ នៅពេលដែលសហគ្រាសបានផ្គត់ផ្គង់ទំនិញឬសេវាលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ច ត្រូវបានចាត់ទុកថាបានកើតឡើងនៅពេលដែលការទូទាត់ណាមួយ។

ដូចខាងក្រោមនេះបានកើតឡើង៖

-ការប៉ះប៉ូវឱ្យកម្មករ សំណងជំងឺចិត្ត ឬ សំណងលើការបំពានកិច្ចសន្យា

-ការចុះថ្លៃ ឬ ការបង្វិលសងវិញ

-ប្រាក់រង្វាន់ផ្សេងៗ

-សំណងលើការទទួលធានា ឬ តាមកិច្ចព្រមព្រៀងផ្តល់សេវា

-ប្រាក់ពន្ធនានាក្រៅពីឥណទានពន្ធបរទេស ពន្ធអប្បបរមា និង ពន្ធលើប្រាក់ចំណូល។

គ-ចំណាយរបស់សហគ្រាសត្រូវបានកត់ត្រាច្បាស់លាស់ ក្នុងបញ្ជីគណនេយ្យក្នុងឆ្នាំជាប់ពន្ធ ដោយត្រូវមានភស្តុតាងបញ្ជាក់ត្រឹមត្រូវអំពីចំនួនទឹកប្រាក់និងមានកាលបរិច្ឆេទ។

២-បន្ថែមលើលក្ខខណ្ឌទាំង ៣ ខាងលើ៖

ក-សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ដើម្បីអាចកាត់កងបាននូវចំណាយ

ដែលមិនទាន់បានទូទាត់ នៅដំណាច់ឆ្នាំជាប់ពន្ធ លុះណាតែចំណាយនោះ គឺ ជាបំណុលពិតប្រាកដរបស់សហគ្រាស។ ប្រសិនបើទឹកប្រាក់ដែលមិនបានទូទាត់មិនតំណាងឱ្យបំណុល ពិតប្រាកដទេនោះ ការកាត់កង វាមិនត្រូវបានអនុញ្ញាតឡើយ។ដើម្បីបញ្ជាក់នូវបំណុលពិតប្រាកដត្រូវតែមានដាក់កំហិតទារដោយម្ចាស់បំណុលជាមួយនឹង ការរំពឹងដោយសមស្របថាបំណុល នឹង ត្រូវទូទាត់ពិតប្រាកដដោយសហគ្រាស។

ខ-ចំពោះចំណាយប្រាក់បៀវត្សដែលត្រូវបើកឱ្យនិយោជិត សហគ្រាសអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធចរន្ត ប្រសិនបើប្រាក់បៀវត្សនោះត្រូវបានបើក ក្នុងអំឡុងពេល ១៨០ ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់។ ក្នុងករណីចំណាយប្រាក់បៀវត្ស ដែលត្រូវបើកទៅឱ្យនិយោជិតដូចមានចែងក្នុងចំណុចនេះមិនត្រូវបានទូទាត់ក្នុងរយៈពេល ១៨០ ថ្ងៃ នៃ ឆ្នាំជាប់ពន្ធបន្ទាប់ចំណាយនេះត្រូវបញ្ចូលជា ចំណូលជាពន្ធសម្រាប់ឆ្នាំជាប់ពន្ធចរន្តវិញ។ ប៉ុន្តែប្រសិនបើមានការទូទាត់កើតឡើងក្រោយរយៈពេល ១៨០ ថ្ងៃ ចំណាយត្រូវបានអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ចំពោះតែការទូទាត់ដែលបានធ្វើឡើងក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះតែប៉ុណ្ណោះ។ គោលការណ៍ ១៨០ ថ្ងៃ នេះមិនអនុវត្តចំពោះប្រាក់បម្រុងសម្រាប់សោធនរបស់និយោជិតឡើយ។

គ-ចំពោះចំណាយដែលត្រូវទូទាត់ឱ្យបុគ្គលទាក់ទិន សហគ្រាសអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធចរន្តប្រសិនបើចំណាយនោះ ត្រូវបានបើកក្នុងអំឡុងពេល១៨០ ថ្ងៃ នៃ ឆ្នាំជាប់ពន្ធបន្ទាប់ លើកលែងតែចំណាយដែលអាចកាត់កងបាននៃសារ

ពើកណ្ឌទ្រព្យជាមូលធន និង ទ្រព្យដែលអាចធ្វើរំលស់បាន។ ចំពោះចំណាយ ដែលត្រូវទូទាត់ឱ្យបុគ្គលទាក់ទិននិវាសនជន ដែលមិនស្ថិតនៅក្នុងរបបស្វ័យ ប្រកាសមិនត្រូវបានអនុញ្ញាតឱ្យកាត់កងមុនការទូទាត់ជាក់ស្តែងឡើយ។ ក្នុងករណីចំណាយ ដែលត្រូវទូទាត់ឱ្យបុគ្គលទាក់ទិន ដូចមានចែងក្នុងចំណុច នេះ មិនត្រូវបានទូទាត់ក្នុងរយៈពេល ១៨០ ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់ ចំណាយ នេះត្រូវបញ្ចូលជាចំណូលជាប់ពន្ធ សម្រាប់ឆ្នាំជាប់ពន្ធចរន្តវិញនិងមិនត្រូវបាន អនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធបន្ត បន្ទាប់ទេ។

ឃ-ក្នុងករណី សហគ្រាសធ្វើការកែតម្រូវដោយខ្លួនឯង ដោយត្រូវបញ្ចូលចំណាយ ដែលមិនបានទូទាត់មកជាចំណូលឆ្នាំជាប់ពន្ធចរន្តវិញ ដូចបានតម្រូវនៅ ក្នុង អំឡុងពេល ៣០ថ្ងៃ ក្រោយរយៈពេល ១៨០ថ្ងៃ សហគ្រាសមិនទទួលរងពន្ធ បន្ថែម និងការប្រាក់ទេ។ ក្នុងករណីសហគ្រាសមិនបានកែតម្រូវទាន់ពេលវេលា ពន្ធបន្ថែម និង ការប្រាក់ត្រូវចាប់ផ្តើមគិតពីខែបន្ទាប់ ពីរយៈពេល ១៨០ ថ្ងៃ ។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

## ១០.៣-គោលការណ៍សម្រាប់ចំណាយមិនអាចកាត់កងបាន

លើកលែងតែមានការបកស្រាយផ្សេង ក្រៅពីចំណាយដែលបំពេញលក្ខខណ្ឌដូចមាន ចែងក្នុងចំណុចខាងលើនេះ ចំណាយផ្សេងទៀតទាំងអស់គឺ ជាចំណាយមិនអាចកាត់កងបាន និង ត្រូវបញ្ចូលមកជាចំណូលជាប់ពន្ធវិញ។

## ១១-ចំណាយអាចកាត់កងបាន និងចំណាយមិនអាចកាត់កងបាន

### ១១.១-ចំណាយបង្កើតសហគ្រាស

១-ចំណាយបង្កើតសហគ្រាសគឺ ជាចំណាយដែលបានចាយដើម្បីបង្កើតសហគ្រាស ចំណាយនេះមិនអាចកត់ត្រា បញ្ចូលក្នុងគណនីទ្រព្យសកម្មដទៃណាមួយទេ។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ចំណាយការបង្កើតសហគ្រាសអាចត្រូវបានកាត់កងបាន ទាំងស្រុងក្នុងឆ្នាំជាប់ពន្ធដំបូង។ ប៉ុន្តែបើសហគ្រាសត្រូវធ្វើការកាត់កង តាមការរំលស់វិញ ចំណាយទាំងនេះអាចធ្វើរំលស់ស្មើភាគក្នុងរយៈពេលមិនលើសពី២ឆ្នាំជាប់ពន្ធបានទេ។ ចំណាយក្នុងការបង្កើតសហគ្រាសជាអាទិ៍មាន៖

ក-ចំណាយបង្កើតសហគ្រាសនិងអភិវឌ្ឍន៍ដំបូង៖គឺជាចំណាយដែលត្រូវទាក់ទិនទៅនឹងសកម្មភាពមុនពេល ឬ នាពេលបង្កើតសហគ្រាស។ ចំណាយទាំងនេះជាអាទិ៍មាន៖ ចំណាយសិក្សាសមិទ្ធិ លទ្ធភាពក្នុងការបង្កើតសហគ្រាសផ្សាយពាណិជ្ជកម្ម ដឹកនាំនិងត្រួតពិនិត្យការដ្ឋាន បណ្តុះបណ្តាលបុគ្គលិក បុរេហិរញ្ញប្បទាន ជំនួយ បច្ចេកទេស...។

ខ-ចំណាយទាក់ទិននឹងលក្ខន្តិកៈរបស់ក្រុមហ៊ុន៖ គឺជាចំណានៅក្នុងពេលបង្កើតក្រុមហ៊ុនពេលបន្ថែមឬបន្ថយមូលធនរបស់ក្រុមហ៊ុន ឬចំណាយដែលធ្វើឡើងក្នុងប្រតិបត្តិការប្រហាក់ប្រហែលណាមួយ (ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា.)។ ចំណាយនេះមានជាអាទិ៍ មានពន្ធប្រថាប់ត្រាលើលិខិតផ្សេងៗរបស់ក្រុមហ៊ុន (ឧបហារិតការបង្កើនមូលធន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា...) ប្រាក់កម្រៃ នៃការបង្កើតក្រុមហ៊ុនត្រូវចំណាយធ្វើបែប

បទស្របច្បាប់ ។

គ-ចំណាយក្នុងឱកាសចុះកិច្ចសន្យាខ្ចីបុល

ឃ-ចំណាយក្នុងការទទួលទ្រព្យសកម្មរយៈពេលវែង ក្នុងនេះមានតែពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់កម្រៃជើងសា និងចំណាយលើលិខិតស្នាមតាមផ្លូវច្បាប់តែប៉ុណ្ណោះ។ ឯចំណាយផ្សេងទៀតគឺជាចំណែកនៃបរិយាទាននៃទ្រព្យសកម្មឬ ជាចំណាយនៅក្នុងឆ្នាំជាប់ពន្ធ ដែលចំណាយទាំងនោះបានកើតឡើង។

២-ចំណាយខាងក្រោមនេះ មិនកំណត់ថាជាចំណាយបង្កើតសហគ្រាសទេ៖

ក-ចំណាយដែលតែងតែកើតឡើងជាធម្មតា ក្នុងឆ្នាំជាប់ពន្ធ (ឧទាហរណ៍៖ ចំណាយនៃការផ្សាយពាណិជ្ជកម្មទំនិញ ឬ សេវា...)

ខ-ចំណាយលើឋាបនកម្ម និង ការផ្គុំដំឡើងដែលត្រូវបានគិតបញ្ចូលក្នុងតម្លៃទិញទ្រព្យសកម្មរយៈ ពេលវែងជាប់ពាក់ព័ន្ធ។

(តាមមាត្រា១១ ដល់ ១៨ នៃច្បាប់សារពើពន្ធ)

## ១១.២-ការទិញ

១-ការទិញអាចបែងចែកជា ៣ ប្រភេទ៖

ក-ការទិញដែលអាចស្តុកបាន ដូចជា គ្រឿងផ្គត់ផ្គង់ និង ទំនិញ

ខ-ការទិញមិនអាចស្តុកបាន ឬមិនបានស្តុក ដូចជា ទឹក អគ្គិសនី ប្រេងឥន្ធនៈនិងប្រេងរំអិល សម្ភារៈផ្គត់ផ្គង់តូចតាច សម្រាប់នៅការិយាល័យ ហត្ថូបករណ៍តូចតាចដែលត្រូវផ្លាស់ថ្មី ជាញឹកញាប់ (នៅដំណាច់ឆ្នាំជាប់ពន្ធ ការទិញប្រភេទ

នេះមិនត្រូវបានធ្វើនិយ័តកម្មដោយគណនីស្តុកទេ ប៉ុន្តែ ត្រូវធ្វើដោយគណនី "ចំណាយបានពិនិត្យ កត់ត្រាមុន")។

គ-ការទិញសេវាដែលជាទឹកប្រាក់បានចាយ ឱ្យអ្នកទទួលម៉ៅការបន្ត សម្រាប់ការផលិត ការបំប្លែង ការរក្សា ផលិតផលទុកឱ្យបានយូរ ឬការជួសជុល ថែទាំ. ។ អ្នកទទួល ម៉ៅការបន្ត អាចជាអ្នកផលិតយកតែថ្លៃឈ្នួលពលកម្ម (អ្នកទិញជាអ្នកផ្តល់វត្ថុធាតុដើមឱ្យ) អ្នកទទួលម៉ៅការបន្តខាងឧស្សាហកម្ម ឬ អ្នកទទួលម៉ៅការបន្តសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬ សេវា (តាមធម្មតាគឺមានការងារខាងសាធារណការ ការងារសាងសង់អគារ)

២-កំណត់ត្រានៃការទិញ៖ ការទិញត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យនាពេលបានទទួលវិក្កយបត្រទៅតាមបរិយាទានពិត នៃការទិញនោះ។

ក-ចំពោះទ្រព្យសកម្មដែលទិញក្នុងស្រុកបរិយាទានទិញគឺ ជាចំណាយពិតប្រាកដរបស់សហគ្រាសក្នុងការទិញ ដែលមានថ្លៃទិញ បូកចំណាយបន្ទាប់បន្សំដែលជាប់ទាក់ទិន ដោយផ្ទាល់ នឹងការទិញដូចជាចំណាយដឹកជញ្ជូន ធានារ៉ាប់រង និងដកចេញនូវការបញ្ចុះថ្លៃផ្សេងៗ ដែលអ្នកផ្គត់ផ្គង់បានយល់ព្រមផ្តល់ឱ្យ។

ខ-ចំពោះទ្រព្យសកម្មរយៈពេលវែងដែលត្រូវនាំចូល បរិយាទានទិញ ជាអាទិ៍មាន៖

-ថ្លៃទិញ

-ចំណាយដឹកជញ្ជូន

-ចំណាយធានារ៉ាប់រងដែលបានចាយនៅក្រៅប្រទេស

-ពន្ធគយ ឬ អាករដែលមិនអាចស្នើសុំវិញបាន

-ចំណាយឆ្លងកាត់កម្រៃជើងសា និងជើងសាជំនួញដែលត្រូវបង់ឱ្យសហគ្រាស នានា ដែលស្ថិតនៅឯបរទេស (គិតរួមបញ្ចូលទាំងកម្រៃជើងសា ធនាគារ ចំណាយសំណុំរឿងនិងចំណាយនៃការទូទាត់)

-ចំណាយផ្សេងៗ ក្រោយការបញ្ចូលទ្រព្យសកម្ម មកនៅក្នុងប្រទេស ដូចជាចំណាយឆ្លងកាត់ តម្លៃជើងសា និង ជើងសាជំនួញ ដែលត្រូវបង់ឱ្យសហគ្រាសក្នុងស្រុកចំណាយដឹកជញ្ជូននិងចំណាយធានារ៉ាប់រងពីព្រំដែនមកដល់ឃ្លាំង។

៣-កំណត់ត្រាពន្ធគយ៖ ពន្ធគយលើទំនិញនាំចេញ នាំចូល ត្រូវកត់ត្រាក្នុងគណនីពន្ធគយនិងមិនត្រូវកត់ត្រានៅក្នុងគណនីទិញ ទំនិញទេ។

៤-កំណត់ត្រាអាករលើតម្លៃបន្ថែម៖

ក-ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់មិនជាប់អាករ ត្រូវបានអនុវត្តតាមគោលការណ៍ ទៅតាមអាករ ផ្សេងៗ ដូចមានចែងក្នុងចំណុចទី៥។

ខ-ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ៖

-ចំពោះអាករលើធាតុចូលដែលអាចសុំជាឥណទានបាន ត្រូវកត់ត្រាក្នុងគណនីត្រូវទទួល

-ចំពោះ អាករលើធាតុចូលដែលមិនអាចសុំជាឥណទានបាន ត្រូវអនុវត្តតាមគោលការណ៍សម្រាប់អាករផ្សេងៗ ដូចមានចែងក្នុងចំណុចទី៥។

-ចំពោះ អាករលើធាតុចូលដែលបានកត់ត្រាក្នុងគណនីត្រូវទទួល ដូចមាននៅក្នុងចំណុចទី១ ប៉ុន្តែក្រោយមកទៀតក្លាយជាឥណទានមិនអាច ស្នើសុំបានដោយបទប្បញ្ញត្តិមិនអនុញ្ញាត សហគ្រាសត្រូវកត់ត្រាអាករលើធាតុចូលនេះ

ក្នុងគណនីទ្រព្យសកម្មឬ គណនីទិញដែលជាប់ទាក់ទិន។ ប៉ុន្តែប្រសិនបើអាករលើជាតុចូលនេះមិនអាចកត់បញ្ចូលទៅក្នុងគណនីទ្រព្យសកម្ម ឬគណនីទិញណាមួយបានទេ សហគ្រាសអាចកត់ត្រាអាករលើជាតុចូលនេះជាចំណាយក្នុងឆ្នាំជាប់ពន្ធដែលឥណទានមិនត្រូវបានអនុញ្ញាត។

៥-កំណត់ត្រាអាករផ្សេងៗ ដូចជាអាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈអាករលើការស្នាក់នៅ អាករទាំងនេះ មិនត្រូវកាត់ចេញពីបរិយាទានទិញទេ។ ប្រសិនបើអាករទាំងនេះមានឆ្លុះបញ្ចាំងក្នុងវិក្កយបត្រនៃការទិញទ្រព្យសកម្ម ឬ សេវា អាករទាំងនេះត្រូវបូកបន្ថែមលើថ្លៃទិញ និងត្រូវកត់ត្រាក្នុងគណនីចំណាយ ឬ គណនីទ្រព្យសកម្មដែលទាក់ទិន។

៦-ការដកយកទំនិញ ឬសេវាមកប្រើប្រាស់សម្រាប់ប្រកបអាជីវកម្ម ការដកយកទំនិញ ឬសេវាមកប្រើប្រាស់សម្រាប់ប្រកបអាជីវកម្ម មិនត្រូវចាត់ទុកថាបានលក់ទេ ប៉ុន្តែត្រូវមានភ័ស្តុតាងបញ្ជាក់ច្បាស់លាស់ ហើយមិនត្រូវកត់ត្រាជាចំណាយដែរ។

៧-កំណត់ត្រាការទិញ និង ការធ្វើនិយ័តកម្ម ការទិញស្តុក និង បំណុលអ្នកផ្គត់ផ្គង់៖ ដូចចំណាយផ្សេងទៀតដែរ ការទិញត្រូវកត់ត្រាបញ្ចូលក្នុងឆ្នាំជាប់ពន្ធដែលការទិញបានកើតឡើង ផ្អែកតាមគោលការណ៍នៃការកត់ត្រា ការទិញនាថ្ងៃទទួលវិក្កយបត្រនាំឱ្យមានចន្លោះក្នុងពេលមួយនាថ្ងៃបញ្ចប់ឆ្នាំជាប់ពន្ធ គឺការកើតឡើងមុនក្រោយគ្នា រវាងការទទួលវិក្កយបត្រ ឬ ការទទួលទំនិញ និងការកត់ត្រាគណនេយ្យ។ ក្នុងករណីនេះ ត្រូវធ្វើនិយ័តកម្មនាឱកាសធ្វើសារពើភណ្ឌ តាមវិធីដូចខាងក្រោម៖

ក-ប្រសិនបើវិក្កយបត្រមិនទាន់បានទទួល ប៉ុន្តែទំនិញបានប្រគល់ទទួលរួចហើយ បំណុលដែលមានទឹកប្រាក់ប៉ាន់ស្មានមួយត្រូវបានកត់ត្រាចូល ក្នុងគណនីត្រូវ

សង " អ្នកផ្គត់ផ្គង់- វិក្កយបត្រមិនទាន់មកដល់" ដោយកត់ត្រា ខាងឥណពន្ធនៃគណនី ការទិញ។

ខ-ប្រសិនបើវិក្កយបត្រត្រូវបានកត់ត្រា ប៉ុន្តែ ទំនិញមិនទាន់បានទទួលទំនិញនេះត្រូវកត់បញ្ចូលក្នុងសារពើភណ្ឌនៅដំណាច់ឆ្នាំជាប់ពន្ធដោយប្រើប្រាស់គណនី "ស្តុកកំពុងនៅតាមផ្លូវ" ។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

## ១១.៣-ចំណាយសេវាខាងក្រៅ

១-ការជួល ជាអាទិ៍មាន ៖

ក-ការជួលអចលនទ្រព្យឬ ចលនទ្រព្យសម្រាប់បម្រើអាជីវកម្ម៖ ក្នុងនេះអាចមានការបង់ប្រាក់ផ្សេងៗ ដូចខាងក្រោម៖

-ប្រាក់ឈ្នួល និងចំណាយផ្សេងៗទៀត នៃការជួលអចលនទ្រព្យឬ ចលនទ្រព្យសម្រាប់បម្រើអាជីវកម្ម (រួមទាំងអ្វីដែលបានបង់ នៅក្នុងក្របខ័ណ្ឌកិច្ចសន្យានៃភតិសន្យាហិរញ្ញវត្ថុ) អាចកាត់កងបាន នៅក្នុងឆ្នាំជាប់ពន្ធដែលត្រូវសង នូវប្រាក់ឈ្នួលនិងចំណាយទាំងនេះទោះបី ជាការបង់ប្រាក់ជាក់ស្តែងត្រូវបានធ្វើឡើងនៅថ្ងៃណាក៏ដោយ។

-ប្រាក់ឈ្នួលបង់មុន៖ប្រាក់នេះត្រូវកត់ត្រា ខាងទ្រព្យសកម្ម នៃ តារាងតុល្យការទៅក្នុងគណនី "ចំណាយបានកត់ត្រាមុន" ដែលពុំមានផលប៉ះពាល់ដល់លទ្ធផលនៃឆ្នាំជាប់ពន្ធ នៃការបង់ប្រាក់ឡើយ។ ទឹកប្រាក់នេះត្រូវបានកាត់ចេញតែពីលទ្ធផលនៃឆ្នាំជាប់ពន្ធ ដែលចំណាយជួលបានកើតឡើងប៉ុណ្ណោះ។

-ប្រាក់ធានា៖ ប្រាក់ដែលបានបង់ជាប្រាក់ធានា ត្រូវកត់ត្រានៅខាងទ្រព្យសកម្ម

នៃតារាងតុល្យការ។ប្រាក់ជានាអាចមានឥទ្ធិពលតែលើលទ្ធផលនៃឆ្នាំជាប់ពន្ធ ដែលប្រាក់នេះ ត្រូវបានទទួលយ៉ាងពិតប្រាកដដោយម្ចាស់កម្មសិទ្ធិ នៃទ្រព្យជួលតែប៉ុណ្ណោះ។

-សម្រាប់គោលដៅសារពើពន្ធ៖ ប្រាក់ទឹកតែដែលសហគ្រាសបានបង់សម្រាប់ការជួលទ្រព្យ គឺ ជាចំណាយមិនអាចកាត់កងបាន។

ខ-ការជួលកន្លែងស្នាក់នៅប្រាក់ឈ្នួល កន្លែងស្នាក់នៅអាចកាត់កងបានទៅតាមកម្មវត្ថុនៃការប្រើប្រាស់កន្លែងស្នាក់នៅ។ ចំពោះកន្លែងស្នាក់នៅដែលសម្រាប់បម្រើតម្រូវការរបស់និយោជិតសហគ្រាស ប្រាក់ឈ្នួលជាចំណាយដែលអាចកាត់កងបាននិងជាអត្ថប្រយោជន៍បន្ថែមដែលនិយោជិតទទួលបាន។ ចំពោះកន្លែងស្នាក់នៅសម្រាប់បម្រើតម្រូវការផ្សេងទៀតប្រាក់ឈ្នួលគឺ ជាចំណាយមិនអាចកាត់កងបាន។

២-ការងារថែទាំនិងជួសជុលជាគោលការណ៍ត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយចរន្តចំពោះតែការថែទាំជួសជុលណាមួយដែលអាចធ្វើឱ្យទ្រព្យសកម្ម អាចដំណើរការឬ ប្រើប្រាស់បានជាប្រក្រតី ឬដំណើរការបានរហូតដល់ពេលបញ្ចប់នៃរយៈកាលរំលស់របស់វាប៉ុណ្ណោះ។ដោយឡែក ចំពោះការកែលម្អណាមួយ ដែលជាការជួសជុលកែលម្អ ដើម្បីធ្វើឱ្យទ្រព្យសកម្ម មានតម្លៃលើស ឬ បង្កើនផលិតភាព ឬ ពន្យារអាយុកាលប្រើប្រាស់ ឱ្យបានវែងជាងអាយុកាលដែលបានកំណត់ទុកពីដើមដំបូង ត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មជាប់ទាក់ទិន។

៣-ចំណាយធានារ៉ាប់រង៖ ចំណាយដែលបានបង់លើកិច្ចសន្យាធានារ៉ាប់រងហានិភ័យចំពោះទ្រព្យសកម្ម (គ្រោះថ្នាក់ អគ្គិភ័យ ព្យុះ........) ឬ កិច្ចសន្យាធានារ៉ាប់រងបន្ទុកជាយថាហេតុ

(ការទទួលខុសត្រូវខាងពាណិជ្ជកម្ម ឬ វេជ្ជប្បវេណី) ត្រូវបានអនុញ្ញាតឱ្យកាត់កងសម្រាប់ ឆ្នាំជាប់ពន្ធដែលចំណាយនេះបានកើតឡើង (គឺ ត្រូវគណនាតាមចំនួនថ្ងៃ ដែលកិច្ចសន្យាធានារ៉ាប់រងត្រូវគ្របដណ្តប់នៅក្នុងឆ្នាំជាប់ពន្ធ...)

៤-កម្រៃជើងសា និង លាភការខាងក្រៅ៖

ក-កម្រៃជើងសា និង លាភការផ្សេងៗ បានបង់ចំនួនប្រាក់បង់ថ្លៃសេវាដែលបានផ្តល់ឱ្យដល់សហគ្រាសត្រូវបានអនុញ្ញាត ឱ្យកាត់កងតែក្នុងករណីដែលភាពពិត និង ប្រយោជន៍របស់សេវាទាំងនេះត្រូវបានបង្ហាញ ហើយចំនួនទឹកប្រាក់មិនត្រូវបានបំផ្លើស។

ខ-សួយសារ ចំពោះសម្បទាន ប្រកាសនីយបត្រ អាជ្ញាប័ណ្ណ សញ្ញាផលិត សិទ្ធិអ្នកនិពន្ធ សិទ្ធិចម្លង៖សួយសារប្រភេទទាំងនេះអាចកាត់កងបាន ក្នុងករណីដែលមិនមែនជាការចំណាយ លើការទិញទ្រព្យសកម្មណាមួយហើយចំនួនទឹកប្រាក់មិនត្រូវបានបំផ្លើស។

៥-បេសកកម្ម៖ ចំណាយបេសកកម្ម អាចអនុញ្ញាតឱ្យ កាត់កងបានប្រសិនបើបេសកកម្មនេះបម្រើអាជីវកម្មយ៉ាងពិតប្រាកដ ហើយចំនួនទឹកប្រាក់ក៏មិនច្រើនហួសហេតុ ធៀបទៅ នឹងប្រភេទ និង ទំហំរបស់អាជីវកម្ម ឬ ធៀបទៅនឹងប្រាក់ចំណូលសុទ្ធ ដែលសម្រេចបាន។ ចំពោះចំណាយចម្រុះ (ជាអាទិ៍ មានចំណាយធ្វើដំណើរ និង បេសកកម្មដែលមានលក្ខណៈបម្រើអាជីវកម្មផង និងធ្វើទេសចរណ៍កំសាន្តផង) ត្រូវបានអនុញ្ញាតឱ្យកាត់កង តែចំពោះចំណែកណាដែលបម្រើអាជីវកម្មតែប៉ុណ្ណោះ។ ចំណាយធ្វើដំណើរ និង បេសកកម្មទៅបរទេស ឬ ការទៅចូលរួម ឬ

ការរៀបចំ សន្និសិទ្ធិ សិក្ខាសាលា ប្រជុំ..អាចអនុញ្ញាតឱ្យកាត់កងបានប្រសិនបើប្រយោជន៍សម្រាប់សហគ្រាសនៃការចំណាយទាំងនេះ តែត្រូវបានបង្ហាញយ៉ាងច្បាស់លាស់និង មានការជាប់ទាក់ទិនដោយផ្ទាល់ទៅនឹង អាជីវកម្មរបស់សហគ្រាស។

៦-ការទទួលភ្ញៀវការកំសាន្ត ឬ ការសម្រាកលំហែមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេនូវចំណាយលើសកម្មភាព ទទួលភ្ញៀវ កំសាន្ត ឬសម្រាកលំហែ ជាអាទិ៍មាន ការផ្គត់ផ្គង់ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់នៅ ឬបដិសណ្ឋារកិច្ច ណាមួយ ។ (តាមមាត្រា១១ ដល់ ១៨ នៃច្បាប់សារពើពន្ធ )

**១១.៤-ពន្ធនិងអាករ**

១-ពន្ធអាករដែលបានបង់ក្នុងឆ្នាំជាប់ពន្ធ៖

ក-ពន្ធអាករណាមួយដែលត្រូវបានបង់តាមវិធីដាក់លិខិតប្រកាសសារពើពន្ធ និង ជាប្រភេទ ពន្ធ អាករ ដែលអាចកាត់កងបានត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធដែល ពន្ធ អាករ ទាំងនេះត្រូវបានបង់ ឬ ត្រូវបង់។

ខ-ចំពោះ ពន្ធ អាករ ដែលបានបង់ដោយមិនដាក់លិខិតប្រកាសសារពើពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់កង ក្នុងឆ្នាំជាប់ពន្ធដែល ពន្ធ អាករ ទាំងនេះបំពេញបាននូវលក្ខខណ្ឌនានានៃចំណាយអាចកាត់កងបាន។

២-ពន្ធ អាករ អាចកាត់កងបានសម្រាប់គោលដៅ នៃពន្ធលើប្រាក់ចំណូលសហគ្រាស អាចកាត់កងបាននូវពន្ធអាករ ទាំងឡាយដែលសហគ្រាសបានបង់រួមមានពន្ធប៉ាតង់ ពន្ធលើការនាំចូលនិងការនាំចេញ (ពន្ធគយ) អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសា

ជារណៈ អាករលើការស្នាក់នៅ អាករលើជាតុចូលដែលមិនអនុញ្ញាតជា ឥណទាន ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធតែមប្រ៏សារពើពន្ធ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ...។

៣-ពន្ធ អាករ ដែលមិនអាចកាត់កងបានសហគ្រាសមិនអាចកាត់កងបានទេ នូវប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូលនិងពន្ធអប្បបរមានិងពន្ធអាករនានាដែលមិនមែនជាបន្ទុករបស់សហគ្រាស ប៉ុន្តែគឺជាបន្ទុករបស់ អ្នកទទួលចំណូលដែលត្រូវជាប់ពន្ធ (ឧទាហរណ៍ ពន្ធកាត់ទុកទូទៅ ពន្ធលើប្រាក់បៀវត្ស) ។

## ១១.៥-បៀវត្ស និងចំណាយប្រហាក់ប្រហែល

១-លក្ខខណ្ឌនៃការកាត់កង៖ ប្រាក់បៀវត្ស និង អត្ថប្រយោជន៍បន្ថែមអាចអនុញ្ញាតឱ្យកាត់កងបានក្នុងករណីដែលទឹកប្រាក់ទាំងនេះមានលក្ខណៈសមស្របនិងជាប់ទាក់ទិននឹងការងារពិតប្រាកដរបស់និយោជិត។

២-ចំណាយដែលត្រូវកត់ត្រាក្នុងឆ្នាំជាប់ពន្ធ។ ប្រាក់បៀវត្ស និង អត្ថប្រយោជន៍បន្ថែម គឺជាចំណាយប្រចាំឆ្នាំសម្រាប់ អាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យកាត់កង តែក្នុងឆ្នាំជាប់ពន្ធដែលទទួលរងដោយពិតប្រាកដនូវចំណាយនេះប៉ុណ្ណោះ។ ដោយឡែកនៅជំណាច់ឆ្នាំជាប់ពន្ធអាចមានប្រាក់បៀវត្សខ្លះត្រូវបានបើកមុន ឬ មិនទាន់បានបើកឱ្យនិយោជិតដែលបានកត់ត្រា ក្នុងគណនីចំណាយកត់ត្រាមុន ឬ គណនីត្រូវសង។

៣-លាភការផ្សេងៗ ជាទឹកប្រាក់ដែលទទួលបាន ពីការបំពេញការងារក្នុងរយៈពេលកំណត់ណាមួយ ជាអាទិ៍មាន ។

ក-លាភការនៃបុគ្គលិកទទួលបៀវត្ស ដែលមិនមែនជាអ្នកគ្រប់គ្រងដែលមានចែង

លម្អិតនៅពន្ធលើប្រាក់បៀវត្ស ។

ខ-លាភការនៃសមាជិកសហគ្រាសសហកម្មសិទ្ធិ និង ម្ចាស់សហគ្រាសឯកបុគ្គល ដោយសារសមាជិក សហគ្រាសសហកម្មសិទ្ធិ ឬ ម្ចាស់សហគ្រាសឯកបុគ្គល មានសកម្មភាពបំពេញការងារ នៅក្នុងសហគ្រាស និង ដោយហេតុថាប្រាក់ចំណូលរបស់សហគ្រាសជាកម្មសិទ្ធិ ទាំងស្រុងរបស់សមាជិក ឬ ម្ចាស់សហគ្រាស ដូច្នេះចំណាយលើលាភការ ដល់សមាជិក ឬ ម្ចាស់សហគ្រាសមិនត្រូវបានអនុញ្ញាតឱ្យកាត់កង ហើយក៏មិនចាត់ទុកជាការបែងចែកភាគលាភទេ។ ប៉ុន្តែ ក្នុងករណី ដែលរដ្ឋបាលសារពើពន្ធមានមូលដ្ឋានត្រឹមត្រូវ ជឿជាក់ថា ការដកយកជាមុននូវទឹកប្រាក់ណាមួយ ចេញពីប្រាក់ចំណូលអាចធ្វើឱ្យមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចតម្រូវ ឱ្យអ្នកជាប់ពន្ធបង់ពន្ធភ្លាម។

គ-លាភការផ្តល់ឱ្យសមាជិកផ្សេងទៀត នៃក្រុមគ្រួសាររបស់ម្ចាស់សហគ្រាសឯកបុគ្គល៖ លាភការដែលផ្តល់ ឱ្យកូន កូនប្រសារ និងញាតិពន្ធនានា របស់ម្ចាស់សហគ្រាសគឺ អាចកាត់កងបានដរាបណាវាជាថ្នូរ នៃ ការងារពិតប្រាកដ មានចំនួនទឹកប្រាក់មិនបំផ្លើស និង ពិតជាបានទូទាត់ឱ្យជាក់ស្តែងមែន។

ឃ-លាភការរបស់អ្នកគ្រប់គ្រងសហគ្រាសនីតិបុគ្គល៖ ដោយហេតុថាអ្នកគ្រប់គ្រងទាំងនេះមានសិទ្ធិត្រួតពិនិត្យនិងសិទ្ធិសម្រេច លាភការដែលពួកគេបានទទួលអាចមានលក្ខណៈ បំភ្លើស។លក្ខណវិនិច្ឆ័យដូចតទៅដែលអាចប្រើប្រាស់បានសម្រាប់បញ្ជាក់បង្ហាញ និង កំណត់ចំនួននៃការបំផ្លើសនេះ (ភាគនៃលាភការដែលត្រូវបានចាត់ទុកថាជាការបំផ្លើស គឺជាចំណាយមិនអាច កាត់កងបាន)៖

-សារៈប្រយោជន៍ នៃ សកម្មភាពដែលបានបំពេញដោយអ្នកគ្រប់គ្រង និង ការទទួលខុសត្រូវដែល ត្រូវបានប្រគល់ឱ្យអ្នកគ្រប់គ្រងនោះ

-ការវិវត្ត នៃ ប្រាក់ចំណូលរបស់សហគ្រាស

-ទំហំសហគ្រាស

-ការប្រៀបធៀបលាភការនេះ ជាមួយ នឹង លាភការ ដែលបានផ្តល់ឱ្យអ្នកគ្រប់គ្រងសហគ្រាស ដែលមានការងារស្រដៀងគ្នា នៅក្នុងសហគ្រាសមានអាជីវកម្មប្រហាក់ប្រហែលគ្នា នៅក្នុងតំបន់ ឬ ជាមួយនឹងលាភការ ដែលបានផ្តល់ឱ្យនិយោជិតដែលមានឋានៈ និង តួនាទីនៅក្នុងសហគ្រាស។

-ការប្រៀបធៀបរវាង លាភការ សរុបដែលបានផ្តល់ឱ្យទៅអ្នកគ្រប់គ្រង និងបៀវត្សដែលបានផ្តល់ឱ្យបុគ្គលិកទាំងអស់ ដែលត្រូវទទួលបៀវត្ស។

៤-ត្រូវបានចាត់ទុកថាបានចាយក្នុងឆ្នាំជាប់ពន្ធ ប្រសិនបើមានការកត់ត្រាខាងឥណពន្ធនៃគណនីចំណាយ និងកត់ត្រាខាងឥណទាន នៃគណនីសមាគត(អ្នកចូលហ៊ុន) ឬគណនីបុគ្គលទាក់ទិន។ ពាក្យ " ឥណទាន " និង " ឥណទានបានកត់ត្រា " សំដៅដល់ហេតុការណ៍ដែលសហគ្រាសបានកត់ត្រាជាមុននូវ បំណុលសម្រាប់ទូទាត់ឱ្យម្ចាស់បំណុល អនិវាសនជន ដែលក្នុងនោះមាន៖

ក-ការទូទាត់ប្រាក់ទៅឱ្យអ្នកជួល ឬ ភ្នាក់ងារតាមរយៈគណនីធនាគារ ក្នុងនាមម្ចាស់សហគ្រាសជាអនិវាសនជន។

ខ-ការទូទាត់ការប្រាក់ទៅក្នុងគណនីសន្សំរបស់អ្នកជាប់ពន្ធអនិវាសនជន

គ-ការតម្កល់ប្រាក់សោធននិវត្តន៍ ឬ ប្រាក់បំណាច់ជាប្រចាំឆ្នាំ របស់ក្រុមហ៊ុនជានា

រ៉ាប់រង ឬ ក្រុមហ៊ុនបរធនបាល ទៅក្នុងគណនីធនាគាររបស់អ្នកជាប់ពន្ធអនិវាសនជន។

ឃ-ការកាត់កងទឹកប្រាក់ដែលត្រូវទូទាត់ ដោយអ្នកជាប់ពន្ធនិវាសនជន (ឬ អ្នកដែលត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធនិវាសនជន) នូវទឹកប្រាក់ដែលអ្នកជាប់ពន្ធអនិវាសនជនជំពាក់។

ង-ចំនួនទឹកប្រាក់ដែលបានកត់ត្រាជាឥណទានទៅក្នុងគណនីសមាគត។

៥-ចំណាយខាងសង្គមកិច្ចទាំងឡាយណាដែលបានប្បញ្ញត្តនៅក្នុងច្បាប់ស្តីពីការងារគឺអាចកាត់កងបាន។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

## ១១.៦-ការប្រាក់

ការប្រាក់សំដៅ ដល់ទឹកប្រាក់ដែលជាកាតព្វកិច្ចបំណុល ដែលកូនបំណុលត្រូវបង់ឱ្យម្ចាស់បំណុលរួមបញ្ចូលទាំងប្រាក់ចុះថ្លៃបុព្វលាភ ឬ ការទូទាត់ប្រហាក់ប្រហែលលើកលែងតែការបង្វិលសងប្រាក់ដើម។ ការប្រាក់អាចជាតម្លៃ នៃការយល់ព្រមមិនទាមទារឥណទានដែលបានផ្តល់ឱ្យជាទំនិញឬ សេវាដែលកូនបំណុលត្រូវសងម្ចាស់បំណុល។ កាតព្វកិច្ចបំណុលសំដៅដល់កាតព្វកិច្ចទូទាត់សងជាសាច់ប្រាក់ឬជាវត្ថុទៅឱ្យបុគ្គលម្នាក់ទៀត រួមបញ្ចូលទាំងកាតព្វកិច្ចរបស់ធនាគារចំពោះប្រាក់បញ្ញើ កាតព្វកិច្ចចំពោះសមតុល្យ ក្នុងគណនីត្រូវសង រូបិយាណត្តិ សញ្ញាប័ណ្ណ...។ ការប្រាក់ជាអាទិ៍មាន ៖

១-ការប្រាក់នៃប្រាក់ខ្ចីពីតតិយជន៖

ក-ការប្រាក់ នៃ ប្រាក់ដែលសហគ្រាសខ្ចី ពីតតិយជនសម្រាប់បម្រើតម្រូវការក្នុងអាជីវកម្មត្រូវបានអនុញ្ញាតឱ្យកាត់កង ក្នុងឆ្នាំជាប់ពន្ធដែលការប្រាក់ក្លាយជា

បំណុលត្រូវសង។ក្នុងនេះសហគ្រាសត្រូវបង្ហាញឱ្យឃើញនូវភាពពិតនៃប្រាក់ខ្ចី ដោយត្រូវមានភ័ស្តុតាងអាចត្រួតពិនិត្យបាន ដូចជាកិច្ចសន្យាខ្ចីប្រាក់ដែលមានកាលបរិច្ឆេទជាក់លាក់ និង ដែលមានកំណត់ច្បាស់លាស់នូវបែបបទ នៃការសងប្រាក់ដើម និង ការប្រាក់។

ខ-ការប្រាក់ នៃ ប្រាក់ខ្ចីពីតតិយជនសម្រាប់តម្រូវការផ្ទាល់ខ្លួន របស់ម្ចាស់សហគ្រាស មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។ចំពោះសហគ្រាសឯកបុគ្គល ស្ថានភាព នេះកើតមានឡើងកាលប្រសិនបើ គណនីម្ចាស់សហគ្រាសមានសមតុល្យឥណាយិក (សមតុល្យចុងគ្រានៃគណនីម្ចាស់សហគ្រាស នៃ ឆ្នាំជាប់ពន្ធណាមួយគឺ ត្រូវស្មើនឹងសមតុល្យដើមគ្រា នៃឆ្នាំជាប់ពន្ធនោះដកចេញនូវការបន្ថែមដើមទុន និង ចំណេញក្នុងឆ្នាំជាប់ពន្ធហើយបូកបញ្ចូល នូវការខាតនៅក្នុងឆ្នាំជាប់ពន្ធ និង ការដកយកទៅប្រើប្រាស់មុនរបស់ម្ចាស់សហគ្រាស...)។ ស្ថានភាពនេះសគ្រាសអាចត្រូវធ្វើការខ្ចីបុល ដើម្បីទប់ទល់នឹងកង្វះខាតសាច់ប្រាក់ដែលបណ្តាលមកពីការដកយកមកប្រើប្រាស់ ជាមុនរបស់ម្ចាស់សហគ្រាស នូវ ទឹកប្រាក់លើសពីចំនួនដែលសហគ្រាសចំណេញ ឬ សហគ្រាសមានការខាតបង់ក្នុងឆ្នាំជាប់ពន្ធ ក្នុងករណីនេះ ការប្រាក់អាចកាត់កងបាន គឺកម្រិតត្រឹមតែការប្រាក់ដែលទាក់ទិននឹងចំណែកនៃការខ្ចី ដែលលើសពីតួលេខសមតុល្យ ឥណាយិកខ្ពស់បំផុត ក្នុងឆ្នាំជាប់ពន្ធ នៃ គណនីម្ចាស់សហគ្រាសតែប៉ុណ្ណោះ។

២-ទឹកប្រាក់នានាដែលបានទូទាត់ឱ្យសម្រាប់ជា លាភការ នៃដើមទុនផ្ទាល់របស់សហ

គ្រាស ឬការប្រាក់សងឱ្យគណនី ម្ចាស់សហគ្រាសឯកបុគ្គល មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។

៣-កំហិតលើការកាត់កង ការប្រាក់ កំហិតលើការកាត់កង ការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ គឺជាចំនួនទឹកប្រាក់ ការប្រាក់អតិបរមាដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធនោះ និង ត្រូវ **គណនាតាមរូបមន្ត "ក + ខ" ដែលៈ**

**ក** = ចំណូលការប្រាក់ដែលបានទទួល ឬត្រូវបានទទួលនៅក្នុងឆ្នាំជាប់ពន្ធ

**ខ** =៥០% នៃប្រាក់ចំណូលសុទ្ធដោយមិនគិតពីចំណូលការប្រាក់ និង ចំណាយការប្រាក់ ការប្រាក់អនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនានៅដំណាច់ឆ្នាំជាប់ពន្ធនោះ។ ចំណាយការប្រាក់ដែលមិនត្រូវបានអនុញ្ញាតឱ្យកាត់កង ក្នុងឆ្នាំជាប់ពន្ធចរន្ត អាចយោងជាចំណាយការប្រាក់ សម្រាប់ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀត នៅក្នុងកំហិតដូចគ្នារហូតដល់ឆ្នាំជាប់ពន្ធទី ៥ គិតតាមលំដាប់ឆ្នាំដែលការប្រាក់បានកើតឡើង។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

**១១.៧-ចំណាយពិសេស**

១-ទោសទណ្ឌនានារួមមាន ពន្ធបន្ថែម ការប្រាក់ យឺតយ៉ាវ និង ប្រាក់ពិន័យផ្សេងៗ ដែលសហគ្រាសបានទទួលរងដោយសារការមិនអនុវត្តត្រឹមត្រូវតាមច្បាប់ និង បទប្បញ្ញត្តិនានា មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។ ទោសទណ្ឌទាំងនោះ ជាអាទិ៍មានៈ

ក-ពន្ធបន្ថែម និង ការប្រាក់យឺតយ៉ាវពីការមិនគោរពកាតព្វកិច្ចសារពើពន្ធ

ខ-ប្រាក់ពិន័យខាងគយ

គ-ប្រាក់ពិន័យពីការល្មើសបទប្បញ្ញត្តិច្បាប់ស្តីពីថ្លៃ ឬ បទប្បញ្ញត្តិខាងសេដ្ឋកិច្ច

ឃ-ប្រាក់ពិន័យអនុវត្តលើបទល្មើសផ្ទាល់ខ្លួនរបស់បុគ្គល

ង-ប្រាក់ពិន័យដែលជាការដាក់ទោសចំពោះការល្មើសនឹងបទប្បញ្ញត្តិសាធារណៈ

២-វិភាគទានសប្បុរសធម៌៖ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូលវិភាគទានសប្បុរសធម៌ សំដៅដល់វិភាគទានជាសាច់ប្រាក់ ឬ ក៏ជាវត្ថុ ឱ្យដល់សកម្មភាពមិនស្វែងរកចំណេញមាន ដូចមាននៅក្នុងកថាខណ្ឌ ២ នៃ ចំណុចទី **៦** ខាងលើនេះ កម្រិត នៃ ការអនុញ្ញាតឱ្យកាត់កងវិភាគទានសប្បុរសធម៌ដូចមានចែងដូចខាងក្រោម ៖

ក-ចំនួនទឹកប្រាក់វិភាគទានសប្បុរសធម៌ ដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធណាមួយមិនត្រូវឱ្យលើសពី៥ ភាគរយ នៃ ប្រាក់ចំណូលសុទ្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌។

ខ-ចំពោះទឹកប្រាក់វិភាគទានសប្បុរសធម៌ ដែលនៅសល់ពីការកាត់កងដូចមានចែងនៅក្នុងចំណុច " **ក** " មិនត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កង នៅឆ្នាំជាប់ពន្ធណាមួយផ្សេងទៀតបានទេ គឺ ត្រូវក្លាយជាចំណាយមិនអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធដែលទឹកប្រាក់នេះបានកើតឡើង។

៣-អំណោយ៖ អំណោយដែលសហគ្រាសធ្វើឡើង ជាចំណាយមិនអាចកាត់កងបាន

៤-ឧបត្ថម្ភកធនផ្សេងៗ៖ ឧបត្ថម្ភកធន សំដៅដល់ប្រាក់ ប៉ះប៉ូវ សម្រាប់បំពេញថ្លៃទៅសម្រាលបន្ទុក អាជីវកម្មជានាលំនឹងអាជីវកម្មដែលសហគ្រាសបានធ្វើ ទោះបីក្នុងគោលដៅបែបណាក៏ដោយមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។

៥-ការខាតលើឥណទេយ្យ គឺ ជាការទទួលស្គាល់ជាចំណាយរបស់សហគ្រាសចំពោះបំណុលមិនអាចទារបាន។ សម្រាប់គោលដៅ នៃពន្ធលើប្រាក់ចំណូលចំណាយនេះអាចអនុញ្ញាតឱ្យកាត់កងបាន តែនៅក្នុងករណីដែលភាពមិនអាចទារបាននៃបំណុលនេះ ត្រូវបានបញ្ជាក់បង្ហាញ

ដោយជាក់ស្តែង (ឧទាហរណ៍៖ការព្យាយាមបង្ហាញឯកសារប្រមូលបំណុល ឬមានភស្តុតាងច្បាស់លាស់ នៃការខិតខំព្យាយាមក្នុងការប្រមូល ឬទទួលបានទឹកប្រាក់ដែលជំពាក់ ដោយអសាធនភាពជាស្ថាពររបស់កូនបំណុល...) ហើយបំណុលនោះត្រូវបានលុបចេញពីបញ្ជីគណនេយ្យរបស់សហគ្រាស។ ជាទូទៅការបោះបង់ចោលនូវបំណុលជាទង្វើមិនប្រក្រតី នៃការគ្រប់គ្រងដែលមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។

៦-ចំណាយពិសេសផ្សេងៗ ការបាត់បង់ផ្សេងៗ និង ចំណាយដទៃទៀតតាមធម្មតាគឺអាចកាត់កងបានតែក្នុងករណីដែលការបាត់បង់និងចំណាយទាំងនេះកើតមានឡើងក្នុងក្របខ័ណ្ឌនៃដំណើរការអាជីវកម្មធម្មតារបស់សហគ្រាស។ ដោយឡែកចំពោះការបាត់បង់និងចំណាយណាមួយដែលទាក់ទិននឹងទង្វើ មិនធម្មតា នៃ ការគ្រប់គ្រងគឺមិនអាចកាត់កងបានទេ។ ម្យ៉ាងវិញទៀតត្រូវជានាថា ការបាត់បង់និងចំណាយទាំងនេះ មិនត្រូវបានកាត់កងរួចហើយ តាមរបៀបណាមួយផ្សេងទៀតនោះទេ (ឧទាហរណ៍៖ ការបាត់បង់ទំនិញដោយសារចោរកម្ម ឬ គ្រោះមហន្តរាយពុំត្រូវមានការកាត់កងអ្វីដោយឡែកនោះទេ ពីព្រោះការបាត់បង់នេះ ត្រូវបានគិតបញ្ចូលមកកាត់កងជាស្វ័យប្រវត្តិតាមយន្តការនៃការធ្វើគណនេយ្យកម្ម ការទិញ ការលក់ និង ស្តុក) ។ (មាត្រា១២៨ ដល់ ១៣៥ នៃច្បាប់សារពើពន្ធ)

## ១២-វិធានទូទៅស្តីពីរំលស់

### ១២.១-រំលស់ និងលក្ខខណ្ឌរំលស់

រំលស់ និង លក្ខខណ្ឌរំលស់ ត្រូវបានកំណត់ដូចខាងក្រោម៖

១-លទ្ធកម្ម (ការទិញ ការទទួលបាន ការបញ្ចូល...) នៃ ទ្រព្យសកម្មរយៈពេលវែង ពុំបណ្តាលឱ្យមានការថយចុះ នៃ ទ្រព្យសកម្មសុទ្ធទេ ពីព្រោះការចំណាយត្រូវបានជាថ្នូរបញ្ចូលមក

វិញ នៅក្នុងទ្រព្យសកម្មរបស់សហគ្រាស នូវទ្រព្យសកម្មថ្មីមួយ ដែលពុំមានឥទ្ធិពលដល់លទ្ធផលជាប់ពន្ធឡើយ។ទ្រព្យសកម្មរយៈពេលវែង តែងតែត្រូវសឹករេចដោយការប្រើប្រាស់ និង ដោយអាយុកាលឬភាពហួសសម័យហើយការសឹករេចនេះ គឺជាចំណាយពិតប្រាកដមួយដែលត្រូវអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធរបស់សហគ្រាសតាមរយៈការធ្វើរំលស់។

២-រំលស់ គឺ ជាការកត់ត្រាអំពីការសឹករេចនៃទ្រព្យសកម្ម ដែលបណ្តាលមកពីការប្រើប្រាស់ ពេលវេលាប្រើប្រាស់ ការផ្លាស់ប្តូរបច្ចេកវិទ្យា ឬ ពីមូលហេតុផ្សេងទៀតដោយធ្វើការបែងចែកបរិយាទាននៃទ្រព្យសកម្មទៅតាមរយៈពេលគ្រោងទុកនៃការប្រើប្រាស់(អាយុកាលប្រើប្រាស់) ដែលផ្អែកតាមផែនការរំលស់មួយ។ រាល់ការកែប្រែធំដុំក្នុងលក្ខខណ្ឌ នៃការប្រើប្រាស់ទ្រព្យសកម្មតម្រូវឱ្យមានការសើរើផែនការរំលស់ដែលកំពុងអនុវត្ត។

៣-សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល រំលស់ដែលអាចកាត់កងបានត្រូវបំពេញលក្ខខណ្ឌ៥ ដូចខាងក្រោម ៖

ក-រំលស់ត្រូវធ្វើតែលើទ្រព្យសកម្មរយៈពេលវែង ដែលបានកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់សហគ្រាស

ខ-រំលស់ត្រូវធ្វើតែលើទ្រព្យសកម្មរយៈពេលវែង ដែលទទួលរងការសឹករេច

គ-រំលស់ត្រូវធ្វើលើមូលដ្ឋាន និង ក្នុងដែនកំណត់នៃថ្លៃដើម

ឃ-រំលស់ត្រូវគណនាតាមវិធីដូចមានចែងក្នុង **១២.២** ដល់ **១២.៦** នៃចំណុចខាងក្រោមនេះ។

ង-រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស ប៉ុន្តែ ដោយឡែកដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ។

៤-ក្នុងការកំណត់ប្រាក់ចំណូលជាប់ពន្ធ ការកាត់កងរំលស់ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យសកម្មរូបី ឬ អ្នកជួលទ្រព្យសកម្មរូបី ក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ ឬ ការខូចខាតនៃទ្រព្យ។ ជាធម្មតាចំពោះភតិសន្យាហិរញ្ញវត្ថុ ភតិកៈជាអ្នកទទួលរងនូវហានិភ័យខាងលើ។(តាមមាត្រា ១៣ នៃច្បាប់សារពើពន្ធ)

## ១២.២-ទ្រព្យសកម្មរយៈពេលវែងដែលអនុញ្ញាតឱ្យធ្វើរំលស់

១- សហគ្រាសត្រូវធ្វើរំលស់ តែលើទ្រព្យសកម្មរយៈពេលវែង ដែលកត់ត្រា ក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់ខ្លួន។ ទ្រព្យសកម្មរយៈពេលវែង គឺជាចំណែក (ឬសមាសភាគ) នៃទ្រព្យសកម្ម សម្រាប់ប្រើប្រាស់យូរអង្វែង នៅក្នុងសកម្មភាពអាជីវកម្ម និង រក្សាបាននូវរូបរាងដើមដដែលចាប់ពីពេលដាក់ប្រើប្រាស់រហូតដល់ពេលឈប់ប្រើការ។ អាចចាត់ទុកទ្រព្យសកម្មណាមួយជាទ្រព្យសកម្មរយៈពេលវែង ប្រសិនបើទ្រព្យសកម្មនោះមានលក្ខណៈស្រប តាមលក្ខណវិនិច្ឆ័យទាំងពីរដូចខាងក្រោម៖

ក-គោលដៅ៖ ទ្រព្យសកម្មគ្រប់ប្រភេទ (ទ្រព្យសកម្មអរូបី ឬទ្រព្យសកម្មរូបី) ដែលសហគ្រាសបានទិញបានផលិត មិនមែនសម្រាប់បំប្លែងភាពដើម្បីលក់ ឬ មិនមែនសម្រាប់លក់ ឬ សម្រាប់ប្រើប្រាស់យូរអង្វែង (ឧទាហរណ៍៖រថយន្តដែលសហគ្រាសលក់រថយន្ត ទិញមកសម្រាប់លក់ទៅវិញ គឺ ជាចំណែកមួយនៃការទិញនិងស្តុក រី ឯរថយន្តសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាស គឺជាទ្រព្យសកម្មរយៈពេលវែង) ទ្រព្យសកម្មទាំងនេះអាចលក់ទៅវិញបាន តែក្នុងករណីនៅក្រោយពេលបានប្រើប្រាស់រួចហើយ។

ខ-រយៈពេល៖ ការរក្សាទុកទ្រព្យសកម្មនៅក្នុងអង្គភាពអាជីវកម្ម ត្រូវបានកំណត់

ថាជាប់លាប់ប្រសិនបើមានរយៈពេលលើសពី១ឆ្នាំ ដោយគិតចាប់តាំងពីពេលដាក់ប្រើប្រាស់ដំបូង។

២-ភាពខុសគ្នារវាងទ្រព្យសកម្មរយៈពេលវែង និង ចំណាយដែលមានថ្លៃជាការបញ្ចូលនូវចំណែកថ្មីមួយទៅក្នុងទ្រព្យសកម្មនៃសហគ្រាសគឺ ជាទ្រព្យសកម្មរយៈពេលវែង។ ចំពោះចំណាយទាក់ទិននឹងទ្រព្យសកម្មដែលបានកត់ត្រារួចហើយ នៅក្នុងតារាងតុល្យការសហគ្រាសត្រូវអនុវត្តតាមចំណុច **១២.៦** ខាងក្រោមនេះ។

៣-ទ្រព្យសកម្មរយៈពេលវែងត្រូវបានបែងចែកដូចខាងក្រោម៖

ក-ទ្រព្យសកម្មអរូបី៖ ទ្រព្យសកម្មអរូបីដែលអាចរំលស់បាន ជាអាទិ៍មាន៖

-ចំណាយបង្កើតសហគ្រាស

-ចំណាយស្រាវជ្រាវនិងអភិវឌ្ឍន៍៖ គឺជាចំណាយនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ដែលសហគ្រាសបានធ្វើឡើង សម្រាប់បម្រើការងារអាជីវកម្ម។ ដូចគ្នានឹងចំណាយបង្កើតសហគ្រាសដែរ ចំណាយនេះគឺ ជាចំណាយគ្មានថ្លៃមកវិញនៅក្នុងទ្រព្យសកម្មរបស់សហគ្រាសទេ។ គណនីទាំងឡាយដែលសម្រាប់កត់ត្រានូវចំណាយទាំងនេះគឺជាគណនីទ្រព្យសកម្មដែលគ្មានតម្លៃពិតប្រាកដ។ ដូច្នេះក្នុងការកត់ត្រា ជាទ្រព្យសកម្មរយៈពេលវែង នូវគម្រោងការស្រាវជ្រាវ និង ការអភិវឌ្ឍន៍ណាមួយ គម្រោងការនោះត្រូវអាចសម្គាល់ និងញែកដាច់តែឯងបាន និង ត្រូវមានរំពឹងយ៉ាងមុតមាំ ក្នុងការទទួលផលខាងពាណិជ្ជកម្ម...។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូលចំណាយ នេះអាចកាត់ចេញទាំងស្រុងបានពីលទ្ធផលនៃការិយបរិច្ឆេទដែលចំណាយបានកើតឡើង។

-ប្រកាសនីយបត្រ ពាណិជ្ជសញ្ញា អាជ្ញាប័ណ្ណសម្បទានកម្មវិធីប្រើប្រាស់កុំព្យូទ័រ (ចំណែកដែលមានច្បាប់ការពារ)

-មូលនិធិពាណិជ្ជកម្ម

-សិទ្ធិធ្វើអាជីវកម្ម

-ទ្រព្យសកម្មរយៈពេលវែងអរូបីផ្សេងទៀត

ទ្រព្យសកម្មអរូបីដែលមិនអាចរំលស់បានជាអាទិ៍មាន៖មូលបត្រភាគកម្មទ្រព្យសកម្មរយៈពេលវែង ហិរញ្ញវត្ថុផ្សេងៗ និង សិទ្ធិប្រើប្រាស់ ដី ។

ខ-ទ្រព្យសកម្មរូបី៖ ទ្រព្យសកម្មរូបីត្រូវបានបែងចែកជា ៤ ថ្នាក់ ដូចខាងក្រោម៖

-ទ្រព្យថ្នាក់១៖ រួមមាន សំណង់នានា រួមបញ្ចូលទាំង អគារ រចនាសម្ព័ន្ធ របស់អគារសំណង់ដែលជា សមាសភាគនៃអគារ ផ្លូវថ្នល់ ផ្លូវដែក នាវាដឹកជញ្ជូន

-ទ្រព្យថ្នាក់២៖ រួមមាន កុំព្យូទ័រ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឧបករណ៍អេឡិចត្រូនិក និង បរិក្ខារទុកដាក់ទិន្នន័យ

-ទ្រព្យថ្នាក់៣៖ រួមមាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារិម និង បរិក្ខារការិយាល័យ

-ទ្រព្យថ្នាក់៤៖រួមមានរាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីដទៃផ្សេងៗ ទៀតក្រៅពីទ្រព្យក្នុង ថ្នាក់ ១ ថ្នាក់ ២ និង ថ្នាក់ ៣។

ក្នុងករណីទ្រព្យសកម្មរូបីណាមួយដែលមានលក្ខណៈពិសេស អគ្គនាយកដ្ឋានពន្ធដារអាចកំណត់វិធីរំលស់ដោយឡែកបាន។

## ១២.៣-វិធីកត់ត្រាទ្រព្យសកម្មរយៈពេលវែង

១-ចំពោះទ្រព្យសកម្មអរូបី និងទ្រព្យសកម្មនៅក្នុងថ្នាក់១ សហគ្រាសត្រូវកត់ត្រាដោយដែកតាមគណនីទ្រព្យសកម្មនីមួយៗ នូវទឹកប្រាក់ដែលជាប់ទាក់ទិន ទៅនឹងទ្រព្យសកម្មនោះ (ថ្លៃទិញ ទឹកប្រាក់កាត់បន្ថយ ទឹកប្រាក់បង្វិលសងវិញ ការកែលម្អជាប់លាប់) ។

២-ចំពោះប្រភេទទ្រព្យសកម្មរូបី ក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤ សហគ្រាសត្រូវកត់ត្រាក្នុងគណនីទ្រព្យសកម្មរួមសម្រាប់ថ្នាក់នីមួយៗ ហើយត្រូវកត់ត្រាចូលនូវចំនួនទឹកប្រាក់ ដែលមិនទាន់បានធ្វើរំលស់ចំនួនទឹកប្រាក់ទាំងអស់ ដែលទាក់ទិននឹងលទ្ធកម្មបន្ថែម នូវ ទ្រព្យសកម្ម (ការទិញបន្ថែម ការទទួលបន្ថែម ការបញ្ចូលបន្ថែម) និង ចំនួនទឹកប្រាក់ទាំងអស់ដែលទាក់ទិននឹងការបញ្ចេញទ្រព្យសកម្មក្នុងឆ្នាំជាប់ពន្ធ។

៣-ធនធានធម្មជាតិ៖ ចំណាយនានាក្នុងការស្វែងរុករក និង អភិវឌ្ឍន៍រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការស្វែងរុករកនិងអភិវឌ្ឍន៍ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីធនធានធម្មជាតិ។

៤-កសិកម្មរយៈពេលវែង(ទ្រព្យសកម្មជីវសាស្ត្រ)

ក-ដំណាំកសិកម្ម៖ ត្រូវកត់ត្រាបង្គរ ទៅក្នុងគណនីទ្រព្យសកម្ម ជីវសាស្ត្រមាន ចំណាយនានាក្នុងការអភិវឌ្ឍន៏ ចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការដាំដុះ រួមទាំងចំណាយការប្រាក់ទាក់ទិន នឹងការអភិវឌ្ឍ និង ការដាំដុះ និង ចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការដាំដុះ។

ខ-ការចិញ្ចឹមសត្វ៖ ត្រូវកត់ត្រាបង្គរ ទៅក្នុងគណនីទ្រព្យសកម្ម ជីវសាស្ត្រនូវ ចំណាយនានាក្នុងការអភិវឌ្ឍន៏ ចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការចិញ្ចឹមសត្វ រួមទាំងចំណាយការប្រាក់ទាក់ទិនការអភិវឌ្ឍន៏ និង ការចិញ្ចឹមសត្វ និងចំណាយ

រៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការចិញ្ចឹមសត្វ។

៥-ក្នុងករណីទ្រព្យសកម្មរយៈពេលវែង ត្រូវបានប្រើប្រាស់នៅក្នុងអាជីវកម្មផងនិង ប្រើប្រាស់ក្រៅអាជីវកម្មផង សហគ្រាសត្រូវអនុវត្តដូចខាងក្រោម៖

ក-ការប្រើប្រាស់ទ្រព្យសកម្មរយៈពេលវែង សម្រាប់បម្រើតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស ឬ ផ្តល់ឱ្យនិយោជិត ឬតតិយជនត្រូវចាត់ទុកថាបានផ្គត់ផ្គង់សេវាតាមតម្លៃទីផ្សារ (កត់ត្រាចូលក្នុងចំណូលបន្ទាប់បន្សំ)។ ក្នុងករណីនេះការផ្តល់ឱ្យនិយោជិតត្រូវបានអនុញ្ញាត ជាចំណាយកាត់កងបាន និង ត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម។

ខ-ចំពោះសហគ្រាសឯកបុគ្គល ឬ សហគ្រាសសហកម្មសិទ្ធិ ការប្រើប្រាស់ដី និងអគារផ្ទាល់ខ្លួនសម្រាប់ធ្វើអាជីវកម្ម សហគ្រាសមិនត្រូវកត់ត្រាចូលក្នុង តារាងតុល្យការ ហើយក៏មិនត្រូវបានចាត់ទុកជាការជួលដែរ។ ក្នុងករណីសហគ្រាសបានកត់ត្រាចូលក្នុងតារាងតុល្យការ ចំណាយរំលស់មិនត្រូវបាន អនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធឡើយ ហើយមិនត្រូវចាត់ទុកថា បានលក់ទៅនៅពេលឈប់ប្រើប្រាស់ក្នុងអាជីវកម្ម។ សម្រាប់គោលដៅ នៃចំណុចខាងលើនេះម្ចាស់ដី និងអគាររួមបញ្ចូលបុគ្គលទាំងឡាយដែលមានឈ្មោះក្នុងសៀវភៅគ្រួសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

គ-ចំពោះសហគ្រាសដែលបានអនុវត្តតាមវិធានដូចមានចែងក្នុងចំណុច " **៣** " នៃការប្រើប្រាស់ចម្រុះនូវទ្រព្យសកម្មរយៈពេលវែង ការកត់ត្រាក្នុងតារាងតុល្យការពុំមានផលប៉ះពាល់អ្វីដល់ការធ្វើរំលស់ទេ។(តាមមាត្រា១៤ ១៥ ១៦ ចព)

## ១២.៤-រំលស់ត្រូវធ្វើនៅលើមូលដ្ឋាន និងក្នុងដែនកំណត់ថ្លៃ

១-រំលស់ត្រូវធ្វើលើមូលដ្ឋាន នៃថ្លៃដើម នៃទ្រព្យសកម្មដែលត្រូវរំលស់។ ទឹកប្រាក់បូកយោងនៃរំលស់ទ្រព្យសកម្មណាមួយ មិនអាចលើសពីថ្លៃដើមនៃទ្រព្យសកម្មនោះបានទេ ទោះបីការវាយតម្លៃឡើងវិញធំជាងថ្លៃដើមក៏ដោយ។ ថ្លៃដើមគឺជាតម្លៃពីដំបូងនៃទ្រព្យសកម្មនៅពេលនិងនៅទីកន្លែងដែលទ្រព្យសកម្មនោះ ត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ បញ្ចូលទៅក្នុងទ្រព្យរបស់សហគ្រាស។ ថ្លៃដើមនៃទ្រព្យសកម្មហៅថាបរិយាទានប្រវត្តិសាស្រ្ត ដែលជាគោលការណ៍មិនអាចកែប្រែបានឡើយ។

២-ថ្លៃដើម ឬ បរិយាទានប្រវត្តិសាស្រ្ត នៃទ្រព្យសកម្មដែលត្រូវបញ្ចូល ជាទ្រព្យរបស់សហគ្រាសត្រូវបានកំណត់ដូចខាងក្រោម ៖

ក-ចំពោះទ្រព្យសកម្មដែលសហគ្រាសបានទិញត្រូវបានកំណត់តាមថ្លៃទ្រព្យដែលបានទិញដោយ៖

-ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យ នូវថ្លៃទិញដកចេញនូវការបញ្ចុះថ្លៃ បូកបញ្ចូលនូវ ចំណាយបន្ទាប់បន្សំផ្សេងៗ (ពន្ធគយ និង ចំណាយជាប់ទាក់ទិន ការដឹកជញ្ជូនចំណាយឆ្លងកាត់ និង ឃ្លាំងស្តុក ចំណាយទទួលទ្រព្យសកម្មរយៈពេលវែងមានការលើកដាក់ធានារ៉ាប់រងលើការដឹកជញ្ជូន........) និង ចំណាយផ្គុំដំឡើងដែលចាំបាច់ក្នុងការដាក់ទ្រព្យសកម្មឱ្យដំណើរការ។

-ចំណាយទូទៅនិងចំណាយហិរញ្ញវត្ថុ ទាក់ទិននឹងទ្រព្យសកម្ម រយៈពេលវែង មិនត្រូវគិតបញ្ចូលក្នុងថ្លៃដើមនៃការទិញទេ។

-ក្នុងករណីមានការពន្យារពេលទូទាត់ តម្លៃទ្រព្យសកម្ម ដែលត្រូវកត់ត្រា ត្រូវ

ផ្អែកលើថ្លៃព្រមព្រៀង ដូច្នេះគឺ ពុំទាក់ទិនទៅនឹងបែបបទនៃការទូទាត់នៅថ្ងៃក្រោយឡើយ ទោះបីតម្លៃត្រូវសងកើនឡើង ឬ ថយចុះក៏ដោយ។

ខ-ចំពោះទ្រព្យសកម្ម ដែលសហគ្រាសបានផលិត ត្រូវកំណត់តាមថ្លៃដើមផលិតកម្មដោយៈ

-ត្រូវកត់ត្រាក្នុងបញ្ជី គណនេយ្យតាមតម្លៃពិត នៃផលិតកម្ម ដែលជាថ្លៃដើមនៃការទិញវត្ថុធាតុនិងសម្ភារៈផ្គត់ផ្គង់ដែលបានប្រើប្រាស់ បូកបន្ថែមនូវ ចំណាយផ្ទាល់ទាំងអស់ (ចំណាយពលកម្ម ចំណាយសេវា ខាងក្រៅ) និង ចំណាយប្រយោលនៃផលិតកម្មក្នុងលក្ខណៈ ដែលចំណាយទាំងនោះអាចកំណត់បាន និងសមហេតុសមផលទៅក្នុងថ្លៃដើមផលិតកម្ម នៃ ទ្រព្យសកម្មនោះ។ ថ្លៃដើមនៃផលិតកម្ម ត្រូវបានគណនាទៅតាមគណនេយ្យថ្លៃដើម ឬប្រសិនបើគ្មានគណនេយ្យថ្លៃដើមទេ ត្រូវគណនាតាមវិធីគណនាស្ថិតិ។

-ថ្លៃដើមផលិតកម្មមិនត្រូវរួមបញ្ចូលទេ នូវចំណាយលើ ការស្តុក ការលក់ និងការគ្រប់គ្រងទូទៅការស្រាវជ្រាវ និងអភិវឌ្ឍន៍ និង ចំណាយហិរញ្ញវត្ថុ។ ដោយឡែកចំពោះថ្លៃដើមផលិតកម្មនៃទ្រព្យសកម្មធំៗ ដូចជាការសាងសង់រោងចក្រឧស្សាហកម្មការដាំដំណាំ ឬការចិញ្ចឹមសត្វរយៈពេលវែងការប្រាក់នៃបំណុលនានាដែលបានផ្តល់ទុនក្នុងការសាងសង់ការដាំដុះ ឬ ការចិញ្ចឹមទាំងនេះត្រូវបានអនុញ្ញាតឱ្យបូកបញ្ចូល ចាប់ពីពេលខ្ចីបុលដំបូង រហូតដល់ពេលធ្វើផលិតកម្មប៉ុណ្ណោះ។

គ-ចំពោះទ្រព្យសកម្មដែលសហគ្រាសទទួលបាន ពីរដ្ឋសមូហភាពសាធារណៈ ឬ

អ្នកវិនិយោគឯកជនត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យ តាមតម្លៃ ឧបហារិត ដូច ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង នៃ ឧបហារិត។

ឃ-ចំពោះទ្រព្យសកម្មដែលសហគ្រាស បានមកដោយគ្មានបង់ថ្លៃ ត្រូវកត់ត្រាក្នុង បញ្ជីគណនេយ្យតាមតម្លៃទីផ្សារ ឬ ថ្លៃដែលសហគ្រាសឯករាជ្យធ្វើប្រតិបត្តិការ ជាមួយគ្នា។

៣-អាករលើតម្លៃបន្ថែម ដែលបានបង់លើការទិញ ឬ ការផលិតទ្រព្យសកម្ម ដែលមិន អនុញ្ញាតជាឥណទានអាករលើធាតុចូល ត្រូវបានអនុញ្ញាតឱ្យបូកបញ្ចូលក្នុងថ្លៃដើមនៃទ្រព្យនោះ។

**១២.៥-វិធីរំលស់ធម្មតា**

វិធីរំលស់ធម្មតានៃទ្រព្យសកម្មរយៈពេលវែងត្រូវបានកំណត់ដូចខាងក្រោម៖

១-ទ្រព្យសកម្មអរូបី៖ ទ្រព្យសកម្មអរូបីទាំងអស់ត្រូវធ្វើរំលស់តាមវិធីរំលស់ស្មើភាគទៅ តាមអាយុកាលប្រើប្រាស់នៃទ្រព្យទាំងនោះ ឬ ១០ ភាគរយ ក្នុងមួយឆ្នាំប្រសិនបើមិនអាចកំណត់ អាយុកាលប្រើប្រាស់បាន។

២-ទ្រព្យសកម្មរូបី៖

-ទ្រព្យសកម្មថ្នាក់១៖ ត្រូវធ្វើរំលស់ដោយឡែកពីគ្នាតាមវិធីរំលស់ស្មើភាគតាមអត្រា ៥ ភាគរយ ក្នុងមួយឆ្នាំ នៃបរិយាទានលទ្ធកម្ម (ថ្លៃដើម)។ ចំពោះអគារដែលមាន លក្ខណៈជាអគារមិនមែនបេតុង រំលស់ត្រូវធ្វើឡើងតាមអត្រា ១០ ភាគរយ ក្នុង មួយឆ្នាំ។

-ទ្រព្យសកម្មថ្នាក់២៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ ថយចុះជាលំដាប់ តាមអត្រា ៥០ ភាគរយ នៃមូលដ្ឋានរំលស់ ក្នុងមួយឆ្នាំ។

-ទ្រព្យសកម្មថ្នាក់៣៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ ថយចុះជាលំដាប់ តាមអត្រា ២៥ ភាគរយ នៃមូលដ្ឋានរំលស់ ក្នុងមួយឆ្នាំ។

-ទ្រព្យសកម្មថ្នាក់៤៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ ថយចុះជាលំដាប់ តាមអត្រា ២០ ភាគរយនៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ។

៣-ធនធានធម្មជាតិទឹកប្រាក់រំលស់ ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវបានគណនា ដោយយកសមតុល្យ នៃគណនីធនធានធម្មជាតិ ទៅគុណនឹងផលចែករវាងបរិមាណដែលផលិតបាននៅក្នុងឆ្នាំជាប់ពន្ធ និង ចំនួនប៉ាន់ស្មាន នៃ ផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ។

៤-កសិកម្មរយៈពេលវែង

ក-ដំណាំកៅស៊ូ៖ អនុញ្ញាតឱ្យធ្វើរំលស់ក្នុងរយៈពេល ២០ ឆ្នាំ ទៅតាមអត្រាដែលបានកំណត់ដូចខាងក្រោម៖

| ឆ្នាំទទួលផល | អត្រារំលស់ |
|---|---|
| ឆ្នាំទី១ និងទី២ | ៣% |
| ឆ្នាំទី៣ និងទី៤ | ៤% |
| ឆ្នាំទី៥ ដល់ឆ្នាំទី១០ | ៥% |
| ឆ្នាំទី១១ និងទី១២ | ៧% |
| ឆ្នាំទី១៣ ដល់ឆ្នាំទី១៥ | ៦% |
| ឆ្នាំទី១៦ ដល់ឆ្នាំទី១៩ | ៥% |
| ឆ្នាំទី២០ | សមតុល្យនៅសល់ |

ខ-ដំណាំកសិកម្មក្រៅពីកៅស៊ូ៖ ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់កង នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាតាមវិធីរំលស់ស្មើភាគតាមអាយុកាល នៃការទទួលផល ឬ ៥ ភាគរយក្នុងមួយឆ្នាំដោយជ្រើសរើស ជម្រើសណាមួយ ដែលធាប់ជាង។

គ-ការចិញ្ចឹមសត្វ៖ ទឹកប្រាក់រំលស់ ដែលត្រូវបានអនុញ្ញាតឱ្យកាត់កង នៅក្នុងឆ្នាំ ជាប់ពន្ធណាមួយ ត្រូវគណនាតាមវិធីរំលស់ ស្មើភាគតាមអាយុកាល នៃការ ទទួលផល ១០ ភាគរយក្នុងមួយឆ្នាំ ដោយជ្រើសរើសជម្រើសណាមួយដែល ធាប់ជាង។(តាមមាត្រា ១៣ ថ្មី នៃច្បាប់សារពើពន្ធ)

## ១២.៦-ពេលចាប់ផ្ដើមធ្វើរំលស់

១-រំលស់ទ្រព្យសកម្មតាមវិធីរំលស់ស្មើភាគត្រូវអនុវត្តដូចខាងក្រោម៖

ក-រំលស់ ត្រូវធ្វើឡើងចាប់ពីពេលដែលទ្រព្យសកម្ម ត្រូវបានដាក់ប្រើប្រាស់ និង បញ្ចប់នៅពេលដែលទ្រព្យសកម្មត្រូវបានរំលស់អស់ (នៅពេលនោះទឹកប្រាក់ រំលស់បូកយោង ត្រូវស្មើនឹងថ្លៃដើមនៃទ្រព្យសកម្ម) ចំណុចបញ្ចប់ក៏អាចកើត មានឡើងមុនកាលបរិច្ឆេទរំលស់អស់ ក្នុងករណីនៃការបញ្ចេញទ្រព្យសកម្មជា របស់សហគ្រាស ដោយការលក់ការដាក់ឱ្យទៅជាកាកសំណល់ ឬ ការបំផ្លាញ ចោលដែរ រីឯទ្រព្យសកម្ម ដែលបានដាក់ឱ្យប្រើប្រាស់ក្នុងអំឡុងពេលណាមួយ នៃឆ្នាំជាប់ពន្ធ ត្រូវអនុញ្ញាតឱ្យគិតរំលស់ពេញមួយឆ្នាំ។

ខ-ចំពោះឆ្នាំបញ្ចប់រំលស់៖

-ក្នុងករណីទ្រព្យសកម្មត្រូវបានបញ្ចេញពីសហគ្រាស ទឹកប្រាក់រំលស់ត្រូវស្មើនឹងសូន្យ។

-ក្នុងករណីទ្រព្យសកម្មណាមួយបានបញ្ចប់ អាយុកាលប្រើប្រាស់របស់វា ទឹកប្រាក់រំលស់ ត្រូវស្មើនឹងសមតុល្យ មិនទាន់រំលស់ នៃគណនីទ្រព្យសកម្ម នៃទ្រព្យនោះ។ ប៉ុន្តែ ប្រសិនបើសមតុល្យនេះ ធំជាងទឹកប្រាក់រំលស់ ប្រចាំឆ្នាំ (ឧទាហរណ៍៖ មានការកែលម្អជាប់លាប់) ទ្រព្យសកម្មជាប់ទាក់ទិនត្រូវបានចាត់ទុកថាបានកើន អាយុកាលប្រើប្រាស់ និង ត្រូវបានធ្វើរំលស់ជាបន្តទៀតរហូតដល់សមតុល្យនេះតូចជាងទឹកប្រាក់រំលស់ប្រចាំឆ្នាំ ទើបធ្វើរំលស់ឱ្យអស់ដើម្បីបញ្ចប់រំលស់តែម្តង។

២-រំលស់ទ្រព្យសកម្មតាមវិធីរំលស់ថយចុះជាលំដាប់ត្រូវអនុវត្តដូចខាងក្រោម៖

ក-រំលស់ ត្រូវធ្វើឡើងចាប់ពីពេលដែលទ្រព្យសកម្ម ត្រូវបានដាក់ប្រើប្រាស់ ទ្រព្យសកម្ម ក្នុងអំឡុងពេលណាមួយនៃឆ្នាំជាប់ពន្ធ ត្រូវអនុញ្ញាតឱ្យគិតរំលស់ពេញមួយឆ្នាំ។

ខ-ទឹកប្រាក់រំលស់ដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ថ្នាក់នីមួយៗ ស្មើនឹងមូលដ្ឋានរំលស់គុណ នឹង អត្រារំលស់សម្រាប់ថ្នាក់នីមួយៗ។

គ-មូលដ្ឋានរំលស់ សម្រាប់ឆ្នាំទី១ នៃអាជីវកម្មគឺ ស្មើនឹងចំនួនសរុប នៃថ្លៃដើម នៃទ្រព្យសកម្ម ក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នា តាមថ្នាក់នីមួយៗ ដែលបានដាក់ប្រើប្រាស់។

ឃ-ចំពោះឆ្នាំជាប់ពន្ធជាបន្តបន្ទាប់ មូលដ្ឋានរំលស់ស្មើ នឹង សមតុល្យដើមគ្រា នៃ

គណនីទ្រព្យសកម្មរួមបញ្ចូលគ្នា បូកនឹងថ្លៃដើមទ្រព្យសកម្មដាក់ប្រើប្រាស់ក្នុងឆ្នាំជាប់ពន្ធ ដកថ្លៃទ្រព្យសកម្មដែលត្រូវបានដកចេញ ឬ លក់ក្នុងឆ្នាំជាប់ពន្ធ។

ង-នៅក្នុងឆ្នាំជាប់ពន្ធ ប្រសិនបើទ្រព្យណាមួយ នៅក្នុងគណនីទ្រព្យសកម្ម ត្រូវរួមបញ្ចូលគ្នាបានដកចេញ ឬលក់ពីអាជីវកម្មសហគ្រាសត្រូវដកចេញពីមូលដ្ឋានរំលស់នៃទ្រព្យសកម្មរួមបញ្ចូលគ្នានូវ តម្លៃទ្រព្យដែលបានដកចេញឬ ក៏លក់។

-ប្រសិនបើការកត់ត្រាបែបនេះ ធ្វើឱ្យសមតុល្យគណនីទ្រព្យសកម្ម រួមបញ្ចូលគ្នាក្លាយជាអវិជ្ជមាន សហគ្រាសត្រូវកត់ត្រាជាប្រាក់ចំណូលជាប់ពន្ធ នូវទឹកប្រាក់ ស្មើនឹងសមតុល្យអវិជ្ជមាននេះ ហើយសមតុល្យគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវកែតម្រូវមកសូន្យវិញ។

-នៅចុងឆ្នាំជាប់ពន្ធ ប្រសិនបើក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នា ណាមួយជាក់ស្តែងគ្មាននៅសល់ទ្រព្យសកម្មអ្វីទៀតទេនោះសមតុល្យវិជ្ជមាននៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នានោះ ត្រូវបានកត់ត្រាជាការខាតបង់អាចកាត់កងបាន ហើយសមតុល្យនៃគណនីទ្រព្យសកម្ម រួមបញ្ចូលគ្នាត្រូវបានកែតម្រូវមកសូន្យវិញ។

៣-រំលស់ធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង សហគ្រាសត្រូវចាប់ផ្តើមធ្វើរំលស់ធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង នៅឆ្នាំដែលចាប់ផ្តើមធ្វើផលិតកម្ម។ សម្រាប់គោលដៅនៅក្នុងចំណុចនេះចាប់ផ្តើមធ្វើផលិតកម្មគឺ ជាឆ្នាំដែលសហគ្រាសបានទទួលចំណូលពីការធ្វើ អាជីវកម្មលើធនធានធម្មជាតិ ឬ កសិកម្មរយៈពេលវែង។ ចំពោះទ្រព្យសកម្មរយៈពេលវែងដែលបានទិញឬបានបង្កើតក្រោយឆ្នាំចាប់ផ្តើមធ្វើផលិតកម្ម សហគ្រាសត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធ

ដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់ តាមវិធីដូចមាននៅក្នុងចំណុច ១ និង ចំណុច ២ នៃ ចំណុចទី **១២.៥** ខាងលើនេះ។ ប្រសិនបើអាជីវកម្មលើធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង ត្រូវបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធណាមួយ សហគ្រាសត្រូវបានអនុញ្ញាតឱ្យ គាត់កងជាចំណាយ នៅក្នុងឆ្នាំជាប់ពន្ធនូវតម្លៃទ្រព្យសកម្ម ដែលនៅសេសសល់ទាំងអស់ រួមបញ្ចូលទាំងចំណាយស្វែងរុករក ចំណាយអភិវឌ្ឍន៍ ចំណាយដាំដុះ និង ចំណាយចិញ្ចឹមសត្វ។(តាមមាត្រា ១៥ ថ្មី នៃច្បាប់ពន្ធ)

### ១២.៧-រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស

១-នៅក្នុងឆ្នាំជាប់ពន្ធនីមួយៗសហគ្រាស ត្រូវតែធ្វើរំលស់សម្រាប់ធានាការសឹករេចដើម្បីកាត់កងក្នុងឆ្នាំជាប់ពន្ធនោះ ទោះបីមានប្រាក់ចំណូលជាប់ពន្ធគ្រប់គ្រាន់ ឬ មិនគ្រប់គ្រាន់សម្រាប់ការកាត់កងក៏ដោយ។ រំលស់ត្រូវធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស ក្រោមមូលដ្ឋានបរិយាទានប្រវត្តិសាស្ត្រ។ ក្នុងករណីនៅដំណាច់ឆ្នាំជាប់ពន្ធណាមួយ សហគ្រាសធ្វើការវាយតម្លៃទៅតាមតម្លៃពិតបច្ចុប្បន្ន នូវទ្រព្យសកម្មរបស់ខ្លួន (ធ្វើសារពើភណ្ឌលម្អិត) សហគ្រាសត្រូវជូនដំណឹងមករដ្ឋបាលសារពើពន្ធអំពីលទ្ធផលនៃការវាយតម្លៃនោះ។ សម្រាប់គោលដៅពន្ធដារប្រសិនបើ លទ្ធផលនៃការវាយតម្លៃ ធ្វើឱ្យមានការប្រែប្រួលតម្លៃពិតនៃទ្រព្យសកម្មក្នុងឆ្នាំជាប់ពន្ធ លម្អៀងលើសនៃការវាយតម្លៃឡើងវិញ ត្រូវចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធ និងជាមូលដ្ឋានបន្ថែមសម្រាប់រំលស់បន្ត។

២-ទឹកប្រាក់រំលស់ ដែលអាចកាត់កងបានត្រូវតែ គណនាតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងជំពូកនេះ និងបានកត់ត្រាក្នុងតារាងគណនារំលស់ នៃ លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ នៃ ឆ្នាំជាប់ពន្ធនីមួយៗ ។

៣-សហគ្រាសមិនត្រូវបានអនុញ្ញាតឱ្យលើកពេលរំលស់ទ្រព្យសកម្មណាមួយទេ។

៤-ទឹកប្រាក់រំលស់ ឬចំណែកណាមួយ នៃទឹកប្រាក់រំលស់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ដែលពុំបានកត់ត្រា ក្នុងតារាងគណនារំលស់ នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យយកទៅកាត់កងក្នុងឆ្នាំជាប់ពន្ធផ្សេងទៀតបានឡើយ ។

៥-រំលស់ដែលត្រូវបានបដិសេធចេញ ពីចំណាយអាចកាត់កងបាន ដូចមានចែងក្នុងចំណុចទី ៤ នេះត្រូវបានចាត់ទុកថា ត្រូវបានធ្វើឡើងជាប្រក្រតីសម្រាប់ការ គណនាតម្លៃលើស ឬតម្លៃខ្វះ នៃ ការលក់។

៦-ឧទាហរណ៍៖

ក-សហគ្រាសមួយបានទិញឃ្លាំងមួយនៅ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤ ដែលមានថ្លៃដើម ៤០ ០០០០ ០០០ រៀល។

ខ-សហគ្រាសបានធ្វើរំលស់ឃ្លាំងនោះជាទៀងទាត់ ទៅតាមវិធីរំលស់ស្មើភាគតាមអត្រា ៥ ភាគរយសម្រាប់អាយុកាលប្រើប្រាស់ ២០ ឆ្នាំ លើកលែងតែមាននៅឆ្នាំ ២០០៦ ដោយសារតែនៅក្នុងឆ្នាំជាប់ពន្ធនោះ សហគ្រាសមានការខាតបង់ធ្ងន់ធ្ងរ។

គ-ឃ្លាំងត្រូវបានលក់ចេញនៅ ថ្ងៃ ទី ១០ ខែ មិថុនា ឆ្នាំ២០១៨ ដែលបានប្រាក់ ១៥០ ០០០ ០០០ រៀល។

ឃ-ស្ថានភាពទាក់ទិន នឹង ការគណនារំលស់តម្លៃលើស ឬ តម្លៃខ្វះ នៃឃ្លាំងនេះមានដូចតទៅ ៖

-អត្រារំលស់ ៥ ភាគរយ ( ឃ្លាំងមានអាយុកាលប្រើប្រាស់២០ឆ្នាំជាទ្រព្យសកម្មរូបីថ្នាក់១ )

-រំលស់ត្រូវបានកត់ត្រាជាចំណាយសម្រាប់ឆ្នាំនីមួយៗ ។

-រំលស់ឆ្នាំ ២០០៤= (៤០០ ០០០ ០០០ រៀល x ៥%)= ២០ ០០០ ០០០ រៀល

(ឆ្នាំចាប់ផ្តើមរំលស់គិតស្មើនឹងរំលស់ប្រចាំឆ្នាំ)

-រំលស់ឆ្នាំ២០០៥ = ២០ ០០០ ០០០ រៀល រំលស់ឆ្នាំ២០០៦ = 0 រៀល

-រំលស់ឆ្នាំ២០០៧ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០០៨ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០០៩ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១០ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១១ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១២ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១៣ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១៤ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១៥ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១៦ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ២០១៧ = ២០ ០០០ ០០០ រៀល

-រំលស់ឆ្នាំ ២០១៨ = 0 រៀល (ឆ្នាំបញ្ចេញទ្រព្យសកម្ម រំលស់គិតស្មើសូន្យ)

- តម្លៃនៅសល់មិនទាន់រំលស់=ថ្លៃដើម (បរិយាទានប្រវត្តិសាស្ត្រ) – តម្លៃរំលស់បូកយោង

-ថ្លៃដើម (បរិយាទានប្រវត្តិសាស្ត្រ) = ៤០០ ០០០ ០០០ រៀល

-តម្លៃរំលស់បូកយោង = ២៦០ ០០០ ០០០ រៀល

-តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល

*តម្លៃលើស = ថ្លៃលក់ – តម្លៃនៅសល់មិនទាន់រំលស់

-ថ្លៃលក់ = ១៥០ ០០០ ០០០ រៀល

-តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល

*តម្លៃលើស = ១០ ០០០ ០០០ រៀល

ង-សម្រាប់គោលដៅពន្ធដារតម្លៃលើសនេះ ត្រូវតែបន្ថែមនៅទឹកប្រាក់រំលស់ លើកពេលចំនួន ២០ ០០០ ០០០ រៀល នៅឆ្នាំ២០០៦។ដូច្នេះតម្លៃលើសជាប់ពន្ធគឺ (១០ ០០០ ០០០រៀល + ២០ ០០០ ០០០រៀល)= ៣០ ០០០ ០០០ រៀល

ច-ករណីនៃតម្លៃខ្វះ៖ ប្រសិនបើ ឃ្លាំងលក់បានថ្លៃ ១១០ ០០០ ០០០ រៀលវិញ តម្លៃខ្វះ គឺ៖

-ថ្លៃលក់ = ១១០ ០០០ ០០០ រៀល

-តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល

-តម្លៃខ្វះ (ខាត) = ៣០ ០០០ ០០០ រៀល

តម្លៃខ្វះ (ខាត)ដែលអាចកាត់កងបានសម្រាប់គោលដៅនៃ(ពបច)គឺមានតែ ១០ ០០០ ០០០ រៀលប៉ុណ្ណោះ គឺតម្លៃដែលកត់ត្រាខាត ៣០ ០០០ ០០០រៀល ត្រូវបានកាត់បន្ថយតម្លៃរំលស់លើកពេលក្នុងឆ្នាំ ២០០៦ ចំនួន ២០ ០០០ ០០០រៀល។

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្តីណែនាំគណនាពន្ធ)

៧-ការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលៈ

ក-ឆ្លងតាមឧទាហរណ៍ក្នុងចំណុចទី ៦ ខាងលើនេះ ឃើញថាសហគ្រាសត្រូវជាប់ពន្ធលើប្រាក់ចំណូល ចំពោះទឹកប្រាក់រំលស់ដែលបានលើកពេល។ សម្រាប់ការអនុវត្តជាក់ស្តែង សហគ្រាសត្រូវធ្វើការកែតម្រូវគណនី រំលស់ទ្រព្យសកម្ម នៃឆ្នាំជាប់ពន្ធដែលមានកំហុស ដោយគិតបញ្ចូលមកវិញ នូវទឹកប្រាក់រំលស់លើកពេល។

ខ-ចំពោះទឹកប្រាក់រំលស់ ឬ ទឹកប្រាក់សំវិធានធន ដែលត្រូវបង្កើតឡើងដោយខុសគោលការណ៍ ឬដែលមានទឹកប្រាក់លើសពីការកម្រិតអនុញ្ញាតសហគ្រាសត្រូវកែតម្រូវទឹកប្រាក់រំលស់ ឬ សំវិធានធនដែលខុសនេះ សម្រាប់ឆ្នាំជាប់ពន្ធដែលមានកំហុស។

គ-សម្រាប់ករណីដូចមាននៅចំណុច **ក** និង ចំណុច **ខ** ខាងលើនេះសហគ្រាសត្រូវបានដាក់លិខិតប្រកាសកែតម្រូវ លិខិតប្រកាសពន្ធ លើប្រាក់ចំណូលប្រចាំឆ្នាំតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ។

ឃ-នៅក្រោយពេលដែលសហគ្រាសបានអនុវត្តតាមការណែនាំដូចមាននៅចំណុច **ក** ចំណុច **ខ** និង ចំណុច **គ** ខាងលើនេះ រួចហើយសហគ្រាសអាចធ្វើរំលស់ ឬ សំវិធានធនជាបន្តទៀតទៅតាមគោលការណ៍ដែលច្បាប់ស្តីពីសារពើពន្ធ បានអនុញ្ញាត។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

**១២.៨-វិធីរំលស់ពិសេស**

១-រំលស់ពិសេស ត្រូវបានអនុញ្ញាតឱ្យកាត់កង នៅក្នុងឆ្នាំ ទី ១ នៃការទិញ ឬនាពេលក្រោយមកទៀតនៅឆ្នាំ ទី ១ នៃការដាក់ប្រើប្រាស់ទ្រព្យសកម្មរូបី។ ចំនួនដែលអនុញ្ញាតឱ្យកាត់កងនេះស្មើនឹង ៤០ ភាគរយ នៃតម្លៃមូលធននៃទ្រព្យសកម្មរូបី ថ្មី ឬ ទ្រព្យសកម្មរូបីប្រើប្រាស់រួចដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្ម ឬ ការកែច្នៃ។ ក្នុងឆ្នាំជាប់ពន្ធដដែលតម្លៃមូលធននៃទ្រព្យសកម្មរូបីដែលនៅសល់ត្រូវបានអនុញ្ញាតឱ្យធ្វើរំលស់ តាមវិធីរំលស់ធម្មតាដូចមាននៅក្នុងចំណុច **១២.៥** ខាងលើនេះ។

២-រំលស់ពិសេសនៃទ្រព្យសកម្មរូបី នឹងត្រូវបានយកមកកាត់កងដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ សម្រាប់ឆ្នាំជាប់ពន្ធប្រសិនបើអ្នកវិនិយោគមិនជ្រើសយកការប្រើប្រាស់សិទ្ធិទទួលរយៈពេលលើកលែងពន្ធដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រា ២០ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

៣-ទ្រព្យសកម្មរូបី ដែលបានទទួលនូវការកាត់កង រំលស់ពិសេស ត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត៤ឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធ ដែលរំលស់ពិសេសត្រូវបានកាត់កង។ ប្រសិនបើទ្រព្យសកម្មរូបីនោះ ត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ អ្នកវិនិយោគត្រូវកត់ត្រា បញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធវិញ នូវ ចំនួនមួយស្មើ នឹង ទឹកប្រាក់រំលស់ពិសេស ដែលបានកាត់កងកាត់បន្ថយដោយចំនួនមួយស្មើ នឹង ២ ភាគរយ នៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កង សម្រាប់ខែនីមួយៗ ឬ ចំណែក នៃ ខែ ដែលទ្រព្យនោះត្រូវបានដាក់ប្រើប្រាស់។ ចំនួននេះ នឹងមិនប៉ះពាល់ដល់តម្លៃពិតគណនេយ្យនៃ ទ្រព្យសកម្មរូបីសម្រាប់ការកំណត់ ប្រាក់ចំណេញមូលធន តាមមាត្រា ៧ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធទេ។

៤-ករណីសិក្សា៖

សហគ្រាសវិនិយោគមួយចាប់ផ្តើម ប្រកបអាជីវកម្ម នៅដើមឆ្នាំជាប់ពន្ធ ២០០៤ មានម៉ាស៊ីន៣គ្រឿង សម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម។ សម្រាប់គោលដៅ នៃពន្ធលើប្រាក់ចំណូល ម៉ាស៊ីនស្ថិតក្នុងទ្រព្យសកម្មថ្នាក់៤ ដែលបានកត់ត្រា ក្នុងតារាងរំលស់មានតម្លៃ ២៦ ០០០ ០០០ រៀល(ម៉ាស៊ីនទី១៖ ១០ ០០០ ០០០ រៀល, ម៉ាស៊ីនទី២៖ ១០ ០០០ ០០០ រៀល និងម៉ាស៊ីនទី៣ ៖៦ ០០០ ០០០រៀល)។ នៅឆ្នាំ ២០០៥ សហគ្រាសបានលក់ម៉ាស៊ីនទី៣ទៅឱ្យសហគ្រាសផ្សេង ក្នុងតម្លៃ ៥ ០០០ ០០០ រៀល ហើយបានទិញម៉ាស៊ីនគំរូថ្មីមួយគ្រឿងមកវិញមានតម្លៃ ២០ ០០០ ០០០រៀល។

សហគ្រាសបានជ្រើសយក វិធីរំលស់ពិសេសសម្រាប់ដំណើរការវិនិយោគ។

**រំលស់ត្រូវបានគណនាដូចខាងក្រោម៖**

•រំលស់ម៉ាស៊ីនទាំង ៣ គ្រឿងសម្រាប់ឆ្នាំ២០០៤ ៖

•រំលស់ពិសេស (២៦ ០០០ ០០០ x ៤0%) = ១០ ៤០០ ០០០ រៀល

•មូលដ្ឋានរំលស់ធម្មតា (២៦ ០០០ ០០០ - ១០ ៤០០ ០០០) = ១៥ ៦០០ ០០០ រៀល

•រំលស់ធម្មតា (១៥ ៦០០ ០០០ x ២0%) = ៣ ១២០ ០០០ រៀល

•សរុបរំលស់សម្រាប់ឆ្នាំ២០០៤ (១០ ៤០០ ០០០ + ៣ ១២០ ០០០)= ១៣ ៥២០ ០០០ រៀល

•មូលដ្ឋានរំលស់យោងទៅឆ្នាំ២០០៥ (២៦ ០០០ ០០០ - ១៣ ៥២០ ០០០) =

១២ ៤៨០០០០រៀល រំលស់សម្រាប់ឆ្នាំ២០០៥ + – រំលស់ពិសេសសម្រាប់ម៉ាស៊ីនទិញថ្មី

(២០ ០០០ ០០០ x ៤0%) = ៨ ០០០ ០០០ រៀល

•មូលដ្ឋានរំលស់ធម្មតា ម៉ាស៊ីនទិញថ្មី (២០ ០០០ ០០០ - ៨ ០០០ ០០០)

= ១២ ០០០ ០០០ រៀល

•មូលដ្ឋានរំលស់ធម្មតាសម្រាប់ម៉ាស៊ីនទាំងអស់៖

១២ ៤៨០ ០០០ + ១២ ០០០ ០០០ - ៥ ០០០ ០០០(ចំណូលពីការលក់ម៉ាស៊ីនចាស់)

= ១៩ ៤៨០ ០០០ រៀល

•ទឹកប្រាក់រំលស់ធម្មតា (១៩ ៤៨០ ០០០ x ២០% ) = ៣ ៨៩៦ ០០០ រៀល

•សរុបទឹកប្រាក់រំលស់សម្រាប់ឆ្នាំ២០០៥ (៨ ០០០ ០០០ + ៣ ៨៩៦ ០០០)

= ១១ ៨៩៦ ០០០ រៀល

•មូលដ្ឋានរំលស់យោងទៅឆ្នាំ២០០៦ (១៩ ៤៨០ ០០០ - ១១ ៨៩៦ ០០០)

= ៧ ៥៨៤ ០០០ រៀល

ការកែតម្រូវពន្ធលើប្រាក់ចំណូលទាក់ទិនទៅនឹង ការលក់ម៉ាស៊ីនក្នុងឆ្នាំ២០០៥ (បន្ទាប់ពីដាក់ប្រើបាន ១៦ ខែ) ៖

•ប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំ ២០០៥ ត្រូវបានកើនឡើងដោយសារការកែតម្រូវការកាត់កងរំលស់។ពិសេសមកវិញនូវចំនួនទឹកប្រាក់ ២% សម្រាប់ខែនីមួយៗ ដែលទ្រព្យសកម្មបានដាក់ប្រើ។

•ប្រាក់ចំណូលជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសម្រាប់ឆ្នាំ២០០៥ ត្រូវបានគណនាដូចខាងក្រោម៖

•រំលស់ពិសេស (៦ ០០០ ០០០ x ៤០%) = ២ ៤០០ ០០០ រៀល

•ដកចេញការកែតម្រូវសម្រាប់រយៈពេលដែលទ្រព្យសកម្មបានប្រើ (២ ៤០០ ០០០ x ២%) x ១៦ ខែ = ៧៦៨ ០០០ រៀល

•ប្រាក់ចំណូលជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសម្រាប់ឆ្នាំ២០០៥ (២ ៤០០ ០០០ –

៧៦៨ ០០០) = ១ ៦៣២ ០០០ រៀល តម្លៃលើស ឬ ខ្វះដែលបានមកពីការលក់ម៉ាស៊ីន។

(ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

## ១៣-វិធានទូទៅស្តីពីតម្លៃលើស និងតម្លៃខ្វះនៃទ្រព្យសកម្ម

### ១៣.១-គោលការណ៍

១-អនុលោមតាមមាត្រា ៧ ថ្មី (មួយ) នៃ ច្បាប់ស្តីពីសារពើពន្ធ តម្លៃលើសដែលបានមកពីការលក់ចំណែកនានា នៃ ទ្រព្យសកម្ម ក្នុងពេលកំពុងប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្មជាចំណែកមួយនៃប្រាក់ចំណូលជាប់ពន្ធ។

២-តម្លៃលើស ឬ តម្លៃខ្វះកើតឡើងអំពីលម្រៀងរវាងថ្លៃលក់ និងតម្លៃនៅសល់មិនទាន់រំលស់នៃទ្រព្យសកម្ម ឬកើតឡើង អំពីការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម។

៣-តម្លៃលើស ឬ តម្លៃខ្វះ ត្រូវបានកំណត់ដូចខាងក្រោម៖

ក-តម្លៃលើសឬតម្លៃខ្វះដែលសម្រេចបាន៖ តម្លៃនេះត្រូវកើតមានឡើងសម្រាប់ការបញ្ចេញទ្រព្យសកម្មរយៈពេលវែងណាមួយ។ ការបញ្ចេញនេះអាចជាការលក់ (ករណីភាគច្រើន) ការធ្វើឧបហារិតទៅក្នុងសហគ្រាសមួយទៀត ការដោះដូរ ការបែងចែក ការផ្តល់ជាអំណោយការយកវិញរបស់ម្ចាស់សហគ្រាស នាពេលកំពុងធ្វើអាជីវកម្ម ឬ នាពេលបញ្ចប់អាជីវកម្ម ការរុះរើចេញ ការបំផ្លាញ ឈប់ប្រើប្រាស់ ។ ការបញ្ចេញនេះអាចជាអំពើដោយចេតនារបស់ម្ចាស់សហគ្រាស ឬ អ្នកគ្រប់គ្រងសហគ្រាស ឬ ជាវិបាកនៃការដកហូតតាមផ្លូវច្បាប់ ឬ គ្រោះមហន្តរាយ...។

ខ-តម្លៃលើសបានកត់ត្រា ៖ ការវាយតម្លៃឡើងវិញ នូវ ទ្រព្យសកម្មដែលបានកត់

ត្រា ក្នុងបញ្ជីគណនេយ្យ នូវ តម្លៃបច្ចុប្បន្នរបស់ទ្រព្យទាំងនោះ ជំនួសឱ្យតម្លៃចាស់នាំឱ្យកើតឡើង នូវតម្លៃលើស។ តម្លៃលើសនេះជាតម្លៃគណនេយ្យ សុទ្ធសាធ និង មិនមានឥទ្ធិពលលើប្រាក់ចំណូលជាប់ពន្ធឡើយ ក្នុងករណីដែលតម្លៃនេះ មិនត្រូវបានប្រើប្រាស់ក្នុងគោលដៅរំលស់សារពើពន្ធ។

គ-តម្លៃខ្វះ ក្រោមរូបភាពជាសំវិធានធនមិនត្រូវបានអនុញ្ញាតឱ្យកាត់កង ដែលជាចំណាយទេ វៀរលែងតែតម្លៃខ្វះដែលសម្រេចបាន ដូចមានចែងក្នុងចំណុច **ក** ខាងលើនេះប៉ុណ្ណោះ។

**១៣.២-ការគណនាតម្លៃលើសឬតម្លៃខ្វះ**

១- ការលក់ទ្រព្យសកម្មរយៈពេលវែងណាមួយ បង្កើតបាននូវតម្លៃលើស កាលបើថ្លៃលក់មានតួលេខធំជាងតម្លៃនៅសល់ មិនទាន់រំលស់នៃទ្រព្យដែលបានលក់នោះ។

២-តម្លៃនៅសល់មិនទាន់រំលស់៖

ក-ចំពោះទ្រព្យសកម្មរយៈពេលវែង ដែលត្រូវបានរំលស់ តាមវិធីរំលស់ស្មើភាគ៖ តម្លៃនៅសល់ មិនទាន់រំលស់ស្មើនឹងបរិយាទានប្រវត្តិសាស្ត្រ នៃ ទ្រព្យសកម្មរយៈពេលវែង ជាប់ទាក់ទិនណាមួយបូកការកែលម្អជាប់លាប់ ដកទឹកប្រាក់រំលស់ បូកយោងដែលបានអនុវត្តចំពោះទ្រព្យនោះ។

ខ-ចំពោះទ្រព្យសកម្មរយៈពេលវែង ដែលត្រូវបានរំលស់តាមវិធី រំលស់ថយជាលំដាប់។ ចំពោះការបញ្ចេញទ្រព្យសកម្មរយៈពេលវែងប្រភេទនេះ ណាមួយសហគ្រាសមិនត្រូវគណនាតម្លៃលើស ឬតម្លៃខ្វះ សម្រាប់ទ្រព្យនោះដោយផ្ទាល់ទេ។ សហគ្រាសត្រូវអនុវត្តដូចមានចែងក្នុងចំណុច ២ នៃចំណុច **១២.៦** ខាង លើ

នេះហើយតម្លៃលើស ឬ តម្លៃខ្វះនឹងត្រូវស្តែងចេញសម្រាប់គណនីទ្រព្យសកម្ម រួមបញ្ចូលគ្នាក្នុងថ្នាក់នីមួយៗ តែម្តង ។

៣-ឧទាហរណ៍

ក-សហគ្រាសបានទិញ និង ដាក់ឱ្យប្រើប្រាស់ទ្រព្យសកម្មថ្នាក់១ ចំនួនមួយមាន តម្លៃ ២៥០ ០០០ ០០០រៀល។ នៅឆ្នាំ ទី ៣ សហគ្រាសបានធ្វើការកែលម្អ ជាប់លាប់ចំនួន ៥០ ០០០ ០០០ រៀល នៅឆ្នាំទី៥ សហគ្រាសបានលក់ទ្រព្យ សកម្មនោះ ចេញវិញក្នុងតម្លៃ ៣៥០ ០០០ ០០០ រៀល។

ខ-ការគណនារំលស់៖

-អត្រារំលស់ ៥ ភាគរយ (ទ្រព្យសកម្មរបីថ្នាក់១) រំលស់ត្រូវបានកត់ត្រាជាចំ ណាយសម្រាប់ឆ្នាំនីមួយៗ៖

-រំលស់ឆ្នាំទី១៖ ២៥០ ០០០ ០០០ x ៥% = ១២ ៥០០ ០០០ រៀល

-រំលស់ឆ្នាំទី២៖ ២៥០ ០០០ ០០០ x ៥% = ១២ ៥០០ ០០០ រៀល

-រំលស់ឆ្នាំទី៣៖ (២៥០ ០០០ ០០០ + ៥០ ០០០ ០០០) x ៥%

= ១៥ ០០០ ០០០ រៀល

-រំលស់ឆ្នាំទី៤៖ (២៥០ ០០០ ០០០ + ៥០ ០០០ ០០០) x ៥%

= ១៥ ០០០ ០០០ រៀល

- សរុបទឹកប្រាក់រំលស់បូកយោង = ៥៥ ០០០ ០០០ រៀល

គ-តម្លៃលើស ឬ តម្លៃខ្វះ ៖

-បរិយាទានប្រវត្តិសាស្ត្រ = ២៥០ ០០០ ០០០ រៀល

-ការកែលម្អជាប់លាប់ = ៥០ ០០០ ០០០ រៀល

-រំលស់បូកយោង = ៥៥ ០០០ ០០០ រៀល

-តម្លៃនៅសល់មិនទាន់រំលស់ = ២៤៥ ០០០ ០០០ រៀល

-ថ្លៃលក់ = ៣៥០ ០០០ ០០០ រៀល

-តម្លៃលើស (៣៥០ ០០០ ០០០ - ២៤៥ ០០០ ០០០) = ១០៥ ០០០ ០០០ រៀល

**១៣.៣-ករណីពិសេស**

ក្នុងករណីពិសេសមួយចំនួនទាក់ទិនទៅនឹងតម្លៃលើស ឬតម្លៃខ្វះត្រូវកំណត់ដូចខាងក្រោម៖

១-ការខាតបង់ពីការលក់ ឬ ដោះដូរទ្រព្យសម្បត្តិ ទោះដោយផ្ទាល់ ឬ ប្រយោលក្តី រវាងបុគ្គលទាក់ទិន ដែលមិនអនុវត្តតាមគោលការណ៍ជំហោងដៃ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃប្រកាស លេខ ៩៨៦ សហវ. ប្រក ចុះ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន។

២-ចំពោះឧបហារិតចូលក្រុមហ៊ុនតម្លៃលើស ឬ តម្លៃខ្វះ ត្រូវគណនាតាមតម្លៃពិតនៃសន្លឹកហ៊ុន ឬ ភាគហ៊ុនដែលបានប្រគល់សម្រាប់ជាថ្នូរ នៃឧបហារិត។ ជាធម្មតាតាមតម្លៃពិតនៃសន្លឹកហ៊ុន ឬ ភាគហ៊ុនត្រូវស្មើនឹងតម្លៃប៉ាន់ស្មាននៃទ្រព្យសកម្ម ដែលបានយកមកបញ្ចូលដោយឧបហារិតទៅក្នុងបញ្ជីគណនេយ្យរបស់សហគ្រាសដែលទទួលឧបហារិត។

៣-ចំពោះការដោះដូរទោះបីមាន ឬ គ្មានការបន្ថែមប្រាក់ក៏ដោយត្រូវបានចាត់ទុក ជាប្រតិបត្តិការលក់ និង ប្រតិបត្តិការទិញជាធម្មតា។ តម្លៃលើសឬតម្លៃខ្វះគឺស្មើនឹងទឹកប្រាក់លម្អៀងរវាងតម្លៃទីផ្សារនៃទ្រព្យសកម្មដែលបានទទួលក្នុងការដោះដូរ និងតម្លៃនៅសល់មិនទាន់រំលស់នៃ

ទ្រព្យសកម្មដែលបានដោះដូរ។ ការដោះដូរត្រូវជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ ដែលកើតមានការដោះដូរនេះ។

៤-ចំពោះការធ្វើអំណោយ ឬការដកយកវិញនូវទ្រព្យពីទ្រព្យសកម្ម របស់សហគ្រាស ឬ ការបញ្ឈប់សកម្មភាពអាជីវកម្ម តម្លៃលើស ឬ តម្លៃខ្វះ នៃ អំណោយ ឬ ទ្រព្យត្រូវគណនាតាមតម្លៃទីផ្សារនាថ្ងៃធ្វើអំណោយ ឬ ថ្ងៃដកយកវិញ ឬ ថ្ងៃបញ្ឈប់សកម្មភាព។

## ១៤-ការគណនាពន្ធលើប្រាក់ចំណូល

### ១៤.១-ប្រាក់ចំណូលជាប់ពន្ធ

១-ការបញ្ចូលមកវិញ និងការកាត់ចេញផ្សេងៗ អាស្រ័យដោយបទប្បញ្ញត្តិស្តីពីពន្ធដារមិនស្របគ្នាទាំងស្រុងទៅនឹងវិធានគណនេយ្យនាំឱ្យប្រាក់ចំណូលជាប់ពន្ធអាចមិនស្មើគ្នានឹងប្រាក់ចំណេញគណនេយ្យទេ។ ដូច្នេះដើម្បី គណនាប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធណាមួយ សហគ្រាសត្រូវយកលទ្ធផលគណនេយ្យ មុនបង់ពន្ធនៃឆ្នាំជាប់ពន្ធនោះ មកធ្វើការកែតម្រូវឲ្យដូចខាងក្រោម៖

ក-បូកបញ្ចូលមកវិញនូវចំណាយមិនអនុញ្ញាតឱ្យកាត់កងដូចជា៖

-ចំណាយរំលស់គណនេយ្យ

-ចំណាយលើការកំសាន្តសប្បាយ ការលំហែកំសាន្ត និងការទទួលភ្ញៀវ

-ការកើនឡើងនូវសំវិធានធន

-អំណោយនិងឧបត្ថម្ភកធនផ្សេងៗ

-ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ

-ចំណាយផ្សេងទៀត ដែលមិនអនុញ្ញាតឱ្យកាត់កង

ខ-បូកបញ្ចូលមកវិញនូវចំណូលជាប់ពន្ធដែលមិនត្រូវបានកត់ត្រា ជាចំណូលក្នុង
បញ្ជីគណនេយ្យដូចជា៖

-ការផ្គត់ផ្គង់ទំនិញ និង សេវាដោយឥតគិតថ្លៃ

-អំណោយ និង ឧបត្ថម្ភកធនផ្សេងៗ

-តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែង តាមបទប្បញ្ញត្តិ នៃពន្ធលើប្រាក់ចំណូល

-ចំណូលជាប់ពន្ធផ្សេងទៀតដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ

គ-ដកចេញវិញនូវចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណាយកាត់កងបានក្នុងឆ្នាំ៖

-រំលស់អនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធ

-រំលស់ពិសេសអនុញ្ញាតតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូល

-ការថយចុះនូវសំវិធានធន

-ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូល

-ចំណាយផ្សេងៗទៀតអនុញ្ញាតឱ្យកាត់កងបាន

ឃ-ដកចេញវិញនូវចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ៖

-ចំណូលលើភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសនជន

-ចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ

-ចំណូលផ្សេងៗ បានកត់ត្រាក្នុងបញ្ជីតែជាចំណូលមិនត្រូវជាប់ពន្ធ ក្នុងឆ្នាំ

២-ក្រោយពីបានធ្វើការកែតម្រូវ ដូចមានចែងក្នុងចំណុចទី ១ ខាលើនេះ សហគ្រាស ត្រូវគណនាវិភាគទានសប្បុរសធម៌ ដែលអាចកាត់កងបានតាមបទប្បញ្ញត្តិ នៃពន្ធលើប្រាក់ចំណូល សម្រាប់ឆ្នាំជាប់ពន្ធដោយត្រូវអនុវត្តដូចខាងក្រោម៖

ក-គណនាមូលដ្ឋាន សម្រាប់គិតវិភាគទានសប្បុរសធម៌ ដោយត្រូវយកវិភាគទាន សប្បុរសធម៌ដែលបានចំណាយនៅក្នុងឆ្នាំជាប់ពន្ធទៅបូកនឹងលទ្ធផលក្រោយ ការកែតម្រូវដែលបានគណនាតាមចំណុចទី ១ ខាងលើនេះ។

ខ-គណនាវិភាគទានសប្បុរសធម៌អតិបរមា ដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ ពន្ធដោយយកលទ្ធផលដែលបានគណនាក្នុងចំណុច ក ខាងលើនេះទៅគុណ នឹង ៥ ភាគរយ។

គ-វិភាគទានសប្បុរសធម៌អាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ៖

-ក្នុងករណីទឹកប្រាក់វិភាគទានសប្បុរសធម៌ ក្នុងឆ្នាំជាប់ពន្ធតិចជាង ឬ ស្មើនឹង វិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបាន សម្រាប់ឆ្នាំជាប់ពន្ធគ្មានការ កែតម្រូវចំណាយ វិភាគទានសប្បុរសធម៌ទេ។

-ក្នុងករណីទឹកប្រាក់វិភាគទានសប្បុរសធម៌ ក្នុងឆ្នាំជាប់ពន្ធច្រើនជាងវិភាគទាន សប្បុរសធម៌អតិបរមាដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ នៅទឹកប្រាក់ លម្អៀងត្រូវចាត់ទុកថាជាចំណាយមិនអាចកាត់កងបាន សម្រាប់ឆ្នាំជាប់ពន្ធ។ ទឹកប្រាក់លម្អៀងនេះ ត្រូវបូកបញ្ចូលវិញទៅក្នុងលទ្ធផល ក្រោយការកែតម្រូវ ដែលបាន គណនាតាមចំណុចទី ១ ខាងលើនេះដើម្បីរកលទ្ធផលក្រោយការ

កាត់កងវិភាគទានសប្បុរសធម៌។

៣-បន្ទាប់មកសហគ្រាសត្រូវគណនាកលទ្ធផលក្រោយការកែតម្រូវការប្រាក់ ដោយៈ

ក-គណនាប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ ដោយយកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរសធម៌ ទៅបូកនឹងចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធរួចដក នឹង ចំណូលការប្រាក់ក្នុងឆ្នាំជាប់ពន្ធ។

ខ-គណនាចំណាយការប្រាក់អតិបរមាអាចកាត់កងបាន ក្នុងឆ្នាំជាប់ពន្ធដោយយកចំណូលការប្រាក់ក្នុងឆ្នាំជាប់ពន្ធទៅបូកនឹង ៥០ ភាគរយនៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ដូចបានគណនាក្នុងចំណុច **ក** ខាងលើនេះ។

គ-ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ច្រើនជាងចំណាយការប្រាក់ អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ សហគ្រាសត្រូវគណនាចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយកតែចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ដកចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធដែលបានគណនា នៅក្នុងចំណុច **ខ** ខាលើនេះ។ ចំណាយការប្រាក់ ដែលនៅសល់ពីការកាត់កងនេះ ត្រូវបានចាត់ទុកជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ រហូតដល់ឆ្នាំជាប់ពន្ធទី ៥ តាមលំដាប់ឆ្នាំដែលចំណាយ ការប្រាក់បានកើតឡើងតាមវិធី ដូចមានចែងក្នុងចំណុចខាងលើនេះ។

ឃ-ក្នុងករណីចំណាយការប្រាក់ ក្នុងឆ្នាំជាប់ពន្ធស្មើ នឹង ចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់ត្រូវបានអនុញ្ញាតទាំងស្រុងដោយមិនមានការកែតម្រូវទេ។

ង-ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធតិចជាងចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ អាចកាត់កងបានទាំងអស់សម្រាប់ឆ្នាំជាប់ពន្ធ។ ប្រសិនបើនៅក្នុងសហគ្រាសមានចំណាយការប្រាក់ដែលនៅសល់យោងពីឆ្នាំមុន សហគ្រាសអាចយកមកកាត់កងបានប៉ុន្តែ ចំនួនដែលត្រូវបានអនុញ្ញាតឱ្យកាត់កងសរុបមិនត្រូវឱ្យលើសតែពីចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ប៉ុណ្ណោះ ក្នុងករណីនេះ ការប្រាក់យោងពីឆ្នាំមុនដែលអនុញ្ញាតឱ្យកាត់កងត្រូវដកចេញពីចំណូលជាប់ពន្ធ។

ច-គណនាលទ្ធផលក្រោយការកែតម្រូវការប្រាក់ ក្នុងឆ្នាំជាប់ពន្ធដោយយក លទ្ធផលក្រោយការកាត់កងរំលោះទានសប្បុរសធម៌ បូកចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធតាមចំណុច ឃ ឬ ដកចំណាយការប្រាក់យោងពីឆ្នាំមុន តាមចំណុច ង ។

៤- គណនាប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលក្រោយការកែតម្រូវការប្រាក់ក្នុងឆ្នាំជាប់ពន្ធ នៅចំណុច ច នៃ ចំណុចទី ៣ ខាងលើនេះ ដកការខាតបង់ពីឆ្នាំមុនៗ ដែលបានអនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធប្រសិនបើមាន។ (ប្រក. លេខ០៩៨. សហវ. ២៩.០១. ២០២០)

### ១៤.២-ការគណនាពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល ត្រូវបានគណនា ដូចតទៅ ៖

ក-គណនាពន្ធលើប្រាក់ចំណូល ដោយយកប្រាក់ចំណូលជាប់ពន្ធ នៃ ឆ្នាំជាប់ពន្ធ

ដូចបានគណនានៅក្នុងចំណុច **១៤.១** ខាងលើនេះទៅគុណនឹងអត្រាពន្ធដូច មានចែងក្នុងមាត្រា ២០ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

ខ-ដកឥណទានពន្ធបរទេសទៅតាមមាត្រា ៣៦ នៃ ច្បាប់ស្តីពីសារពើពន្ធដូចមាន ចែងក្នុង **១៤.៧** ខាងលើនេះ ចំពោះសហគ្រាសនិវាសនជន ដែលមានប្រាក់ចំណូលប្រភពបរទេស ប៉ុន្តែ មិនត្រូវឱ្យលើសពីពន្ធលើប្រាក់ចំណូល នៅក្នុងចំណុច **ក** ខាងលើនេះទេ។

គ-ដកប្រាក់ពន្ធបង់មុនលើការបែងចែកភាគលាភដែលបានបង់ដោយសហគ្រាស តាមមាត្រា២៣ថ្មី( ពីរ) នៃច្បាប់ស្តីពីសារពើពន្ធប៉ុន្តែមិនត្រូវឱ្យលើសពីពន្ធលើ ប្រាក់ចំណូលបន្ទាប់ពីកាត់កងឥណទានពន្ធបរទេស ។ ការដកពន្ធបង់មុនលើ ការបែងចែកភាគលាភនៅក្នុងចំណុចនេះ កម្រិតត្រឹមតែពន្ធបង់មុនលើការបែង ចែកភាគលាភណាមួយ ចេញពីប្រាក់ចំណូលដែលកើតឡើង ក្នុងឆ្នាំជាប់ពន្ធ ប៉ុណ្ណោះ។

## ១៤.៣-ការគណនាពន្ធលើប្រាក់ចំណូលត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

ពន្ធលើប្រាក់ចំណូលត្រូវបង់ ឬ ឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ៖

១-ក្នុងករណីដែលលទ្ធផលគណនានៅចំណុច **១៤.២** ខាងលើនេះ មានចំនួនច្រើនជាងផលបូក នៃឥណទានពន្ធកាត់ទុក ដូចមានចែងនៅក្នុងមេរៀនពន្ធកាត់ទុក។ ចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាម មាត្រា ២៨ ថ្មី នៃច្បាប់ស្តី

ពីសារពើពន្ធ សហគ្រាសត្រូវបង់បន្ថែមនូវចំនួនលម្អៀងនោះ ជូនរដ្ឋបាលសារពើពន្ធ។

២-ប្រសិនបើលទ្ធផលគណនា តាមចំណុច **១៤.២** ខាងលើនេះ មានចំនួនតិចជាងផលបូកនៃឥណទានពន្ធកាត់ទុកតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមេរៀនពន្ធកាត់ទុកខាងលើនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់ សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាសអាចប្រើប្រាស់ចំនួនលម្អៀង ជាឥណទានសម្រាប់កាត់កងទៅនឹងការបង់ប្រាក់រំដោះពន្ធ លើប្រាក់ចំណូល នៅក្នុង ខែ បន្ទាប់ ពី ខែ ដែលបានដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ឬ ពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំបន្ទាប់។

៣-មុននឹងធ្វើការទូទាត់ប្រាក់ពន្ធនៅក្នុងចំណុច ទី ១ ខាងលើនេះ ឬ យោងទៅប្រើជាប្រាក់រំដោះពន្ធលើប្រាក់ចំណូល តាមចំណុច ទី ២ ខាងលើនេះ សហគ្រាសត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមា ក្នុងករណីដែលសហគ្រាសមិនបានទទួលលិខិតបញ្ជាក់ ពីការកាន់បញ្ជីកាគណនេយ្យ បានត្រឹមត្រូវពីអគ្គនាយកដ្ឋានពន្ធដារ។

### ១៤.៤-ការគណនាប្រាក់ពន្ធអប្បបរមាប្រាក់ពន្ធត្រូវបង់ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

ប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបានបង់ ឬ ឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ៖

១-ពន្ធអប្បបរមាដូចមានចែងក្នុងមាត្រា ២៤ ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធត្រូវបង់នៅពេលធ្វើការទូទាត់ប្រាក់ពន្ធ លើប្រាក់ចំណូលប្រចាំឆ្នាំ។ ពន្ធអប្បបរមាត្រូវបង់សម្រាប់ឆ្នាំ ជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូល ដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ។

២-ក្នុងករណីដែលពន្ធលើប្រាក់ចំណូល ដែលបានគណនា ក្នុងចំណុច **១៤.២** ខាងលើនេះ លើសពីពន្ធអប្បបរមាសហគ្រាស គ្មានទឹកប្រាក់ពន្ធអប្បបរមត្រូវបង់ទេ ហើយសហគ្រាសត្រូវអនុវត្តដូចមានចែងក្នុងចំណុច ទី ១ និង ចំណុច ទី ២ នៅក្នុងចំណុច ទី **១៤.៣** ខាងលើនេះ នៅពេលដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

៣-ក្នុងករណីដែលពន្ធអប្បបរមា លើសពីពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមាត្រូវបានកាត់បន្ថយដោយឥណទានពន្ធរបស់សហគ្រាសតាមចំណុច ទី ១ នៃ ចំណុច ទី **១៤.៣** ខាងលើនេះ (គឺផលបូកនៃចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដែលសហគ្រាសបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាម មាត្រា ២៨ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ និង ប្រាក់ពន្ធដែលសហគ្រាសដទៃបានកាត់ទុកតាមបទប្បញ្ញត្តិដូចមានចែងក្នុង មេរៀនពន្ធកាត់ទុកខាងក្រោមនេះ និង ឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុនប្រសិនបើមាន) ក្នុងនោះ៖

ក-ប្រសិនបើពន្ធអប្បបរមាច្រើនជាង ឥណទានពន្ធតាម ចំណុចទី ៣ ខាងលើនេះ សហគ្រាសត្រូវបង់បន្ថែមនូវចំនួនលម្អៀង។

ខ-ប្រសិនបើឥណទានពន្ធតាមចំណុចទី ៣ ខាងលើ នេះ ច្រើនជាងពន្ធអប្បបរមា ចំនួនលម្អៀងត្រូវបានអនុញ្ញាត ឱ្យយោងទៅប្រើប្រាស់ជាឥណទានពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ (ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ឬ ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ) ។

### ១៤.៥-វិធានស្តីពីការយោងការខាតបង់

១-ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីសារពើពន្ធការយោងការខាតបង់ត្រូវបានកំណត់ដូចខាងក្រោម៖

ក-ការខាតបង់កើតឡើងក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវបានចាត់ជាបន្ទុកនិងត្រូវបាន អនុញ្ញាតឱ្យកាត់ចេញពីប្រាក់ចំណូលសម្រេចបាន នៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់ (ឆ្នាំជាប់ពន្ធ ទី ១ នៃ ការយោងការខាតបង់) ។ ប្រសិនបើប្រាក់ចំណូលនេះ មិនគ្រប់គ្រាន់សម្រាប់ការទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅ សេសសល់ត្រូវ យោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់ រហូតដល់ឆ្នាំជាប់ពន្ធទី ៥ ។

ខ-ចំនួនកាត់កងក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវស្មើ នឹង ចំនួនប្រាក់ចំណូលដែលនឹង សម្រេចបានក្នុងឆ្នាំជាប់ពន្ធនោះ ដោយមិនត្រូវរក្សាទុកចំណែកណាមួយ នៃ ការខាតបង់សម្រាប់យោងទៅឆ្នាំបន្ទាប់ទៀតឡើយ។

គ-នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ ដូចមានចែងក្នុងចំណុច **ក** ខាងលើនេះ ត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយ តាមលំដាប់ឆ្នាំ ដែលការ ខាតបង់បានកើតឡើង។

២-លក្ខខណ្ឌនៃការអនុញ្ញាតការខាតបង់៖

ក-ភស្តុតាងបញ្ជាក់ពីការខាតបង់៖

-ដើម្បីអាចកាត់កងបាន សហគ្រាសត្រូវគណនាការខាតបង់ ស្របទៅតាមបទ ប្បញ្ញត្តិស្តីពីពន្ធដារ ហើយការខាតបង់នោះបានបំពេញ ក្នុងលិខិតប្រកាសពន្ធ លើប្រាក់ចំណូលប្រចាំឆ្នាំដែលបានដាក់ជូនរដ្ឋបាលសារពើពន្ធ។

-សហគ្រាសដែលត្រូវទទួលរងការកំណត់ពន្ធជាឯកតោភាគី របស់រដ្ឋបាលសារ ពើពន្ធក្នុងឆ្នាំជាប់ពន្ធណាមួយ មិនត្រូវបានអនុញ្ញាត ឱ្យយោងការខាតបង់ ពី ឆ្នាំជាប់ពន្ធមុនមកកាត់កងក្នុងឆ្នាំជាប់ពន្ធ ដែលមានការកំណត់ពន្ធជាឯកតោ

ភាគី ឬ យោងការខាតបង់ក្នុងឆ្នាំដែលមានការកំណត់ពន្ធ ជាឯកតោភាគីទៅកាត់កងទៅឆ្នាំជាប់ពន្ធបន្ទាប់បានទេ ចំពោះការខាតបង់ដែលកើតមានមុនឆ្នាំជាប់ពន្ធដែលមានការកំណត់ពន្ធជាឯកតោភាគី ត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កងនៅឆ្នាំជាប់ពន្ធបន្ទាប់ ពីឆ្នាំជាប់ពន្ធដែលមានការកំណត់ពន្ធ ជាឯកតោភាគីបាន ប្រសិនបើមិនទាន់ហួសអាយុកាលយោងខាត ៥ឆ្នាំ។

-ការខាតបង់ដែលត្រូវបានអនុញ្ញាតឱ្យយកមកកាត់កង ត្រូវតែមានការបញ្ជាក់អះអាងដោយឯកសារ និងបញ្ជីគណនេយ្យស្របតាមស្តង់ដាគណនេយ្យ អន្តរជាតិនៃកម្ពុជា និងបានធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

ខ-អត្តសញ្ញាណនៃសហគ្រាស៖

-ការខាតបង់របស់សហគ្រាសណាមួយអាចអនុញ្ញាតឱ្យយោងបានសម្រាប់តែសហគ្រាសនោះប៉ុណ្ណោះ

-ក្នុងករណីផ្លាស់ប្តូរសកម្មភាពអាជីវកម្ម ដែលក្នុងនោះជាការបញ្ឈប់សកម្មភាពចាស់ និង ចាប់ផ្តើមសកម្មភាពថ្មីទៀត។ (ឧទាហរណ៍៖ សហគ្រាសឈប់ធ្វើសកម្មភាពខាងលក់ដូរមកធ្វើសកម្មភាពខាងការងារសំណង់...) ការខាតបង់ដែលសហគ្រាសបានទទួលរងក្នុងសកម្មភាពចាស់របស់ខ្លួន ហើយមិនត្រូវបានអនុញ្ញាត ឱ្យយកមកកាត់ចេញពីប្រាក់ចំណូលទេ ដែលសហគ្រាសសម្រេចបានក្នុងសកម្មភាពថ្មីរបស់ខ្លួន។

គ-ឆ្នាំជាប់ពន្ធដែលត្រូវអនុវត្តការយោងការខាតបង់៖

-ការខាតបង់ក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវយោងមកកាត់កង ជាដាច់ខាតពីលទ្ធ

ផលចំណេញ នៃឆ្នាំជាប់ពន្ធបន្តបន្ទាប់ដោយមិនអនុញ្ញាតឱ្យ រំលងឆ្នាំជាប់ពន្ធដែលមានលទ្ធផលចំណេញណាមួយទេ។

-ប្រសិនបើដោយមូលហេតុណាមួយ សហគ្រាសមិនបានយោងការខាតបង់ទាំងអស់ឬ យោងតែចំណែកណាមួយទៅកាត់កង នឹងលទ្ធផលចំណេញនៃឆ្នាំជាប់ពន្ធបន្ទាប់ណាមួយដែលបទប្បញ្ញត្តិស្តីពីពន្ធដារ បានអនុញ្ញាតឱ្យកាត់កងការខាតបង់នេះមិនអាចយោងទៅកាត់កង ពីលទ្ធផលចំណេញ នៃឆ្នាំជាប់ពន្ធបន្ទាប់ៗ ទៀតបានទេ។

-ការយោងការខាតបង់ត្រូវអនុវត្តរៀងៗ គ្នាទៅតាមលំដាប់ឆ្នាំដែលការខាតបង់បានកើតឡើងដោយមិនឱ្យលើសពី ៥ឆ្នាំ។

### ១៤.៦- អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ៖

១-២០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធ ដែលសម្រេចបានដោយនីតិបុគ្គល។

២-៣០ ភាគរយចំពោះប្រាក់ចំណូលជាប់ពន្ធ ដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំងព្រៃឈើ រ៉ែ មាស ឬ ត្បូងថ្មមានតម្លៃនានា។

៣-០ ភាគរយចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុង រយៈពេលលើកលែងពន្ធ។

៤-តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោមចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយ រូបវន្តបុគ្គលសហគ្រាសឯកបុគ្គល និង សមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្ម

សិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ៖

| **ភាគរយនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ** | **អត្រាពន្ធ** |
|---|---|
| ពី 0៛ ដល់ ១៦ 000 000៛ | 0 % |
| ពី ១៦ 000 00១៛ ដល់ ២៤ 000 000៛ | ៥ % |
| ពី ២៤ 0000 00១៛ ដល់ ១0២ 000 000៛ | ១0 % |
| ពី ១0២ 000 00១៛ ដល់ ១៥0 000 000៛ | ១៥ % |
| លើសពី ១៥0 000 000៛ | ២0 % |

(តាមមាត្រា ២0 ថ្មី (មួយ) នៃច្បាប់សារពើពន្ធ)

**១៤.៧-ឥណទានពន្ធបរទេស**

១-អ្នកជាប់ពន្ធនិវាសនជន ដែលបានទទួលប្រាក់ចំណូលប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេសត្រូវបានទទួលនូវ ឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណូលដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់ពីការបង់ពន្ធនៅបរទេសនោះ។

២-ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា នៅមុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលដែលបានទទួលពីប្រភពកម្ពុជា និង ប្រភពបរទេសមកគិត។

៣-ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែក ពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយ និវាសនជនកម្ពុជា នៅប្រទេសក្រៅនីមួយៗ ។ ឥណទានពន្ធដែលបានអនុញ្ញាតឱ្យកាត់កង

សម្រាប់ឆ្នាំជាប់ពន្ធ និងសម្រាប់ប្រាក់ពន្ធដែលបានបង់នៅប្រទេសក្រៅណាមួយគឺ ចំនួនដែលទាបជាងគេក្នុងចំណោមៈ

ក-ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយនោះ

ខ-ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណូលជាប់ពន្ធសរុប ពីគ្រប់ប្រភពសម្រាប់រយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាពន្ធក្នុងមាត្រា ២០ ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធទៅ គុណ នឹង ផលចែក រវាងប្រាក់ចំណូលជាប់ពន្ធដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់ចំណូលជាប់ពន្ធសរុបពីគ្រប់ប្រភព។

៤-ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធ និវាសនជន បានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសត្រូវមានសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេស និង រដ្ឋបាលសារពើពន្ធបរទេសនោះ។

**១៤.៨-ពន្ធបង់មុនលើការបែងចែកភាគលាភ**

១-អនុលោមតាម មាត្រា ២៣ ថ្មី (ពីរ) នៃ ច្បាប់ស្តីពីសារពើពន្ធប្រសិនបើសហគ្រាសណាមួយបែងចែកភាគលាភ ចេញពីប្រាក់ចំណូលមុនបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ទៅឱ្យអ្នកចូលហ៊ុនក្នុងស្រុក ឬអ្នកចូលហ៊ុនបរទេសសហគ្រាសនោះត្រូវបង់ពន្ធបង់មុនលើការបែងចែកភាគលាភ ដែលមានចំនួនស្មើ នឹងផលគុណ នៃទឹកប្រាក់ភាគលាភបំប៉ោងទៅតាមអត្រាពន្ធ លើប្រាក់ចំណូលគុណ នឹង អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា ២០ ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

២-ពន្ធបង់មុនលើការបែងចែកភាគលាភមិនអនុវត្តទេ ចំពោះគម្រោងវិនិយោគមាន

លក្ខណសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល។

៣-ប្រាក់ពន្ធដែលបានបង់តាមចំណុច ទី ១ ខាងលើនេះ ត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កង នឹង ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធដែលមានការបែងចែក។ ប្រសិនបើឥណទានពន្ធមានចំនួនលើស ពីប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ចំនួនលើសនោះ នឹងត្រូវបានអនុញ្ញាតឱ្យយោងទៅមុខ សម្រាប់កាត់កង នឹង ពន្ធលើប្រាក់ចំណូលនៃឆ្នាំជាប់ពន្ធ បន្តបន្ទាប់។

៤-ភាគលាភដែលបានបង់ពន្ធតាម ចំណុច ទី ១ ខាងលើនេះ នៅពេលបែងចែកបន្តមិនត្រូវជាប់ពន្ធបង់មុនលើការ បែងចែកភាគលាភទៀតទេ។

៥-ពន្ធបង់មុនលើការបែងចែកភាគលាភ ដូចមានក្នុងចំណុចនេះ មិនអនុវត្តទេចំពោះប្រាក់ចំណូលពីបុព្វលាភធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬ ហានិភ័យផ្សេងៗ នៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រា ២១ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

៦-ឧទាហរណ៍៖ ក្នុងខែ តុលា ឆ្នាំ២០២០ សហគ្រាសមួយបានបែងចែកប្រាក់ចំណូលនៃ ឆ្នាំចរន្ត ចំនួន ៤០ ០០០ ០០០ រៀល ទៅឱ្យម្ចាស់ភាគហ៊ុននៃសហគ្រាសនោះ។ ដូចនេះសហគ្រាសត្រូវប្រកាសបង់ពន្ធ បង់មុនលើការបែងចែកភាគលាភសម្រាប់រយៈពេលជាប់ពន្ធ ខែ តុលា ឆ្នាំ ២០២០ នូវ ចំនួនដូចខាងក្រោម៖

**រូបមន្តបំប៉ោង សម្រាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០%**

$$\textbf{ភាគលាភមុនបង់ពន្ធ} = \frac{\text{ភាគលាភដែលបានទទួល}}{១ - \frac{២០}{១០០}(\text{អត្រាពន្ធ})} = \frac{\text{ភាគលាភដែលបានទទួល}}{០,៨}$$

$$= ៤០\ ០០០\ ០០០ \div ០,៨ = ៥០\ ០០០\ ០០០ \text{ រៀល}$$

**ពន្ធបង់មុនលើការបែងចែកភាគលាភ** = ៥០ ០០០ ០០០ x ២០% = <u>**១០ ០០០ ០០០ រៀល**</u>

## ១៥-បញ្ជីគណនេយ្យ

### ១៥.១-ភាតព្វកិច្ចគណនេយ្យ

១-ការកាន់បញ្ជីគណនេយ្យ៖

ក-សហគ្រាសត្រូវកត់ត្រាបញ្ជីគណនេយ្យ តាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ខ-គោលការណ៍សំខាន់ៗ ក្នុងការកត់ត្រាបញ្ជីគណនេយ្យ ជាអាទិ៍មាន៖

-ត្រូវប្រើប្រាស់ប្រព័ន្ធគណនេយ្យទ្វេភាគ ដោយផ្អែកលើមូលដ្ឋាន គណនេយ្យបង្គរ

-រាល់ប្រតិបត្តិការត្រូវកត់ត្រាជាប្រាក់រៀល ឬរូបិយប័ណ្ណបរទេសណាមួយដែលមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច

-ត្រូវចេញវិក្កយបត្រលើរាល់ប្រតិបត្តិការជាមួយបុគ្គលដទៃទៀត។ វិក្កយបត្រត្រូវមានលេខរៀង និង និទ្ទេស ត្រឹមត្រូវតាមការកំណត់

-ត្រូវកត់ត្រាសេចក្តីរាយលម្អិតនៃវិក្កយបត្រឱ្យបានត្រឹមត្រូវចូលក្នុងទិនានុប្បវត្តិ

-លិខិតយុត្តិការត្រូវមានចុះថ្ងៃខែឆ្នាំ និងរៀបចំទុកដាក់តាមលំដាប់ច្បាស់លាស់

-ត្រូវកត់ត្រាចូលបញ្ជីគណនេយ្យ នូវ រាល់ប្រតិបត្តិការតាមលំដាប់ ដែលប្រតិបត្តិការ ទាំងនោះបានកើតឡើង

-កំណត់ត្រាគណនេយ្យនីមួយៗ ត្រូវបង្ហាញអំពីប្រភព ខ្លឹមសារ ខ្ទង់គណនីលក្ខណៈសង្ខេប នៃ ប្រតិបត្តិការ និង ឯកសារយោងជាសំអាង

-រាល់ការកែតម្រូវ ត្រូវរក្សាទុកនូវភ័ស្តុតាងបញ្ជាក់ពីការកែតម្រូវនោះ ដើម្បីអាច

រកឃើញឡើងវិញបាន នូវ ទឹកប្រាក់ពិតប្រាកដ នៃ ចលនាសាច់ប្រាក់នៅក្នុង គណនី

-បញ្ជីគណនេយ្យត្រូវធ្វើជាភាសាខ្មែរ ដោយប្រើលេខខ្មែរ ឬ លេខឡាតាំង ប៉ុន្តែ អាចកាន់បញ្ជីគណនេយ្យជំនួយជាភាសាផ្សេងបាន

២-ការបង្ហាញឯកសារគណនេយ្យ៖ សហគ្រាសត្រូវមានភស្តុតាងមកបញ្ជាក់ នូវ រាល់ចំណូលចំណាយដែលបានប្រកាស។ នៅពេលរដ្ឋបាលសារពើពន្ធមានសំណើ ឱ្យបង្ហាញភស្តុតាង សហគ្រាសត្រូវបង្ហាញនូវរាល់ឯកសារគណនេយ្យ បញ្ជីសារពើភណ្ឌ ប័ណ្ណចំណូល ប័ណ្ណចំណាយ ដើម្បីបញ្ជាក់អះអាងនូវភាពពិតប្រាកដ នៃព័ត៌មានដែលបានចុះនៅក្នុងលិខិតប្រកាស។ ក្នុងករណីដែលសហគ្រាសមិនអនុញ្ញាត ឱ្យរដ្ឋបាលសារពើពន្ធពិនិត្យបញ្ជីគណនេយ្យ ឬ ឯកសារផ្សេងៗ សហគ្រាសត្រូវបានចាត់ទុកជាអំពើរាំងស្ទះ ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។

៣-ការរក្សាទុកឯកសារគណនេយ្យ៖ ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃ មាត្រា ៩៨ នៃច្បាប់ស្តីពីសារពើពន្ធ បុគ្គលដែលត្រូវកាន់កត់ត្រា ឬ រក្សាទុកបញ្ជីឯកសារនានា ឬ ទិនានុប្បវត្តិ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ ឬ បទប្បញ្ញត្តិដ៏ទៃត្រូវរក្សាទុកបញ្ជី ឬ ឯកសារទាំងនេះ ក្នុងរយៈពេល ១០ ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធដែលបញ្ជី ឬ ឯកសារទាំងនេះបានកត់ត្រានូវព័ត៌មានផ្សេងៗ លើប្រតិបត្តិការរបស់សហគ្រាស។

៤-សហគ្រាសដែលបានប្រព្រឹត្តដូចខាងក្រោម ត្រូវបានចាត់ទុកជាអំពើរាំងស្ទះ ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ៖

ក-មិនបានរក្សាទុកបញ្ជីគណនេយ្យ និងឯកសារផ្សេងទៀត ឬ មិនបានចេញវិក្កយបត្រលើប្រតិបត្តិការ

ខ-បានកសាង ឬ ផ្តល់នូវកំណត់ត្រា ឯកសាររបាយការណ៍ ឬ ព័ត៌មានក្លែងបន្លំផ្សេងៗ

គ-បានលាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬ ព័ត៌មានផ្សេងៗ ។ ដោយមិនគិតដល់ទោសទណ្ឌ ដទៃទៀត សហគ្រាសដែលប្រព្រឹត្តអំពើខាងលើនេះ ត្រូវទទួលរងទោសទណ្ឌ ដូចមានចែងក្នុងមាត្រា ១៣៣ និង មាត្រា ១៣៦ នៃ ច្បាប់ស្តីពីសារពើពន្ធ។

# មេរៀនទី ៦ ៖ ការប្រមូលពន្ធលើចំណេញមូលធន

## ១-គោលបំណង

ពន្ធលើចំណេញមូលធនអនុវត្តចំពោះអ្នកជាប់ពន្ធ ស្របតាមមាត្រា ៧ ថ្មី (មួយ) នៃច្បាប់សារពើពន្ធ។

## ២-គោលដៅ

ពន្ធលើចំណេញមូលធនមានគោលដៅសម្រាប់គ្រប់គ្រងប្រមូលពន្ធលើប្រាក់ចំណេញមូលធន ដែលសម្រេចបានដោយអ្នកជាប់ពន្ធនៅក្នុងព្រះរាជណាចក្រកម្ពុជា។

## ៣-និយមន័យ

១-ពាក្យ "អ្នកជាប់ពន្ធ" សំដៅដល់អ្នកជាប់ពន្ធនិវាសនជន ឬ អ្នកជាប់អនិវាសនជន ដែលបានលក់ ឬ ផ្ទេរមូលធនទៅអោយអ្នកដ៏ទៃ។

២-ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" គឺ៖ សំដៅដល់នូវរូបវន្តបុគ្គលណាម្នាក់ដែលមានលក្ខណៈវិនិច្ឆ័យចាប់ពី ១ ឡើងទៅក្នុងចំណោមលក្ខណៈទាំងបីខាងក្រោម៖

ក-មាននិវាសនដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិទ្ធិ ឬ ជួល ឬ ភតិសន្យាជួលផ្ទះ អគារ បន្ទប់ជួល អនិវាសនដ្ឋាន ។ ល ។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅ ឬ កាន់កាប់។

ខ-មានទីកន្លែងស្នាក់នៅគោលដើមនៅក្នុង ព្រះរាជាណាចក្រកម្ពុជាទៅតាមរូភាពស្នាក់នៅជាក់ស្តែង នៃការស្នាក់នៅដោយត្រូវពឹងផ្អែកទៅលើកត្តានានា ដូចជាមជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់ រូបវន្តបុគ្គលរយៈពេលស្នាក់នៅ ចរិតនៃការស្នាក់នៅ ទីកន្លែងដែលគ្រួសារបុគ្គលមកស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល

ទីកន្លែងដែលបុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់។

គ-មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី ១៨២ ថ្ងៃ ក្នុងមួយលើក ឬ ច្រើនលើកក្នុងរយៈពេល ១២ ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វត្តមាន ក្នុងចំណែកណាមួយ នៃ ថ្ងៃត្រូវរាប់ថាជា ១ ថ្ងៃពេញ។

ក្នុងករណី មានភាពមិនច្បាស់លាស់ក្នុងការវិនិច្ឆ័យ តាមលក្ខខណ្ឌដែលបានចែងក្នុងចំណុច **ក** និង ចំណុច **ខ** ខាងលើនេះ វត្តមានរបស់បុគ្គលដែលមានចែងចំណុច **គ** គឺ ជាលក្ខណៈចុងក្រោយសម្រាប់កំណត់ភាពជា និវាសនជនរបស់រូបវន្តបុគ្គល។

៣-ពាក្យ "ជាអ្នកជាប់ពន្ធអនិវាសនជន" គឺ រូបវន្តបុគ្គលឬ និតិបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន។

៤-ពាក្យ "មូលធន" សំដៅដល់អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញារូបិយវត្ថុបរទេស។ សំរាប់គោលដៅនៃកថាខណ្ឌនេះពាក្យ៖

ក-អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ ស្របតាមបញ្ញត្តិស្តីពីច្បាប់សារពើពន្ធលើអចលនទ្រព្យ។

ខ-ភតិសន្យា សំដៅដល់ប្រតិបត្តិការភតិបតិកៈដែលបានចុះកិច្ចព្រមព្រៀងជាមួយភតិកៈក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិអោយកាន់កាប់ និងប្រើប្រាស់អចលនវត្ថុ ក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬ តាមតម្លៃសមមូល ។ ភតិសន្យារួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ វៀវលែងតែភតិសន្យាហិរញ្ញវត្ថុ

នៃ ចលនៈវត្ថុ និង ភតិសន្យាពិសេសដែលមានចែង ក្នុងច្បាប់ស្តីពីភតិសន្យាពិសេស។

គ-ទ្រព្យវិនិយោគ សំដៅដល់ ភាគហ៊ុន សញ្ញាប័ណ្ណ និងមូលបត្រ ដែលបោះផ្សាយដោយសហគ្រាសឯកជន។

ឃ-កេរ្តិ៍ឈ្មោះអាជីវកម្ម សំដៅដល់អាជ្ញាប័ណ្ណ បញ្ជីឈ្មោះអតិថិជន និង យីហោ ។

ង-កម្មសិទ្ធិបញ្ញា រួមមាន តក្កកម្ម ស្នាដៃអក្សរសាស្ត្រ និង សិល្បៈ និមិត្តសញ្ញា រូបភាព និង គំនូរ ដែលត្រូវបានប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម។

ច-រូបិយវត្ថុបរទេស សំដៅដល់រូបិយប័ណ្ណក្រៅពីប្រាក់រៀល

ឆ-ពាក្យ "ចំណេញមូលធន" សំដៅដល់ប្រាក់ចំណូល ជាប់ពន្ធដែលបានពីការយកចំណូលពីការលក់ ឬ ផ្ទេរចូលមកមូលធនដកការកាត់កងចំណាយដែលបានអនុញ្ញាត។(ប្រក. លេខ ៣៤៦ សហវ. ប្រក ចុះថ្ងៃ ០១ ខែ មេសា ឆ្នាំ២០២០)

**៤-ការលើកលែងពន្ធ**

ពន្ធចំណេញមូលធន ត្រូវបានលើកលែងចំពោះការលក់ ឬ ផ្ទេរ

ក-ទ្រព្យដែលជារបស់ស្ថាប័នរដ្ឋ

ខ-ទ្រព្យជាកម្មសិទ្ធិរបស់បេសកម្មទូត ឬ កុងស៊ុលបរទេសអង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស នៃ រដ្ឋាភិបាលដទៃ។

គ-និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធដែលបានកាន់កាប់រយៈពេលយ៉ាងតិចប្រាំ ៥ ឆ្នាំ មុនពេលលក់ ឬ ផ្ទេរ។ ក្នុងករណីអ្នកជាប់ពន្ធមាននិវាសដ្ឋានទីកន្លែងច្រើនជាងមួយ ឬអ្នកជាប់ពន្ធនិង សហព័ន្ធមាននិវាសនដ្ឋានផ្សេងពីគ្នា

និវាសដ្ឋានតែមួយប៉ុណ្ណោះដែលត្រូវបានការអនុញ្ញាត ជានិវាសនដ្ឋានជាគោល ដើម។

ឃ-អចលនៈទ្រព្យក្នុងរង្វង់ញាតិ មានចែងនៅក្នុងបទប្បញ្ញាត្តិ ស្តីពីពន្ធប្រថាប់ត្រា វៀរលែងតែការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ រវាងបងប្អូនបង្កើត និងបងប្អូនបង្កើត រវាងឪពុក ម្តាយក្មេក និងកូនប្រសារ និងរវាងយាយតាក្មេក និងចៅប្រសារ។

ង-ទ្រព្យដែលត្រូវបានលក់ឬផ្ទេរ ដើម្បីបម្រើផលប្រយោជន៏សាធារណៈ ស្របតាម ច្បាប់អស្សាមិករណ៏។

## ៥-ពេលសម្រេចបានចំណេញមូលធន

សម្រាប់គោលដៅ អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធននៅពេល៖

ក-លក់ ឬ ផ្ទេរ ឬ បង្កើតអោយមានសិទ្ធិគ្រប់គ្រងលើទ្រព្យ

ខ-ចុះបញ្ជីសម្រាប់ផ្ទេរកម្មសិទ្ធិ ឬ សិទ្ធកាន់កាប់ទ្រព្យនៅអាជ្ញាធរមានសមត្ថកិច្ច

គ-ពេលសម្រេចផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ទ្រព្យដោយសាលក្រម ឬសាលដីកា ស្ថាពររបស់តុលាការ។

## ៦-ចំណាយដែលអាចកាត់កងបាន

ចំណាយដែលអាចកាត់កងបានត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក-ហេតុការណ៏បញ្ជាក់ពីការកើតឡើងនូវបន្ទុក ឬ ចំណាយដែលមានភ័ស្តុតាង អាចត្រួតពិនិត្យបាន

ខ-លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងទៅការចំណាយ

គ-មានវិក្កយបត្រ ឬ ឯកសារភស្តុតាងបញ្ជាក់

## ៧-វិធាននៃការកាត់កងចំណាយ

វិធាននៃការកាត់កងចំណាយ ត្រូវបានកំណត់ដូចខាងក្រោម៖

១-ចំពោះមូលធនជាអចលនទ្រព្យ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតអោយជ្រើសរើស វិធីណាមួយក្នុងចំណោម វិធីទាំងពីរដូចខាងក្រោម៖

ក-វិធីកាត់កងចំណាយតាមការកំណត់ ត្រូវបានអនុញ្ញាតអោយធ្វើការកាត់កងនូវចំណាយ ៨០% នៃ ប្រាក់ចំណូលដែលទទួលបានពីការលក់ ឬ ផ្ទេរទ្រព្យ។

ខ-វិធីកាត់កងចំណាយជាក់ស្តែង ត្រូវបានអនុញ្ញាតអោយធ្វើការកាត់កងចំណាយដែលបានកើតឡើងជាក់ស្តែង។

២-ចំពោះមូលធនដ៏ទៃទៀត អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតអោយកាត់កងចំណាយ តែតាមវិធីកាត់កងតាមចំណាយជាក់ស្តែងប៉ុណ្ណោះ។

៣-ក្នុងករណីដែលអ្នកជាប់ពន្ធជ្រើសរើសវិធីកាត់កងចំណាយជាក់ស្តែងហើយចំណាយដែលបានកើតឡើងជាក់ស្តែង មានចំនួនច្រើនជាងចំណូលពីការលក់ ឬ ផ្ទេរទ្រព្យ ចំនួនដែលលើសមិនអនុញ្ញាតអោយធ្វើការបង្វិលសង ឬ យកទៅកាត់កងចេញពីចំណេញមូលធន នៃទ្រព្យដ៏ទៃទៀតទេ។(ប្រក.លេខ ៣៤៦ សហវ. ប្រក ចុះថ្ងៃ ០១ ខែ មេសា ឆ្នាំ២០២០)

## ៨-ថ្លៃលក់និងថ្លៃដើមនៃទ្រព្យ

ដើម្បីគណនាពន្ធលើចំណេញមូលធនថ្លៃលក់ និងថ្លៃដើមនៃទ្រព្យត្រូវកំណត់ដូចខាងក្រោម៖

១-ថ្លៃលក់ទ្រព្យត្រូវគិតតាមតម្លៃលក់ ឬ ផ្ទេរទ្រព្យដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាទិញលក់ និង ឯកសារពាក់ព័ន្ធដទៃៗ ទៀតក្នុងករណីដែលរដ្ឋបាលសារពើពន្ធ រកឃើញថាថ្លៃលក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាទិញលក់ មានតម្លៃទាបជាងទីផ្សារ រដ្ឋបាលសារពើពន្ធមានសិទ្ធិធ្វើការកំណត់ពន្ធឡើងវិញ នូវថ្លៃលក់ទ្រព្យដោយឈរលើតម្លៃទីផ្សារ ឬ តម្លៃកំណត់ដែលមាននៅក្នុង ឧបសម្ព័ន្ធនៃប្រកាសស្ដីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ ឬ តម្លៃកំណត់ដោយគណៈកម្មការវាយតម្លៃទ្រព្យ នៃ ពន្ធលើចំណេញមូលធន។

២-ថ្លៃដើមនៃទ្រព្យរួមមាន ថ្លៃដើមពេលទិញទ្រព្យ និងចំណាយដែលបានកើតឡើងក្នុងពេលទិញ ឬ ទទួលកាន់កាប់លក់ ឬ ផ្ទេរទ្រព្យដែលមានដូចខាងក្រោម៖

ក-ចំណាយលើសេវាពិគ្រោះយោបល់

ខ-ប្រាក់ពន្ធប្រថាប់ត្រាដែលបានបង់នៅពេលទិញ ឬ ទទួលទ្រព្យ

គ-ប្រាក់ពន្ធលើអចលនទ្រព្យ ឬ ប្រាក់ពន្ធលើដីធ្លីមិនប្រើប្រាស់

ឃ-ចំណាយលើសេវារដ្ឋបាលសុរិយោដី ឬ ភូមិបាល

ង-ចំណាយលើការផ្សព្វផ្សាយពាណិជ្ជកម្ម

ច-ចំណាយលើកម្រៃជើងសារ

ឆ-ចំណាយលើការវាយតម្លៃទ្រព្យ

ជ-ចំណាយលើសេវារដ្ឋបាលចំពោះការខ្ចីប្រាក់ ដើម្បីទិញ ឬ ទទួលទ្រព្យ

ឈ-ចំណាយការប្រាក់ចំពោះការខ្ចីប្រាក់ ដើម្បីទ្រព្យដែលបានបង់ក្នុងអំឡុងពេលកាន់កាប់ទ្រព្យ។

ញ-ចំណាយថែទាំទ្រព្យ និង កែលម្អទ្រព្យ

ដ-ចំណាយក្នុងការបង្កើតឬរក្សាការពារនូវសិទ្ធិកាន់កាប់ទ្រព្យ

**៩-អត្រាពន្ធ**

អត្រាពន្ធលើចំណេញមូលធន ត្រូវបានកំណត់តាមអត្រា ២០ %

**១០-ការគណនាចំណេញមូលធន**

អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតអោយជ្រើសរើសវិធីគណនាចំណេញមូលធនណាមួយក្នុងចំណោមវិធីទាំងពីរដូចខាងក្រោម៖

១-វិធីកាត់កងចំណាយតាមការកំណត់

**ឧទាហរណ៍ ទី ១ ៖** លោក "**ក**" បានលក់ផ្ទះមួយល្វែងមួយទៅអោយលោក "**ខ**" ក្នុងតម្លៃ ៨០០ ០០០ ០០០ រៀល។ លោក "**ក**"មិនរក្សាទុកឯកសារចំណាយនានាពាក់ព័ន្ធនឹងផ្ទះល្វែងនោះ។ ដូចនេះលោក "**ក**" អាចជ្រើសរើសវិធីកាត់កងចំណាយតាមការកំណត់ ដែលត្រូវបានគណនាដូចខាងក្រោម៖

ចំណូលពីការលក់ឬផ្ទេរទ្រព្យ = ៨០០ ០០០ ០០០ រៀល

ការកាត់កងចំណាយតាមការកំណត់ = ៨០% × ចំណូលពីការលក់ ឬ ផ្ទេរទ្រព្យ

= ៨០% × ៨០០ ០០០ ០០០

= ៦៤០ ០០០ ០០០ រៀល

ចំណេញមូលធន = ចំណូលពីការលក់ឬផ្ទេរទ្រព្យ – ចំណាយតាមការកំណត់

= ៨០០ ០០០ ០០០ – ៦៤០ ០០០ ០០០

= ១៦០ ០០០ ០០០ រៀល

២-វិធីកាត់កងចំណាយជាក់ស្តែង

**ឧទាហរណ៍ ទី ២ ៖** លោក "**ក**" បានលក់ផ្ទះមួយល្វែងទៅអោយលោក "**ខ**" ក្នុងតម្លៃ ៦០០ ០០០ ០០០ រៀល ដែលបានទិញក្នុងតម្លៃ ៤០០ ០០០ ០០០ រៀល ដោយបានបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនវត្ថុ ១៦ ០០០ ០០០ រៀល បានចំណាយកម្រៃជើងសាសម្រាប់ការលក់ផ្ទះ ២៤ ០០០ ០០០ រៀល និងបានចំណាយជួសជុលកែលម្អផ្ទះ ២០ ០០០ ០០០ រៀល។

លោក "**ក**" បានរក្សាទុកនូវឯកសារចំណាយនានាពាក់ព័ន្ធការនឹងរកាន់កាប់ និងកែលម្អផ្ទះល្វែងនោះ។

ដូចនេះលោក "**ក**" អាចជ្រើសរើសយកវិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម៖

ចំណូលបានពីការលក់ផ្ទះឬផ្ទេរទ្រព្យ = ៦០០ ០០០ ០០០រៀល

**ចំណាយជាក់ស្តែងសរុប = ថ្លៃដើម + ប្រាក់ពន្ធបានបង់ + ចំណាយកម្រៃជើងសា + ចំណាយកែលម្អ**

= ៤០០ ០០០ ០០០ + ១៦ ០០០ ០០០ + ២៤ ០០០ ០០០ + ២០ ០០០ ០០០

= ៤៦០ ០០០ ០០០ រៀល

ចំណេញមូលធន = ចំណូលពីការលក់ឬផ្ទេរទ្រព្យ - ចំណាយជាក់ស្តែងសរុប

= ៦០០ ០០០ ០០០ – ៤៦០ ០០០ ០០០

= ១៤០ ០០០ ០០០ រៀល

(ប្រក. លេខ ៣៤៦ សហវ. ប្រក ចុះថ្ងៃ ០១ ខែ មេសា ឆ្នាំ២០២០)

**១១-ការគណនាពន្ធលើចំណេញមូលធន**

ពន្ធលើចំណេញមូលធន ត្រូវបានគណនាដោយយកចំណេញមូលធន គុណនឹងអត្រាពន្ធ

**ឧទាហរណ៍ ទី ៣ ៖** លោក "**ក**" ជាអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីការលក់ផ្ទះល្វែងចំនួន ៣៤០ ០០០ ០០០ រៀល។

**ពន្ធលើចំណេញមូលធន** = **ចំណេញមូលធន** × **អត្រា២០** %

= ៣៤០ ០០០ ០០០ × ២០%

= ៦៨ ០០០ ០០០ រៀល

**ឧទាហរណ៍ ទី ៤ ៖** លោក "**ខ**"ជាអ្នកជាប់ពន្ធអនិវាសនជន ទទួលបានចំណេញមូលធនពីការលក់ភាគហ៊ុនក្នុងក្រុមហ៊ុននៅក្នុងព្រះរាជណាចក្រកម្ពុជា ចំនួន ៤០០ ០០០ ០០០ រៀល។

**ពន្ធលើចំណេញមូលធន** = **ចំណេញមូលធន** × **អត្រាថេរ ២០** %

= ៤០០ ០០០ ០០០ × ២០ %

= ៨០០ ០០០ ០០០រៀល

**១២-ពន្ធលើចំណេញមូលធនចំពោះទ្រព្យនៅក្រៅពីព្រះរាជាណាចក្រកម្ពុជា**

ក្នុងករណីអ្នកជាប់ពន្ធជានិវាសនជន ទទួលបានចំណេញមូលធនពីទ្រព្យណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងបានបង់ពន្ធលើចំណេញមូលធនទៅតាមច្បាប់ពន្ធដារបរទេសរួចហើយប្រសិនបើប្រាក់នៅបរទេសនោះ មានចំនួនតិចជាងប្រាក់ពន្ធដែលគណនាតាមចំនុច **១១** ខាងលើនេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមតែចំនុចលម្អៀងប៉ុណ្ណោះ។

## ១៣-ការដាក់លិខិតប្រកាសពន្ធនិងបង់ប្រាក់ពន្ធ

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាសារពើពន្ធ និងបង់ពន្ធលើចំណេញមូលធនតាមប្រតិបត្តិការនីមួយៗ ជូនរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេលមិនលើសពី ០៣ ខែ បន្ទាប់ពីសម្រេចបានចណេញមូលធន។ ចំពោះទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះទ្រព្យនៅតាមបណ្តាខេត្តអ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅតាមសាខាពន្ធដារខេត្តដែលទ្រព្យនោះស្ថិតនៅ។

## ១៤-ឯកសារតម្រូវ

អ្នកជាប់ពន្ធត្រូវផ្តល់ នូវ ឯកសារពាក់ព័ន្ធសម្រាប់ការបង់ពន្ធលើចំណេញមូលធនដូចខាងក្រោម៖

ក- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សំបុត្រកំណើត ឬ លិខិតឆ្លងដែនសម្រាប់ជនបរទេស។

ខ-សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ លិខិតបញ្ជាក់ទីលំនៅផ្សេងៗ

គ- លិខិតបញ្ជាក់របស់អ្នកជាប់ពន្ធអំពីការកំណត់ និវាសនដ្ឋានជាគោលដើមរបស់ខ្លួន។

ឃ-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចនលវត្ថុ ឬ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ដែលចេញដោយសុរិយោលដីឬ ឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបានបញ្ជាក់ដោយអាជ្ញាធរឃុំ, សង្កាត់ឡើងទៅ ឬ

ឯកសារបញ្ជាក់ការទទួលស្គាល់របស់ស្ថាប័នមានសមត្ថកិច្ច។

ង-កិច្ចសន្យាទិញ.លក់ទ្រព្យ ឬ កិច្ចសន្យាដោះដូរ ឬអំណោយ

ច-វិក្កយបត្រទូទាត់ប្រាក់ និង វិក្កយបត្រចំណាយផ្សេងៗ

ឆ-ឯកសារដ៏ទៃទៀតពាក់ព័ន្ធនឹងការលក់ ឬ ផ្ទេរមូលធន។

**១៥-សិទ្ធិក្នុងការត្រួតពិនិត្យ**

រដ្ឋបាលសារពើពន្ធមានសិទ្ធិត្រួតពិនិត្យ ដើម្បីធ្វើការកំណត់ឡើងវិញនូវ មូលដ្ឋានគិតពន្ធ និងប្រាក់ពន្ធត្រូវបង់ក្នុងករណីដែលអ្នកជាប់ពន្ធមិនផ្តល់ឯកសារពាក់ព័ន្ធត្រឹមត្រូវ។

**១៦-ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មូលធន**

រាល់ការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់មូលធនមិនមានលក្ខណៈគតិយុត្តគ្រប់គ្រាន់ទេក្នុងករណីដែលមូលធននោះ មិនទាន់មានការបញ្ជាក់ពីការបង់ពន្ធលើចំណេញមូលធន។

**១៧-ការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន**

ពន្ធលើចំណេញមូលធន ត្រូវចាប់អនុវត្តលើចំណេញមូលធនដែលកើតមានឡើងចាប់ពី ថ្ងៃ ០១ ខែ កក្កដា ឆ្នាំ ២០២០ តទៅ ។

# មេរៀនទី ៧៖ ពន្ធកាត់ទុក

## ១-និយមន័យ

ពន្ធកាត់ទុកគឺជាប្រភេទពន្ធដែលត្រូវកាត់ទុកដោយអ្នកជាប់ពន្ធ និវាសនជនលើការទូទាត់មួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ ឬ ជាវត្ថុទៅឲ្យអ្នកជាប់ពន្ធនិវាសនជន និង អនិវាសនជន។

## ២-គោលការណ៍

១-ស្របតាមមាត្រា ២៥ ថ្មី មាត្រា ២៦ថ្មី (មួយ)និង មាត្រា ៣១ ថ្មី នៃច្បាប់ស្ដីពីសារពើពន្ធអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស ដែលធ្វើការទូទាត់ជាសាច់ប្រាក់ ឬ ជាវត្ថុ ឱ្យទៅបុគ្គលនិវាសជន ឬ អនិវាសនជនត្រូវធ្វើការកាត់ទុកប្រាក់ពន្ធ បង់ជូនរដ្ឋបាលសារពើពន្ធនាពេលទូទាត់។ សម្រាប់គោលដៅនៃពន្ធកាត់ទុកប្រតិបត្តិការណាមួយ ដែលជាកម្មវត្ថុនៃពន្ធកាត់ទុកដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់។

២-ដូចមានចែងក្នុងមាត្រា ៣១ ថ្មី នៃច្បាប់ស្ដីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬ បុគ្គលណាមួយដែលបទប្បញ្ញត្តិ ស្ដីពីពន្ធដារបានតម្រូវឱ្យធ្វើការកាត់ទុក និង បង់ប្រាក់ពន្ធ ក្នុងនាមនៃតតិយជន ត្រូវបានកំណត់ថាជាភ្នាក់ងារកាត់ទុក។

## ៣-ការទូទាត់ប្រភេទពន្ធកាត់ទុកទៅឲ្យនិវាសនជន

ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅទៅដល់៖

ក-រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬ មានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងកម្ពុជា ឬដែលមានវត្តមាននៅក្នុងកម្ពុជាលើសពី ១៨២ ថ្ងៃនៅក្នុងរយៈ១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

ខ-នីតិបុគ្គល ដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រងនៅក្នុងកម្ពុជា ឬដែលមាន កន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងកម្ពុជា។

ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" មានន័យថា៖

បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធ និង និវាសនជន

ពាក្យ "ធនាគារ" សំដៅដល់អង្គភាពដែលអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយក្នុង ចំណោមប្រតិបត្តការដូចខាងក្រោម៖

ក-ផ្តល់ឥណទានគ្រប់ប្រភេទដល់សាធារណជន ដោយមានកម្រៃរាប់បញ្ចូលទាំង ឥទាណភតិសន្យា។

ខ-ទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន

គ-ប្រព្រឹត្តកម្ម និងការដាក់អោយអតិថិជនបានប្រើប្រាស់នូវមធ្យោបាយ ទូទាត់ជា រូបិយវត្ថុ ឬ ជារូបិយប័ណ្ណ។

ពាក្យ "សេវា" រួមមានការគ្រប់គ្រង ឬពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល ក្រៅពី ទំនិញ ភតិសន្យា ការជួល ការលក់ទ្រព្យនិងសកម្មភាពបម្រើការងារដែលជាប់ ពន្ធលើប្រាក់បៀវត្ស។

ពាក្យ "ប្រាក់ចំណូល" សំដៅទៅដល់ប្រាក់ចំណូលកម្រៃជើងសា ឬ ក៏ជើងសារជំនួញ ប្រាក់ចំណូលពីសកម្មភាពដឹកជញ្ជូន ជួសជុល សាងសង់ គ្រប់គ្រង ឬពិគ្រោះ យោបល់ ប្រាក់ចំណូលបានពីសេវាវិទ្យាសាស្ត្របច្ចេកទេស សិល្បៈ ឬការអប់រំ ប្រាក់ចំណូលបានពីសេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ វិស្វកម្ម នីតិសាស្ត្រ ឬស្ថាបត្យ កម្ម ការសិក្សា និងស្រាវជ្រាវគណនេយ្យ ។ល។

ស្ថួយសារពីទ្រព្យសកម្មអរូបីយ៖ សម្រាប់គោលដៅនៃពន្ធកាត់ទុក ស្ថួយសារពីទ្រព្យសកម្មអរូបីយគឺ សំដៅទៅដល់ចំណូលបានមកពីការអនុញ្ញាតឲ្យប្រើប្រាស់នូវសិទ្ធិបោះពុម្ពផ្សាយលក់ស្នាដៃអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រឬការផ្តល់សិទ្ធិប្រហាក់ប្រហែល (ក្នុងនោះរួមមានរាប់បញ្ចូលទាំងសិទ្ធិថតចម្លង ឬការផ្សាយខ្សែអាត់សម្លេង ឬ វីដេអូ) ចំណេះដឹង ឬ ចំណេះធ្វើ ឬ ព័ត៌មានដែលទាក់ទិនបទពិសោធន៏ផ្សេងៗ ទាក់ទងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម ឬ វិទ្យាសាស្ត្របច្ចេកទេស។ល។ ការផ្ទេរសិទ្ធិលើចំណេះ ឬ ព័ត៌មានដូចមានរៀបរាប់នៅក្នុងចំណុចនេះ ឬ ការផ្តល់យោបល់ ឬ ការផ្តល់សេវាទាក់ទិននឹងការអនុវត្ត ឬ ការប្រើប្រាស់សិទ្ធិដូចបានរៀបរាប់នៅចំណុចខាងលើនេះ។

ស្ថួយសារបានមកពីភាគកម្មក្នុងធនធានរ៉ែ៖ សម្រាប់គោលដៅនៃពន្ធកាត់ទុក ជាស្ថួយសារបានមកពីភាគកម្មក្នុងធនធានរ៉ែ សំដៅទៅដល់អត្ថប្រយោជន៏ជាប្រាក់ ឬជាវត្ថុដែលទទួលបានទាក់ទិននិងភាគកម្មនេះ និងភាគកម្មនេះក្រៅតែពីប្រាក់ចំណេញបានមកពីអាជីវកម្មលើធនធាននេះនិងភាគលាភដែលត្រូវជាប់ពន្ធ។

ចំណូលពីការប្រាក់(ស្ថាប័នមិនមែនធនាគារ ឬ ស្ថាប័នសញ្ជ័យធន)៖ ការប្រាក់ដែលអ្នកជាប់ពន្ធ និវាសនជនមិនមែនជាធនាគារ ឬ ស្ថាប័នសញ្ជ័យធន ក្នុងស្រុកបង់ទៅឲ្យរូបវន្តបុគ្គល ឬសហគ្រាស។

ថ្លៃឈ្នួល៖ សម្រាប់គោលបំណងនៃពន្ធកាត់ទុកថ្លៃឈ្នួលពីការជួលចលនទ្រព្យ ឬជួលអចលនទ្រព្យ សំដៅទៅដល់សាច់ប្រាក់ ឬវត្ថុដែលអ្នកជួលបានបង់សម្រាប់ជាថ្នូរនៃការប្រើប្រាស់ចលនទ្រព្យ (ដូចជាបរិក្ខារឧស្សាហកម្ម ពាណិជ្ជកម្ម បច្ចេក

ទេស ឬវិទ្យាសាស្ត្រ) រីឯអចលនទ្រព្យមានដូចជា (ដីធ្លី ផ្ទះ ឬសំណង់ផ្សេងៗ រួមបញ្ចូលលក្ខណៈទាំងអស់របស់ទ្រព្យបន្ទាប់បន្សំ នៃអចលនទ្រព្យនោះ ព្រមទាំងសិទ្ធិអនុវត្តទៅតាមច្បាប់ ស្ដីពីកម្មសិទ្ធិដីធ្លី សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនទ្រព្យ)។ ក្នុងករណីទ្រព្យនោះពុំមានការខូចខាត ឬ ការបំផ្លិចបំផ្លាញណាមួយ និងសិទ្ធិនានាដែលបង្កឲ្យមានការទូទាត់តាមចំនួនកំណត់ឬមិនកំណត់។

ចំណូលពីការប្រាក់ (ប្រាក់បញ្ញើមានកាលកំណត់)៖ ការប្រាក់ដែលធនាគារ ឬ ទៅស្ថាប័នសញ្ញ័យធនក្នុងស្រុក បង់ទៅឲ្យអ្នកជាប់ពន្ធ និវាសនជន រូបវន្តបុគ្គល នីតិបុគ្គល ដែលមានគណនីបញ្ញើមានកាលកំណត់។

ចំណូលពីការប្រាក់ (ប្រាក់បញ្ញើសន្សំគ្មានកាលកំណត់)៖ ការប្រាក់ដែលធនាគារ ឬ ទៅស្ថាប័នសញ្ញ័យធនក្នុងស្រុក បង់ទៅឲ្យរូបវន្តបុគ្គល និវាសនជនដែលមានប្រាក់បញ្ញើនៅក្នុងគណនីសន្សំគ្មានកាលកំណត់។

## ៤-អត្រាភាគរយ នៃ ពន្ធកាត់ទុកលើការទូទាត់ឱ្យទៅបុគ្គល និវាសនជន និង អនិវាសនជន

ភ្នាក់ងារកាត់ទុកដែលធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ឱ្យទៅបុគ្គលនិវាសនជនត្រូវបានកាត់ទុកនិង បង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ៖

១-តាមអត្រា ១៥ ភាគរយ ចំពោះ ៖

ក-ការទូទាត់ចំពោះការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់

ឬ សេវាប្រហាក់ប្រហែល ឱ្យទៅបុគ្គលនិវាសជន ដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ ប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬ ការពិគ្រោះយោបល់ ឬ សេវាប្រហាក់ប្រហែល សំដៅដល់ប្រាក់ចំណូលពីរាល់សកម្មភាពសេដ្ឋកិច្ច របស់បុគ្គលក្រៅពីការផលិត និង ការលក់ទំនិញភតិសន្យា ការជួល ការលក់ទ្រព្យ និង ក្រៅពីសកម្មភាពបម្រើការងារដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស។ ដោយមិនកំណត់ត្រឹមតែដូចតទៅនេះ ប្រាក់ចំណូលពីការបំពេញសេវាជាអាទិ៍មាន។ កម្រៃជើងសា ឬជើងសាជំនួញ ប្រាក់ចំណូលពីសកម្មភាព ដឹកជញ្ជូន ជួសជុល ការសាងសង់គ្រប់គ្រង ពិគ្រោះយោបល់ ប្រាក់ចំណូលពីសេវាប្រហាក់ប្រហែល ដូចជាសេវាខាងបច្ចេកទេស វិទ្យាសាស្ត្រ សិល្បៈ អប់រំសិក្សាធិការ វេជ្ជសាស្ត្រ ទន្តសាស្ត្រនីតិសាស្ត្រ វិស្វកម្មស្ថាបត្យកម្ម ការសិក្សា ស្រាវជ្រាវ គណនេយ្យ ...។

ខ-ការទូទាត់ឱ្យទៅបុគ្គល និវាសជន នូវ ចំណូលពីសួយសារចំពោះទ្រព្យសកម្មអរូបី និងការទូទាត់រាល់អត្ថប្រយោជន៍ផ្សេងៗ ពីភាគកម្មក្នុងធនធានរ៉ែ ក្រៅពីប្រាក់ចំណូលសុទ្ធបានមកពីអាជីវកម្មលើធនធាននេះ និង ភាគលាភដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិដោយឡែក។

គ-ការទូទាត់ការប្រាក់ដែលអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស ដែលមិនមែនជាធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន។

២-តាមអត្រា ១៤ ភាគរយ អនិវាសនជនចំពោះការទូទាត់គ្រប់ប្រភេទទាំងអស់។

៣-តាមអត្រា១០ ភាគរយ ចំពោះការទូទាត់ប្រាក់ចំណូល ពីការជួលចលនទ្រព្យ ឬ

អចលនទ្រព្យ៖ សម្រាប់គោលដៅ នៃពន្ធកាត់ទុកប្រាក់ចំណូល ពីការជួលចលនទ្រព្យ ឬ អចលនទ្រព្យសំដៅដល់សាច់ប្រាក់ ឬ វត្ថុដែលអ្នកទទួលជួល បានបង់សម្រាប់ជាថ្នូរនៃការប្រើប្រាស់ចលនទ្រព្យ ដូចជា បរិក្ខារឧស្សាហកម្ម ពាណិជ្ជកម្ម បច្ចេកទេស វិទ្យាសាស្ត្រ មធ្យោបាយ ដឹកជញ្ជូន និង អចលនទ្រព្យដូចជា ដីធ្លី អគារសំណង់ផ្សេងៗ...។ ក្នុងនេះ អចលនទ្រព្យ ត្រូវបានរួមបញ្ចូលទាំងទ្រព្យបន្ទាប់បន្សំ នៃ អចលនទ្រព្យនោះ ព្រមទាំងសិទ្ធិអនុវត្តទៅតាមច្បាប់ ដែលបានចែងពីកម្មសិទ្ធិដីធ្លី សិទ្ធិកាន់កាប់ សិទ្ធិអាស្រ័យផល លើអចលនទ្រព្យ និង សិទ្ធិនានា ដែលបង្កឱ្យមានការទូទាត់ជាប្រាក់ ឬ ជាវត្ថុតាមចំនួនផ្សេងៗ ឬតាមចំនួនកំណត់។

៤-តាមអត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនី បញ្ញើមានកាលកំណត់។

៥-តាមអត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ទៅឱ្យទៅអ្នកជាប់ពន្ធ និវាសនជនដែលមានគណនីសន្សំ គ្មានកាលកំណត់។

## អត្រាភាគរយពន្ធកាត់ទុក

| ប្រភេទការទូទាត់ | អត្រាភាគរយ |
|---|---|
| ១.អ្នកទទួលនិវាសនជន ចំពោះការបំពេញសេវានានា សួយសារនិងការប្រាក់ទូទាត់ដោយអ្នកជាប់ពន្ធ ក្រៅពីធនាគារ ឬ ស្ថាប័នសញ្ជ័យធន | ១៥% |
| ២.អ្នកទទួលអនិវាសនជនចំពោះការទូទាត់គ្រប់ប្រភេទទាំងអស់ | ១៤% |
| ៣.អ្នកទទួលនិវាសនជន ចំពោះការជួលចលនទ្រព្យនិងអចលនទ្រព្យ | ១០% |
| ៤.អ្នកទទួលអនិវាសនជនចំពោះការប្រាក់ទូទាត់ដោយធនាគារ ឬ ស្ថាប័នសញ្ជ័យធនសម្រាប់គណនីប្រាក់បញ្ញើមានកាលកំណត់ | ៦% |

| | |
|---|---|
| ៥.អ្នកទទួលអនិវាសនជនចំពោះការប្រាក់ទូទាត់ដោយធនាគារ ឬ ស្ថាប័នសញ្ញ័យធនសម្រាប់គណនីសន្សំគ្មានកាលកំណត់ | ៤% |

## ៥-ការលើកលែងការកាត់ទុកប្រាក់ពន្ធ

១-ការទូទាត់ជាសាច់ប្រាក់ ឬ ជាវត្ថុចំពោះករណីដូចខាងក្រោម មិនតម្រូវឱ្យធ្វើការកាត់ទុកប្រាក់ពន្ធទេ៖

ក-ការប្រាក់ដែលបង់ទៅឱ្យធនាគារក្នុងស្រុក និង ការទូទាត់ប្រាក់ចំណូលលើកលែងពន្ធដូចមានចែង (ក្នុងចំណុចទី ៦ ពន្ធលើប្រាក់ចំណូល) ខាងលើនេះ។

ខ-ការទូទាត់ទៅឱ្យរាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាលនូវសួយសារ ឬប្រាក់ថ្លៃឈ្នួលលើចលនទ្រព្យ ឬអចលនទ្រព្យ (ក្នុងនេះមានរួមបញ្ចូលផងដែរនូវប្រាក់បង់លើឡូត៍នេសាទ ព្រៃគុប កំពង់ចម្លង ភាស៊ីផ្សារ.......) ដែលបំពេញបាននូវលក្ខខណ្ឌទាំងពីរ ដូចតទៅ៖

-ការទូទាត់នេះ ត្រូវទាក់ទិននឹងចលនទ្រព្យ ឬ អចលនទ្រព្យបានកត់ត្រាទៅជាទ្រព្យសម្បត្តិរដ្ឋនៅក្នុងបញ្ជីសារពើភណ្ឌដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

-ប្រាក់ទូទាត់ត្រូវមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុថា ជាចំណូលបង់ចូលថវិការដ្ឋ។

គ-ការទូទាត់ប្រាក់ចំណូលរបស់រូបវន្តបុគ្គល ដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ឬ ពន្ធលើអត្ថប្រយោជន៍បន្ថែម ដូចមានចែងក្នុងបទប្បញ្ញត្តិ ស្តីពីពន្ធលើប្រាក់

បៀរត្យ។

ឃ-ការទូទាត់នូវការប្រាក់ដោយរាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាលផ្តល់ទៅឱ្យ បុគ្គលអនិវាសនជនចំពោះប្រាក់ខ្ចីដែលរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានទទួលស្គាល់និងយល់ព្រម។

ង-ការទូទាត់ប្រាក់ចំពោះការផ្គត់ផ្គង់ ឲ្យទៅសេវាណាមួយ ដែលមានតម្លៃក្រោម ៥០ ០០០ រៀល។

២- ការទូទាត់ជាសាច់ប្រាក់ ឬ ជាវត្ថុ ក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបានលើកលែងពីពន្ធកាត់ទុក ចំពោះករណីដូចខាងក្រោម៖

ក-ប្រាក់ចំណូលពីការបំពេញសេវានានា រួមថែមទាំងការគ្រប់គ្រង ឬ ការពិគ្រោះ យោបល់ ឬ សេវាប្រហាក់ប្រហែល។

ខ-ប្រាក់ចំណូលពីការផ្គត់ផ្គង់៖

-កញ្ចប់សូហ្វវែរ ដែលអនុញ្ញាតឱ្យប្រើប្រាស់ដោយបានភ្ជាប់លក្ខខណ្ឌ (Shrink wrap Software)

-សូហ្វវែរ សម្រាប់ប្រើប្រាស់ដោយអង្គភាពមានការកំណត់ (SiteLicense)

-សូហ្វវែរ ដែលអាចទាញយកមកប្រើប្រាស់ (Downloadable Software)

-សូហ្វវែរ ដែលភ្ជាប់ជាមួយកុំព្យូទ័រ (Software Bundled with Computer Hardware)

គ-ប្រាក់ចំណូលពីការជួលចលនទ្រព្យ ឬ អចលនទ្រព្យសម្រាប់ករណីដូចមាន ចែងក្នុងកថាខណ្ឌការទូទាត់ណាមួយដែលត្រូវបានអនុញ្ញាតឱ្យលើកលែងពន្ធ

កាត់ទុកលុះត្រាណាតែចំនួនទឹកប្រាក់នោះ ត្រូវបានកត់ត្រាក្នុងវិក្កយបត្រដែលបានចេញយ៉ាងត្រឹមត្រូវ ដោយភាគីអ្នកជាប់ពន្ធតាម របបស្វ័យប្រកាស ម្ខាងទៀត។

## ៦-ការគណនាទឹកប្រាក់ពន្ធកាត់ទុក

១-ចំនួនប្រាក់ពន្ធត្រូវកាត់ទុកត្រូវបានគណនា លើទឹកប្រាក់ដែលត្រូវទូទាត់ឱ្យបុគ្គលណាមួយនៅមុនពេលកាត់ទុក ប្រាក់ពន្ធ។

២-ចំពោះការទូទាត់ប្រាក់ឱ្យអនិវាសនជន ដែលទាក់ទិនទៅ នឹង ការផ្គត់ផ្គង់សម្ភារៈបរិក្ខារផង និងសេវាផង ដូចជាការទូទាត់ចំណាយទិញម៉ាស៊ីន ពីក្រៅប្រទេសដែលរួមមានថ្លៃទិញម៉ាស៊ីននិងថ្លៃសេវាផ្គុំដំឡើងដោយអ្នកបច្ចេកទេសជាបុគ្គល អនិវាសនជនសម្រាប់ដំណើរការដើមដំបូងនៃម៉ាស៊ីនមូលដ្ឋានសម្រាប់គិតពន្ធកាត់ទុកគឺ ជាចំណែកប្រាក់ដែលទាក់ទិន នឹង ការផ្តល់សេវាផ្គុំដំឡើងតែប៉ុណ្ណោះ។

## ៧-ភាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភ្នាក់ងារកាត់ទុក

១- ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹម ថ្ងៃ ទី ២០ នៃ ខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុកតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ។

២-ភ្នាក់ងារកាត់ទុកដែលមានកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ ប៉ុន្តែមិនបានធ្វើការកាត់ទុកនិងបង់ជាប្រាក់ពន្ធ ជូនរដ្ឋបាលសារពើពន្ធ ត្រូវទទួលខុសត្រូវ ចំពោះប្រាក់ពន្ធដែលមិនបានកាត់ទុកនោះ ព្រមទាំងទោសទណ្ឌផ្សេងៗ ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។

# មេរៀនទី ៨៖ ការប្រមូលពន្ធលើអាករលើតម្លៃបន្ថែម

## ១-និយមន័យ

១- ពាក្យ "ទំនិញ" សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លីនិងប្រាក់កាស។

២- ពាក្យ "សេវា" សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញដីធ្លីនិងប្រាក់កាស។

៣-ពាក្យ "ការផ្គត់ផ្គង់ទំនិញ" សំដៅដល់ការផ្ទេរសិទ្ធិប្រើប្រាស់ ឬ សិទ្ធិចាត់ចែងក្នុងឋានៈ ជាម្ចាស់កម្មសិទ្ធិទំនិញ ទោះបីមានសំណង ឬ គ្មានសំណងក្តី។ ការផ្គត់ផ្គង់សេវាបន្ទាប់បន្សំដែលទាក់ទិននិងការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកដូចការផ្គត់ផ្គង់ទំនិញ។

៤-ពាក្យ "ការផ្គត់ផ្គង់សេវា" សំដៅទៅដល់ការផ្គត់ផ្គង់ ដែលមិនមែនជាការផ្គត់ផ្គង់ទំនិញ ដីធ្លី ឬ ប្រាក់កាសដែលធ្វើឡើងដើម្បីបានទទួលសំណងអ្វីមួយ។ ការផ្គត់ផ្គង់ទំនិញបន្ទាប់បន្សំដែលទាក់ទង និង ការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់សេវា។

៥-ពាក្យ"បុគ្គល"សំដៅទៅដល់បុគ្គល ឬ ក្រុមបុគ្គលដែលធ្វើអាជីវកម្ម ហើយនិងបុគ្គលណាមួយទៀតដែលទាក់ទិនជាមួយបុគ្គលនោះ។

៦-ពាក្យ "ទាក់ទិន" ចំពោះបុគ្គលណាមួយ មានន័យថាៈ

ក-បុគ្គលណាមួយដែលមានកម្មសិទ្ធិចាប់ពី ២០% ឡើងទៅលើតម្លៃ ឬ ត្រូវមានសិទ្ធិបោះឆ្នោត នៃភាគកម្មនៅក្នុងដើមទុនផ្ទាល់។

ខ-មានការគ្រប់គ្រងរួមគ្នា ឬ មាននាយករួមគ្នា

គ-ជាសមាជិកគ្រួសារ ឬ ជាសហព័ន្ធ ឬ ជាសមាជិកគ្រុមគ្រួសារនៃសហព័ន្ធ

៧- ពាក្យ "អាករ" ក្នុងជំពូកនេះ សំដៅដល់អាករលើតម្លៃបន្ថែម

## ២-ភាតព្វកិច្ចចុះបញ្ជី

១- ដូចមានចែងក្នុងមាត្រា ៥៩ និងមាត្រា ៧៦ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបពិត ដែលបានធ្វើការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងមាត្រា ៦០ នៃច្បាប់ស្តីពីសារពើពន្ធ គឺជាបុគ្គលជាប់អាករ។ បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែម មុនពេលចាប់ផ្តើមប្រកបអាជីវកម្ម។ បុគ្គលដទៃទៀតត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឲ្យបានស្រេចបាច់ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ។ បុគ្គលទាំងនោះរួមមាន ៖

ក- ក្រុមហ៊ុនគ្រប់ប្រភេទសហគ្រាសនិហរ័ណ អាហរ័ណ និងសហគ្រាសវិនិយោគទាំងអស់។

ខ-សហគ្រាសដទៃទៀតដែលមានផលរបរជាប់អាករ ក្នុងរយៈពេលបីខែ ប្រតិទិនជាប់គ្នាណាមួយចាប់ពី ១២៥ លានរៀល ឡើងទៅ សម្រាប់ការផ្គត់ផ្គង់ទំនិញ ឬ ចាប់ពី ៦៤ លានរៀល ឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា។

គ-សហគ្រាសទាំងឡាយ ដែលក្នុងពេលចាប់ផ្តើមនៃរយៈពេល ៣ ខែប្រតិទិនជាប់គ្នាណាមួយមានមូលដ្ឋានជឿជាក់ថា ក្នុងរយៈពេលបី ខែ ប្រតិទិនជាប់គ្នានោះនឹង មានផលរបរជាប់អាករចាប់ពី ១២៥ លានរៀល ឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬ ចាប់ពី ៦០ លានរៀល ឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា។

ឃ-សហគ្រាសទាំងឡាយដែលមានក្នុងពេលចាប់ផ្តើមនៃរយៈពេល៣ ខែប្រតិទិនជាប់គ្នាណាមួយ មានផលរបរជាប់អាករបានមកពីការធ្វើកិច្ចសន្យា ជាមួយរដ្ឋ

ចាប់ពី ៣០ លានរៀលឡើងទៅ។

ក្នុងករណីដែលបុគ្គលធ្វើការផ្គត់ផ្គង់ទំនិញនិងផ្គត់ផ្គង់សេវាផង មានផលរបរជាប់អាករលើសពីកម្រិតអប្បបរមា នៃផលរបរត្រូវចុះបញ្ជីដែលបានកំណត់ក្នុងចំណុច **ខ** ចំណុច **គ** និងចំណុច **ឃ** នៃ ចំណុច ១ ខាងលើនេះ បុគ្គលនោះត្រូវដាក់ពាក្យស្នើសុំចុះបញ្ជី។

សម្រាប់គោលដៅដូចមានចែងខាងលើនេះ ៖

-ពាក្យ "ផលរបរជាប់អាករ" សំដៅ ដល់ផលរបរដែលបានមកពីការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា ឬការចុះកិច្ចសន្យាជាមួយរដ្ឋ ដោយមិនទាន់គិតបញ្ចូលអាករទេ។

-ពាក្យ "អាករ" មានន័យថា អាករលើតម្លៃបន្ថែម ហៅកាត់ថា "អតប" ។

២-កម្រិតអប្បបរមា នៃ ផលរបរជាប់អាករប្រចាំឆ្នាំ សម្រាប់ការចុះបញ្ជី អនុវត្តចំពោះបុគ្គលដែលមិនមានលក្ខណៈជា សហគ្រិន និហរណៃ អាហរណៃ ឬ សហគ្រាសវិនិយោគគឺ ៥០០ លានរៀល សម្រាប់ការផ្គត់ផ្គង់ទំនិញ ២៥០ លានរៀល សម្រាប់ការផ្គត់ផ្គង់សេវានិង ១២៥លានរៀលសម្រាប់ការធ្វើកិច្ចសន្យាជាមួយនឹងរដ្ឋ។

៣-ស្ថាប័នរដ្ឋ ឬ អង្គភាពរបស់ស្ថាប័នរដ្ឋគ្រប់លំដាប់ថ្នាក់ ដែលធ្វើសកម្មភាពអាជីវកម្មក្រោមរូបភាពស្វ័យភិបាលសេដ្ឋកិច្ច ត្រូវដាក់ពាក្យស្នើសុំធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមអោយបានស្រេចបាច់ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយថ្ងៃដែលស្ថាប័នរដ្ឋ ឬអង្គភាពនោះក្លាយជាបុគ្គលជាប់អាករ។

៤-បុគ្គលណាមួយដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬ សេវាដោយមានតម្លៃដែលជាចំណែកមួយ នៃ សកម្មភាពអាជីវកម្មរបស់ខ្លួន ហើយដែលមិនស្ថិតក្រោមកាតព្វកិច្ច ចុះបញ្ជីតាមការតម្រូវ

នៃចំណុច ១ ឬ ចំណុច ៣ ខាងលើនេះ បុគ្គលនោះអាចធ្វើការស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីចុះបញ្ជីស្របទៅតាមបទប្បញ្ញត្តិច្បាប់។

## ៣-ការតម្រូវចំពោះការចុះបញ្ជី

### ៣.១-ទម្រង់នៃពាក្យស្នើសុំចុះបញ្ជី

ការដាក់ពាក្យស្នើសុំចុះបញ្ជីដូចមានចែងក្នុងចំណុច ២ ខាងលើនេះ ត្រូវធ្វើឡើងតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ហើយបុគ្គលដែលបានដាក់ពាក្យស្នើសុំ ត្រូវធ្វើការផ្តល់ព័ត៌មាននានាទៅតាមការតម្រូវរបស់នាយកដ្ឋានពន្ធដារ។

### ៣.២-សិទ្ធិក្នុងការចុះបញ្ជី

នាយកដ្ឋានពន្ធដារ ត្រូវចុះបញ្ជីបុគ្គលដែលបានដាក់ពាក្យស្នើសុំ ដូចមានចែងក្នុងចំណុច ១ និងចំណុច ៣ នៃចំណុច ២ ខាងលើនេះ ហើយត្រូវចេញឲ្យបុគ្គលនោះនូវវិញ្ញាបនបត្រចុះបញ្ជីដោយក្នុងនោះមានទាំងលេខអត្តសញ្ញាណកម្ម អតប ផង លើកលែងតែក្នុងករណីដែលនាយកដ្ឋានពន្ធដារយល់ឃើញថា បុគ្គលដែលបានដាក់ពាក្យស្នើសុំពុំមានកាតព្វកិច្ចចុះបញ្ជីតាមចំណុច ២ ខាងលើនេះ ឬ ចំពោះករណីនៃការដាក់ពាក្យស្នើសុំតាមកថាខណ្ឌ៤ នៃចំណុច ២ ខាងលើនេះដោយមូលហេតុ ៖

ក- បុគ្គលពុំមានកន្លែងស្នាក់នៅ ឬកន្លែងធ្វើអាជីវកម្មពុំជាប់លាប់

ខ-នាយកដ្ឋានពន្ធដារ មានមូលដ្ឋានត្រឹមត្រូវជឿជាក់ថា បុគ្គលនោះនឹងមិនកាន់កាប់ កត់ត្រាបានត្រឹមត្រូវនូវបញ្ជីឯកសារគណនេយ្យជាប់ទាក់ទិន នឹង សកម្មភាពអាជីវកម្មរបស់ខ្លួន នឹង មិនដាក់លិខិតប្រកាសសារពើពន្ធឲ្យបានទៀងទាត់ និងច្បាស់លាស់អាចប្រើការបានតាមការតម្រូវដូចមានចែងក្នុងមាត្រា ៧០ នៃ

ច្បាប់ស្តីពីសារពើពន្ធ។

**៣.៣-កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី**

កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី គឺជាការបរិច្ឆេទដែលបុគ្គលស្នើសុំចុះបញ្ជីក្លាយជាបុគ្គលជាប់អាករ។ កាលបរិច្ឆេទមានប្រសិទ្ធភាពនេះចាប់ផ្តើម ៖

ក-ពីដើម ខែ បន្ទាប់ ពី ខែ ដែលកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីបានកើតមានឡើង សម្រាប់ករណីនៃការដាក់ពាក្យស្នើសុំមានចែងក្នុងចំណុច ១ ចំណុច ៣ នៃចំណុច **២** ខាងលើនេះ។

ខ-ពីដើមខែបន្ទាប់ ពីខែដែលបុគ្គលបានដាក់ពាក្យស្នើសុំចុះបញ្ជីសម្រាប់ករណីនៃការដាក់ពាក្យស្នើសុំដូចមានចែងក្នុងកថាខណ្ឌ៤ នៃចំណុច **២** ខាងលើនេះ។

**៣.៤-វិញ្ញាបនបត្រចុះបញ្ជី**

វិញ្ញាបនប័ត្រចុះបញ្ជីត្រូវមានចុះ ឈ្មោះ លេខអត្តសញ្ញាណកម្ម អតប កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី និងព័ត៌មានលម្អិតផ្សេងទៀតរបស់បុគ្គលជាប់អាករ។

**៣.៥-ការដាក់តាំងវិញ្ញាបនប័ត្រចុះបញ្ជី**

បុគ្គលជាប់អាករដែលបានចុះបញ្ជីត្រូវដាក់តាំង ឬ ព្យួរវិញ្ញាបនប័ត្រចុះបញ្ជីដែលបានចេញឱ្យតាមបទប្បញ្ញត្តិ នៅទីកន្លែងអាជីវកម្មជាសំខាន់របស់ខ្លួន។

**៣.៦-បញ្ជីអាករលើតម្លៃបន្ថែម**

នាយកដ្ឋានពន្ធដារ ត្រូវមានបញ្ជីសម្រាប់កត់ត្រាតាមដាននូវព័ត៌មានលម្អិត ដែលទាក់ទិននឹងបុគ្គលជាប់អាករម្នាក់ៗ ។

**៣.៧-អំណាចក្នុងការចុះបញ្ជី**

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធិចុះបញ្ជីបុគ្គលណាមួយ បើសិនជាមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាបុគ្គលនោះ មានកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីដូចមានចែងក្នុងចំណុច ១ និង ចំណុច ៣ នៃ ចំណុច **២** ខាងលើនេះ ក៏ប៉ុន្តែមិនបានដាក់ពាក្យស្នើសុំ ហើយការចុះបញ្ជីត្រូវមានប្រសិទ្ធិភាពចាប់ពីកាលបរិច្ឆេទដែលមានចុះបញ្ជីនៅក្នុងវិញ្ញាបនបត្រចុះបញ្ជី។

**៣.៨-សេចក្តីជូនដំណឹងអំពីការសម្រេចយល់ព្រម ឬ មិនយល់ព្រមចុះបញ្ជី**

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការសម្រេចយល់ព្រមឬមិនយល់ព្រមចុះបញ្ជី អោយដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំដូចមានចែងក្នុង ចំណុច **៣.២** ខាងលើនេះ ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយបានទទួលពាក្យស្នើសុំ។

**៣.៩-សេចក្តីជូនដំណឹងអំពីការចុះបញ្ជីជាឯកតោភាគី**

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចចុះបញ្ជីជាឯកតោភាគីឱ្យដល់បុគ្គលដូចមានចែងក្នុងចំណុច **៣.៧** ខាងលើនេះ ក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលមានការសម្រេច។

**៣.១០-ការប្រែប្រួលព័ត៌មានបុគ្គលជាប់អាករ**

បុគ្គលជាប់អាករ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយកដ្ឋានពន្ធដារ អំពីការប្រែប្រួល ៖

ក-នាមករណ៍ ឬអាសយដ្ឋានរបស់បុគ្គលនោះ

ខ-ស្ថានភាពផ្សេងៗ ដែលបណ្តាលឲ្យបុគ្គលនោះមិនអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីតទៅទៀត

គ-ប្រភេទនៃសកម្មភាពអាជីវកម្ម ឬ ប្រភេទនៃការផ្គត់ផ្គង់ជាប់អាករដែលកំពុងតែ អនុវត្ត និង ព័ត៌មានផ្សេងៗ ទៀតការជូនដំណឹងនេះត្រូវធ្វើក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយការប្រែប្រួលបានកើតមានឡើង។

## ៤-ការចុះបញ្ជីសហគ្រាសវិនិយោគ

### ៤.១-ការចុះបញ្ជីសហគ្រាសវិនិយោគ

បុគ្គលដែលមានការទទួលស្គាល់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសហគ្រាសវិនិយោគ ហើយដែលមិនទាន់បានធ្វើការផ្គត់ផ្គង់ជាប់អាករ អាចស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីសហគ្រាសវិនិយោគសម្រាប់រយៈពេលមិនលើសពី ២ ឆ្នាំ។

### ៤.២-លក្ខខណ្ឌនៃការចុះបញ្ជី

បុគ្គលដែលស្នើសុំចុះបញ្ជីសហគ្រាសវិនិយោគ ត្រូវផ្តល់នូវកិច្ចសន្យា និងវត្ថុធានាទៅតាមការតម្រូវរបស់នាយកដ្ឋានពន្ធដារ សម្រាប់ទូទាត់សងវិញនូវប្រាក់អាករដែលនាយកដ្ឋានពន្ធដារបានបង្វិលសង បើសិនជាបុគ្គលនោះមិនបានធ្វើការផ្គត់ផ្គង់ជាប់អាករក្នុងរយៈពេលដែលត្រូវបានចុះបញ្ជីសហគ្រាសវិនិយោគ។

### ៤.៣-ការបង្វិលសងវិញនូវអាករលើធាតុចូល

សហគ្រាសវិនិយោគអាចទាមទារ និង ត្រូវបានបង្វិលសងវិញ នូវអាករលើធាតុចូលដែលបានបង់លើចំណាយលើធាតុចូល ទោះបីជាការនាំចូល ឬ ជាការទទួលក្នុងស្រុកក្តី ដែលទាក់ទិនទៅនឹងគម្រោងសកម្មភាពអាជីវកម្មជាប់អាកររបស់សហគ្រាស។

### ៤.៤-ភាតព្វកិច្ចរបស់សហគ្រាសវិនិយោគ

សហគ្រាសវិនិយោគត្រូវគោរពប្រតិបត្តិរាល់ភារកិច្ច និងកាតព្វកិច្ចទាំងអស់របស់បុគ្គលជាប់អាករដែលបានចុះបញ្ជី មានជាអាទិ៍ ការកាន់កាប់ថែរក្សាបញ្ជីគណនេយ្យ និង ការដាក់លិខិតប្រកាសឲ្យបានទៀងទាត់។

### ៤.៥-ការបញ្ចប់លក្ខណៈសម្បត្តិជាសហគ្រាសវិនិយោគ

ការចុះបញ្ជីសហគ្រាសវិនិយោគរបស់បុគ្គលណាមួយ ត្រូវបានបញ្ចប់ភ្លាមកាលណា ៖

ក-បុគ្គលបានធ្វើការផ្គត់ផ្គង់ជាប់អាករក្នុងដំណើរការប្រកបអាជីវកម្ម

ខ-ផុតរយៈពេលពីរឆ្នាំក្រោយពីកាលបរិច្ឆេទខេត្តចុះបញ្ជី បើសិនជាបុគ្គលពុំបានធ្វើការផ្គត់ផ្គង់ជាប់អាករ។

## ៥-ការលុបចោលការចុះបញ្ជី

### ៥.១-ការបញ្ចប់អាជីវកម្ម

បុគ្គលជាប់អាករត្រូវបានស្នើសុំជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋានពន្ធដារ ឲ្យលុបចោលការចុះបញ្ជីរបស់ខ្លួន បើសិនជាបុគ្គលនោះឈប់ធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាដោយមានតម្លៃដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួន។

### ៥.២-ការថយចុះផលរបរជាប់អាករ

បុគ្គលជាប់អាករអាចស្នើសុំជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋានពន្ធដារ ឲ្យធ្វើការលុបចោលការចុះបញ្ជីរបស់ខ្លួន ប្រសិនបើកម្រិតផលរបរជាប់អាករ របស់ខ្លួនក្នុងរយៈពេលបីខែប្រតិទិនចុងក្រោយ មានចំនួនមិនលើសពីកម្រិតអប្បបរមានៃផលរបរត្រូវចុះបញ្ជី ដូចមានចែងក្នុង

ចំណុច ១ នៃចំណុច **២** ខាងលើនេះ ឬ ប្រសិនបើកម្រិតផលរបរជាប់អាករសម្រាប់រយៈពេល ១២ ខែប្រតិទិនចុងក្រោយមានចំនួនលើសពី៧៥% នៃកម្រិតអប្បបរមានៃផលរបរប្រចាំឆ្នាំត្រូវចុះបញ្ជី។

### ៥.៣-សិទ្ធិលុបចោលការចុះបញ្ជីដោយស្ម័គ្រចិត្ត

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធិលុបចោលការចុះបញ្ជីរបស់បុគ្គលដែលស្នើសុំចុះបញ្ជីតាមកថាខណ្ឌ៤ នៃចំណុច **២** ខាងលើនេះ ក្នុងករណីដែលបុគ្គលនោះ៖

ក-គ្មានទីកន្លែងស្នាក់នៅ ឬ កន្លែងអាជីវកម្មជាប់លាប់

ខ-មិនបានរក្សាទុកបញ្ជីគណនេយ្យឲ្យត្រឹមត្រូវដែលទាក់ទិនទៅ នឹង សកម្មភាពអាជីវកម្មណាមួយរបស់បុគ្គលនោះ

គ-មិនបានដាក់លិខិតប្រកាស អតប ទៀងទាត់និងត្រឹមត្រូវ ដូចមានចែងនៅក្នុងមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធ។

### ៥.៤-សិទ្ធិលុបចោលការចុះបញ្ជី

ប្រធាននាយកដ្ឋានពន្ធដារមានសិទ្ធិលុបចោលការចុះបញ្ជី៖

ក-របស់បុគ្គលដែលបានស្នើសុំលុបតាមចំណុច **៥.១** ឬ **៥.២** នៃចំណុចខាងលើនេះ

ខ-របស់បុគ្គលដែលមិនបានស្នើសុំលុបការចុះបញ្ជី ដោយប្រធាននាយកដ្ឋានពន្ធដារយល់ឃើញថាបុគ្គលនោះគ្មានការតម្រូវ គ្មានសិទ្ធិចុះបញ្ជី តាមចំណុច **២** ខាងលើនេះ

គ-របស់បុគ្គលដែលមិនបានដាក់ពាក្យស្នើសុំលុបចោលការចុះបញ្ជីក៏ប៉ុន្តែមិនបានប្រកាសអំពីការផ្គត់ផ្គង់ជាប់អាករ ក្នុងរយៈពេលបីខែប្រតិទិនជាប់គ្នា។

### ៥.៥-លិខិតជូនដំណឹងដែលទាក់ទិននឹងការស្នើសុំលុបចោលការចុះបញ្ជី

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលជាប់អាករ អំពីការសម្រេចយល់ព្រម ឬមិនយល់ព្រមលុបចោលការចុះបញ្ជីតាមផ្នែកនេះ ក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលទទួលពាក្យស្នើសុំលុបចោលការចុះបញ្ជី តាមចំណុច **ក** នៃចំណុច **៥.៣** ខាងលើនេះ ឬក្នុងរយៈពេល 30 ថ្ងៃក្រោយ ការសម្រេចអាចលុបចោលការចុះបញ្ជីតាចំណុច **ខ** នៃចំណុច **៥.៣** និងចំណុច **៥.៤** ខាងលើនេះ។

### ៥.៦-កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការលុបចោលការចុះបញ្ជី

ការលុបចោលការចុះបញ្ជីត្រូវមានប្រសិទ្ធិភាពចាប់ពីដំណាច់ខែ ដែលការចុះបញ្ជីត្រូវបានលុបចោល។

### ៥.៧-ការលុបចេញពីបញ្ជី

ក្នុងករណីដែលការចុះបញ្ជីរបស់បុគ្គលត្រូវបានលុបចោល នាយកដ្ឋានពន្ធដារត្រូវលុបឈ្មោះបុគ្គលនោះ និងព័ត៌មានលម្អិតដូចមានចែងក្នុងចណុច **៣.៤** ខាងលើនេះ ចេញពីបញ្ជីបុគ្គលជាប់អាករ។

### ៥.៨-បំណុលអាករនៅពេលលុបចោលការចុះបញ្ជី

នៅពេលដែលបុគ្គលជាប់អាករត្រូវបានលុបឈ្មោះចេញពីបញ្ជីតាមផ្នែកនេះ បុគ្គលជាប់អាករត្រូវចាត់ទុកថា បានធ្វើការផ្គត់ផ្គង់ជាប់អាករ នូវទំនិញទាំងអស់ដែលនៅក្នុងដៃរួមទាំងទំនិញជាមូលធនផង និងត្រូវបង់អាករលើជាតុចេញលើរាល់ទំនិញទាំងអស់ដែលបានទទួលឥណទានអាករលើជាតុចូលរួចមកហើយ។ អាករលើជាតុចេញត្រូវបង់ ត្រូវផ្អែកតាមតម្លៃទីផ្សារនៃទំនិញនៅពេលលុបចោលការចុះបញ្ជីនោះ។

### ៥.៩-ប្រសិទ្ធភាពនៃការលុបចោលចំពោះកាតព្វកិច្ចតាមផ្លូវច្បាប់

ការលុបចោលការចុះបញ្ជីរបស់បុគ្គលពុំមានផលប៉ះពាល់ដល់កាតព្វកិច្ច បំណុល និង ទោសទណ្ឌរបស់បុគ្គលដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ រួមទាំងការតម្រូវឲ្យ ដាក់លិខិតប្រកាសតាមមាត្រា ៧០ នៃ ច្បាប់ស្តីពីសារពើពន្ធដែលបុគ្គលបានធ្វើ ឬ មិនបានធ្វើនៅ ពេលដែលខ្លួនជាបុគ្គលជាប់អាករ។

## ៦-ឥណទានអាករលើធាតុចូល

### ៦.១-ឥណទានអាករលើធាតុចូលនៅពេលចាប់ផ្តើមចុះបញ្ជីអាករលើតម្លៃបន្ថែម

១-នៅពេលដែលបានធ្វើការចុះបញ្ជីបុគ្គលជាប់អាករត្រូវបានអនុញ្ញាតឱ្យនូវឥណទាន សម្រាប់អាករលើធាតុចូលដែលបានបង់ឬត្រូវបង់ចំពោះ ៖

ក-ការផ្គត់ផ្គង់ជាប់អាករទាំងអស់នូវទំនិញ រួមទាំងទ្រព្យសកម្មជាមូលធនដែលជា បុគ្គលបានទទួលមុនពេលចុះបញ្ជី។

ខ-ការនាំចូលទាំងអស់នូវទំនិញ រួមទាំងទ្រព្យសកម្មជាមូលធន ដែលបុគ្គលបាន ធ្វើមុនពេលចុះបញ្ជី។

២- លក្ខខណ្ឌនៃការអនុញ្ញាតអោយជាឥណទានត្រូវបានកំណត់ដូចតទៅ ៖

ក-ទំនិញត្រូវបានទិញសម្រាប់ការលក់ជាប់អាករ ឬ សម្រាប់ប្រើប្រាស់ដើម្បីធ្វើការ ផ្គត់ផ្គង់ជាប់អាកររបស់បុគ្គលជាប់អាករ។

ខ-ទំនិញដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌ ត្រូវនៅក្នុងដៃមានកាលបរិច្ឆេទមាន ប្រសិទ្ធភាពនៃការចុះបញ្ជី។

គ-ការផ្គត់ផ្គង់ ឬ ការនាំចូលទាំងនោះត្រូវបានធ្វើឡើងមិនលើសពី ៦០ ថ្ងៃ មុនកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។

ឃ-ពាក្យស្នើសុំឥណទានត្រូវបានធ្វើឡើងតាមទម្រង់ ដែលនាយកដ្ឋានពន្ធដារបានកំណត់។

ង-ត្រូវមានឯកសារភ័ស្តុតាងត្រឹមត្រូវច្បាស់លាស់ជូននាយកដ្ឋានពន្ធដារ បញ្ជាក់ថាបុគ្គលបានបង់អាករដែលអាចអនុញ្ញាតជាឥណទានពិតមែន។

## ៦.២-ការគណនាអាករដែលត្រូវបង់

នៅពេលបុគ្គលជាប់អាករគណនាប្រាក់អាករដែលត្រូវបង់ក្នុងខែ បុគ្គលជាប់អាករនោះត្រូវបានអនុញ្ញាតឲ្យជាឥណទានសម្រាប់អាករដែលបានបង់លើ៖

ក-រាល់ការផ្គត់ផ្គង់ជាប់អាករដែលបុគ្គលជាប់អាករបានទទួលក្នុងខែ

ខ-រាល់ការនាំចូលទំនិញ ដែលបុគ្គលជាប់អាករក្នុងខែផ្តល់ឥណទានអាករត្រូវបានអនុញ្ញាតផ្តល់ឱ្យតែចំពោះការផ្គត់ផ្គង់ជាប់អាករ ឬការនាំចូលសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អាករតែប៉ុណ្ណោះ។

ឧទាហរណ៍ទី១ ការទិញ នៅដើមខែ មករា ឆ្នាំ២០២០៖

| | | |
|---|---|---|
| តម្លៃជាប់អាករ( នាំចូល ) | = | ១ 000 |
| អបត ១០% បង់នៅពេលនាំចូល | = | ១០០ |
| ការទិញក្នុងស្រុក | = | ២០០ |
| អបត ១០% | = | ២០ |

- ការលក់នៅដើម ខែ មករា ឆ្នាំ ២០២០៖

តម្លៃជាប់អាករ = ១ ៥០០

អបត ១០% គិតពីអតិថិជន = ១៥០

**គណនា អតប = អាករលើធាតុចេញ – អាករលើធាតុចូល**

អាករលើធាតុចេញ = ១៥០

អាករលើធាតុចូល (១០០+២០) = ១២០

អាករត្រូវបង់ = ១៥០ – ១២០ = <u>៣០</u>

ឧទាហរណ៍ ទី២ (ឥណទាន អតប យោង)៖

- ការទិញនៅខែ កុម្ភៈ ឆ្នាំ ២០២០៖

តម្លៃជាប់អាករ (នាំចូល) = ១ ០០០

អបត ១០% បង់ពេលនាំចូល = ១០០

ការទិញក្នុងស្រុក = ២០០

អបត ១០% = ២០

- ការលក់ នៅខែ កុម្ភៈ ឆ្នាំ ២០២០៖

តម្លៃជាប់អាករ = ៩៥០

អបត ១០% = ៩៥

**គណនា អតប៖ = អាករលើធាតុចូល – អាករលើធាតុចេញ**

អាករលើធាតុចេញ = ៩៥

អាករលើធាតុចូល (១០០+២០) = (១២០)

**ឥណទាន អតប យោងទៅមុខ** = ១២០ – ៩៥ = <u>២៥</u>

(អគ្គនាយកដ្ឋានពន្ធដារ,២០១៣,សេចក្តីណែនាំគណនាពន្ធ)

## ៦.៣-ការបរិច្ឆេទដល់កំណត់នៃអាករលើធាតុចូល

ឥណទានអាករលើធាតុចូលត្រូវកើតមានឡើងនៅពេលដូចខាងក្រោមនេះ៖

ក-នៅពេលដែលទំនិញ ឬសេវា ត្រូវបានផ្គត់ផ្គង់ទៅឱ្យបុគ្គលជាប់អាករ ឬ នាំចូលដោយបុគ្គលជាប់អាករ ក្នុងករណី ឥណទានអាករនឹងដូចមានចែងក្នុងចំណុច **៦**.**២** ខាងលើនេះ។

ខ-នៅពេលបុគ្គលជាប់អាករត្រូវបានចុះបញ្ជី ក្នុងករណីឥណទានអាករដូចមានចែងក្នុងចំណុច **៦**.**១** ខាងលើនេះ។

## ៦.៤-អាករលើធាតុចូលដែលមិនអនុញ្ញាតជាឥណទានអាករ

បុគ្គលជាប់អាករទាំងឡាយ មិនត្រូវបានអនុញ្ញាតឲ្យជាឥណទានអាករលើជាតុចូលទេចំពោះប្រាក់អាករដែលបានបង់លើ៖

ក-ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬ ការសម្រាកលំហែលើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មផ្គត់ផ្គង់ ការទទួលភ្ញៀវការកំសាន្ត ឬការសម្រាកលំហែ។

ខ-ការទិញ ឬ ការនាំចូលរថយន្ត លើកលែងតែបុគ្គល ជាប់អាករប្រកបអាជីវកម្មលក់ ឬ ជួលរថយន្ត។

គ-ការទិញឬការនាំចូលផលិតផលគេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករ ប្រកបអាជីវកម្មផ្គត់ផ្គង់ផលិតផលគេលសិលាទាំងនោះ។

ឃ-ការនាំចូលផលិតផលគេលសិលាសំដៅដល់ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែ ប្រេងម៉ាស៊ូត ប្រេងរំអិល។

គ-ការបង់លើសេវាទូរស័ព្ទចល័ត។ ( តាមមាត្រា ៦៩ នៃ ច្បាប់សារពើពន្ធ )

**៦.៥-អាករលើធាតុចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និង មួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ**

ក្នុងករណីទំនិញ ឬ សេវាទិញចូល ត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និង មួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ។

**៦.៦-ការគណនាឥណទានអាករលើធាតុចូល**

អាករលើធាតុចូលដែលអាចអនុញ្ញាតជាឥណទានអោយដល់បុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករគឺ៖

ក-អាករលើធាតុចូលទាំងអស់ដែលមានបញ្ជាក់នៅក្នុង ចំណុច **៦**.**២** ខាងលើនេះ ក្នុងករណីដែលការផ្គត់ផ្គង់ទាំងអស់របស់បុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករនោះ ជាការផ្គត់ផ្គង់ជាប់អាករ។

ខ-ក្នុងករណីដែលការផ្គត់ផ្គង់របស់បុគ្គលជាប់អាករ នៅក្នុងរយៈពេលជាប់អាករមានតែមួយផ្នែកប៉ុណ្ណោះ ជាការផ្គត់ផ្គង់ជាប់អាករចំនួនឥណទានដែលអាចផ្តល់ឱ្យត្រូវបានតាមរូបមន្ត

**គណនាតាមរូបមន្ត៖ ក** $\times \frac{ខ}{គ}$

**ក** ៖ ទឹកប្រាក់សរុបនៃអាករលើធាតុចូលក្នុងរយៈពេលជាប់អាករ

**ខ** ៖ តម្លៃសរុបគ្មាន អតប នៃការផ្គត់ផ្គង់ជាប់អាករដែលធ្វើឡើងដោយបុគ្គលជាប់អាករក្នុង រយៈពេលជាប់អាករ។

**គ** ៖ តម្លៃសរុបគ្មាន អតប នៃការផ្គត់ផ្គង់ជាប់អាករ និង ការផ្គត់ផ្គង់មិនជាប់អាករ ដែលធ្វើឡើងដោយបុគ្គលជាប់អាករនៅក្នុងរយៈពេលជាប់អាករលើកលែងតែ តម្លៃនៃការផ្គត់ផ្គង់មិនជាប់អាករនៃការផ្ទេរអាជីវកម្ម។

## ៦.៧-ការផ្គត់ផ្គង់ជាប់អាករដែលមានលក្ខណៈតិចតួច

ក្នុងករណីដែលប្រភាគ $\frac{ខ}{គ}$ ក្នុងចំណុច **៦.៦** ខាងលើនេះ តិចជាង ០.០៥ បុគ្គលជាប់អាករមិនត្រូវបាន ផ្តល់ឥណទានអាករលើធាតុចូល នៅក្នុងរយៈពេលជាប់អាករទេ។

## ៦.៨-ការផ្គត់ផ្គង់មិនជាប់អាករ

ក្នុងករណីដែលប្រភាគ $\frac{ខ}{គ}$ ក្នុងចំណុច **៦.៦** ខាងលើនេះច្រើនជាង ០.៩៥ បុគ្គលជាប់អាករត្រូវបានអនុញ្ញាត នូវឥណទានអាករចំពោះអាករលើធាតុចូលទាំងអស់នៅក្នុងរយៈពេលជាប់អាករ។

-សេវាប្រៃសណីយ៍សាធារណៈ

-សេវាមន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិនដល់ ការបំពេញសេវាកម្មទាំងនេះ។

-សេវាដឹកជញ្ជូនអ្នកដំណើរ ដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។

-សេវាធានារ៉ាប់រង

-សេវាមូលដ្ឋានខាងហិរញ្ញវត្ថុ

-ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ(ដាំដុះក្នុងស្រុក)

-សេវាសិក្សាអប់រំ

-ថាមពលអគ្គីសនី និង ទឹកស្អាត

-សេវាប្រមូលសំរាម នឹង សម្អាតកាកសំណល់រឹង និង រាវ

-ការនាំចូលរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ដែលរួចពន្ធគយ

-សកម្មភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីផលប្រយោជន៍សាធារណៈ

-ការនាំចូលនូវទំនិញសម្រាប់ យកមកបំពេញមុខងារជាផ្លូវការ របស់បេសកម្ម ការទូតនិង កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា (អនក្រ. លេខ ១១៤ អនក្រ បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៩)។

## ៦.៩-វិធីផ្សេងទៀតសម្រាប់គណនាអាករលើធាតុចូលដែលអាចកាត់កងបាន

ក្នុងករណីដែលបុគ្គលជាប់អាករធ្វើការផ្គត់ផ្គង់ជាប់អាករផង និង ការផ្គត់ផ្គង់មិនជាប់អាករផង មានផលពិបាកដោយសារការអនុវត្តនៅចំណុច **ខ** នៃចំណុច **៦.៦** ខាងលើនេះ នាយកដ្ឋានពន្ធដារអាចអនុញ្ញាតឱ្យបុគ្គលជាប់អាករ អនុវត្តតាមរបៀបមួយផ្សេងទៀត ដូចខាងក្រោមនេះ ដើម្បីគណនាអាករលើធាតុចូលដែលអាចកាត់កងបាន ៖

ក-បែងចែកអាករលើធាតុចូលនៃការផ្គត់ផ្គង់ជាប់អាករ និង អាករលើធាតុចូល នៃការផ្គត់ផ្គង់មិនជាប់អាករក្នុងករណីដែលអាចធ្វើទៅបាន។ នៅក្នុងករណីនេះ បុគ្គលជាប់អាករអាចស្នើសុំឥណទាន សម្រាប់អាករលើធាតុចូលទាំងអស់នឹងដែលពាក់ព័ន្ធ និង ការផ្គត់ផ្គង់ជាប់អាករ តែមិនអាចស្នើសុំឥណទានសម្រាប់អាករលើធាតុចូលដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់មិនជាប់អាករទេ។

ខ-ចំពោះអាករលើជាតុចូលនៅសល់ដែលមិនអាចបែងចែកតាម ចំណុច **ក** ខាង

លើនេះបាន ឥណទានអាករត្រូវគណនាតាមចំណុច **ខ** នៃ ចំណុច **៦.៦** ខាងលើនេះ

**៦.១០-ជម្រើសវិធីគណនាឥណទានអាករលើធាតុចូលដែលអាចកាត់កងបាន**

ក្នុងករណីដែលបុគ្គលជាប់អាករ ធ្វើការផ្គត់ផ្គង់ជាប់អាករផង និងការផ្គត់ផ្គង់មិនជាប់អាករផង ចង់ប្រើវិធីគណនាអាករលើធាតុចូលដែលអាចកាត់កងបាន តាមវិធីណាមួយទៀតក្រៅពីវិធីដែលបានចែងក្នុងចំណុច **ខ** នៃចំណុច **៦.៦** ខាងលើនេះ បុគ្គលជាប់អាករនោះត្រូវដាក់ពាក្យស្នើសុំជាលាយល័ក្ខអក្សរទៅនាយកដ្ឋានពន្ធដារ និងត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីនាយកដ្ឋានពន្ធដារ។

**៦.១១-ការគណនាប្រចាំឆ្នាំនៃអាករលើធាតុចូលដែលអាចកាត់កងបាន**

នៅក្នុងខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់ បុគ្គលជាប់អាករដែលបានគណនាអាករលើជាតុចូលតាមចំណុច **ខ** នៃចំណុច **៦.៦** ឬតាមចំណុច **ខ** នៃចំណុច **៦.៩** ឬតាមចំណុច **៦.១០** ខាងលើនេះ ត្រូវធ្វើការគណនាឥណទានអាករដែលអាចកាត់កងបានសម្រាប់ឆ្នាំប្រតិទិនកន្លងមកដោយផ្អែកលើចំនួនទឹកប្រាក់សរុបប្រចាំឆ្នាំនៃ៖

ក-អាករលើជាតុចូលដែលមិនអាចបែងចែកបាន

ខ-ការផ្គត់ផ្គង់ជាប់អាករគ្មាន អតប

គ-ការផ្គត់ផ្គង់ជាប់អាករគ្មាន អតប និងការផ្គត់ផ្គង់មិនជាប់អាករ លើកលែងតែការផ្គត់ផ្គង់មិនជាប់អាករនៃការផ្ទេរអាជីវកម្ម។

(ប្រក. លេខ ១០៣១ សហវ ពដ.ប្រក ចុះថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ១៩៩៨)

**៦.១២-អំណែតម្រូវប្រចាំឆ្នាំនៃអាករលើធាតុចូលដែលអាចកាត់កងបាន**

ក្នុងករណីដែល ៖

ក-ឥណទានអាករប្រចាំឆ្នាំប្រតិទិន នឹងមានចំនួនលើសឥណទានអាករក្នុងលិខិតប្រកាស ចំនួនលំអៀងត្រូវចាត់ទុកជាឥណទានសម្រាប់ខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់។

ខ-ឥណទានអាករប្រចាំឆ្នាំប្រតិទិនមានចំនួនតិចជាង ឥណទានអាករក្នុងលិខិតប្រកាស ចំនួនលំអៀងត្រូវចាត់ទុកជាអាករដែលបុគ្គលជាប់អាករប្រមូលពីការផ្គត់ផ្គង់ជាប់អាករក្នុងខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់។

**៦.១៣-ភ័ស្តុតាងដើម្បីស្នើសុំឥណទានអាករលើធាតុចូលដែលអាចកាត់កងបាន**

ដើម្បីស្នើសុំឥណទានអាករលើធាតុចូល ដែលអាចកាត់កងបានចំពោះបុគ្គលជាប់អាករត្រូវមាន ៖

ក-ច្បាប់ដើមនៃវិក្កយបត្រអាករសម្រាប់ការផ្គត់ផ្គង់ជាប់អាករ

ខ-ប្រតិវេទន៍នាំចូលដែលបញ្ជាក់ដោយទីចាត់ការគយ និងរង្វាករជាភ័ស្តុតាងនៃទឹកប្រាក់អាករដែលបានបង់លើការនាំចូលទំនិញ។

**៦.១៤-ការបង្វិលសងឥណទានអាករលើធាតុចូលលើស**

១-ដូចមានចែងក្នុងមាត្រា៧២ និងមាត្រា៧៣ នៃច្បាប់ស្តីពីសារពើពន្ធ បុគ្គលជាប់អាករដែលធ្វើការនាំចេញ ឬបានចុះបញ្ជីជាសហគ្រាសវិនិយោគ បុគ្គលនោះអាចស្នើសុំបង្វិលសង

អាករលើធាតុចូលលើសជារៀងរាល់ខែ។ រីឯបុគ្គលជាប់អាករដទៃទៀត ដែលមានអាករលើធាតុចូលលើស ក្នុងរយៈពេលបីខែជាប់បន្ត ឬច្រើនជាង បុគ្គលនោះអាចដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារឲ្យបង្វិលសងនូវអាករលើធាតុចូលលើសនោះនៅដំណាច់ខែទី ៣ ឬក្នុងខែណាមួយជាបន្តមកទៀត។ ពាក្យស្នើសុំត្រូវធ្វើទៅតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ហើយត្រូវដាក់ក្នុងរយៈពេល ២០ ថ្ងៃក្រោយដំណាច់ខែ។

២-ចំពោះបុគ្គលជាប់អាករស្នើសុំបង្វិលសងប្រាក់អាករ ក៏ប៉ុន្តែមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករនាយកដ្ឋានពន្ធដារមិនត្រូវធ្វើការបង្វិលសងឡើយលើកលែងតែបុគ្គលជាប់អាករនោះបានចុះបញ្ជីជាសហគ្រាសវិនិយោគ។

៣-នៅក្នុងខែណាមួយដែលបុគ្គលជាប់អាករត្រូវបានទទួលការបង្វិលសងប្រាក់អាករ ហើយបុគ្គលនោះបានដាក់ពាក្យស្នើសុំបង្វិលសងក្នុងរយៈពេល ២០ ថ្ងៃក្រោយដំណាច់ខែ នាយកដ្ឋានពន្ធដារត្រូវបង្វិលសងប្រាក់អាករនោះនៅដំណាច់ខែបន្ទាប់ ពីខែដែលការស្នើសុំបានធ្វើឡើង។

៤-ក្នុងករណីដែលនាយកដ្ឋានពន្ធដារ ខកខានមិនបានធ្វើការបង្វិលសងទៅតាមរយៈពេលដូចមានចែងក្នុងចំណុច ៣ ខាងលើនេះនាយកដ្ឋានពន្ធដារត្រូវបង់ការប្រាក់ទៅឱ្យបុគ្គលជាប់អាករចំនួន ២% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់បង្វិលសងនៅជំពាក់។

៥-បើសិនជាបុគ្គលជាប់អាករដែលស្នើសុំបង្វិលសង មានការតម្រូវពីនាយកដ្ឋានពន្ធដារឲ្យផ្តល់ឯកសារគណនេយ្យ ឬកំណត់ត្រាដើម្បីបញ្ជាក់ភស្តុតាងនៃការស្នើសុំបង្វិលសងមិនបានផ្តល់ឯកសារទាំងនោះទៅតាមបែបបទ ដែលកំនត់ដោយនាយកដ្ឋានពន្ធដារក្នុងរយៈពេល ៧ ថ្ងៃក្រោយមានការតម្រូវទេនោះ រយៈពេលដែលត្រូវធ្វើការបង្វិលសងដូចមានចែងក្នុងចំណុច ៣ ខាងលើនេះ មិនមានតម្លៃអនុវត្តទៅលើនាយកដ្ឋានពន្ធដារទេ។

### ៦.១៥-គោលដៅសំខាន់ៗនៃអាករតម្លៃបន្ថែម

ក- ពាក្យ "ការទទួលភ្ញៀវ" មានន័យថាការផ្គត់ផ្គង់ម្ហូបអាហារ ភេសជ្ជៈ ឬ ថ្នាំជក់ កន្លែងស្នាក់អាស្រ័យ ឬបដិសណ្ឋារកិច្ចណាមួយ។

ខ- ពាក្យ "រថយន្ត" សំដៅដល់ទៅ រថយន្តសម្រាប់តែដឹកមនុស្ស ដែលមានកន្លែងអង្គុយមិនលើសពី ១០។

គ- ពាក្យ "ផលិតផលតេលសិលា" សំដៅដល់ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែ និង ប្រេងរំអិល។

ឃ- ពាក្យ "ឥណទានអាករប្រចាំឆ្នាំប្រតិទិន" មានន័យថា អាករលើធាតុចូលសរុប ដែលអាចកាត់កងបានសម្រាប់ឆ្នាំប្រតិទិនដោយផ្អែកទៅលើការគណនាសរុបប្រចាំឆ្នាំ។

ង-ពាក្យ "ឥណទានអាករក្នុងលិខិតប្រកាស" មានន័យថា អាករលើធាតុចូលសរុប ដែលបានស្នើសុំជាឥណទានក្នុងខែនីមួយៗនៃឆ្នាំប្រតិទិន។

## ៧-វិក្កយបត្រអាករ

### ៧.១-លក្ខខណ្ឌដែលទាក់ទិននិងការចេញ និងការប្រើប្រាស់វិក្កយបត្រអាករ

បន្ថែមលើ សេចក្តីថែង តាមមាត្រា ៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ការប្រើប្រាស់វិក្កយបត្រអាករត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិដូចតទៅៈ

ក-នៅពេលធ្វើការផ្គត់ផ្គង់ទៅអោយបុគ្គលជាប់អាករម្នាក់ទៀត បុគ្គលជាប់អាករត្រូវចេញវិក្កយបត្រ  អាករដល់បុគ្គលជាប់អាករនោះ។

ខ-វិក្កយបត្រត្រូវមានចុះលេខអត្តសញ្ញាណកម្ម នៃការចុះបញ្ជីអាករលើតម្លៃបន្ថែម នៃអ្នកទិញ។

គ-បុគ្គលជាប់អាករអាចទាមទារអោយបុគ្គលជាប់អាករម្នាក់ទៀត ដែលជាអ្នកផ្គត់ផ្គង់ទំនិញ ឬ សេវាអោយខ្លួន ផ្តល់វិក្កយបត្រអាករនៃការផ្គត់ផ្គង់នោះ។

ឃ-បុគ្គលជាប់អាករដែលមិនបានផ្តល់វិក្កយបត្រអាករ អោយទៅបុគ្គលជាប់អាករផ្សេងទៀត ត្រូវទទួលទោសទណ្ឌដូចមានក្នុងច្បាប់ស្តីពីសារពើពន្ធ។

ង-បុគ្គលជាប់អាករមិនត្រូវចេញវិក្កយបត្រអាករ ទៅអោយអតិថិជនដែលមិនមែនជាបុគ្គលជាប់អាករទេ ប៉ុន្តែ ត្រូវចេញវិក្កយបត្រធម្មតា ឬ ក៏ឯកសារផ្សេងទៀតអោយអតិថិជនដែលមិនមែនជាបុគ្គលជាប់អាករ។

ច-នៅពេលធ្វើការផ្គត់ផ្គង់បុគ្គលជាប់អាករ ត្រូវការរក្សាច្បាប់ចម្លង វិក្កយបត្រ វិក្កយបត្រធម្មតា ឬ ឯកសារផ្សេងទៀតដែលបានចេញឲ្យអតិថិជនរបស់ខ្លួន។

## ៨-ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ

### ៨.១-ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ

ការផ្គត់ផ្គង់មិនជាប់អាករ ចំពោះបេសកកម្មទូត និង អង្គការអន្តរជាតិ ត្រូវបានកំណត់ដូចតទៅៈ

១-ការនាំចូលទំនិញសម្រាប់ ឬ ដោយបេសកកម្មទូត និង កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើប្រាស់ក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ។ ការ

ផ្គត់ផ្គង់ជាប់អាករត្រូវបានផ្តល់ឲ្យតែក្នុងករណី មានការបញ្ជាក់ពីប្រធានបេសកកម្មជូននាយកដ្ឋានពន្ធដារទំនិញទាំងនោះត្រូវបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ដូចខាងលើនេះមែន។

២-បេសកកម្មទូត និង កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា អាចដាក់ពាក្យស្នើសុំបង្វិលសងប្រាក់អាករ លើទំនិញដែលបានទិញក្នុងស្រុក ដែលមានការចុះនៅក្នុងបញ្ជីរាយមុខទំនិញ កំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការបង្វិលសងប្រាក់អាករអាចអនុវត្តទៅបានតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្មជន នាយកដ្ឋានពន្ធដារថា ទំនិញត្រូវបានទិញសម្រាប់យកទៅប្រើប្រាស់នៅក្នុងការបំពេញមុខងារជាផ្លូវការរបស់អង្គភាពសាមី។

៣-ការស្នើរសុំបង្វិលសងប្រាក់អាករដូចមានចែងក្នុងចំណុច ២ ខាងលើនេះត្រូវអនុវត្តតាមលក្ខណ្ឌដូចខាងក្រោមៈ

ក-ពាក្យស្នើរសុំធ្វើតាមទម្រង់ដែលនាយកដ្ឋានបានកំណត់

ខ-វិក្កយបត្រនីមួយៗ ត្រូវមានទឹកប្រាក់សរុបគ្មាន អតប នៃទំនិញដែលត្រូវបានអនុញ្ញាតឲ្យបង្វិលសងប្រាក់អាករ ចាប់ពី ២០០.០០០ រៀល ឡើងទៅ។

គ-ពាក្យស្នើរសុំបង្វិលសងនីមួយៗ ដែលត្រូវមានទឹកប្រាក់សរុបគ្មាន អតប ចាប់ពី ២ ០០០.០០០ រៀលឡើងទៅ។

ឃ-ការស្នើរសុំអាចធ្វើបានតែ១ដងក្នុងមួយខែ។

ចំពោះការស្នើរសុំបង្វិលសងប្រាក់អាករដូចមានចែង នៅក្នុងចំណុច ២ ខាងលើនេះ នាយកដ្ឋានពន្ធដារត្រូវជូនដំណឹងពីការយល់ព្រម ឬ មិនយល់ព្រមបង្វិលសងប្រាក់អាករ ក្នុងរយៈពេល ១ ខែ ក្រោយពេលទទួលពាក្យស្នើរសុំ។ (តាមមាត្រា ៥៨ នៃ ច្បាប់សារពើពន្ធ)

## ៩-វិធាននិងនីតិវិធីសម្រាប់ការផ្គត់ផ្គង់ជាប់អាករ

### ៩.១-ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញ

ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញ ត្រូវបានកំណត់ដូចតទៅៈ

១-ការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកថាបានធ្វើឡើងក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់ឲ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម។

### ៩.២-ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញនិងសេវា

ការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនសេវានោះ ត្រូវបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឡែកតែៈ

ក-ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទង នឹង អចលនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ។

ខ-ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទង នឹង ការដឹកជញ្ជូនត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅកន្លែងនៃការដឹកជញ្ជូននោះ។

គ-ការផ្គត់ផ្គង់សេវាត្រូវបានប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ថាបានធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

(តាមមាត្រា ៦៣ នៃ ច្បាប់សារពើពន្ធ)

### ៩.៣-ទីកន្លែងនៃការផ្គត់ផ្គង់ការនាំចូល

ទីកន្លែងនៃការផ្គត់ផ្គង់លើការនាំចូល គឺជាទីកន្លែងដែលទំនិញត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយ នៃព្រះរាជាណាចក្រកម្ពុជា ជាទីកន្លែងត្រូវបង់ពន្ធគយ និង បន្ទុកសារពើពន្ធផ្សេងទៀតនៃការនាំចូល។

### ៩.៤-ការផ្គត់ផ្គង់លាយឡំគ្នារវាងទំនិញនិងសេវា

១- ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនឹងការផ្គត់ផ្គង់ទំនិញ គឺជាចំណែកមួយនៃការផ្គត់ផ្គង់ទំនិញ។

២- ការផ្គត់ផ្គង់នូវទំនិញបន្ទាប់បន្សំដែលរួមជាមួយនឹងការផ្គត់ផ្គង់សេវា គឺជាចំណែកមួយនៃការផ្គត់ផ្គង់សេវា។

៣- ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនឹងការនាំចូល គឺជាចំណែកមួយនៃការនាំចូល។

### ៩.៥-ពេលផ្គត់ផ្គង់

១- ពេលផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវបានកំណត់ដូចតទៅ៖

ក-ពេលផ្គត់ផ្គង់ទំនិញនិងសេវា គឺ ជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវបានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រនោះ។ អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រអាករ យ៉ាងយឺតបំផុត ៧ ថ្ងៃក្រោយពីការបញ្ជូនទំនិញ ឬ ការបំពេញសេវា ឬ ក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញ ឬ ការបំពេញសេវា។

ខ-ក្នុងករណីដែលទំនិញ ត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន នៅពេលផ្គត់ផ្គង់គឺ ជាពេលដែលទំនិញនោះ ត្រូវបានយកទៅប្រើប្រាស់ដំបូង។

គ-ក្នុងករណីទំនិញ ឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់ គឺ ជាពេលដែលទំនិញត្រូវបានប្រគល់ឲ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាផ្គត់ផ្គង់ត្រូវបានបំពេញរួចរាល់។

២- ពេលផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួលទិញ ឬកតិសន្យាហិរញ្ញវត្ថុ គឺជាពេលដែលទំនិញត្រូវបានប្រគល់ឲ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ ឬ សិទ្ធិចាត់ចែងក្តី។

៣- ក្នុងករណីដែល

ក-ទំនិញត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួល

ខ-ទំនិញ ឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យា ឬ ច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក។

គ-សេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត ទំនិញ ឬសេវា ត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ចំពោះចំណែកដែលត្រូវបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលនៃកិច្ចសន្យា ឬ រយៈពេលដែលច្បាប់បានកំណត់ ហើយពេលផ្គត់ផ្គង់ នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗ គឺជាកាលបរិច្ឆេទមុនគេ ក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។

៤.-ចំពោះការនាំចូលទំនិញនៅពេលផ្គត់ផ្គង់ គឺ ជាពេលដែលអ្នកនាំចូល ដាក់លិខិតប្រកាសជូនអាជ្ញាធរគយ និងរដ្ឋាករ ទៅតាមគោលការណ៍ជាធរមាន ហើយពន្ធគយ និង អាករ នានាត្រូវបានបង់។(តាមមាត្រា ៦២ នៃច្បាប់សារពើពន្ធ)

## ១០-ការកែតម្រូវទឹកប្រាក់អាករ

### ១០.១-នីតិវិធីកែតម្រូវទឹកប្រាក់អាករនៅក្រោយពេលផ្គត់ផ្គង់និងពេលចេញវិក្កយបត្រ

១-បុគ្គលជាប់អាករដែលចេញវិក្កយបត្រ អាករ ឬ បានដាក់លិខិតប្រកាសប្រចាំខែរួចហើយ  បុគ្គលនោះអាចធ្វើការកែតម្រូវទឹកប្រាក់ឡើងវិញបាន  បើសិនជាមានហេតុការណ៍ដូចខាងក្រោម បានកើតឡើង ៖

ក- ការផ្គត់ផ្គង់ត្រូវបានលុបចោល

ខ-ចរិតនៃការផ្គត់ផ្គង់ត្រូវបានប្រែប្រួល ឬ បានផ្លាស់ប្តូរជាមូលដ្ឋាន

គ-អត្ថប្រយោជន៍សម្រាប់ការផ្គត់ផ្គង់ដែលបានព្រមព្រៀងគ្នាពីពេលមុន ត្រូវបានប្រែប្រួល ឬ បានផ្លាស់ប្តូរដោយកិច្ចព្រមព្រៀងថ្មីជាមួយនឹងអ្នកទទួលការ ផ្គត់ផ្គង់ដោយមូលហេតុនៃការបញ្ចុះថ្លៃ ឬដោយហេតុផលផ្សេងទៀត។

ឃ-ទំនិញ ឬចំណែកណាមួយនៃទំនិញឬសំបកវេចខ្ចប់ ត្រូវបានបញ្ជូនត្រឡប់មកអ្នកផ្គត់ផ្គង់វិញឬ សេវាមិនត្រូវបានបំពេញរួចរាល់។

២- ក្នុងករណីមានការកែតម្រូវដូចចែងក្នុងចំណុច ១ ខាងលើនេះ បុគ្គលជាប់អាករត្រូវធ្វើការកែតម្រូវបន្ទុកអាកររបស់ខ្លួនដូចតទៅ ៖

ក-បើសិនជាប្រាក់អាករលើធាតុចេញកែតម្រូវ មានចំនួនលើសពីប្រាក់ អាករលើធាតុចេញ ដែលបុគ្គលជាប់អាករ បានកត់ត្រា ចំនួនលើសត្រូវបានចាត់ទុកជាប្រាក់អាករដែលបុគ្គលជាប់អាករបានប្រមូលនៅក្នុងខែ ដែលហេតុការណ៍ដូចមានចែងក្នុងចំណុច ១ ខាងលើនេះបានកើតឡើង។

ខ-បើសិនជាប្រាក់អាករលើធាតុចេញ ដែលបុគ្គលជាប់អាករបានកត់ត្រាមានចំនួន លើសពីប្រាក់អាករលើធាតុចេញកែតម្រូវ នូវចំនួនលើសត្រូវបានចាត់ទុក ជាឥណទានអាករ សម្រាប់ខែដែលហេតុការណ៍មានដូចចែងក្នុងចំណុច ១ ខាងលើនេះបានកើតឡើង។

៣-ចំពោះការផ្គត់ផ្គង់អោយបុគ្គលដែលមិនមែនជាបុគ្គលជាប់អាករ ប្រាក់អាករលើសដូចមានចែងក្នុងចំណុច **ខ** នៃចំណុច ២ ខាងលើនេះ មិនត្រូវបានអនុញ្ញាតជាឥណទានអាករទេ លើកលែងតែបុគ្គលជាប់អាករបានទូទាត់សងប្រាក់ អាករលើសអោយអ្នកទទួលការផ្គត់ផ្គង់វិញ ជាសាច់ប្រាក់ឬការកាត់កងនឹងបំណុល ដែលអ្នកទទួលការផ្គត់ផ្គង់ជំពាក់បុគ្គលជាប់អាករ។

៤-ក្នុងករណីដែលបុគ្គលជាប់អាករ បានចេញ វិក្កយបត្រ អាករ ដោយមកពីហេតុការណ៍ដូចមានចែងក្នុងចំណុច ១ ខាងលើនេះ ហើយចំនួនប្រាក់អាករដែលបានកត់ត្រា លើវិក្កយបត្រ មានចំនួនមានចំនួនលើសពីប្រាក់អាករ កែតម្រូវនៃការផ្គត់ផ្គង់ទំនិញ បុគ្គលជាប់អាករដែល ធ្វើការផ្គត់ផ្គង់ទំនិញ ត្រូវផ្តល់អោយទៅអ្នកទទួលការផ្គត់ផ្គង់នូវលិខិតឥណទានអាករ ដែលមាននិទ្ទេសដូចមានចែងក្នុងចំណុច **៧** ខាងលើនេះ នឹងមាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ។

៥-ក្នុងករណីដែលបុគ្គលជាប់អាករ បានចេញវិកយបត្រអាករ ដោយមកពីហេតុការណ៍ដូចមានចែងក្នុង ចំណុច ១ ខាងលើនេះ ហើយប្រាក់អាករដែលបានកត់ត្រាលើវិក្កយបត្រមានចំនួនតិចជាង ប្រាក់អាករកែតម្រូវនៃការ ផ្គត់ផ្គង់ទំនិញ បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញត្រូវផ្តល់អោយអ្នកទទួលការផ្គត់ផ្គង់នូវ លិខិតឥណពន្ធ អាករដែលមាននិទ្ទេសដូចចែងក្នុងចំណុច **៧** ខាងលើនេះ នឹង មាត្រា ៧៧ នៃច្បាប់ស្តីពីសារពើពន្ធ។

៦-បុគ្គលជាប់អាករជាអ្នកធ្វើការផ្គត់ផ្គង់ ឬ ជាអ្នកទទួលការផ្គត់ផ្គង់ដែលបានចេញឬបានទទួលលិខិត ឥណពន្ធឬលិខិត ឥណទានអាករ ត្រូវកត់ត្រាចលនា ទឹកប្រាក់ នៃលិខិតឥណពន្ធ ឬ លិខិតឥណទានអាករដូចគ្នា ទៅនឹងចលនាទឹកប្រាក់នៃវិក្កយបត្រអាករដែល។

## ១១-បញ្ជីគណនេយ្យ កំណត់ត្រា និង ព័ត៌មាន

### ១១.១-បញ្ជីគណនេយ្យ និង កំណត់ត្រាដែលត្រូវកាន់កាប់ថែរក្សាដោយបុគ្គលជាប់អាករ

បុគ្គលជាប់អាករត្រូវកាន់កាប់នឹងកត់ត្រាបញ្ជីគណនេយ្យនៃការផ្គត់ផ្គង់ទាំងអស់ ដែលខ្លួនបានធ្វើ នឹង បានទទួលនៅក្នុងដំណើរការប្រកបអាជីវកម្ម រួមទាំងការផ្គត់ផ្គង់ដែលជាប់អាករតាមអត្រា សូន្យ និងការផ្គត់ផ្គង់មិនជាប់អាករ។

សម្រាប់គោលដៅនៃគណនេយ្យអាករលើតម្លៃបន្ថែម បុគ្គលជាប់អាករត្រូវកាន់កាប់នឹងថែរក្សា បញ្ជីគណនេយ្យ កំណត់ត្រា និង ព័ត៌មានមានដូចខាងក្រោមនេះ ៖

ក- គណនីអាករលើតម្លៃបន្ថែមប្រចាំខែ ដែលបញ្ជាក់អំពីអាករលើធាតុចេញសរុប អាករលើធាតុចូល សរុបប្រាក់អាករត្រូវបង់ ឬ ឥណទានអាករលើសត្រូវយោងទៅមុខ ឬ កំណត់ត្រូវបង្វិលសងវិញ។

ខ-កំណត់ត្រាទិញទាំងអស់ ដែលលំអិតអំពី ការទិញទាំងអស់ដែលបានបង់អាករ និង ការទិញទាំងអស់ដែលគ្មានការបង់អាករ។ ច្បាប់ដើម នៃ វិក្កយបត្រ អាករសម្រាប់ការទិញនៅក្នុងស្រុកបានបង់អាករ ប្រតិវេទន៍នាំចូល បញ្ជាក់ដោយទីចាត់ការគយ ដែលត្រូវបានបង្ហាញអំពីអាករបានបង់ហើយ និង វិក្កយបត្រ នៃការទិញដែលគ្មានបង់អាករ ត្រូវរក្សាទុកតាមលំដាប់ ថ្ងៃ ខែ នឹងលេខរៀង។

គ-កំណត់ត្រាលក់ទាំងអស់ ដែលរួមមានក្នុងការលក់ ជាប់អាករតាមអត្រាស្តង់ដារ ១០ ភាគរយ អត្រាសូន្យ នឹងការលក់មិនជាប់អាករ ។ ច្បាប់ចម្លងនៃវិក្កយបត្រ ដែលមានទាក់ទងទៅនឹងការលក់ជាប់អាករហើយនិងវិក្កយបត្រដែលទាក់ទិន ការលក់មិនជាប់អាករ ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែនឹងលេខរៀង។

ឃ-លិខិតឥណទាននិង លិខិតឥណទាន ដែលបានចេញនឹងបានទទួល ត្រូវរក្សា ទុកតាមលំដាប់ថ្ងៃខែ នឹង លេខរៀង។

ង-កំណត់ត្រានៅលើរាល់ការនាំចេញនូវទំនិញ និងសេវាតាមអត្រាសូន្យ ព្រមទាំង ប្រតិវេទន៍គយសម្រាប់ធ្វើការនាំចេញ ច្បាប់ចម្លងនៃវិកយបត្រដែលបានចេញ អោយទៅអ្នកទិញបរទេស ឯកសារដឹកជញ្ជូនសម្រាប់ការនាំចេញទំនិញលិខិត បញ្ជាទិញឬកិច្ចសន្យាជាមួយអ្នកទិញបរទេសហើយនិងភ័ស្តុតាងនៃការទូទាត់ ប្រាក់ទៅតាមវិធីផ្ទេរប្រាក់តាមធនាគារ ដែលបានចុះបញ្ជីនៅ ក្នុងព្រះរាជាណា ចក្រកម្ពុជា ឬ ទៅតាមលិខិតឥណទាន។ ចំពោះលិខិតឥណទានត្រូវមានចុះ បញ្ជាក់អោយបើកប្រាក់ទូទាត់ពីធនាគារបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រ កម្ពុជាដែលបានទទួលយល់ព្រមណាមួយ។

ច-កំណត់ត្រាកក្នុងចលនាសាច់ប្រាក់របស់ អ្នកលក់រាយដែលរួមមានបញ្ជីបេឡា និង បញ្ជីដាក់ប្រាក់នៅធនាគារ ប័ណ្ណចំណាយ ប្រាក់បេឡា និង កំណត់ត្រា គណនេយ្យផ្សេងទៀត រួមទាំងច្បាប់ចម្លងនៃបង្កាន់ដៃទទួលប្រាក់ ឬ ក៏មាន បញ្ជីលំអិត អំពីចំនួនទឹកប្រាក់នៃការលក់ដូរប្រចាំថ្ងៃ។

ឆ-កំណត់ត្រាដោយ កំព្យូទ័របើសិនជាមាន

ជ-ព័ត៌មានលម្អិត ស្តីពីការគណនាលើជាតុចូល ក្នុងករណីដែលបុគ្គលជាប់អាករ ធ្វើការផ្គត់ផ្គង់ជាប់អាករផង និង ការផ្គត់ផ្គង់មិនជាប់អាករផង។

ឈ-ឯកសារ កំណត់ត្រានានា និងទម្រង់ស្នើសុំឥណទានចំពោះអាករ លើផលរបរ នឹងអាករប្រើប្រាស់ក្នុងរយៈពេលអន្តរកាល។

ញ-កំណត់ត្រាស្តុក ដែលត្រូវបង្ហាញអំពីការបញ្ចូលបញ្ចេញទំនិញ និង កំណត់ត្រាផលិតកម្ម។

ដ-កំណត់ត្រាបញ្ជាទិញ និងប័ណ្ណប្រគល់ទំនិញ

ឋ-លិខិតឆ្លើយឆ្លងអាជីវកម្ម

ឌ-សៀវភៅណាត់ជួប នឹងសៀវភៅការងារ

ឍ-របាយការណ៍គណនេយ្យប្រចាំឆ្នាំ រួមមានគណនីលទ្ធផល ឬ តារាងតុល្យការ នឹងតារាព័ត៌មានបន្ថែម។

ណ-កំណត់ត្រាខាងធនាគា រួមមានទម្រង់គណនី គល់សៀវភៅមូលប្បទានបត្រ និងប័ណ្ណបង់ប្រាក់ចូលធនាគារ។

កំណត់ត្រាទាំងអស់ត្រូវបានធ្វើឡើងទៅតាមនៃទម្រង់ ដែលនាយកដ្ឋានពន្ធដារបាន កំណត់ឬទទួលស្គាល់ហើយត្រូវថែរក្សានិងត្រៀមបម្រុង សម្រាប់ការត្រួតពិនិត្យ ក្នុងរយៈពេល១០ ឆ្នាំ។(អនក្រ. លេខ ១១៤ បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩)

## ១២-ការផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់

### ១២.១-ការគណនាអាករលើការលក់ទំនិញដល់បុគ្គលមិនជាប់អាករ

បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ជាប់អាករតាមអត្រាស្តង់ដារ ឱ្យដល់បុគ្គលមិនជាប់អាករ ត្រូវកាន់បញ្ជីគណនេយ្យ និង កំណត់ត្រានានាដូចមានចែងក្នុងចំណុច **១១** ខាងលើនេះ ហើយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមនេះ ៖

ក-ក្នុងករណីដែលបានចេញវិក្កយបត្រ បើសិននៅលើវិក្កយបត្រមានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកនោះ ប្រាក់អាករដល់កំណត់ក្នុងខែត្រូវបានគណនាចេញពីកំណត់ត្រាការលក់។

ខ-បើសិននៅលើវិក្កយបត្រគ្មានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកទេនោះ ឬ បុគ្គលជាប់អាករត្រូវធ្វើការលក់រាយដោយមិនបានចេញវិក្កយបត្រ បុគ្គលជាប់អាករ ត្រូវកាន់កំណត់ត្រាការលក់សរុបប្រចាំថ្ងៃ នៃការលក់ជាប់អាករ និង ការលក់មិនជាប់អាករ។ នៅក្នុងការគណនាប្រាក់អាករត្រូវយកតម្លៃសរុប នៃ ការលក់ប្រចាំខែទៅ គុណប្រភាគអាករ។ ប្រភាគអាករសម្រាប់អត្រា ១០ ភាគរយ គឺ : $\frac{១}{១១}$ ។ ដើម្បីរកតម្លៃជាប់អាករត្រូវយកតម្លៃសរុប នៃ ការលក់ប្រចាំខែដកទឹកប្រាក់អាករចេញ។ (អនក្រ. លេខ ១១៤ បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩)

## ១៣-ការផ្គត់ផ្គង់ដោយភ្នាក់ងារ

### ១៣.១-លក្ខខ័ណ្ឌនៃការផ្គត់ផ្គង់ទំនិញឬសេវាដោយភ្នាក់ងារ

១-ការផ្គត់ផ្គង់ទំនិញឬសេវា ធ្វើឡើងដោយបុគ្គលជាភ្នាក់ងារដើម្បីជាគុណប្រយោជន៍របស់បុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់របស់បុគ្គលដើមនោះ។

២-ក្នុងករណីដែលភ្នាក់ងារជាបុគ្គលជាប់អាករ ភ្នាក់ងារនោះត្រូវតែគិតអាករលើកម្រៃដែលបានមកពីការផ្គត់ផ្គង់ទំនិញ ឬ សេវាក្នុងនាមបុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម ។ បើសិនជាបុគ្គលដើម និង ភ្នាក់ងារជាបុគ្គលជាប់អាករទាំងពីរនាក់ ប្រាក់អាករដែលកំណត់លើប្រាក់កម្រៃដោយភ្នាក់ងារត្រូវចាត់ទុកជាអាករលើធាតុចូលរបស់បុគ្គលដើម ។

**១៤-ការប្រមូលអាករលើតម្លៃបន្ថែមលើការនាំចូល**

**១៤.១-ការប្រមូលអាករលើតម្លៃបន្ថែមនៅពេលនាំចូល**

១-អាករដល់កំណត់នៅពេលនាំចូល និងត្រូវប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ ។

២-អាករត្រូវបានប្រមូលតាមរយៈការប្រកាស ក្នុងប្រតិវេទន៍គយសម្រាប់ការនាំចូលហើយត្រូវបានចាត់ចែងតាមរបៀបដូចគ្នា និង ពន្ធគយ ។

៣-តម្លៃជាប់អាករនៃការនាំចូលទំនិញគឺជាចំនួនសរុបនៃ ៖

ក-តម្លៃទំនិញ សម្រាប់គិតពន្ធគយស្របតាមច្បាប់ដែលទាក់ទិន និង ពន្ធគយ

ខ-ចំនួនទឹកប្រាក់នៃពន្ធគយអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងបន្ទុកសារពើពន្ធផ្សេងៗ ទៀតដែលត្រូវបង់លើទំនិញទាំងនោះ ក្រៅពីអាករលើតម្លៃបន្ថែម។

គ-តម្លៃសេវាណាមួយដែលមានចែងក្នុងចំណុច ៣ នៃចំណុច **៩.៤** ខាងលើនេះ ដែលមិនបានបូកបញ្ចូលក្នុងតម្លៃទំនិញសម្រាប់គិតពន្ធគយ ដូចមានចែងក្នុងចំណុច **ក** នៃចំណុច ៣ ខាងលើនេះ ។

៤-ទីចាត់ការគយនិងរដ្ឋាករ ត្រូវផ្តល់អោយអ្នកនាំចូល នូវច្បាប់ចម្លងនៃប្រតិវេទន៍គយសម្រាប់ការនាំចូលដែលក្នុងនោះត្រូវ ៖

ក-ចុះលេខអត្តសញ្ញាណកម្ម អតប បើសិនជាបុគ្គលនាំចូលជាប់អាករ

ខ-សរសេរថា"គ្មាន" ក្នុងប្រអប់សម្រាប់ចុះលេខអត្តសញ្ញាណកម្ម អតប បើសិនជាអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ។

គ-បញ្ជាក់នូវចំនួនទឹកប្រាក់អាករដែលបានបង់ លើប្រតិវេទន៍គយសម្រាប់ការនាំចូល បើសិនជាអ្នកនាំចូលជាបុគ្គលជាប់អាករ ធ្វើការនាំចូលដើម្បីប្រកបអាជីវកម្មជាប់អាករ ។

ឃ-បញ្ជាក់អំពីអសុពលភាព នៃ ការបង្វិលសងប្រាក់អាករ ប្រសិនបើអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ ឬ ធ្វើការនាំចូលដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន។

(អនក្រ. លេខ ១១៤ បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩)

## ១៥-អត្រាសូន្យភាគរយនៃការនាំចេញនូវទំនិញនិងសេវា

### ១៥.១-ដែនអនុវត្តន៍នៃអត្រាសូន្យភាគរយសម្រាប់ការនាំចេញទំនិញនិងសេវាកម្ម

១-ស្របតាមកថាខ័ណ្ឌ ២ នៃមាត្រា៦៤ នៃច្បាប់ស្តីពីសារពើពន្ធ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រាសូន្យភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ទំនិញនីមួយៗ ដែលបាននាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់ជាប់អាករនៃសេវា ដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ។

ដែនអនុវត្តនៃបទប្បញ្ញត្តិនេះត្រូវរួមបញ្ចូល៖

ក-ការផ្គត់ផ្គង់ទំនិញ ទៅទីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានឯកសារភ័ស្តុតាង មានការយល់ព្រមពីនាយកដ្ឋានពន្ធដារ។

ខ-ការផ្គត់ផ្គង់សេវា សម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រ ដែលមានឯកសារភ័ស្តុតាងមានការយល់ព្រមពីនាយកដ្ឋានពន្ធដារ។

គ-ការផ្គត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរ និង ទំនិញជាអន្តរជាតិ

ឃ-ការផ្គត់ផ្គង់សេវាដែលទាក់ទិន និងការដឹកជញ្ជូនរបស់អ្នកដំណើរនិង ទំនិញជាអន្តរជាតិ។

២-សម្រាប់គោលដៅនៅចំណុច ឆ នៃចំណុច ១ ខាងលើនេះ ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវគោក ផ្លូវទឹកឬ ផ្លូវអាកាស គឺជាការដឹកជញ្ជូនអន្តរជាតិ បើសិនជាការដឹកជញ្ជូននោះត្រូវបានធ្វើឡើងៈ

ក-ពីកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

ខ-ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មកកន្លែងមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា។

គ-ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀត នៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលការដឹកជញ្ជូន ឬ ចំណែកណាមួយនៃ ការដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

## ១៦-ការផ្ទេរអាជីវកម្ម

### ១៦.១-លក្ខខណ្ឌនិងការតម្រូវសម្រាប់ការផ្ទេរអាជីវកម្ម

ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតស្របទៅតាមលក្ខខណ្ឌខាងក្រោមនេះ មិនត្រូវជាប់អាករលើតម្លៃបន្ថែមទេះ

ក-អាជីវកម្មត្រូវបានផ្ទេរពីបុគ្គលម្នាក់ ទៅបុគ្គលម្នាក់ទៀត ដើម្បីបន្តធ្វើអាជីវកម្ម ក្រោមកម្មសិទ្ធិថ្មី។

ខ-បុគ្គលជាប់អាករដែលផ្ទេរអាជីវកម្ម ត្រូវជូនដំណឹងដល់ការិយាល័យប្រមូលពន្ធ តាមរបបពិត អំពីការផ្ទេរអាជីវកម្ម ក្នុងរយៈពេល១០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការផ្ទេរ។

គ-បុគ្គលជាប់អាករដែលផ្ទេរអាជីវកម្ម ត្រូវស្នើសុំការលុបចុះបញ្ជីរបស់ខ្លួន ហើយត្រូវអនុវត្តទៅបទប្បញ្ញត្តិ នៃ មាត្រា ៨១ នៃ ច្បាប់ស្តីពីសារពើពន្ធ និង ប្រការដែលពាក់ព័ន្ធទាំងឡាយផ្សេងៗ ទៀត។

ឃ-អ្នកទទួលអាជីវកម្មត្រូវចុះបញ្ជី ជាបុគ្គលជាប់អាករសម្រាប់អាករលើតម្លៃបន្ថែម នៅពេលដែលទទួលអាជីវកម្ម និង ត្រូវគិតអាករលើទំនិញក្នុងស្តុក និង ទ្រព្យសកម្មដែលបានទទួលនៅពេលធ្វើការផ្គត់ផ្គង់ទំនិញ និងទ្រព្យសកម្មទាំងនោះ

ង-បុគ្គលដែលទទួលអាជីវកម្ម ត្រូវរក្សាទុកឯកសារអាករ ដែលទាក់ទិន នឹង អាជីវកម្ម ដែលបានផ្ទេរនោះក្នុងរយៈពេល ១០ ឆ្នាំ ដូចមានចែងក្នុងមាត្រា ៩៨ នៃ ច្បាប់ស្តីពីសារពើពន្ធ។

## ១៧-ឥណទានសម្រាប់អាករលើធាតុចូល ឬអាករប្រើប្រាស់ដែលបានបង់លើទំនិញក្នុងស្តុកនៅពេលចាប់ផ្តើមអនុវត្តអាករលើតម្លៃបន្ថែម

**១៧.១-ភាពអាចទទួលបាននូវឥណទានអាករលើផលរបរឬឥណទាន**
**អាករប្រើប្រាស់**

នៅថ្ងៃទី ០១ មករា ឆ្នាំ១៩៩៩ បើសិនជាបុគ្គលជាប់អាករមាននៅក្នុងស្តុករបស់ខ្លួន នូវ ទំនិញជាមូលធន និងទំនិញផ្សេងៗទៀត ដែលបានបង់អាករលើផលរបរ ឬ អាករប្រើប្រាស់ បុគ្គលនោះអាចមានសិទ្ធិស្នើរសុំឥណទានសម្រាប់អាករទាំងនោះបាន ចំពោះតែទំនិញដែលបាន ទិញក្នុងរយៈពេល ៦០ ថ្ងៃ មុន ថ្ងៃទី ០១ មករា ឆ្នាំ ១៩៩៩។

**១៧.២-លក្ខណ្ឌក្នុងការស្នើរសុំឥណទានអាករលើផលរបរ ឬឥណទាន**
**អាករប្រើប្រាស់**

លក្ខណ្ឌៈក្នុងការស្នើរសុំឥណទានអាករលើផលរបរ ឬ ក៏ឥណទានអាករប្រើប្រាស់មាន ដូចតទៅ៖

ក-បុគ្គលដែលស្នើរសុំឥណទាន ត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម ហើយក្លាយទៅ ជាបុគ្គលជាប់អាករ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ១៩៩៩។

ខ-ការស្នើរសុំឥណទាន តាមចំណុច **១៧.១** ខាងលើនេះ ត្រូវធ្វើទៅតាមទម្រង់ កំណត់ដោយនាយកដ្ឋានពន្ធដារ។

គ-ការស្នើរសុំឥណទានទៅ តាមចំណុច **១៧.១** ខាងលើនេះ ត្រូវផ្តល់បញ្ជីសារពើ ភណ្ឌ នៃទំនិញមាននៅក្នុងដៃនូវ ថ្ងៃ ទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ទាំងអស់ ដែល ទាក់ទិននឹងការស្នើរសុំឥណទានអាករ។

ឃ-ការស្នើរសុំឥណទានអាករលើផលរបរ ឬឥណទានអាករប្រើប្រាស់ ត្រូវមានឯក សារ ភ័ស្តុតាងបញ្ជាក់អំពីការបង់អាករលើផលរបរ និង អាករប្រើប្រាស់។

ង-ពាក្យស្នើសុំឥណទានមានចែងចំណុច **ខ** ខាលើនេះ ត្រូវដាក់ជូននាយកដ្ឋាន

ពន្ធដារយ៉ាងយឺតបំផុតនៅថ្ងៃទី១០ ខែ មករា ឆ្នាំ១៩៩៩។

ច-បុគ្គលជាប់អាករត្រូវរក្សាទុករាល់ឯកសារពាក់ព័ន្ធ ដល់ការស្នើសុំឥណទាន ក្នុង

រយៈពេល១០ឆ្នាំ ហើយត្រូវផ្តល់ឯកសារទាំងនេះ ជូននាយកដ្ឋានពន្ធដារត្រួត

ពិនិត្យក្នុងករណីមានសំណូមពរ។

(អនក្រ. លេខ ១១៤ បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៨)

**១៧.៣-វិធីស្នើសុំឥណទានអាករ**

ក្នុងករណីដែលការស្នើសុំឥណទានតាមចំណុច **១៥.១** ខាងលើនេះត្រូវបានបញ្ជាក់យល់ព្រមដោយប្រធាននាយកដ្ឋានពន្ធដារ ចំនួនដែលបានបញ្ជាក់ជាឥណទាន អាចត្រូវបានស្នើសុំជាឥណទាននៅក្នុងលិខិតប្រកាសប្រចាំ ខែ ដំបូងរបស់បុគ្គលជាប់អាករ។

**១៧.៤-សិទ្ធិនៃការប្រមូលមកវិញនូវឥណទានអាករ**

ដោយមិនទាន់គិតដល់ទោសទណ្ឌដទៃទៀត ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ក្នុងករណីដែលពិនិត្យឃើញថាបុគ្គលជាប់អាករ បានប្រព្រឹត្តិល្មើសនឹងច្បាប់ វិញ្ញាបនបត្រចុះបញ្ជីដែលបានចេញឲ្យបុគ្គលជាប់អាករ តាមចំណុច **៣.៤** ខាងលើនេះ ត្រូវបានលុបចោលទាំងស្រុងឬមួយផ្នែកដោយប្រធាននាយកដ្ឋានពន្ធដារ ហើយឥណទានណាមួយដែលបានអនុញ្ញាតកន្លងមកត្រូវបានប្រមូលមកវិញ។

**១៨-អាករលើតម្លៃបន្ថែមលើទំនិញមួយចំនួន**

អាករលើតម្លៃបន្ថែម នៃទំនិញដែលរាយមុខខាងក្រោម ត្រូវអនុវត្តតាមបែបបទដោយឡែក

-បារី

-ស្រាដែលមានជាតិសុរា ក្នុងឯកតាចំណុះ ៣៥ ភាគរយ នៃចំណុះ ឬ លើសពីនេះ

-ទោចក្រយានយន្តថ្មី

-ថាមពលអគ្គិសនី និង ទឹក។

(ប្រក. លេខ ៦០៥ សហវ.ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០០)

**១៩-អាករតម្លៃបន្ថែមសម្រាប់គោលដៅកសិកម្ម**

អាករលើតម្លៃបន្ថែម លើទំនិញនាំចូល និងផ្គត់ផ្គង់ក្នុងស្រុក សម្រាប់គោលដៅកសិកម្ម ត្រូវបាត់ទុកជាបន្ទុករបស់រដ្ឋ ដូចខាងក្រោម៖

-ជីកសិកម្មគ្រប់ប្រភេទ

-ពូជដំណាំគ្រប់ប្រភេទ

-បសុឱសថគ្រប់ប្រភេទ

-ចំណីសត្វគ្រប់ប្រភេទ

-ពូជសត្វគ្រប់ប្រភេទ

-គ្រឿងយន្ត និង ឧបករណ៍កសិកម្មមួយចំនួន

(ប្រក. លេខ៣១២ សហវ. ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤)

**២០-អាករតម្លៃបន្ថែមលើអាហារ**

អាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ក្នុងស្រុក នូវអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋ ដូចខាងក្រោមត្រូវបាត់ទុកជាបន្ទុករបស់រដ្ឋ៖

-សាច់សត្វចិញ្ចឹម (ស្រស់ ឬ កែច្នៃតាមវិធីប្រឡាក់ ឬ ឆ្អើរ)

-ស៊ុតសត្វចិញ្ចឹម (ស្រស់ ឬ កែច្នៃតាមវិធីប្រឡាក់ ឬ ឆ្អើរ)

-ត្រីទឹកសាប និង ត្រីទឹកប្រៃគ្រប់ប្រភេទ (ស្រស់ ឬ កែច្នៃតាមវិធីប្រឡាក់ ឬ ឆ្អើរ)

-ស្ករគ្រប់ប្រភេទ ដែលមិនមានលក្ខណៈជាស្ករគ្រាប់, អំបិលគ្រប់ប្រភេទ

-ទឹកត្រី និង ទឹកស៊ីអ៊ីវគ្រប់ប្រភេទ។

(ប្រក. លេខ៣៦១ សហវ.ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៨)

## ២១-ការគណនាអាករតម្លៃបន្ថែមសម្រាប់អ្នកជាប់ពន្ធតូច

ការគណនាអាករតម្លៃបន្ថែម សម្រាប់អ្នកជាប់ពន្ធតូច ច្បាប់អនុញ្ញាតឲ្យកាត់កង អាករលើធាតុចូល ៨០%។

### រូបមន្តគណនា

| |
|---|
| **មូលដ្ឋានគិតអាករតម្លៃបន្ថែម = ផលរបរគ្មាន អតប × ២០%** |
| **អាករលើតម្លៃបន្ថែមត្រូវបង់ = មូលដ្ឋានគិតអបត × អត្រាអាករ** |

ឧទាហរណ៍៖ ផលរបរគ្មាន អតប = 199 680 000/1.1 = 181 527 000 រៀល

មូលដ្ឋានគិត អតប = 181 527 000 × 20 % = 36 305 400 រៀល

អាករត្រូវបង់ = 36 305 400 × 10 % = 3 630 540 រៀល

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្តីណែនាំគណនាពន្ធ)

# មេរៀនទី ៩៖ ការប្រមូលពន្ធលើអាករពិសេស

## ១-និយមន័យ

ភេសជ្ជៈគ្មានជាតិសុរា សំដៅទៅដល់ទឹកដែលមាន៖ ជាតិឧស្ម័ន, ដាក់ស្ករ ឬ ដាក់សារជាតិផ្អែមផ្សេងៗ ទៀត, ឬដាក់គ្រឿងក្រអូប, ឬភេសជ្ជៈដ៏ទៃទៀតដែលគ្មានជាតិសុរា លើកលែងតែទឹក និងទឹកមីណេរ៉ាល ទឹកដោះគោ និងទឹកដមផ្លែឈើ ឬទឹកដមបន្លែ។

ទឹកដមផ្លែឈើនិងទឹកដមបន្លែ៖ សំដៅទៅដល់ផលិតផលដែលផលិតចេញពីផ្លែឈើ ឬបន្លែសុទ្ធសាធពីធម្មជាតិ ដែលមានលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

- គ្មានការកែច្នៃរក្សាគុណភាព និងវេចខ្ចប់ តាមរូបភាពសិប្បកម្ម ឬឧស្សាហកម្ម
- គ្មានសារជាតុបន្ថែមរស់ជាតិ ឬ ក្លិន ឬពណ៌។

## ២-គោលបំណង

ដើម្បីជាគុណប្រយោជន៏ក្នុងការប្រមូលថវិការជាតិ ទៅតាមទំហំនិងប្រភេទនៃទំនិញនាំចូលនិងទំនិញនាំចេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ២.១-ការគ្រប់គ្រងនិងការប្រមូលអាករ

អគ្គនាយកដ្ឋានពន្ធដារ មានភារៈកិច្ចប្រមូលអាករពិសេសចំពោះផលិតផលក្នុងស្រុកនិងសេវាមួយចំនួន។

អគ្គនាយដ្ឋានគយ និង រដ្ឋាករកម្ពុជា មានភារៈកិច្ចប្រមូលអាករពិសេសលើទំនិញនាំចូលមួយចំនួន....។

អាករពិសេសលើទំនិញ និង សេវាមួយចំនួនត្រូវយកទៅលើ៖

- ទំនិញដែលធ្វើអោយប៉ះបាល់ដល់សុខភាព ដែលរដ្ឋាភិបាលមិនលើកទឹកចិត្តក្នុង

ការប្រើប្រាស់ច្រើន។

•ទំនិញ ឬ សេវា ដែលមិនចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាជនសាមញ្ញទូទៅ។

•ប្រភេទទំនិញ ឬ សេវាមានលក្ខណៈប្រណិត

ផលិតផលក្នុងស្រុករួមមាន៖

•ភេជ្ជៈគ្រប់ប្រភេទ

•ស្រាគ្រប់ប្រភេទ

•ស្រាបៀរគ្រប់ប្រភេទ

•បារី-ស៊ីហ្គាគ្រប់ប្រភេទ

•ស៊ីម៉ងត៍

(ប្រក. លេខ ០១២ សហវ. ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០)

## ២.២-អាករពិសេសទៅលើសេវាដឹកជញ្ជូនតាមផ្លូវអាកាស

ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ត្រូវឈរលើមូលដ្ឋានតម្លៃដែលបានចុះក្នុងសំបុត្រយន្តហោះដែលបានចេញ ឬលក់អោយអ្នកដំណើរក្នុងប្រទេស។ ចំពោះសំបុត្រទៅ-មក សម្រាប់ធ្វើដំណើរចេញពីកម្ពុជា និងត្រឡប់មកកម្ពុជាវិញ ត្រូវប្រមូលលើ ៥០ % នៃ ថ្លៃមូលដ្ឋាន នៃ សំបុត្រនោះ។

## ២.៣-សេវាទូរគមនាគមន៍ក្នុងនិងក្រៅប្រទេសឬសេវាលំហែរកំសាន្ត

•ការប្រគុំតន្ត្រី ការចាក់ភ្លេងសំដែងឈុតឆាក ឬ កាយវិការមានលក្ខណៈជាសកម្មភាពនៅក្នុងវង្គសាល ខារ៉ាអូខេ ឌីស្កូថែក ទីកន្លែងសាធារណៈ ឬ កន្លែងណាមួយ។

•ចំពោះសណ្ឋាគារ ឬ ភោជនីដ្ឋាន ដែលមានការប្រគុំតន្ត្រី ការសំដែងឈុតឆាក ឬកាយវិការមានលក្ខណៈផ្សារភ្ជាប់នឹងសកម្មភាពសណ្ឋាគារ ឬ ភោជនីដ្ឋាន។

•ម៉ាស្សា ប្រណាំងរថយន្ត ប្រណាំងម៉ូតូ ស្នូកឃ័រ ហ្គេមគ្រប់ប្រភេទ និង វាយកូនគោល។ (ប្រក. លេខ ០១២ សហវ. ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០)

**៣-ការលើកលែងអាករ**

ផលិតផលក្នុងស្រុក ដែលលើកលែងអាករពិសេសរួមមាន៖

•ទឹកត្នោតជូរ

•ថ្នាំជក់ វត្ថុធាតុដើម

•ទឹកសុទ្ធ ឬ ទឹកមីណេរ៉ាល

•ទឹកដោះគោ

•ទឹកដមផ្លែឈើ និង បន្លែ

**៤-មូលដ្ឋានគិតអាករ អត្រាអាករ និងការគណនាអាករ**

**៤.១-មូលដ្ឋានគិតអាករ**

មូលដ្ឋានគិតអាករពិសេសលើទំនិញផលិតក្នុងស្រុក ត្រូវកំណត់ស្មើនឹង ៩០% នៃថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក្កយបត្រឲ្យទៅអតិថិជន ដោយមិនរួមបញ្ចូលនូវ អតប អាករសម្រាប់បំភ្លឺសាធារណៈ និង អាករពិសេសខ្លួនឯង។

មូលដ្ឋានសម្រាប់គិតអាករពិសេសទំនិញផលិតក្នុងស្រុក = ៩០% (ថ្លៃលក់ – អាករតម្លៃបន្ថែម – អាករបំភ្លឺសារណៈ – អាករពិសេស)

ឧទាហរណ៏៖ លក់ស្រាបៀ = ៩០% (ថ្លៃលក់ /110% /103% /130%)

| |
|---|
| **អាករពិសេសលើទំនិញ = មូលដ្ឋានគិតអាករពិសេសលើទំនិញ × អត្រាអាករ** |

**៤.២-មូលដ្ឋានគិតអាករពិសេសលើលើសេវា**

មូលដ្ឋានគិតអាករពិសេសទៅលើសេវា = ថ្លៃផ្គត់ផ្គង់របស់អ្នកជាប់ពន្ធកត់ត្រាក្នុងវិក្កយបត្រទៅឲ្យអតិថិជន – អាករលើតម្លៃបន្ថែម – អាករពិសេសខ្លួនឯង

| **មូលដ្ឋានគិតអាករពិសេសលើសេវា × អត្រាអាករ** |
|---|

**៤.៣-មូលដ្ឋានគិតអាករពិសេសលើទំនិញនាំចេញ**

មូលដ្ឋានសម្រាប់គិតអាករពិសេសចំពោះទំនិញនាំចូល គឺតម្លៃគិតពន្ធគយដែលកំណត់តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ ដោយរួមបញ្ចូលនូវពន្ធនាំចូល។

**៥-មូលដ្ឋានគិតអាករ អត្រាអាករ និងការគណនាអាករ**

**៥.១-អត្រាអាករ**

អាករពិសេសលើទំនិញមួយចំនួន ដែលផលិតនៅក្នុងស្រុកត្រូវអនុវត្តតាមអត្រាអាករដូចខាងក្រោម៖

- ៣៥% ទៅលើសុរា (ស្រា) គ្រប់ប្រភេទ
- ៣០% ទៅលើស្រាបៀគ្រប់ប្រភេទ
- ២០% ទៅលើបារីគ្រប់ប្រភេទ
- ២៥% ទៅលើបារីស៊ីហ្គា
- ១០% ទៅលើភេសជ្ជៈគ្រប់ប្រភេទ
- ៥% ទៅលើស៊ីម៉ង់ត៍គ្រប់ប្រភេទ

(ប្រក. លេខ ០១២ សហវ. ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០)

### ៥.២-អត្រាអាករពិសេសលើសេវា

- ១០% សម្រាប់ថ្លៃលក់សំបុត្រសេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និង ក្រៅប្រទេស។
- ១០% សម្រាប់សេវាលំហែកំសាន្ត
- ៣% សម្រាប់សេវាទូរគមនាគមន៍ក្នុង និង ក្រៅប្រទេស

## ៦-ការប្រកាសពន្ធនិងការបង់ពន្ធ

អ្នកប្រើប្រាស់ទំនិញនិងសេវា៖

- អ្នកប្រើប្រាស់ទំនិញ ឬ សេវាគឺជាអ្នកបង់អាករពិសេសជូនរដ្ឋ ព្រោះវាជាប្រភេទពន្ធប្រយោល ដែលអ្នកជាប់ពន្ធភាគច្រើនមិនបានដឹង។

សហគ្រាស និង អាជីវករ៖

- ម្ចាស់សហគ្រាស ឬអាជីវករ គ្រាន់តែជាភ្នាក់ងារកាត់ប្រាក់អាករពីការលក់ទំនិញ ឬ ពីការបំពេញសេវាឲ្យទៅអ្នកប្រើប្រាស់ និង មានកាតព្វកិច្ចយកប្រាក់អាករទាំងនោះមកបង់ជូនរដ្ឋបាលពន្ធដារ តែប៉ុណ្ណោះ។
- ម្ចាស់សហគ្រាស ឬ អាជីវករ មិនមែនជាអ្នកបង់ប្រាក់អាករទេ ហើយទាមទារឲ្យពន្យល់។

អាករពិសេសត្រូវបង់តែមួយដងគត់ ដោយបុគ្គលជាប់អាករពិសេស អាករពិសេសត្រូវដល់កំណត់ត្រូវបង់នៅពេលផ្គត់ផ្គង់

- ចំពោះទំនិញនាំចូលត្រូវបានចាត់ទុកថាបានផ្គត់ផ្គង់ នៅពេលត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយក្នុងព្រះរាជាណាចក្រកម្ពុជា។

•បំពោះទំនិញផលិត និងសេវាដែលបានផ្គត់ផ្គង់ក្នុងស្រុក គឺជាពេលដែលអ្នកផ្គត់ផ្គង់ចេញវិក្កយបត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក្កយបត្រ។

កាលបរិច្ឆេទបង់អាករ យ៉ាងយឺតបំផុតត្រឹមថ្ងៃ ២០ នៃខែបន្ទាប់។

(ប្រក. លេខ ០១២ សហវ. ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០)

## ៧-សមត្ថកិច្ចគ្រប់គ្រងនិងប្រមូលអាករពិសេស

១-ការគ្រប់គ្រង និងការប្រមូលអាករពិសេសលើទំនិញដែលផលិត ឬសេវាដែលបំពេញក្នុងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។

២-ការគ្រប់គ្រង និងការប្រមូលអាករពិសេសលើទំនិញជាប់អាករ ពិសេសនៅពេលនាំចូល ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា។

៣-ឧទាហរណ៏៖ ក្រុមហ៊ុន KAKA មានលេខអត្តសញ្ញាណកម្ម ០០០០២០២១ បានផលិតស្រាបៀរ ផ្គត់ផ្គង់ក្នុងស្រុក ចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែ ឧសភា ឆ្នាំ២០២១ តម្លៃរួមទាំងអាករក្នុង១កេះ = $១០ ដែលក្នុងនោះលក់ក្នុងស្រុក ៥,០០០កេះ ធ្វើអំណោយ ២,០០០កេះ និងនៅថ្ងៃទី ២២ ក្នុងខែបានលក់ជំពាក់ចំនួន ៣,០០០ កេះ។

### ចូលគណនាអាករពិសេស

គណនាអាករពិសេសដែលក្រុមហ៊ុន KAKA ត្រូវបង់៖

រកផលរបរួមទាំងអាករ = (៥,០០០ +២,០០០ +៣,០០០) × $ ១០= ១០០ ០០០

មូលដ្ឋានគិតអាករ = (១០០ ០០០ /១១០% ១០៣% ១៣០%) × ៩០%

= $ ៦១ ១០៣.៩៤

អាករពិសេស = $ ៦១,១០៣.៩៤ × ៣០% = $ ១៨,៣៣១.១៨

៤-ឧទាហរណ៍៖ ភោជនីដ្ឋាន ម៉ាម៉ា មានប្រគុំតន្ត្រីនិងជាប់ពន្ធតាមរបបស្វ័យប្រកាស ក្នុង ខែ ឧសភា ភោជនីដ្ឋានមានចំណូល លក់ស្រាបៀរចំនួន ៣,០០០$ លក់ទឹកក្រូច ១,០០០$ លក់ទឹកសុទ្ធចំនួន ២,០០០$ និង លក់ម្ហូបអាហារចំនួន ៤,០០០$។

តើភោជនីដ្ឋាន ម៉ាម៉ា ត្រូវបង់អាករពិសេសប៉ុន្មាន?

**ដំណោះស្រាយ**

ប្រាក់អាករពិសេសដែលភោជនីដ្ឋាន ម៉ាម៉ា ត្រូវបង់មាន៖

តម្លៃលក់រួមទាំងអាករគ្រប់ប្រភេទ

មូលដ្ឋានគិតអាករ= (៣,០០០+១,០០០+២,០០០+៤,០០០)

= (១០០០០/១១០/១០៣/១៣០) × ៩០

= ៨,២៦៤.៤៦ $

អាករពិសេស = ៨,២៦៤.៤៦ $ × ១០% = ៨២៦.៤៥ $

៥-ឧទាហរណ៍៖ ក្រុមហ៊ុន A ជានីតិបុគ្គលនិវាសនជននៅកម្ពុជា ហើយត្រូវបានចាត់ថ្នាក់ជាអ្នកជាប់ពន្ធធំ។ ក្រុមហ៊ុននេះនាំចូលនូវផលិតផលមួយចំនួនពីប្រទេសថៃ មកលក់នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា និងផលិតផលមួយចំនួនសម្រាប់លក់នៅក្នុងស្រុក និងសម្រាប់នាំចេញ។ នៅខែ មករា ឆ្នាំ ២០២១ ក្រុមហ៊ុនបានទទួលចំណូលពីការលក់

(ចំណូលរួមទាំងពន្ធ អាករនានា) ដូចខាងក្រោមនេះ៖

| | |
|---|---|
| លក់ស្រាបៀរ(ស្រាបៀរផលិតផលក្នុងស្រុក) | ១០០,០០០ $ |
| លក់ស្រាបៀរ(ស្រាបៀនាំចូល) | ៨០,០០០ $ |
| លក់ទឹកផ្លែឈើ(ផលិតផលនាំចូល) | ៥០,០០០ $ |

នាំចេញស្រាបៀរ(ស្រាបៀរផលិតក្នុងស្រុក) ១២០,០០០ $

ចូលគណនាអាករពិសេសលើស្រាបៀរ?

## ដំណោះស្រាយ

អាករពិសេសលើស្រាបៀរក្រុមហ៊ុន A ត្រូវបង់

ផលរបររួមអាករ

លក់ស្រាបៀរ(ស្រាបៀរផលិតក្នុងស្រុក) ១០០ ០០០ $

មូលដ្ឋានគិតពន្ធ = (១០០ ០០០/១១០ /១០៣ /១៣០) × ៩០

= $ ៦១,១០៣.៩៤

ប្រាក់អាករត្រូវបង់ = $ ៦១,១០៣.៩៤ × ៣០%

= $ ១៨,៣៣១.១៨២

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្តីណែនាំគណនាពន្ធ)

## ៨-អាករបំភ្លឺសាធារណៈ

### ៨.១-កម្មវត្ថុនៃអាករ

អាករបំភ្លឺសាធារណៈត្រូវអនុវត្តទៅលើ៖

- ស្រា៖ ស្រាទំពាំងបាយជូរស្រស់ ស្រាវ៉ែមុត ភេសជ្ជៈ មេវ៉ៃ អាល់កុលអេទីលិកសុទ្ធ
- ស្រាបៀរ
- បារី បារីស៊ីហ្គា គ្រប់ប្រភេទ

ជាថវិការថ្នាក់ខេត្ត សម្រាប់ចំណាយលើការបំភ្លឺសាធារណៈ

**៨.២-ការលើកលែងអាករ**

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបានលើកលែងចំពោះ៖

- ស្រាផលិតជាលក្ខណៈគ្រួសារ
- ទឹកត្នោតជូរ
- ថ្នាំជក់ វត្ថុធាតុដើម

(ប្រក. លេខ ៩៧៦ សហវ. ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៧)

## ៩-មូលដ្ឋានគិតអាករ អត្រាអាករ និងការគណនា

**សម្រាប់អ្នកលក់លើកដំបូង៖**

មូលដ្ឋានគិតអាករ = ថ្លៃផ្គត់ផ្គង់ជាប់អាករ + អាករផ្សេងៗ

=ថ្លៃលក់ – អាករលើតម្លៃបន្ថែម – អាករបំភ្លឺសារណៈ

=(ថ្លៃលក់កត់ត្រាលើវិក្កយបត្រ/១១០%)/១០៣%

**សម្រាប់អ្នកលក់បន្ត**

មូលដ្ឋានគិតពន្ធ =(ថ្លៃលក់កត់ត្រាលើវិក្កយបត្រ – VAT –អាករបំភ្លឺ) × ២០%

= [(ថ្លៃលក់/១១០%)/១០៣%)] × ២០%

អាករ = មូលដ្ឋានគិតអាករ × ៣%

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្ដីណែនាំគណនាពន្ធ)

## ១០-ការប្រកាសនិងការបង់ពន្ធ

អនុវត្តដូចវិធាននៃការបង់ផ្គត់ផ្គង់នៃអាករតម្លៃបន្ថែមពេលផ្គត់ផ្គង់៖

- អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ ឬពេលបានចេញវិក្កយបត្រ
- ការដកហូតទំនិញប្រើប្រាស់ខ្លួនឯង៖ ពេលដែលដកហូតទំនិញ
- អំណោយ៖ ពេលដែលទំនិញត្រូវបានប្រគល់ឲ្យ
- កិច្ចសន្យា៖ ពេលទំនិញត្រូវបានប្រគល់ឲ្យ

ឧទាហរណ៍ទី១៖ ក្រុមហ៊ុន AD ស្ថិតនៅក្នុងរបបស្វ័យប្រកាស បានផលិតស្រាបៀរផ្គត់ផ្គង់ក្នុងស្រុកលក់ឲ្យដេប៉ូ ចាប់ពីថ្ងៃ ០១ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២១ តម្លៃរួមទាំងអាករក្នុង១កេះ= $១០ ដែលក្នុងនោះ លក់ក្នុងស្រុក ៥,០០០កេះ ធ្វើអំណោយ ២,០០០កេះ, និងថ្ងៃទី ២២ ក្នុងខែបានលក់អប្បហាចំនួន ៣,០០០កេះ នូវតម្លៃ១កេះ= $ ៩។

ចូលគណនាអាករបំភ្លឺសាធារណៈ

### ដំណោះស្រាយ

គណនាប្រាក់អាករពិសេសដែលក្រុមហ៊ុននេះបានបង់៖

អាករលើផលរបររួមទាំងអាករ = (៥,០០០ + ២,០០០ + ៣,០០០) × $១០ = $ ១០០, ០០០

មូលដ្ឋានអាករ = (១០០ ០០០ /១១០% /១០៣%)

= $ ៨៨,២៦១.២៥

អាករបំភ្លឺ = $ ៨៨,២៦១.២៥× ៣%

= $ ២,៦៤៧.៨៤

ឧទាហរណ៍ទី២៖ ភោជនីដ្ឋាន DADA មានប្រគុំតន្ត្រី និង ជាប់ពន្ធតាមរបបស្វ័យប្រកាស ក្នុង ខែឧសភា ភោជនីដ្ឋានមានចំណូលរួមបញ្ចូលទាំងអាករគ្រប់ប្រភេទ៖ លក់ស្រាបៀរចំនួ ៣,០០០$ លក់ទឹកក្រូចចំនួន ១,០០០$ លក់ទឹកសុទ្ធចំនួន ២,០០០$ និង ម្ហូបអាហារចំនួន ៤,០០០$ ។

តើភោជនីដ្ឋាន DADA ត្រូវបង់អាករសម្រាប់បំភ្លឺសាធារណៈប៉ុន្មាន?

## ដំណោះស្រាយ

សម្រាប់ភោជនីដ្ឋាន DADA គឺ ជាអ្នកលក់បន្ត និង មានចំណូលរួមទាំងអាករគ្រប់ប្រភេទ ប្រាក់អាករបំភ្លឺសាធារណៈត្រូវបង់៖

មូលដ្ឋានគិតអាករ = (៣,០០០ /១១០% /១០៣%) × ២០%

= ៥២៩.៥៧ $

អាករបំភ្លឺសាធារណៈ = ៥២៩.៥៧ $ × ៣%

= ១៥.៨៩ $

ឧទាហរណ៍ទី៣៖ ក្រុមហ៊ុន BB ជានីតិបុគ្គលនិវាសនជននៅកម្ពុជា ហើយត្រូវបានចាត់ថ្នាក់ជាអ្នកជាប់ពន្ធធំ។ ក្រុមហ៊ុននេះបាននាំចូលនូវផលិតផលមួយចំនួន ពីប្រទេសថៃមកលក់នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា និងផលិតនូវផលិតផលមួយចំនួនសម្រាប់លក់ក្នុងស្រុក និងសម្រាប់នាំចេញ។ ខែមករា ឆ្នាំ ២០២១ ក្រុមហ៊ុនបានទទួលចំណូលពីការលក់ (ចំណូលរួមទាំងពន្ធអាករនានា) ដូចខាងក្រោម៖

| | |
|---|---|
| លក់ស្រាបៀរ (ស្រាបៀរផលិតក្នុងស្រុក) | ១០០,០០០ $ |
| លក់ស្រាបៀរ (ស្រាបៀរនាំចូល) | ៨០,០០០ $ |

ទឹកផ្លែឈើ (ផលិតផលនាំចូល) ៥០,០០០ $

នាំចេញស្រាបៀរ (ស្រាបៀរផលិតក្នុងស្រុក) ១២០,០០០ $

ចូរគណនាអាករសម្រាប់បំភ្លឺសាធារណៈ?

## ដំណោះស្រាយ

អាករសម្រាប់បំភ្លឺសាធារណៈ ក្រុមហ៊ុន BB ត្រូវបង់ផលរបបរួម៖

លក់ស្រាបៀរ (ស្រាបៀរផលិតក្នុងស្រុក) ១០០,០០០ $

លក់ស្រាបៀរ (ស្រាបៀរនាំចូល) ៨០,០០០ $

ផលរបបរួមអាករ = (១០០,០០០ $ + ៨០,០០០ $)

= ១៨០,០០០ $

មូលដ្ឋានគិតអាករ = (១៨០,០០០/ ១១០ /១០៣)

ប្រាក់អាករត្រូវបង់ = ១៥៨,៨៧០.២៥ $ × ៣% = ៤,៧៦៦.១០ $

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្តីណែនាំគណនាពន្ធ)

## ១១-អាករលើការស្នាក់នៅ

### ១១.១-និយមន័យ

អាករស្នាក់នៅត្រូវបានកំណត់ និងប្រមូលលើការស្នាក់នៅក្នុងសណ្ឋាគារ ដែលជាប់ពន្ធលើរបបស្វ័យប្រកាស សម្រាប់ជាគុណប្រយោជន៍ថវិការថ្នាក់ក្រោមជាតិ។

### ១១.២-គោលបំណង

សណ្ឋាគារ៖ សំដៅទៅដល់ការផ្គត់ផ្គង់សេវាស្នាក់នៅ មានលក្ខណៈជាបន្ទប់ គ្រែ និងមាននូវសម្បទា និងសេវាផ្សេងៗ ទៀតទៅតាមមូលដ្ឋានប្រភេទស្នាក់នៅ។

សណ្ឋាគារ៖ អគារស្នាក់នៅ ដែលផ្តល់សេវាស្នាក់នៅពេញលេញ មានភោជនីដ្ឋាន សេវាបំរើម្ហូបអាហារ សេវាបោកគក់...

•សណ្ឋាគារអាផាតម៉ិន៖ សណ្ឋាគារ ដែលមានបំពាក់សម្ភារៈ ផ្ទះបាយ និងបន្ទប់ទទួលភ្ញៀវ

•សណ្ឋាគារស្វ៊ិត៖ សណ្ឋាគារ បន្ទប់ទាំងអស់សុទ្ធតែស្វ៊ីត

•សណ្ឋាគាររីសត៖ សណ្ឋាគារដែលសង់ក្នុងតំបន់ទេសចរណ៍

•ម៉ូតែល៖ អគារស្ថិតនៅតំបន់ជាយក្រុង សេវាមានកម្រិត

•ឡូជ៖ អគារ ដែលមានទីតាំងស្ថិតនៅតំបន់សំរាកវិសម្មកាល

•ប៊ីងកាឡូ៖ អគារ មានបន្ទប់ដេក បន្ទប់ទទួលភ្ញៀវ ចំណតរថយន្ត

•ផ្ទះសំណាក់ ឬ ផ្ទះភ្ញៀវ៖ អគារ ទទួលភ្ញៀវគ្រប់ប្រភេទ

•កន្លែងបោះជំរុំទេសចរណ៍៖ កន្លែងបង្កើតក្នុងតំបន់ទេសចរណ៍

•កន្លែងស្នាក់នៅដ៏ទៃទៀត៖ ដែលមានលក្ខណៈប្រហាក់ប្រហែល

•សណ្ឋាគារ៖ មិនរួមបញ្ចូលផ្ទះជួល ឬ ផ្ទះល្វែងជួលក្នុងរយៈពេលវែង ឬ ខ្លី។

(ប្រក. លេខ ៣៨០ សហវ.ពដ. ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៥)

## ១២-មូលដ្ឋានគិតអាករ អត្រាអាករ ភាគលាភាអាករ

អត្រាអាករលើការស្នាក់នៅ គឺ ២%

មូលដ្ឋានគិតអាករ = ថ្លៃបន្ទប់ + ពន្ធអាករ + បន្ទុកផ្សេងៗ

មូលដ្ឋានគិតអាករ = ថ្លៃផ្គត់ផ្គង់កត់ត្រាលើវិក្កយបត្រឲ្យអតិថិជន – VAT – អាករស្នាក់នៅ

អាករស្នាក់នៅ = មូលដ្ឋានគិតអាករ × ២%

កាលបរិច្ឆេទបង់អាករយឺតបំផុត ថ្ងៃទី ២០ នៃខែបន្ទាប់។

ឧទាហរណ៍ទី១៖ ឧបមាថាសណ្ឋាគារលោក សុខ សម្បត្តិ ជាប់ពន្ធតាមរបបស្វ័យប្រកាសមានចំណូលប្រចាំខែ ដោយមិនរួមបញ្ចូលពន្ធអាករផ្សេងៗ មាដូចខាងក្រោម៖

- ចំណូលបានពីការជួលបន្ទប់សម្រាប់ការស្នាក់ ដល់ភ្ញៀវចំនួន ១,០០០ $
- ចំណូលបានមកពីការជួលបន្ទប់សម្រាប់ការប្រជុំមានចំនួន ២,៥០០ $
- ចំណូលបានពីភោជនីដ្ឋានចំនួន ២៥០ $

ចូលគណនាប្រាក់ពន្ធអាករដែលសណ្ឋាគារ សុខ សម្បត្តិ បង់ប្រចាំខែ?

## ដំណោះស្រាយ

សណ្ឋាគារ សុខ សម្បត្តិ ត្រូវបង់ពន្ធអាករដូចខាងក្រោម៖

- អាករលើការស្នាក់នៅ = ១,០០០ $ × ២% = ២០$
- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ=( ១,០០០$ + ២០$ + ២,៥០០$ + ២៥០$) × ១% = ៣៧.៧ $
- អាករលើតម្លៃបន្ថែម = (១,០០០$ + ២,៥០០$ + ២៥០$) × ១០% = ៣៧៧ $
- ប្រាក់ពន្ធអាករដែលសណ្ឋាគារ សុខ សម្បត្តិ គឺ

= ២០$ + ៣៧.៧$ +៣៣៧$ = <u>៤៣៤.៧ $</u>

ឧទាហរណ៍ទី២៖ សណ្ឋាគារលោក ចាន់ រតនា មានចំណូលប្រចាំខែ ដោយរួមបញ្ចូលពន្ធអាករផ្សេងៗ មានដូចខាងក្រោម៖

- ចំណូលបានពីការជួលបន្ទប់សម្រាប់ស្នាក់នៅដល់ភ្ញៀវ ចំនួន ១,៥០០ ដុលារ
- ចំនួលបានមកពីភោជនីដ្ឋានចំនួន ១,០០០ ដុលារ

ចូលគណនាប្រាក់អាករដែលសណ្ឋាគារ ចាន់ រតនា ត្រូវបង់ប្រចាំខែ

# ដំណោះស្រាយ

១-អាករលើតម្លៃបន្ថែម

•មូលដ្ឋានគិត VAT = ( ១,៥០០$ + ១,០០០$ )× ១០០/១១០

= ២,២៧២.៧២$

• VAT = ២២៧២.៧២$ × ១០% = ២២៧.២៧$

២-ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

•មូលដ្ឋានគិត VAT = ( ១,៥០០$ + ១,០០០$ )× ១០០/១១០

= ២,២៧២.៧២$

•ប្រាក់រំដោះ = ២,២៧២.៧២$ × ១% = ២២.៧៣ $

៣-អាករលើការស្នាក់នៅ

•មូលដ្ឋានគិត អាករ = ១,៥០០$ / ១១០% /១០២% = ១៣៣៦.៩០$

•អាករលើការស្នាក់នៅ= ១៣៣៦.៩០$ × ២% = <u>២៦.៧៣ $</u>

(អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្ដីណែនាំគណនាពន្ធ)

# មេរៀនទី ១០៖ ការប្រមូលពន្ធលើឈ្នួលផ្ទះនិងដី

## ១-និយមន័យ

ពន្ធលើឈ្នួលផ្ទះ និង ដី ជាពន្ធបង់ប្រចាំខែ ដែលត្រូវកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួល៖

- អគារដែលសង់លើដីដូចជាៈ ផ្ទះ រោងចក្រ សណ្ឋាគារ ឃ្លាំង ការិយាល័យ។ល។
- សំណង់អគារពាណិជ្ជកម្ម ឬ ឧស្សាហកម្មផ្សេងៗ ទៀត ដែលនៅនឹងមួយកន្លែង អគារធំៗ ដែលទុកដាក់ជាតុរាវ ឬ ផលិតផលផ្សេងៗ ដូចជាប្រេងឥន្ធនៈ កៅស៊ូ ចាក់ថ្នល់ គ្រាប់ធញ្ញជាតិ។
- ផ្ទះអណ្តែតទឹក កប៉ាល់សម្រាប់ធ្វើជាលំនៅដ្ឋាន ឬ ដើម្បីប្រកបអាជីវកម្មផ្សេងៗ
- ដីធ្លីដែលគ្មានសំណង់ ដោយរាប់បញ្ចូលទាំងកន្លែងយកថ្ម យករ៉ែ ផ្សូងថ្ម បឹងបួរ ស្រែអំបិល។

អត្រាពន្ធលើឈ្នួលផ្ទះ និងដីត្រូវបានកំណត់ស្មើនឹង ១០% នៃប្រាក់ឈ្នួលដុល។ ប្រាក់ឈ្នួលដុស គឺ ជាប្រាក់ឈ្នួលដែលបានចុះកិច្ចសន្យា ឬ បានព្រមព្រៀងជាមួយអ្នកជួល។ ពន្ធនេះត្រូវប្រមូល កម្មសិទ្ធិករ ឬ សិទ្ធិវន្តរបស់កម្មសិទ្ធិករ ក្នុងគោលបំណងដើម្បីរួមចំណែកក្នុងថវិការដ្ឋ ជាថវិកាសម្រាប់ថ្នាក់ជាតិ និងគ្រប់គ្រងអោយបាននៅការជួលផ្ទះ និង ដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

(ប្រក. លេខ ១៤៣១ សហវ.ពដ. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៧)

## ២-ភារៈកិច្ចរបស់កម្មសិទ្ធិករ និង អ្នកជួល

- អ្នកជាប់ពន្ធត្រូវបង់ពន្ធលើឈ្នួលផ្ទះ និងដីជារៀងរាល់ខែ និងត្រូវប្រកាសរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃចុះកិច្ចសន្យាជួល ឬចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យាជួលទៅតាមសាខាពន្ធដារខណ្ឌ/ខេត្ត ដែលទ្រព្យសម្បត្តិនោះស្ថិតនៅ និងត្រូវភ្ជាប់ច្បាប់ថតចម្លងនៃកិច្ចសន្យាជួល។
- ពេលឈប់ជួលក្នុងរយៈពេល ១៥ ថ្ងៃ ត្រូវប្រកាសជាលាយលក្ខណ៍អក្សរជូនទៅពន្ធដារខណ្ឌ/ខេត្តដែលបានទទួលប្រកាសពីមុន។
- លិខិតប្រកាសពន្ធទាំងអស់ត្រូវចុះកាលបរិច្ឆេទ និង ហត្ថលេខា ដោយត្រឹមត្រូវរបស់កម្មសិទ្ធិករ ឬអ្នកទទួលអាណត្តិដោយបានអនុញ្ញាត។
- ក្នុងរយៈពេលកំណត់ ត្រូវបង់ឲ្យគ្រប់ចំនួន នូវប្រាក់ពន្ធ និងប្រាក់ពិន័យដែលសាខាខណ្ឌ/ខេត្តបានកំណត់។
- ប្រសិនបើទ្រព្យសម្បត្តិអ្នកជាប់ពន្ធ កំពុងរងការបំផ្លិចបំផ្លាញឬអ្នកជាប់ពន្ធកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដល់អាយុជីវិត ការទូទាត់ពន្ធនេះអាចត្រូវពន្យាឬចំនួនទឹកប្រាក់ពន្ធត្រូវបានបន្ធូរបន្ថយ ឬ អ្នកជាប់ពន្ធអាចរួចផុតពីការបង់ពន្ធនេះតែម្តង។
- កម្មសិទ្ធិករត្រូវចេញបង្កាន់ដៃទទួលប្រាក់ នៅរាល់ពេលនៃការទូទាត់ពីអ្នកជួល
- ក្នុងករណីដែលកម្មសិទ្ធិករ មិនព្រមបង់បង់ពន្ធលើឈ្នួលផ្ទះ ឬ ដីនោះ អ្នកជួលមានភារកិច្ចទទួលខុសត្រូវ ដកប្រាក់ថ្លៃឈ្នួល ដើម្បីបង់ពន្ធឲ្យគ្រប់ចំនួន។
- អ្នកជួលផ្ទះ ឬ ដី ត្រូវបង្ហាញបង្កាន់ដៃទទួលប្រាក់ដែលកម្មសិទ្ធិករផ្តល់ជូន និង

ត្រូវផ្ដល់ព័ត៌មានផ្សេងៗ ទៀតដែលទាក់ទងដល់ការជួលចំពោះភ្នាក់ងារពន្ធដារ

មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ។

(ប្រក. លេខ ១៤៣១ សហវ.ពដ. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៧)

## ៣-មូលដ្ឋានគិតពន្ធ អត្រាពន្ធ និងការបង់ពន្ធ

### ៣.១-មូលដ្ឋានគិតពន្ធលើឈ្នួលផ្ទះនិងដី

មូលដ្ឋានសម្រាប់គិតពន្ធលើឈ្នួលផ្ទះ និង ដី ត្រូវផ្អែកលើថ្លៃជួលដុលសរុបប្រចាំខែ ដែលបានកំណត់ក្នុងកិច្ចសន្យា ឬតម្លៃដែលបានឯកភាពគ្នារវាងអ្នកជួល និងម្ចាស់កម្មសិទ្ធិ ដោយមិនរាប់បញ្ចូលនូវប្រាក់កក់ជានាទៅក្នុងថ្លៃជួលដុលនោះទេ។

### ៣.២-ការគណនាពន្ធលើឈ្នួលផ្ទះ និងដី

| |
|---|
| **ពន្ធត្រូវបង់ = មូលដ្ឋានគិតពន្ធ × ១0%** |

ឧទាហរណ៏៖ បុគ្គល សុខ សំបូរ មានផ្ទះជួលមួយកន្លែង ដោយតម្លៃជួល ៥000ដុល្លា ក្នុងមួយខែ។ ចូលគណនាពន្ធលើឈ្នួលផ្ទះ និងដី ដែលបុគ្គល សុខ សំបូរ ត្រូវបង់ជូនរដ្ឋបាលសារពើពន្ធ?

**ដំណោះស្រាយ**

តម្លៃផ្ទះជួល ៥000 ដុល្លា ក្នុងមួយខែ

៥000$ × ១0% = ៥00$ × ៤000រៀល = ២,000,000រៀល

ដូចនេះ ប្រាក់ពន្ធឈ្នួលផ្ទះ និងដី ដែលត្រូវបង់គឺមានចំនួន <u>២,000,000រៀល</u>

## ៤-ការលើកលែងពន្ធ

ពន្ធលើប្រាក់ឈ្នួលផ្ទះ និងដី ត្រូវបានលើកលែង៖

- ប្រាក់ឈ្នួលផ្ទះ និងដីដែលត្រូវបានគិតបញ្ចូលក្នុងប្រាក់ចំណេញ នៃសហគ្រាសឧស្សាហកម្ម សិប្បកម្ម កសិកម្ម ពាណិជ្ជកម្ម ឬ មុខរបរពាណិជ្ជណាមួយដែលស្ថិតនៅក្នុងក្របខណ្ឌ ត្រូវយកពន្ធលើប្រាក់ចំណេញតាមរបបពិត។
- ប្រាក់ដែលអ្នកជួលបានតម្កល់ទុកធ្វើប្រាក់ធានា ហើយនៅពេលចប់កិច្ចសន្យាកម្មសិទ្ធិករ ត្រូវប្រគល់គ្រប់ចំនួនឲ្យអ្នកជួលវិញ។
- គ្រប់ករណីជួលទាំងឡាយដែលសរុបប្រាក់ឈ្នួលប្រចាំខែក្រោម ៥០០,០០ រៀល

(ប្រក. លេខ ១៤៣១ សហវ.ពដ. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៧)

# មេរៀនទី១១៖ ការប្រមូលពន្ធអប្បបរមា

## ១-និយមន័យ

ពន្ធអប្បបរមា ត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និង ជាប្រភេទពន្ធផ្ទាល់ ហើយជាពន្ធដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណូល (មាត្រា ២៤ ចព)។

ពន្ធអប្បបរមា ត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា ១% លើផលរបរប្រចាំឆ្នាំ រួមទាំងពន្ធអាករនានា វៀរលែងតែអាករតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ(មាត្រា ២៤ ចព)។ ប៉ុន្តែបើគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនបានកត់បញ្ជិការគណនេយ្យត្រឹមត្រូវ ពន្ធអប្បបរមាត្រូវអនុវត្តទៅតាមអត្រា ១% នៃផលរបរ រួមទាំងពន្ធអាករនានា វៀរលែងតែអាករតម្លៃបន្ថែម (មាត្រា ២៤ ចព)។

## ២-ការគណនាពន្ធអប្បបរមា

ពន្ធអប្បបរមាត្រូវបង់ ឬ ឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១-អ្នកជាប់ពន្ធត្រូវបង់អប្បបរមា នៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ។ ពន្ធអប្បបរមាត្រូវបង់ អាចត្រូវបានកាត់បន្ថយ ដោយបំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំជាប់ពន្ធជាមួយគ្នា តាមមាត្រា ២០ នៃច្បាប់ពន្ធ។

២-ក្នុងករណីបំណុលពន្ធលើប្រាក់ចំណេញ លើសពីប្រាក់បំណុលពន្ធអប្បបរមា

ក-អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធ ត្រូវបង់តាមមាត្រា ៣៧ នៃច្បាប់ពន្ធ នៅពេលដាក់លិខិតប្រកាសសារពើពន្ធ។

ខ-ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកតាមមាត្រា ២៥ និង មាត្រា ២៨ នៃ

ច្បាប់ពន្ធមានចំនួនលើសពីបំណុលពន្ធអប្បបរមា អ្នកជាប់អាចស្នើសុំជាឥណពន្ធបាន។

គ-ក្នុងករណីដូចក្នុងកថាខណ្ឌ ២នៃមាត្រានេះ អ្នកជាប់ពន្ធមិនជាប់ពន្ធអប្បបរមាទេ

៣-ប្រសិនបើបំណុលពន្ធលើប្រាក់ចំណេញតិចជាងបំណុលពន្ធអប្បបរមា

ក-ឥណទានពន្ធរបស់អ្នកជាប់ពន្ធតាមកថាខណ្ឌ ២ មាត្រា ៣៨ នៃច្បាប់ពន្ធ ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លម្អៀងខាងលើ។

ខ-ឥណទានដែលបានកាត់បន្ថយចុះក្នុងការអនុវត្តតាមវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ត្រូវចាត់ជាការទូទាត់ប្រាក់ពន្ធអប្បបរមាសម្រាប់ឆ្នាំជាប់ពន្ធ។

## ៣-មូលដ្ឋានគិតពន្ធនិងអត្រាពន្ធអប្បបរមា

ពន្ធអប្បបរមាត្រូវបានកាត់បន្ថយ ដោយបំណុលពន្ធលើប្រាក់ចំណេញ៖

ប្រសិនបើ៖ បំណុលពន្ធលើប្រាក់ចំណេញច្រើនជាងពន្ធអប្បបរមា ក្នុងករណីនេះ អ្នកជាប់ពន្ធមិនត្រូវជាប់ពន្ធអប្បបរមាទេ។

ប្រសិនបើ៖ បំណុលពន្ធលើប្រាក់ចំណេញតិចជាងពន្ធអប្បបរមា ចំនួនដែលបានលើសនៃពន្ធអប្បបរមាគឺត្រូវបានទទួលស្គាល់ជាឥណទានពន្ធ ហើយនឹងអាចយោងទៅកាត់កងជាមួយប្រាក់រំដោះពន្ធ ទៅលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់។

ឧទាហរណ៍៖ COKA ជាសហគ្រាសនីតិបុគ្គល ដែលមានផលរបរប្រចាំឆ្នាំ ២៥០,០០០,០០០ រៀល និងប្រាក់ចំណេញប្រចាំឆ្នាំ ២០,០០០,០០០ រៀល ។ សហគ្រាសមានសិទ្ធិទទួលឥណទាណពន្ធ ៥០០,០០០រៀល។

## ដំណោះស្រាយ

បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ= ពន្ធលើប្រាក់ចំណេញ – ឥណទាណពន្ធបរទេស

ពន្ធលើប្រាក់ចំណេញ = (២០,000,000 × ២០%) – ៥០០,000

= ៣,៥០០,000 រៀល

ពន្ធអប្បបរមារបស់សហគ្រាសត្រូវបានគណនាដូចខាងក្រោម

ពន្ធអប្បបរមា = ២៥០,000,000 × ១%

= ២,៥០០,000 រៀល

ដោយសារបំណុលពន្ធលើប្រាក់ចំណេញ ច្រើនជាងពន្ធអប្បបរមា

ដូចច្នេះ ពន្ធត្រូវបង់គឺ ៣,៥០០,០០០ រៀល ជាចំនួនទឹកប្រាក់ដែលធំជាង អ្នកជាប់ពន្ធមិនត្រូវជាប់ពន្ធអប្បបរមាទេ។ (អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្ដីណែនាំគណនាពន្ធ)

### ៤-ការដាក់លិខិតប្រកាសពន្ធនិងការបង់ពន្ធ

ប្រាក់រំដោះពន្ធលើប្រាក់ចំណេញត្រូវប្រកាស និងបង់ក្នុងអត្រា ១% នៃផលរបរប្រចាំខែ (រួមបញ្ចូលនូវគ្រប់ប្រភេទពន្ធ-អាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម) ដែលទទួលស្គាល់ជាចំណូលនៅក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ត្រូវបានកត់ត្រាក្នុងទម្រង់លិខិតប្រកាសពន្ធ(From TO1) ដែលត្រូវប្រកាស និងបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ ពីខែដែលបំណុលប្រាក់រំដោះពន្ធលើប្រាក់ចំណេញបានកើតឡើង។

លិខិតប្រកាសប្រាក់រំដោះពន្ធលើប្រាក់ចំណេញតម្រូវឲ្យប្រកាស និងបង់ពន្ធនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ (គម្រោងវិនិយោគមានលក្ខណៈគ្រប់គ្រាន់ សាខាក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនពហុជាតិ និងសហគ្រាសដ៏ទៃទៀតដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១០០០លានរៀល

ឡើងទៅ) ឬសាខាពន្ធដារខណ្ឌ-ខេត្ត នៃរាជធានីភ្នំពេញ ដែលសហគ្រាសនោះតាំងនៅ ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។

## ៥-លិខិតប្រកាសពន្ធប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវបានកត់ត្រាក្នុងទម្រង់លិខិតប្រកាស(From TOP 01) ដែលត្រូវប្រកាស និងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹម៣ ខែ បន្ទាប់ពីដំណាច់ឆ្នាំជាប់ពន្ធ (ថ្ងៃ ទី ៣១ ខែ មីនា សម្រាប់អ្នកជាប់ពន្ធដែលប្រើប្រាស់ឆ្នាំប្រតិទិន)។

លិខិតប្រកាសពន្ធលើប្រាក់ចំណេញតម្រូវអោយប្រកាស និងបង់ពន្ធនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ (គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សាខាក្រុមហ៊ុនបរទេស ឬ ក្រុមហ៊ុនពហុជាតិ និង សហគ្រាសដទៃទៀតដែលមានផលរបរចាប់ពី ១០០០លានរៀឡើងទៅ) ឬ សាខាពន្ធដារខណ្ឌ/ខេត្ត នៃរាជធានីភ្នំពេញ ដែលសហគ្រាសនោះតាំងនៅ ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។

## ៦-អាជីវកម្មជាប់ពន្ធតាមរបបម៉ៅការ

អ្នកជាប់ពន្ធដែលមិនបានបំពេញតាមលក្ខខណ្ឌ នៃអ្នកជាប់ពន្ធតាមរបបពិត គឺជាអ្នកជាប់ពន្ធតាមរបបម៉ៅការ។ វិធានក្នុងអត្ថបទបោះពុម្ពផ្សាយនេះ មិនអនុវត្តលើអ្នកជាប់ពន្ធតាមរបបម៉ៅការ។ផ្ទុយទៅវិញ អ្នកជាប់ពន្ធទាំងនេះ ត្រូវបង់ពន្ធលើប្រាក់ចំណេញ ដែលបានប៉ាន់ប្រមាណរបស់ខ្លួនជាប្រចាំខែ។ សាខាពន្ធដារខណ្ឌ/ខេត្ត កំណត់ចំនួនប៉ាន់ប្រមាណ ដែលត្រូវបង់ដោយផ្អែកលើកត្តាផ្សេងៗជាច្រើន សម្រាប់ព័ត៌មានលម្អិតស្តីពីកាគណនា និងទូទាត់ពន្ធលើប្រាក់ចំណេញសម្រាប់អ្នកជាប់តាមរបបពន្ធម៉ៅការ។ (អគ្គនាយកដ្ឋានពន្ធដារ, ២០១៣, សេចក្តីណែនាំគណនាពន្ធ)

**THE END**

# ឯកសារយោង

១-ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស. រកម. ០២៧៩.០៣ ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

២-ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣។

៣-ប្រកាសលេខ ៧០១ សហវ. ប្រក ចុះថ្ងៃ ១៤ ខែ សីហា ឆ្នាំ២០២០, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការចុះបញ្ជីពន្ធដារ និង ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ។

៤-ប្រកាសលេខ ០០៩ សហវ. ប្រក ចុះថ្ងៃ ១២ ខែ មករា ឆ្នាំ២០២១, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

៥-ប្រកាសលេខ ១០៥៩ សហវ. ប្រក ចុះថ្ងៃ ១២ ខែ ធ្នូ ឆ្នាំ២០០៣,របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីពន្ធលើប្រាក់ចំណេញ។

៦-អគ្គនាយកដ្ឋានពន្ធដារ, ឆ្នាំ ២០១៣ ស្តីពីការណែនាំការអនុវត្ត ក្នុងការគណនាប្រាក់ពន្ធ ។

៧-ប្រកាសលេខ ១១៧៣ សហវ. ពដ.ប្រក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីពន្ធលើប្រាក់បៀវត្ស។

៨-សារាចរណ៍ណែនាំលេខ ០១១ សហវ ចុះថ្ងៃទី៦ ខែ តុលា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធអត្ថប្រយោជន៍បន្ថែម។

៩-សេចក្តីណែនាំលេខ០០២ សហវ ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ ២០១៨ របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី។

១០-អនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២០ របស់រាជរដ្ឋាភិបាល ស្តីអំពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ។

១១-ប្រកាសលេខ ០៩៨ សហវ. ប្រក ចុះថ្ងៃ ២៩ ខែ មករា ឆ្នាំ២០២០, របស់ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ស្តីអំពីពន្ធលើប្រាក់ចំណូល។

១២-ប្រកាសលេខ ៣៤៦ សហវ. ប្រក ចុះថ្ងៃ ០១ ខែ មេសា ឆ្នាំ២០២០, របស់ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ស្តីអំពីពន្ធលើប្រាក់ចំណេញមូលធន។

១៣-ប្រកាសលេខ ៣៧២ សហវ. ប្រក ចុះថ្ងៃ ០៥ ខែ មេសា ឆ្នាំ២០១៩, របស់ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ស្តីអំពីការកែសម្រួលការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ ។

១៤-ប្រកាសលេខ ៥៩៩ សហវ. ប្រក ចុះថ្ងៃ ១៤ ខែ កក្កដា ឆ្នាំ២០០៩, របស់ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ស្តីអំពីការចំណាយរបស់សហគ្រាសដែលអនុញ្ញាតឲ្យកាត់កងទាក់ទិនពន្ធកាត់ទុក។

១៥-សេចក្តីណែនាំលេខ១៨៤១០ អពដ ចុះថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ, ស្តីអំពីការអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកចំពោះអាជីវកម្មក្នុងវិស័យបញ្ចាំងខ្សែភាពយន្ត និងអាជីវកម្មជួលអចលនទ្រព្យបន្ត ។

១៦-ប្រកាសលេខ ១០៣១ សហវ ពដ. ប្រក ចុះថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ១៩៩៨, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីអាករលើតម្លៃបន្ថែម។

១៧-អនុក្រឹត្យលេខ ១១៤ អនក្រ បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីអំពីអាករលើតម្លៃបន្ថែម។

១៨-ប្រកាសលេខ ២៨៨ ចុះថ្ងៃ ៣១ ខែ មីនា ឆ្នាំ១៩៩៨, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីឥណទានសម្រាប់ការប្រើប្រាស់ទូរស័ព្ទ។

១៩-ប្រកាសលេខ ៣០៣ សហវ ពដ. ប្រក ចុះថ្ងៃ ២៣ ខែ ឧសភា ឆ្នាំ២០០១, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីអាករលើតម្លៃបន្ថែមចំពោះទំនិញនាំចូលមួយចំនួន។

២០-ប្រកាសលេខ ៣២៦ សហវ ពដ. ប្រក ចុះថ្ងៃ ០៥ ខែ មិថុនា ឆ្នាំ២០០១, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីអាករលើតម្លៃបន្ថែមចំពោះវិស័យដឹកជញ្ជូន។

២១-ប្រកាសលេខ ៧៣៤ សហវ ពដ. ប្រក ចុះថ្ងៃ ០១ ខែ កញ្ញា ឆ្នាំ២០០៦, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការបង្វិលសងរបស់ គលគ និងគម្រោងហេដ្ឋារចនា សម្ព័ន្ធធុនធ្ងន់។

២២-ប្រកាសលេខ ១១៩០ សហវ . ប្រក ចុះថ្ងៃ ០៧ ខែ ធ្នូ ឆ្នាំ២០០៩, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីអាករលើតម្លៃបន្ថែមចំពោះលទ្ធកម្មសាធារណៈ។

២៣-ប្រកាសលេខ ៣១២ សហវ ពដ. ប្រក ចុះថ្ងៃ ១៩ ខែ កញ្ញា ឆ្នាំ២០១៤, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីអាករលើតម្លៃបន្ថែមចំពោះការនាំចូលនិងផ្គត់ផ្គង់ទំនិញមួយចំនួន។

២៤-ប្រកាសលេខ ១៧០៤ សហវ ពដ. ប្រក ចុះថ្ងៃ ០៩ ខែ ធ្នូ ឆ្នាំ២០១៥, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីយន្តការពន្ធដារសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ។

២៥-ប្រកាសលេខ ១៨២០ សហវ ពដ. ប្រក ចុះថ្ងៃ ២៥ ខែ ធ្នូ ឆ្នាំ២០១៥, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការកំណត់នីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច។

២៦-ប្រកាសលេខ ៥៥៩ សហវ ពដ. ប្រក ចុះថ្ងៃ ២៥ ខែ ឧសភា ឆ្នាំ២០១៧, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ។

២៦-ប្រកាសលេខ ៥៧៦ សហវ ពដ. ប្រក ចុះថ្ងៃ ១៩ ខែ មិថុនា ឆ្នាំ២០១៨, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីយន្តការបង្វិលសងអាករលើតម្លៃបន្ថែម។

២៧-ប្រកាសលេខ ៥៩៧ សហវ ពដ. ប្រក ចុះថ្ងៃ ២៧ ខែ មិថុនា ឆ្នាំ២០១៨, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការទទួលស្គាល់និងកាតព្វកិច្ចសារពើពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់

ទំនិញឬសេវាក្នុងសហគ្រាសដើម។

២៨-ប្រកាសលេខ ៧២៣ សហវ . ប្រក ចុះថ្ងៃ ១៤ ខែ សីហា ឆ្នាំ២០១៩, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីវិធានប្រើប្រាស់វិក្កយបត្រ។

២៩-ប្រកាសលេខ ១៦៨ សហវ ពដ. ប្រក ចុះថ្ងៃ ២១ ខែ កុម្ភៈ ឆ្នាំ២០២០, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការចាត់ជាបន្ទុករដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

៣០-Wilhelm von Siemens,1918. អាករលើតម្លៃបន្ថែម។

៣១-Direction General Des Impots,1954. អាករលើតម្លៃបន្ថែម។

៣២-ប្រទេសកម្ពុជាចាប់ផ្តើមអនុវត្ត អាករលើតម្លៃបន្ថែម នៅថ្ងៃទី១០ ខែ មករា ឆ្នាំ ១៩៩៩។

៣៣-ប្រកាសលេខ ១៥៣ ប្រក. សហវ.ពដ ប្រក ចុះថ្ងៃ ១៥ ខែ កុម្ភៈ ឆ្នាំ២០០១, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីអាករពិសេសលើសេវាលំហែកំសាន្ត។

៣៤-អនុក្រឹត្យលេខ ១៩២ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥ របស់រាជរដ្ឋាភិបាល ស្តីអំពីការកែសម្រួលអត្រាពន្ធគយនិងអត្រាអាករពិសេសលើមុខទំនិញមួយចំនួន។

៣៥-សេចក្តីជូនដំណឹងលេខ០១៥ សហវ ចុះថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ ២០១៤ របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ,ស្តីអំពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួន ដែលផលិតក្នុងស្រុក។

៣៦-សេចក្តីជូនដំណឹងលេខ៤២២៧ អពដ ចុះថ្ងៃទី២២ ខែ មីនា ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ,ស្តីអំពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួន ដែលផលិតក្នុងស្រុក។

៣៧-អនុក្រឹត្យលេខ ២១៤ អនក្រ បក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ របស់រាជរដ្ឋាភិបាល ស្តី អំពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និង អត្រានាំចេញលើមុខទំនិញមួយចំនួន។

៣៨-អនុក្រឹត្យលេខ ០១២ អនក្រ បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ របស់រាជរដ្ឋាភិបាល ស្តី អំពីការកែសម្រួល ការកំណត់មូលដ្ឋានគិតអាករពិសេស លើមុខទំនិញមួយចំនួនដែលផលិតនៅក្នុងស្រុក។

៣៩-ប្រកាសអន្តរក្រសួងលេខ ៥៨៣ ប្រក. សហវ.ពជ ប្រក ចុះថ្ងៃ ៣០ ខែ កក្កដា ឆ្នាំ១៩៩៩, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីអាករសម្រាប់បំភ្លឺសាធារណៈ។

៤០-ប្រកាសលេខ ០២១ ប្រក. សហវ. ប្រក ចុះថ្ងៃ ២៣ ខែ កុម្ភៈ ឆ្នាំ១៩៩៤, របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីអំពីការគ្រប់គ្រងប្រមូពន្ធ លើឈ្នួលផ្ទះនិងដី។